# ឯកសារស្រាវជ្រាវ

សម្រាប់គណៈកម្មការទី២ នៃព្រឹទ្ធសភា ទទួលបន្ទុកសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និង សវនកម្ម

## ស្តីពី

## ការសិក្សាប្រៀបធៀបបញ្ហានានានៃដំណើរការបោះឆ្នោតនៅប្រទេសបារាំង កូរ៉េខាងត្បូង ហ្វីលីពីន និងឥណ្ឌូនេស៊ី

រៀបចំដោយ លោក មូសារ អ៊ីស្សាម
លោក រីត អាឡិច
លោក អាប់ចូរ៉ែនស៊ិន សេប៉ាស្ទាន
កញ្ញា ហុក សៀម
កញ្ញា ស៊ឹម លាង់ហេង

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែមករា ឆ្នាំ២០១៨

**វិទ្យាស្ថានសភាកម្ពុជា**

## មាតិកា


**សង្ខេបឯកសារ ..... VI**

**I. សេចក្តីផ្តើម ..... 1**

**II. ការផ្តល់ហិរញ្ញប្បទានដល់យុទ្ធនាការឃោសនាបោះឆ្នោត ..... 2**

**១. ប្រទេសកម្ពុជា ..... 4**

**២. ប្រទេសបារាំង ..... 6**

២.១. ច្បាប់ និងបទបញ្ញា ..... 6

២.២. ហិរញ្ញប្បទានសាធារណៈសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត ..... 7

២.៣. ការកម្រិតលើការចំណាយក្នុងយុទ្ធនាការឃោសនាបោះឆ្នោត ..... 8

២.៤. ស្ថាប័នត្រួតពិនិត្យ ..... 8

២.៥. ទោសវិន័យ ..... 9

**៣. ប្រទេសកូរ៉េខាងត្បូង ..... 11**

៣.១. ច្បាប់និងបទបញ្ញា ..... 12

៣.២. ហិរញ្ញប្បទានសាធារណៈសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត ..... 13

៣.៣. ការកំរិតលើការចំណាយក្នុងយុទ្ធនាការឃោសនាបោះឆ្នោត ..... 13

៣.៤. ស្ថាប័នត្រួតពិនិត្យ ..... 14

៣.៥. ទោសពិន័យ ..... 15

**៤. ប្រទេសហ្វីលីពីន ..... 15**

៤.១. ច្បាប់និងបទបញ្ញា ..... 15

៤.២. ហិរញ្ញប្បទានសាធារណៈសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត ..... 15

៤.៣. ការកំរិតលើការចំណាយក្នុងយុទ្ធនាការឃោសនាបោះឆ្នោត ........ 15

៤.៤. ស្ថាប័នត្រួតពិនិត្យ ........ 17

៤.៥. ទោសពិន័យ ........ 18

**៥. ប្រទេសឥណ្ឌូនេស៊ី ........ 19**

៥.១. ច្បាប់និងបទបញ្ញា ........ 19

៥.២. ហិរញ្ញប្បទានសាធារណៈសម្រាប់យុទ្ធនាការឃោសនាការបោះឆ្នោត ........ 19

៥.៣. ការកំរិតលើការចំណាយក្នុងយុទ្ធនាការឃោសនាបោះឆ្នោត ........ 20

៥.៤. ស្ថាប័នត្រួតពិនិត្យ ........ 21

៥.៥. ទោសពិន័យ ........ 21

**III. ការចុះឈ្មោះបោះឆ្នោត ........ 22**

**១.ប្រទេសកម្ពុជា ........ 25**

**២. ប្រទេសបារាំង ........ 29**

២.១. ការចុះឈ្មោះបោះឆ្នោត ........ 29

២.២. ដំណើរការនៃការបង្កើតបញ្ជីបោះឆ្នោត ........ 30

២.៣. យន្តការដើម្បីធានានូវភាពត្រឹមត្រូវនៃបញ្ជីបោះឆ្នោត ........ 31

២.៤. ការទទួលបានពត៌មានបញ្ជីបោះឆ្នោតរបស់សាធារណៈជន ........ 33

២.៥. ការបោះឆ្នោតនៅមណ្ឌលផ្សេងទៀតដែលខុសពីទីកន្លែងចុះឈ្មោះបោះឆ្នោត ........ 33

២.៦. ភស្តុតាងបញ្ជាក់អត្តសញ្ញាណសម្រាប់ការបោះឆ្នោត ........ 34

**៣. ប្រទេសកូរ៉េខាងត្បូង ........ 34**

៣.១. ការចុះឈ្មោះបោះឆ្នោត ........ 34

៣.២. ដំណើរការនៃការបង្កើតបញ្ជីបោះឆ្នោត ..... 35
៣.៣. យន្តការដើម្បីធានានូវភាពត្រឹមត្រូវនៃបញ្ជីបោះឆ្នោត ..... 35
៣.៤. ការទទួលបានពត៌មានបញ្ជីបោះឆ្នោតរបស់សាធារណៈជន ..... 35
៣.៥. ការបោះឆ្នោតនៅមណ្ឌលផ្សេងទៀតដែលខុសពីទីកន្លែងចុះឈ្មោះបោះឆ្នោត ..... 35
៣.៦. ភស្តុតាងបញ្ជាក់អត្តសញ្ញាណសម្រាប់ការបោះឆ្នោត
**៤. ប្រទេសហ្វីលីពីន ..... 36**
៤.១. ការចុះឈ្មោះបោះឆ្នោត ..... 36
៤.២. ដំណើរការនៃការបង្កើតបញ្ជីបោះឆ្នោត ..... 37
៤.៣. យន្តការដើម្បីធានានូវភាពត្រឹមត្រូវនៃបញ្ជីបោះឆ្នោត ..... 37
៤.៤. ទទួលបានព័ត៌មានបញ្ជីបោះឆ្នោតរបស់សាធារណៈជន ..... 38
៤.៥. ការបោះឆ្នោតនៅមណ្ឌលផ្សេងទៀតដែលខុសពីទីកន្លែងចុះឈ្មោះបោះឆ្នោត ..... 38
៤.៦. ភស្តុតាងបញ្ជាក់អត្តសញ្ញាណសម្រាប់ការបោះឆ្នោត ..... i
**៥. ប្រទេសឥណ្ឌូនេស៊ី ..... 39**
៥.១. ការចុះឈ្មោះបោះឆ្នោត ..... 39
៥.២. ដំណើរការនៃការបង្កើតបញ្ជីបោះឆ្នោត ..... 39
៥.៣. យន្តការដើម្បីធានានូវភាពត្រឹមត្រូវនៃបញ្ជីបោះឆ្នោត ..... 40
៥.៤. ទទួលបានព័ត៌មានបញ្ជីបោះឆ្នោតរបស់សាធារណៈជន ..... 40
៥.៥. ការបោះឆ្នោតនៅមណ្ឌលផ្សេងទៀតដែលខុសពីទីកន្លែងចុះឈ្មោះបោះឆ្នោត ..... 40
៥.៦. ភស្តុតាងបញ្ជាក់អត្តសញ្ញាណសម្រាប់ការបោះឆ្នោត ..... 41
**IV. ការត្រួតពិនិត្យដោយស្ថាប័នគ្រប់គ្រងការបោះឆ្នោត ..... 41**

**១. ប្រទេសកម្ពុជា ..... 45**

១.១. រចនាសម្ព័ន្ធ សមាសភាព និង ទិដ្ឋភាពទូទៅនៃ ស្ថាប័នគ្រប់គ្រងការបោះឆ្នោត ..... 45

១.២. ការតែងតាំងសមាជិកស្ថាប័នគ្រប់គ្រងការបោះឆ្នោត ..... 46

១.៣. ភារកិច្ច និង អំណាចនៃស្ថាប័នគ្រប់គ្រងការបោះឆ្នោត ..... 47

១.៤. ភ្នាក់ងារពាក់ព័ន្ធក្នុងការជួយសម្របសម្រួលការបោះឆ្នោត ..... 48

**២. ប្រទេសបារាំង ..... 48**

២.១. រចនាសម្ព័ន្ធ សមាសភាព និងទិដ្ឋភាពទូទៅនៃស្ថាប័នគ្រប់គ្រងការបោះឆ្នោត ..... 48

២.២. ការតែងតាំងសមាជិក ..... 48

២.៣. ភារកិច្ច និងអំណាចរបស់ស្ថាប័នគ្រប់គ្រងការបោះឆ្នោត ..... 49

២.៤. ភ្នាក់ងារពាក់ព័ន្ធក្នុងការជួយសម្របសម្រួលការបោះឆ្នោត ..... 49

**៣. ប្រទេសកូរ៉េខាងត្បូង ..... 51**

៣.១. រចនាសម្ព័ន្ធ សមាសភាព និង ទិដ្ឋភាពទូទៅនៃ ស្ថាប័នគ្រប់គ្រងការបោះឆ្នោត ..... 51

៣.២. ការតែងតាំងសមាជិក ..... 52

៣.៣. ភារកិច្ច និងអំណាចរបស់ស្ថាប័នគ្រប់គ្រងការបោះឆ្នោត ..... 52

៣.៤. ភ្នាក់ងារពាក់ព័ន្ធក្នុងការជួយសម្របសម្រួលការបោះឆ្នោត ..... 53

**៤. ប្រទេសហ្វីលីពីន ..... 53**

៤.១. រចនាសម្ព័ន្ធ សមាសភាព និងទិដ្ឋភាពទូទៅនៃស្ថាប័នគ្រប់គ្រងការបោះឆ្នោត ..... 53

៤.២. ការតែងតាំងសមាជិក ..... 54

៤.៣. ភារកិច្ច និងអំណាចរបស់ស្ថាប័នគ្រប់គ្រងការបោះឆ្នោត ..... 54

៤.៤. ភ្នាក់ងារពាក់ព័ន្ធក្នុងការជួយសម្របសម្រួលការបោះឆ្នោត ..... 55

**៥. ប្រទេសឥណ្ឌូនេស៊ី ..... 57**

៥.១. រចនាសម្ព័ន្ធ សមាសភាព និងទិដ្ឋភាពទូទៅនៃស្ថាប័នគ្រប់គ្រងការបោះឆ្នោត ..... 57

៥.២. ការតែងតាំងសមាជិក ..... 58

៥.៣. ភារកិច្ច និងអំណាចរបស់ស្ថាប័នគ្រប់គ្រងការបោះឆ្នោត ..... 58

៥.៤. ភ្នាក់ងារពាក់ព័ន្ធក្នុងការជួយសម្របសម្រួលការបោះឆ្នោត ..... 59

**V. ការវិភាគ ..... 62**

**VI. សេចក្តីសន្និដ្ឋាន ..... 65**

**គន្ថនិទេស ..... 66**

# ឯកសារសង្ខេប


នៅក្នុងប្រទេសដែលត្រូវបានលើកយកមកសិក្សាស្រាវជ្រាវ យើងអាចមើលឃើញកាន់តែច្បាស់លាស់ថា ខណៈដែលប្រពន្ធ័នយោបាយមានភាពល្អប្រសើរ ដំណើរការបោះឆ្នោតក៏ត្រូវបានវិវត្តន៍ផងដែរ។ ប្រទេសបារាំងបានចាប់ផ្តើមរៀបចំការបោះឆ្នោតដែលទទួលបាននូវប្រជាប្រិយភាពនៅឆ្នាំ ១៧៩២, ប្រទេសហ្វីលីពីននៅឆ្នាំ១៩៣៧, ប្រទេសកូរ៉េខាងត្បូងនៅឆ្នាំ១៩៤៨, ប្រទេសឥណ្ឌូនេស៊ី នៅឆ្នាំ១៩៥៥, និងប្រទេសកម្ពុជានៅឆ្នាំ១៩៩៣។ យ៉ាងណាក៏ដោយ ទោះបីជាដំណើរការបោះឆ្នោត ក្នុងប្រទេសដែលត្រូវបានលើកយកមកសិក្សា ត្រូវបានផ្អាកដោយសារបញ្ហានយោបាយ ក្រោយមកការសិក្សាក៏បានចាប់ផ្តើមឡើងវិញនៅក្នុងទម្រង់ថ្មីមួយ។ ប្រព័ន្ធបោះឆ្នោតទំនើបនៃប្រទេសទាំងនេះ បានលេចឡើង នៅក្នុងប្រទេសនីមួយៗ៖ ប្រទេសបារាំងក្នុងឆ្នាំ១៩៤៦ ប្រទេសហ្វីលីពីនក្នុងឆ្នាំ១៩៨៧ ប្រទេសកូរ៉េខាងត្បូងក្នុងឆ្នាំ១៩៨៧ ប្រទេសឥណ្ឌូនេស៊ី ក្នុងឆ្នាំ១៩៩៩។ ឯកសារស្រាវជ្រាវនេះសិក្សាទៅលើចំណុចសំខាន់ៗនៃប្រព័ន្ធបោះឆ្នោតរបស់បណ្តាប្រទេសទាំងនេះដែលឆ្លងកាត់ការវិវត្តន៍ជាជាងការផ្លាស់ប្តូរដោយការបដិវត្តន៍។

ឯកសារស្រាវជ្រាវនេះសិក្សាទៅលើទិដ្ឋភាពបីសំខាន់ៗនៃប្រព័ន្ធបោះឆ្នោតបច្ចុប្បន្នរបស់ប្រទេសទាំងនេះ រួមមាន៖ បទបញ្ញានិងបទបញ្ញត្តិស្តីពីហិរញ្ញប្បទានសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត ដំណើរការនៃការចុះឈ្មោះបោះឆ្នោត និងការត្រួតពិនិត្យនិងភារកិច្ចរបស់ស្ថាប័នគ្រប់គ្រងការបោះឆ្នោត។ ទិដ្ឋភាពទាំងអស់នេះត្រូវបានជ្រើសរើសសម្រាប់ការសិក្សា ដោយហេតុថាទិដ្ឋភាពនីមួយៗសំខាន់ក្នុងការអនុវត្តន៍នូវអ្វីដែល បទដ្ឋានអន្តរជាតិបានចាត់ទុកថាជាការបោះឆ្នោតសេរីនិងយុត្តិធម៌។ ឯកសារស្រាវជ្រាវនេះត្រូវបានរៀបចំដោយសិក្សាពី របបនៃប្រទេសនីមួយៗ តាមទិដ្ឋភាពនីមួយៗ ខាង លើ ដោយចាប់ផ្តើមពីការបង្ហាញទិដ្ឋភាពទូទៅនៃប្រព័ន្ធរបស់ប្រទេសកម្ពុជា ដើម្បីសម្រួលក្នុងការសិក្សាប្រៀបធៀប និងតាមលំដាប់លំដោយនៃលក្ខណៈសំបូរបែប[1] (ឧ៖ ដូចជាប្រទេសបារាំងដែលប្រពន្ធ័បោះឆ្នោតមានល្ខណៈសំបូរបែបជាងគេ) នៃប្រពន្ធ័បោះឆ្នោតដូចតទៅ៖ បារាំង កូរ៉េខាងត្បូង ហ្វីលីពីន និងឥណ្ឌូនេស៊ី។

បណ្តាប្រទេសទាំងនេះត្រូវបានគេជ្រើសរើសដើម្បីលើកយកមកសិក្សាពីព្រោះប្រទេសទាំងនេះមានចំណុចស្រដៀងគ្នានិងផ្ទុយគ្នាទាំងនៅក្នុងបញ្ហានៃការអនុវត្តន៍ និងវិធីសាស្រ្តក្នុងការដោះស្រាយបញ្ហាទាំងនោះ។ ដោយសារតែមានការអភិវឌ្ឍន៍សេដ្ឋកិច្ចខ្ពស់ ប្រទេសបារាំង និងកូរ៉េខាងត្បូងមានធនធានក្នុងការណែនាំដាក់ឲ្យប្រើបញ្ជីឈ្មោះអ្នកបោះឆ្នោតបែបឌីជីថលទំនើបដែលអាចជៀសវាងបញ្ហាជាច្រើនដែលបានកើតមានឡើងនៅពេលចុះឈ្មោះបោះឆ្នោត និងការកំណត់អត្តសញ្ញាណអ្នកបោះឆ្នោតដូចនៅក្នុងប្រទេសកម្ពុជា ប្រទេសហ្វីលីពីន និងប្រទេសឥណ្ឌូនេស៊ី។ ដូចគ្នានេះដែរ បណ្តាប្រទេសទាំងនេះទទួលបានជោគជ័យ ក្នុងការអនុវត្តន៍ច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញប្បទាននិងការកម្រិតចំណាយក្នុង


[1] ភាពល្អិតល្អន់នៃប្រព័ន្ធបោះឆ្នោតសំដៅទៅលើភាពសំបូរបែប និងប្រព័ន្ធដែលមានលក្ខណៈស្ទើរតែគ្រប់ជ្រុងជ្រោយទាក់ទងនឹងចំនួន និងគុណភាពនៃបញ្ញត្តិរបស់ច្បាប់ និងបទបញ្ញា និងប្រសិទ្ធផលរបស់យន្តការទាំងនោះ

យុទ្ធនាការឃោសនាដ៏សំបូរបែប។ ទោះជាយ៉ាងណាក៏ដោយ ខណៈដែលវិធានការណ៍ទាំងពីរខាងលើនេះ ពឹងផ្អែកទៅលើ ធនធាន អ្នកជំនាញនិងការចែកចាយព័ត៌មានឬទិន្នន័យបែបឌីជីថលរវាងស្ថាប័នរដ្ឋប្រទេសហ្វីលីពីននិងឥណ្ឌូនេស៊ីបានប្រើប្រាស់វិធីសាស្ត្រផ្សេងៗគ្នាដើម្បីសម្រេចបាននូវលទ្ធផលកាន់តែប្រសើរទាំងនេះ។ អ្វីដែលគួរឲ្យកត់សម្គាល់នោះគឺប្រទេសហ្វីលីពីនបានប្រើទិន្នន័យជីវសញ្ញាណ (Biometric data) តាមរយៈម៉ាស៊ីនថតស្នាមម្រាមដៃបែបឌីជីថល។ បច្ចេកវិទ្យាបែបនេះប្រហែលជាអាចយកមកអនុវត្តបានចំពោះប្រទេសទាំងឡាយណាដែលបានប្រើប្រាស់បច្ចេកវិទ្យានេះនៅក្នុងនីតិវិធីអន្តោប្រវេសន៍របស់ខ្លួនរួចមកហើយ ហេតុដូច្នេះប្រទេសទាំងនោះប្រហែលជាអាចប្រើប្រាស់បច្ចេកវិទ្យានេះសម្រាប់បង្កើតប្រព័ន្ធចុះឈ្មោះបោះឆ្នោតបាន។ ទាក់ទងនឹងស្ថាប័នរៀបចំការគ្រប់គ្រងបោះឆ្នោតប្រទេសនីមួយៗមានលក្ខណៈផ្សេងគ្នាទាំងរចនាសម្ពន្ធ័និងអំណាច ទោះជាយ៉ាងណាក៏បណ្ដាប្រទេសទាំងនេះមានគោលបំណងផ្ដល់សេវាដូចៗគ្នា។

ខាងក្រោមនេះជាសេចក្ដីសង្ខេបអំពីរបបបោះឆ្នោតនៃប្រទេសនីមួយៗ៖

## ប្រទេសកម្ពុជា

### *ហិរញ្ញប្បទានសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត*

បើទោះបីជាប្រទេសកម្ពុជាមានច្បាប់ស្ដីពីហិរញ្ញប្បទានសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោតដែលផ្ដល់សិទ្ធិឲ្យគណបក្សទាំងអស់ដែលទទួលបានសម្លេងឆ្នោតលើសពី ៣(បី) ភាគរយទទួលបានការឧបត្ថម្ភជាបដិភាគពីរដ្ឋក៏ដោយ ក៏ព័ត៌មានលំអិតនៃកម្មវិធីនេះមិនទាន់ត្រូវបានបង្កើតឡើង ពេញលេញនៅឡើយទេ។ ប្រទេសកម្ពុជាពុំទាន់មានច្បាប់ណាមួយដើម្បីត្រួតពិនិត្យនិងដាក់កម្រិតទៅ លើការចំណាយសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោតទេ។ ផ្ទុយទៅវិញ ប្រទេសបារាំងនិងប្រទេសកូរ៉េខាងត្បូងមានយន្តការហិរញ្ញប្បទានប្រកបដោយលក្ខណៈសំបូរបែបនិងមានការត្រួតពិនិត្យជាច្រើនកម្រិត។

### *ការចុះឈ្មោះបោះឆ្នោត*

របបចុះឈ្មោះបោះឆ្នោតរបស់ប្រទេសកម្ពុជាមានលក្ខណៈចម្រុះ រវាង បញ្ជីឈ្មោះ បោះឆ្នោតតាមប្រព័ន្ធដែលផ្ដល់ទិន្នន័យ ថ្មីបំផុត និងប្រព័ន្ធដែលផ្ដល់ទិន្នន័យតាមដំណាក់កាល ដែលអាច ធ្វើការកែប្រែក្នុងរយៈពេលបីខែជារៀងរាល់ឆ្នាំ ឬក៏កំឡុងពេលមុនការបោះឆ្នោត។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប)មានរយៈពេល៩០(កៅសិប)ថ្ងៃ យ៉ាងតិច (សម្រាប់ការបោះឆ្នោតជាសកល និង១២០ថ្ងៃ(មួយរយម្ភៃ)ច្រើនបំផុត) សម្រាប់ការពិនិត្យបញ្ជីឈ្មោះនិងការចុះឈ្មោះបោះឆ្នោត និងការផ្ដល់សុពលភាពលើបញ្ជីបោះឆ្នោតដែលអាចឱ្យសាធារណៈជនធ្វើការពិនិត្យឡើងវិញលើទិន្នន័យរបស់ខ្លួន រាយ

ការណ៍ និងកែតម្រូវទៅលើកំហុសទាំងនោះ។ អ្នកដែលមានបំណងចង់ចុះឈ្មោះរបស់ខ្លួនដើម្បីបោះឆ្នោតតែខ្វះសំណុំបែបបទត្រឹមត្រូវនៃលេខសម្គាល់រូបភាពអាចចុះឈ្មោះបានឆន្ទានុសិទ្ធិរបស់មេឃុំឬចៅសង្កាត់របស់ខ្លួន ។ ខណៈ ដែលវិធានការណ៍មួយចំនួនត្រូវបានណែនាំឲ្យប្រើដើម្បីកាត់បន្ថយនូវការរំលោភនៃឆន្ទានុសិទ្ធិនេះ បញ្ហានេះនៅតែគេទទួលស្គាល់ថា ជាចំណុចខ្សោយនៃប្រពន្ធ័បោះឆ្នោតនៅកម្ពុជា។ អ្នកបោះឆ្នោតដែលបានចុះឈ្មោះនៅក្នុងបញ្ជីឈ្មោះ តាមតំបន់របស់ខ្លួនមិនអាចទៅបោះឆ្នោតនៅឯតំបន់ផ្សេងបានទេ។

*ការត្រួតពិនិត្យ៖ ដោយស្ថាប័នគ្រប់គ្រងការបោះឆ្នោត*

ការបោះឆ្នោតនៅក្នុងប្រទេសកម្ពុជាត្រូវត្រួតពិនិត្យនិងគ្រប់គ្រងដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ ច្បាប់គ្រប់គ្រងរបស់គ.ជ.ប ត្រូវបានធ្វើវិសោធនកម្មចំនួនបីដងរួចមកហើយ ចាប់តាំងពីស្ថាប័ននេះត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៩៧ ដែលបង្ហាញអំពីការវិវត្តន៍ទៅមុខនៃការគ្រប់គ្រងការបោះឆ្នោតនៅប្រទេសកម្ពុជា។ សមាជិកគ.ជ.បត្រូវបានតែងតាំងដោយព្រះមហា ក្សត្របន្ទាប់ពីការបោះឆ្នោតត្រូវបានអនុម័តយល់ព្រមដោយសភាជាតិដែលអាចជ្រើសរើសបេក្ខជនមួយក្រុមដោយយោងតាមសំណើបេក្ខភាពពីគណៈរដ្ឋមន្ត្រី។ ក្រុមប្រឹក្សាធម្មនុញ្ញមានតួនាទីទទួលនិងដោះស្រាយវិវាទនៃការបោះឆ្នោត។

## ប្រទេសបារាំង

*ហិរញ្ញប្បទានសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត*

ប្រទេសបារាំងចាប់ផ្តើមតាក់តែងច្បាប់ស្តីពីហិរញ្ញប្បទានសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោតនៅឆ្នាំ១៩៨៨។ គណនីរបស់បេក្ខជនឃោសនាបោះឆ្នោតត្រូវ ត្រួតពិនិត្យដោយគណៈកម្មការពិសេស មុនពេលដែលហិរញ្ញប្បទានរបស់ពួកគេត្រូវបានអនុម័តយល់ព្រម និងមានកំណត់ពីចំនួនអតិបរមានៃការឧបត្ថម្ភដែលបុគ្គលម្នាក់អាចឧបត្ថម្ភឲ្យទៅបេក្ខជនម្នាក់។ ក្នុងនោះ ការកំណត់យ៉ាងតឹងតែងទៅលើការចំណាយសម្រាប់យុទ្ធនាការឃោសនាក៏ត្រូវបានអនុវត្តផងដែរ។ រាល់បុគ្គលណាដែលបំពាន ច្បាប់នេះត្រូវប្រឈមមុខនឹងទោសជាកពិន័យ និងជាប់ពន្ធនាគារ។

*ការចុះឈ្មោះបោះឆ្នោត*

ប្រព័ន្ធនៃការចុះឈ្មោះបោះឆ្នោតនៅប្រទេសបារាំងនឹងធ្វើការចុះឈ្មោះដោយស្វ័យប្រវត្តិរាល់បុគ្គលណាដែលគ្រប់អាយុ១៨ឆ្នាំ តាមរយៈការចែករំលែក ទិន្នន័យបានល្អរវាងស្ថាប័នរដ្ឋដែលពាក់ពន្ធ័។ ការចែករំលែកទិន្នន័យទាំងនេះ ក៏ធានាថាមនុស្សម្នាក់អាចត្រូវបានចុះបញ្ជីតែមួយគត់ដើម្បីបោះឆ្នោត។ អ្នកដែលមានបំណង ប្តូរទីតាំងចុះឈ្មោះបោះឆ្នោតអាចធ្វើបាននៅសាលាក្រុងដោយភ្ជាប់ជាមួយនូវ អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន។ បញ្ជីឈ្មោះត្រូវបានរៀបចំនៅថ្ងៃ ទី៣១ ខែធ្នូ នៃឆ្នាំមុនការបោះឆ្នោត ហើយរាល់ការផ្លាស់ប្តូរណាមួយ ត្រូវបានពិនិត្យនិងអនុម័តតាមឋានានុក្រមពីរកម្រិត ។ អ្នកបោះឆ្នោតអាចបោះឆ្នោតនៅមណ្ឌលបោះឆ្នោតណាមួយក៏បាន ដោយមិនចាំបាច់រៀបចំជាមុន។

*ការត្រួតពិនិត្យ៖ ស្ថាប័នគ្រប់គ្រងការបោះឆ្នោត*

ការិយាល័យរៀបចំការបោះឆ្នោតរបស់ក្រសួងមហាផ្ទៃនឹងទទួលបន្ទុក រៀបចំគ្រប់គ្រងការបោះឆ្នោត។ ប៉ុន្តែនៅប្រទេសកម្ពុជា ក្រុមប្រឹក្សាធម្មនុញ្ញដែលធ្វើប្រតិបត្តិការឯករាជ្យពីរដ្ឋាភិបាល គឺជាអាជ្ញាកណ្តាលចុងក្រោយ ក្នុងការដោះស្រាយវិវាទបោះឆ្នោតទាំងឡាយ។

## ប្រទេសកូរ៉េខាងត្បូង

*ហិរញ្ញប្បទានសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត*

ប្រទេសកូរ៉េខាងត្បូងបានបង្កើនបញ្ញត្តិហិរញ្ញប្បទាន សម្រាប់យុទ្ធនាការឃោសនាបោះឆ្នោតនៅក្នុងរយៈពេល២០ឆ្នាំចុងក្រោយនេះ ដែលជាផ្នែកមួយនៃការខិតខំប្រឹងប្រែង ដើម្បីកាត់បន្ថយអំពើពុករលួយ និងកាត់បន្ថយការចូលរួមពីវិស័យឯកជននៅក្នុងនយោបាយរបស់ប្រទេស ។ បន្ថែមពីលើការផ្តល់ហិរញ្ញប្បទានទៅលើការចំណាយរបស់គណបក្សនយោបាយ ដែលមានអាសនៈ នៅក្នុងសភា ប្រទេសកូរ៉េខាងត្បូងក៏បានផ្តល់នូវហិរញ្ញប្បទានសម្រាប់យុទ្ធនាការបោះឆ្នោតបន្ថែមទៀតមុនពេលបោះឆ្នោតផងដែរ។ ហិរញ្ញប្បទានត្រូវបានគណនាទៅតាមចំនួនអសនៈដែលគណបក្សនីមួយៗ មាន ហើយការចំណាយត្រូវបានកម្រិតតែទៅលើយុទ្ធនាការឃោសនាបោះឆ្នោត។ អំណោយពីបុគ្គលនិងពីសមាគមត្រូវបានកំណត់និងកត់ត្រាទុកក្នុងឯកសារ ខណៈដែលអំណោយពីជនអនាមិក ត្រូវកម្រិតត្រឹម ៩៥ដុល្លារប៉ុណ្ណោះ។ ព័ត៌មានពីការចំណាយលើយុទ្ធនាឃោសនាបោះឆ្នោតត្រូវតែបើកចំហរសម្រាប់គណៈកម្មការបោះឆ្នោតដើម្បីធានាថា ដែនកំណត់នៃការចំណាយនិង ប្បត្តិហិរញ្ញប្បទានសម្រាប់ យុទ្ធនាការឃោសនាបោះឆ្នោតត្រូវបានគោរព។ រាល់ការបំពានទៅលើបុញ្ញត្តិនេះអាចទទួលនូវទោសជាកពិន័យ និង ពន្ធនាគារ។

*ការចុះឈ្មោះបោះឆ្នោត*

ដំណើរការចុះឈ្មោះបោះឆ្នោតនៅប្រទេសកូរ៉េខាងត្បូងមានលក្ខណៈឌីជីថលនិងប្រតិបត្តិតាមរយៈប្រព័ន្ធមួយដែលបន្តចុះឈ្មោះអ្នកដែលមានសិទ្ធិបោះឆ្នោតនិងចងក្រងជាបញ្ជីឈ្មោះបោះឆ្នោតមួយដោយស្វ័យប្រវត្តិផងដែរ។ សាធារណៈជនអាចពិនិត្យបញ្ជីទាំងនោះ បានតាមរយៈការិយាល័យដែលបានចាត់តាំងនិងដែលត្រូវបានផ្សព្វផ្សាយតាមប្រព័ន្ធអ៊ិនធើណែត ដើម្បីធានាថាទិន្នន័យរបស់ពួកគេគឺមានភាពត្រឹមត្រូវ។ ប្រជាពលរដ្ឋអាចទៅបោះឆ្នោតនៅមណ្ឌលបោះឆ្នោតណាមួយក៏បាន ដោយមិនចាំបាច់ឲ្យមានការរៀបចំជាមុន។

*ការគ្រប់គ្រង៖ ស្ថាប័នគ្រប់គ្រងការបោះឆ្នោត*

ការបោះឆ្នោតនៅប្រទេសកូរ៉េខាងត្បូងត្រូវបានគ្រប់គ្រងទាំងស្រុងដោយគណៈកម្មការជាតិរៀបចំការបោះឆ្នោតឯករាជ្យមួយ។ អង្គភាពនេះទទួលខុសត្រូវគ្រប់គ្រងលើទិដ្ឋភាពនៃ ការបោះឆ្នោតនិងការដោះស្រាយវិវាទ ហើយថែមទាំងត្រូវបានផ្តល់អំណាចឲ្យធ្វើការស៊ើបអង្កេតទៅលើការបន្លំនៃការបោះឆ្នោតណាមួយដែលអាចនឹងកើតមានឡើងផងដែរ។

## ប្រទេសហ្វីលីន

*ហិរញ្ញប្បទានសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត*

ប្រទេសហ្វីលីពីនបានចាប់ផ្តើមចែងឬវត្តិហិរញ្ញប្បទានឃោសនាការបោះឆ្នោតក្នុងឆ្នាំ ១៩៨៥ ។ គណៈកម្មាការរៀបចំការបោះឆ្នោត (COMELEC) របស់ប្រទេសនេះត្រូវបានផ្តល់អំណាច ក្នុងការស៊ើបអង្កេតទៅលើកំណត់ត្រាហិរញ្ញវត្ថុដែលទាក់ទងនឹងយុទ្ធនាការបោះឆ្នោតទាំងអស់ ហើយផ្សាយជាសាធារណៈពីការរកឃើញនិងការជម្រុញឲ្យមានកាត់ទោសដល់ការរំលោភនេះ។ អំណោយពីអង្គការរដ្ឋាភិបាល ស្ថាប័នសាធារណៈដូចជាសាកលវិទ្យាល័យ និងអ្នកផ្តល់ជំនួយបរទេសត្រូវបានហាមឃាត់។ ម្ចាស់អំណោយដែលឧបត្ថម្ភដល់បេក្ខជននយោបាយ គឺតម្រូវឲ្យជូនដំណឹងទៅគណៈកម្មាការរៀបចំការបោះឆ្នោត (COMELEC) អំពីការបរិច្ចាគរបស់ពួកគេ។ ការចំណាយសរុបសម្រាប់ការធ្វើយុទ្ធនាការត្រូវបានកម្រិតនិងគ្រប់គ្រងដោយ COMELEC ។

*ការចុះឈ្មោះបោះឆ្នោត*

នៅឆ្នាំ១៩៩៨ ប្រទេសហ្វីលីពីនបានបង្កើតដំណើរការចុះឈ្មោះបោះឆ្នោត និងបញ្ជីឈ្មោះបោះឆ្នោតជាលើកដំបូង។ បញ្ជីឈ្មោះនេះត្រូវបានធ្វើបច្ចុប្បន្នភាពជាបន្តបន្ទាប់នៅថ្នាក់តំបន់។ ពាក្យសុំផ្លាស់ប្តូរការចុះបញ្ជីបោះឆ្នោត ឬប្តូរកន្លែងបោះឆ្នោតរបស់ពួកគេ គឺត្រូវធ្វើទៅកាន់ក្រុមប្រឹក្សាភិបាលចុះឈ្មោះបោះឆ្នោត។ ចាប់តាំងពីឆ្នាំ២០០៣ ប្រទេសហ្វីលីពីនបានចាប់ផ្តើមយកជីវៈសញ្ញាណ(Biometric Data) របស់អ្នកបោះឆ្នោតដើម្បីបង្កើត ទិន្នន័យកណ្តាលមួយ ដើម្បីបង្ការ ការ បញ្ចូលនូវទិន្នន័យស្ទួន។ ប្រទេសហ្វីលីពីនមិនបានផ្តល់លទ្ធភាពដើម្បីឲ្យមនុស្សម្នាក់អាចបោះឆ្នោតបាននៅមណ្ឌលផ្សេងពីមណ្ឌលដែលខ្លួនចុះឈ្មោះបោះឆ្នោតនោះទេ។

*ការគ្រប់គ្រង៖ ស្ថាប័នគ្រប់គ្រងការបោះឆ្នោត*

ការបោះឆ្នោតនៅប្រទេសហ្វីលីពីនគ្រប់គ្រងដោយគណៈកម្មការរៀបចំការបោះឆ្នោត(COMELEC)។ គណៈកម្មការរៀបចំការបោះឆ្នោតត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៤០ ហើយត្រូវបានឆ្លង កាត់ការផ្លាស់ប្តូរជាច្រើនដងចាប់តាំងពីពេលនោះមក ហើយឥឡូវនេះគណៈកម្មការនេះបានក្លាយជាអាជ្ញាធរឯករាជ្យ មួយដែលទទួលបន្ទុកគ្រប់គ្រងលើគ្រប់ច្បាប់បោះឆ្នោតនៅប្រទេសហ្វីលីពីន រួមទាំងធ្វើការស៊ើបអង្កេតទៅលើបទល្មើសទាំងឡាយដែលពាក់ព័ន្ធនឹងការបោះឆ្នោត និង ការអនុវត្តន៍បទបញ្ញត្តិបោះឆ្នោត។ ទោះជាយ៉ាងណាក៏ដោយ រាល់ការតែងតាំងនិងលទ្ធផលនៃការបោះឆ្នោតជ្រើសតាំងប្រធានាធិបតី និង

អនុប្រធានាធិបតី ព្រឹទ្ធសភា និងសភាតំណាងរាស្ត្រ(House of Representative) ត្រូវកំណត់ដោយតុលាការពិសេសមួយដែលដឹកនាំដោយចៅក្រមនៃតុលាការកំពូល។ រាល់សេចក្តី សម្រេចរបស់តុលាការនេះ ត្រូវអនុវត្តដោយគណៈកម្មការរៀបចំការបោះឆ្នោត (COMELEC)។

## ប្រទេសឥណ្ឌូនេស៊ី

*ហិរញ្ញប្បទានសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត*

ចាប់ផ្តើមពីឆ្នាំ១៩៩៨មក ប្រទេសឥណ្ឌូនេស៊ីបានចាប់ផ្តើមដាក់ចេញនូវបទប្បញ្ញត្តិមួយចំនួន ក្នុងគោលបំនងធ្វើឲ្យប្រសើរឡើងនូវស្ថាប័នប្រជាធិបតេយ្យ។ ជាផ្នែកមួយនៃដំណើរការនេះ ប្រទេសឥណ្ឌូនេស៊ីបានដាក់កម្រិតទៅលើផ្តល់អំណោយពីបុគ្គលនិងពីអង្គភាព ហើយការផ្តល់អំណោយត្រូវធ្វើឡើងដោយបើកចំហ។ ខណៈដែលអំណោយអនាមិកនិងពីបរទេសត្រូវបានហាមឃាត់។ នៅពេល ដែលគណៈកម្មការជាតិរៀបចំការបោះឆ្នោត (KPU) ប្រទេសឥណ្ឌូនេស៊ី ធ្វើសវនកម្មទៅលើគណនីហិរញ្ញប្បទានឃោសនាបោះឆ្នោត គណៈកម្មការនេះនៅតែកំពុងអភិវឌ្ឍយន្តការអនុវត្តច្បាប់ ដែលសម ស្របផងដែរ។ ការផ្តល់ហិរញ្ញប្បទានសាធារណៈដល់បេក្ខជនគឺនៅមាន ទោះបីជាការផ្តល់ឲ្យនៅក្នុងពេលបច្ចុប្បន្ននេះស្ថិតនៅក្នុងកម្រិតតិចតួចក៏ដោយ។

*ការចុះឈ្មោះបោះឆ្នោត*

ប្រព័ន្ធចុះឈ្មោះបោះឆ្នោតនៅប្រទេសឥណ្ឌូនេស៊ីអនុវត្តតាមវិធីសាស្ត្រពិនិត្យឡើងវិញ តាមដំណាក់កាល ។ បញ្ជីបោះឆ្នោតកាលពីមុនត្រូវបានផ្អែកទៅលើទិន្នន័យជំរឿន។ ទោះជាយ៉ាងណា វិធីសាស្ត្រនេះបាននាំទៅរកកំហុសឆ្គងជាច្រើន ហេតុនេះ នៅពេលបច្ចុប្បន្ន វិធីសាស្ត្រនេះត្រូវបានជំនួសដោយ ចងក្រងបញ្ជីឈ្មោះបោះឆ្នោតដោយពឹងផ្អែកលើទិន្នន័យយោងពីការិយាល័យរដ្ឋាភិបាលជាច្រើន។ តាមរយៈប្រព័ន្ធថ្មីនេះ មុនពេលបោះឆ្នោត ៣៤(សាមសិបបួន) សប្តាហ៍ បញ្ជីឈ្មោះបោះឆ្នោតត្រូវដាក់ឲ្យពិនិត្យឡើងវិញក្នុងរយៈពេល៣សប្តាហ៍។ បន្ទាប់ពីធ្វើការបញ្ចូល នូវទិន្នន័យដែលថ្មីបំផុតរួចហើយ បញ្ជីបោះឆ្នោតនឹងត្រូវផ្សាយជាសាធារណៈក្នុងពេល ២៦(ម្ភៃប្រាំមួយ) សប្តាហ៍ មុនពេលបោះឆ្នោត។ នៅឆ្នាំ ២០១២ អ្នកដែលមិនបានចុះឈ្មោះបោះឆ្នោតអាចចុះឈ្មោះបានដោយគ្រាន់តែបង្ហាញនូវអត្តសញ្ញាណប័ណ្ណ និងលិខិតឆ្លងដែនរបស់ពួកគេតែប៉ុណ្ណោះ។ បទប្បញ្ញត្តិនេះ ក៏បានបញ្ចូល អ្នកដែលខ្វះឯកសារបែបនេះទៅក្នុងបញ្ជីបោះឆ្នោតពិសេសផងដែរ។ សេចក្តីលំអិតថាតើប្រព័ន្ធនេះនឹងត្រូវប្បត្តិបែបណា គឺមិនទាន់ត្រូវបានគេប្រកាសនៅឡើយទេ។ ដំណើរការស្រដៀងគ្នានេះដែរ គឺកំពុងត្រូវបានអភិវឌ្ឍដែលអនុញ្ញាតឲ្យប្រជាពលរដ្ឋចុះឈ្មោះដោយខ្លួនឯងនៅក្នុង ”បញ្ជីឈ្មោះបោះឆ្នោតបន្ថែម” រហូតដល់ទៅ៣(បី)ថ្ងៃ មុនថ្ងៃបោះឆ្នោត ដើម្បីអនុញ្ញាតឲ្យពួកគេអាចបោះឆ្នោតនៅការិយាល័យបោះឆ្នោតដែលខុសគ្នាពីកន្លែងដែលពួកគេបានចុះឈ្មោះបោះឆ្នោត។ សេចក្តីលំអិតអំពីរបៀប គ្រប់គ្រងបញ្ជីបោះឆ្នោតបន្ថែមនេះ កំពុងតែត្រូវបានបង្កើត។

*ការគ្រប់គ្រង៖ ស្ថាប័នគ្រប់គ្រងការបោះឆ្នោត*

ការបោះឆ្នោតរបស់ប្រទេសឥណ្ឌូនេស៊ីត្រូវបានគ្រប់គ្រងដោយគណៈកម្មាការជាតិរៀបចំការបោះឆ្នោត (KPU) ចាប់តាំងពីឆ្នាំ ២០០១ មកម្ល៉េះ ។ ស្ថាប័ននេះមានការផ្លាស់ប្តូរយ៉ាងខ្លាំង គិតចាប់តាំងការបង្កើតដំបូង ហើយឥឡូវនេះបានក្លាយទៅជាអាជ្ញាធរឯករាជ្យនិងអចិន្ត្រៃយ៍មួយដែលមានតួនាទីគ្រប់គ្រងគ្រប់ទិដ្ឋភាពនៃការបោះឆ្នោត។ ការប្រព្រឹត្តទៅរបស់គណៈកម្មការនេះត្រូវបានធ្វើសវនកម្មនិងវាយតម្លៃដោយភ្នាក់ងារត្រួតពិនិត្យការបោះឆ្នោត (Election Supervisory Body) ដែលទទួលបន្ទុកស៊ើបអង្កេតទៅលើភាពខុសឆ្គងណាមួយ និងជាអាជ្ញាកណ្តាលចុងក្រោយទៅលើវិវាទបោះឆ្នោត លើកលែងក្នុងករណីពាក់ព័ន្ធនឹងសេចក្តីសម្រេចទៅលើការបញ្ជាក់នូវលក្ខណៈសម្បត្តិគុណវុឌ្ឍិនៃគណបក្សនយោបាយដែលចូលរួមប្រកួតប្រជែង និងបេក្ខជនដែលឈរឈ្មោះបោះឆ្នោតជា សមាជិកនៃអាជ្ញាធរតាមថ្នាក់មូលដ្ឋាននានា។ ចំពោះករណីលើកលែងទាំងនេះ តុលាការរដ្ឋបាលរបស់រដ្ឋ ជាតុលាការមានសមត្ថកិច្ច។ ក្រុមប្រឹក្សាកិត្តិយសនៃស្ថាប័នគ្រប់គ្រងការបោះឆ្នោត (DKPP) ត្រូវបានបង្កើតឡើងដោយមានតួនាទីក្នុងការរៀបរៀង អនុម័ត និង ដាក់ឲ្យអនុវត្តនូវក្រមសីលធម៌ដើម្បី ធានា ចំពោះ ឯករាជ្យភាព សុចរិតភាព និង ភាពជឿទុកចិត្តរបស់សមាជិករបស់គណៈកម្មការជាតិរៀបចំការបោះឆ្នោត (KPU) និង សមាជិកនៃត្រួតពិនិត្យការបោះឆ្នោត(Election Supervisory Body)។ ក្នុងករណីដែលមានការបំពានលើក្រមសីលធម៌នេះ ក្រុមប្រឹក្សាកិត្តិយសនៃស្ថាប័នគ្រប់គ្រងការបោះឆ្នោត(DKPP)ជាអ្នកមានសមត្ថកិច្ច ដោះស្រាយ ហើយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាកិត្តិយសនេះគឺមានលក្ខណៈ ចាប់បង្ខំនិងបិទផ្លូវតវ៉ា។

# I. សេចក្តីផ្តើម

ឯកសារស្រាវជ្រាវនេះជាការសិក្សាប្រៀបធៀបអំពីបញ្ហាដែលពាក់ព័ន្ធទៅនឹងដំណើរការបោះឆ្នោតក្នុងយុត្តាធិការនៃប្រទេស បួនគឺ៖ ប្រទេសបារាំង កូរ៉េខាងត្បូង ឥណ្ឌូនេស៊ី និងហ្វីលីពីន ដោយរួមមានការសង្ខេបនូវទិដ្ឋភាពទូទៅនៃប្រទេសកម្ពុជានៅក្នុងផ្នែកនីមួយៗសម្រាប់ជាសំអាង។ ការសិក្សានេះនឹងពិនិត្យលើទិដ្ឋភាពសំខាន់បី របស់ប្រព័ន្ធបោះឆ្នោតនៃប្រទេសនីមួយៗដែលចាំបាច់ក្នុងការធានាថាការបោះឆ្នោតនឹងធ្វើឡើង ដោយភាពប្រសិទ្ធភាព សេរី និងយុត្តិធម៌ ដោយរួមមាន៖ បទប្បញ្ញត្តិនៃការផ្តល់ហិរញ្ញប្បទានសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត ដំណើរការនៃការចុះឈ្មោះបោះឆ្នោត និងស្ថាប័នគ្រប់គ្រងការបោះឆ្នោត។ បន្ទាប់ពីនេះផ្នែកវិភាគធ្វើការវាយតម្លៃទៅលើភាពខ្លាំង និងភាពខ្សោយនៃវិធីសាស្ត្ររបស់ប្រទេសនីមួយៗ និងភាពសមស្របព្រមទាំងអត្ថប្រយោជន៍សម្រាប់ប្រទេសនីមួយៗដែលអនុវត្តវិធីសាស្ត្រទាំងនេះ។

ហិរញ្ញប្បទានសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោតគឺជាការសំខាន់ ប៉ុន្តែ បុញ្ញត្តិដែលទាក់ទងនឹងបញ្ហានេះទើបតែនឹងបានបង្កើតនាពេលថ្មីៗនេះនៅក្នុងបទបញ្ញាឬច្បាប់ទាំងឡាយដែលទាក់ទងនឹងការបោះឆ្នោត ។ នេះជាការសំខាន់ដោយសារតែប្បត្តិស្តីពីការផ្តល់ហិរញ្ញប្បទានរបស់សាធារណៈជន អាចអនុញ្ញាតឲ្យបេក្ខជន និងគណបក្សនយោបាយទាំងឡាយណាដែលពុំមានលទ្ធភាព កាន់តែមានលទ្ធភាពច្រើនក្នុងការចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោត។ ការកម្រិតនិងបញ្ញត្តិស្តីពីការចំណាយសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោតក៏សំខាន់ផងដែរ ព្រោះកិច្ចការនេះអាចទប់ស្កាត់បេក្ខជនដែលមានទ្រព្យសម្បត្តិច្រើនជាងគេឈ្នះដោយ ការចំណាយដ៏លើសលុប លើគូរប្រគួតប្រជែង។ ទោះជាយ៉ាងណាក្តី ការចាប់ផ្តើមដោយជោគជ័យនិងការគ្រប់គ្រងដំណើរការនេះ គឺជាមានលក្ខណៈស្មុគស្មាញ និងត្រូវការធនធានជាច្រើន ហើយដែលទិដ្ឋភាពនេះនឹងត្រូវលើកយកមកសិក្សានៅក្នុងឯកសារស្រាវជ្រាវនេះផងដែរ។

ការ ចុះឈ្មោះបោះឆ្នោតត្រឹមត្រូវពិតជាមានសារៈសំខាន់ដល់ ដំណើរការនៃលទ្ធិប្រជាធិបតេយ្យ។ តាមរយៈដំណើរការចុះឈ្មោះនេះហើយ ដែលសិទ្ធិតំណាងប្រជាពលរដ្ឋត្រូវបានទទួលស្គាល់។ ដូច្នេះគោលការណ៍ប្រជាធិបតេយ្យសំខាន់បំផុតនោះគឺ សិទ្ធិស្មើគ្នាក្នុងការបោះឆ្នោត ពឹងផ្អែក ទៅលើការបង្កើតនូវដំណើរការចុះបញ្ជីឈ្មោះដ៏ល្អមួយ។ គោលការណ៍ប្រជាធិបតេយ្យនឹងត្រូវបានធានា នៅពេលដែលបញ្ជីឈ្មោះបោះឆ្នោតមានលក្ខណៈ ពេញលេញនិងត្រឹមត្រូវបំផុតតាមដែលអាចធ្វើទៅបាន។ ខណៈពេលដែលលក្ខខណ្ឌនៃការចុះឈ្មោះត្រូវបានកំណត់នៅក្នុងលិខិតបទដ្ឋានជាច្រើននៅថ្នាក់អន្តរជាតិនិងថ្នាក់តំបន់ មកដល់ពេលនេះ អាស៊ាននៅមិនទាន់មានលិខិតបទដ្ឋាន បែបនេះនៅឡើយទេ[2]។ ប្រទេសនីមួយៗដែលបានលើកយកមកសិក្សានេះ មានបញ្ហាផ្សេងៗគ្នាដើម្បីដោះស្រាយ ដែលធ្វើឲ្យប៉ះពាល់ដល់បញ្ហាប្រឈមនៅពេលដែល គេព្យាយាមបង្កើតបញ្ជីឈ្មោះបោះឆ្នោតដែលត្រឹមត្រូវ និងដែលអាចអនុញ្ញាតឲ្យ

[2]សេចក្តីសង្ខេបនៃស្តង់ដារអន្តរជាតិស្តីពីការបោះឆ្នោតផ្តល់នូវបញ្ជីនៃលិខិតូបករណ៍ទាំងនោះ។ សម្រាប់ដំណើរការនយោបាយ បណ្តាប្រទេសក្នុងអាស៊ានមិនត្រូវការលិខិតូបករណ៍ទាំងនេះទេ ព្រោះអាស៊ានគ្មានការបោះឆ្នោតរួមទេ។ ប៉ុន្តែ អាស៊ានអាចផ្តល់នូវសេចក្តីណែនាំ(មិនមានចំណងគតិយុត្តិ) សម្រាប់រដ្ឋជាសមាជិករបស់ខ្លួន(ដូចជា គណកម្មការវេននីសធ្វើនៅសហគមអឺរ៉ុប)

ប្រជាជនដែលមានសិទ្ធបោះឆ្នោតអាចបោះឆ្នោតបានច្រើនតាមដែលអាចធ្វើទៅបាន។ បញ្ហាទាំងនេះតម្រូវឲ្យមានដំណោះស្រាយខុសគ្នាផង ដែរ។ ឧទាហរណ៍៖ ខណៈដែលប្រទេសបារាំងនិងប្រទេសកូរ៉េខាងត្បូងបានធ្វើការកែលំអរការចុះបញ្ជីឈ្មោះបោះឆ្នោតតាមរយៈការបញ្ចូលឯកសារទៅក្នុងប្រពន្ធ័ឌីជីថល និងការចែករំលែកទិន្នន័យរវាងស្ថាប័នរដ្ឋ ប្រទេសឥណ្ឌូនេស៊ី បានប្រើវិធីសាស្ត្រគ្រប់គ្រងបែបការិយាល័យធិបតេយ្យដ៏ស្មុគស្មាញដែលមានប្រព័ន្ធត្រួតពិនិត្យច្រើនថ្នាក់។ ប្រទេសហ្វីលីពីនដែលបានប្រើប្រាស់វិធីសាស្ត្រទាំងពីរបញ្ចូលគ្នា ដោយមានដំណើរការបែបការិយាល័យធិបតេយ្យច្រើនដំណាក់និងរឹងមាំ ដើម្បីជំរុញដល់ការចុះបញ្ជីបោះឆ្នោត ហើយស្របពេលគ្នានោះប្រទេសហ្វីលីពីនក៏ប្រើប្រាស់ផងដែរនូវទិន្នន័យបែបជីវសញ្ញាណ (Biometric database) នៅក្នុងបញ្ជីបោះឆ្នោតរបស់ខ្លួន ដែលអនុញ្ញាតឲ្យប្រជាពលរដ្ឋចុះឈ្មោះបោះឆ្នោតដោយក្រយៅដៃ ហើយសន្យាកាត់បន្ថយកំហុសឲ្យបានច្រើន ដូចជាការចុះឈ្មោះស្ទួនជាដើម។

ផ្នែកទីបីគឺនិយាយអំពីស្ថាប័នគ្រប់គ្រងការបោះឆ្នោតដែលជាអ្នកគ្រប់គ្រងនិងត្រួតពិនិត្យលើដំណើរការបោះឆ្នោតបង្ហាញថា មានវិធីសាស្ត្រ ផ្សេងៗគ្នាជាច្រើនក្នុងការការគ្រប់គ្រងការបោះឆ្នោត។ ឧទាហរណ៍៖ ស្ថាប័នគ្រប់គ្រងការបោះឆ្នោតរបស់ប្រទេសបារាំង អាចជាចំណែកមួយផ្ទាល់របស់ស្ថាប័នរដ្ឋ ប៉ុន្តែមានយន្តការគ្រប់គ្រងមួយឯករាជ្យ ដូចជាក្រុមប្រឹក្សាធម្មនុញ្ញ។ ប្រទេសកម្ពុជា និងកូរ៉េខាងត្បូងមានស្ថាប័នគ្រប់គ្រងការបោះឆ្នោតមួយឯករាជ្យទាំងស្រុង។ ប្រទេសហ្វីលីពីនមាន ស្ថាប័នគ្រប់គ្រងការបោះឆ្នោតឯករាជ្យ ដោយមានការចូលរួមរបស់តុលាការមួយចំនួន ដែលបង្កើតឡើងដើម្បីដោះស្រាយវិវាទនៃការបោះឆ្នោតទៅតាមមុខតំណែងជាក់លាក់ ចំណែកឯប្រទេសឥណ្ឌូនេស៊ីចាំបាច់ត្រូវមានស្ថាប័នឯករាជ្យពីរ មួយសម្រាប់ធ្វើសវនកម្មស្ថាប័នមួយទៀត និងតុលាការពិសេសមួយទៀតសម្រាប់ដោះស្រាយវិវាទ។

បន្តពីផ្នែកខាងលើ គឺជាការវិភាគដោយសង្ខេប ដែលជាការវាយតម្លៃថាតើបទពិសោធន៍ណាខ្លះដែលអាចទាញយក និងអនុវត្តបានពីបណ្តាប្រទេសដែលត្រូវបានសិក្សាក្នុងការសិក្សាស្រាវជ្រាវនេះ។

## II. ការផ្តល់ហិរញ្ញប្បទានសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត

សំណួរទាក់ទងទៅនឹងការផ្តល់ហិរញ្ញប្បទានសម្រាប់យុទ្ធនាការឃោសនានយោបាយគឺជាសំណួរមួយដែលត្រូវសួរថាតើបទប្បញ្ញត្តិនេះគួរតែមានដែរឬទេ ហើយកម្រិតប៉ុនណាដែលគួរតែត្រូវកំណត់។ គោលបំណងនៃការចែងប្បញ្ញត្តិស្តីពីហិរញ្ញប្បទានសម្រាប់យុទ្ធនាការឃោសនានយោបាយនេះគឺដើម្បីផ្តាច់ប្រាក់ឲ្យដាច់ចេញពីនយោបាយ។ ការផ្តល់ហិរញ្ញប្បទានសម្រាប់យុទ្ធនាការឃោសនានយោបាយមានអត្ថប្រយោជន៍ដូចជា[3]៖

- ការពង្រឹងស្ថាប័ននៃគណបក្សនយោបាយនិងប្រព័ន្ធពហុបក្ស

[3] Magnus OHMAN, *A brief introduction to public funding of political parties and election campaigns* (IFES) ខែមិនា ឆ្នាំ២០១១ ទំព័រទី ២-៣

- ធានានូវ វិធានដូច ឬស៊ីសង្វាក់គ្នារវាងគណបក្សនយោបាយ និងបេក្ខជនដែលទាក់ទងនឹងកម្រិតនៃធនធានក្នុងអំឡុងពេលបោះឆ្នោត
- ការកាត់បន្ថយតួនាទីរបស់ប្រាក់នៅក្នុងនយោបាយ[4] ដែលអនុញ្ញាតឱ្យការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាចកើតចេញពីបេក្ខជនគ្រប់ជាន់ថ្នាក់
- ការកាត់បន្ថយឥទ្ធិពលរបស់រដ្ឋាភិបាលទៅលើឥរិយាបថរបស់គណបក្សនយោបាយដោយការប្រើប្រាស់ហិរញ្ញប្បទានសាធារណៈ (សម្រាប់ការអនុវត្តន៍ល្អប្រសើរជាងមុននូវ គោលការណ៍តម្លាភាពហិរញ្ញវត្ថុ សមភាពយេនឌ័រ និងការលើកកម្ពស់ជនជាតិភាគតិចជាដើម...។ល។)។

ច្បាប់ស្តីពីការផ្តល់ហិរញ្ញប្បទានយុទ្ធនាការឃោសនាបោះឆ្នោតជាធម្មតាមានគោលដៅចំនួន៤(បួន)គឺ[5]:

- ដើម្បីប្រយុទ្ធប្រឆាំងនឹងអតិផរណានៃការចំណាយលើការបោះឆ្នោត
- ដើម្បីធានាថាបេក្ខជនមានមធ្យោបាយនិងលទ្ធភាពគ្រប់គ្រាន់
- ដើម្បីរក្សាតម្លាភាពនៃធនធាននិងការចំណាយ និង
- ដើម្បីធានាបាននូវការ អនុវត្តន៍ ការត្រួតពិនិត្យ និងការដាក់ពិន័យ (ប្រសិនបើគោលការណ៍នេះមិនត្រូវបានគោរពតាមនោះទេ)។

ទោះជាយ៉ាងណា ការនេះនាំមកនូវបញ្ហាប្រឈមផ្សេងៗទៀតដូចជា ការធ្វើឲ្យជីវិតនយោបាយក្លាយទៅជារបស់រដ្ឋាភិបាល ឬការផ្តាច់ទំនាក់ទំនងរវាងគណបក្សនយោបាយពីកង្វល់របស់ប្រជាជន (ទ្រឹស្តីរបស់សម្ពន្ធ័គណៈបក្ស-theory of the party cartel-)។ ទ្រឹស្តីនេះជាញឹកញាប់ត្រូវបានឃើញថាបានអនុវត្ត នៅក្នុងប្រទេស ដែលមានលទ្ធិប្រជាធិបតេយ្យចាស់ទុំ គឺសំដៅទៅលើស្ថានភាពដែលទិដ្ឋភាពនយោបាយមានលក្ខណៈហ្នឹងន[+] ប្រកបដោយប្រសិទ្ធិភាពដែលធ្វើឲ្យគណបក្សនយោបាយថ្មីមានការលំបាកនៅក្នុងការចូលរួមក្នុងឆាកនយោបាយ ។ ការនេះបង្កើតឲ្យមានការត្រួតត្រារបស់គណបក្សមួយចំនួនដែលអាចប្រើហិរញ្ញប្បទានសាធារណៈដើម្បីពង្រឹងគណបក្សរបស់ខ្លួន។ ម្យ៉ាងវិញទៀត ការផ្តល់ហិរញ្ញប្បទានដោយរដ្ឋបែបនេះអាចធ្វើឲ្យប្រជាពលរដ្ឋក្រីក្របាត់បង់នូវទំនុកចិត្ត ដោយពួកគាត់យល់ឃើញថាប្រាក់ត្រូវបានគេយកទៅចាយឥតប្រយោជន៍[6]។ ផ្ទុយទៅវិញ ដើម្បីទទួលបានការផ្តល់ហិរញ្ញប្ប

[4] វិធានស្តីពីការផ្តល់ហិរញ្ញប្បទានលើការឃោនាដែលមានលក្ខណៈជឿនលឿនមិនសំខាន់ក្នុងការកាត់បន្ថយឥទ្ធិពលរបស់លុយនោះទេ ដូចជានៅក្នុងការបោះឆ្នោតប្រធានាធិតីសហរដ្ឋអាមេរិច ។ ប៉ុន្តែ វិធានទាំងនេះធានានូវភាពស្មើគ្នាផ្នែកឃោធា

[5] "សេចក្តីស្នើកំណែទម្រង់ច្បាប់ស្តីពីហិរញ្ញប្បទានសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោតសម្រាប់ការបោះឆ្នោតថ្នាក់ជាតិ" ដោយលោក Pierre Mazeaud *របាយការណ៍ផ្ញើទៅកាន់ប្រធានរដ្ឋសភាជាតិ* ការចងក្រងរបាយការណ៍ផ្លូវការ ឯកសារជាភាសាបារាំង ទីក្រុងប៉ារីស ឆ្នាំ២០០៩ ទំព័រទី៥

[6] Hopkins Jonathan (ឆ្នាំ២០០៤) *The problem with party finance : theoretical perspectives on the funding of party politics.* Party politics ១០(៦) ទំព័រ ៦២៧-៦៥១ ទំព័រទី៦២៨

ទានសាធារណៈ រដ្ឋតម្រូវឱ្យគណបក្សធ្វើការគោរពតាមបញ្ញត្តិជាក់លាក់មួយចំនួន ដែលនេះអាចជាកត្តាមួយក្នុងការជួយកាត់បន្ថយអំពើពុករលួយ[7]។

នេះគឺជា ភាពខុសគ្នារវាងការផ្តល់ហិរញ្ញប្បទានសាធារណៈដោយផ្ទាល់និង ដោយប្រយោល។ ការផ្តល់ហិរញ្ញប្បទានសាធារណៈដោយផ្ទាល់ សំដៅលើការផ្តល់ប្រាក់ទៅគណបក្សនយោបាយ ឬបេក្ខជន ខណៈពេលដែលការផ្តល់ហិរញ្ញប្បទានសាធារណៈដោយប្រយោលធ្វើឡើងក្រោមរូបភាពផ្សេងគ្នាដូចជាទទួលបានដោយឥតគិតថ្លៃនូវប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ ការអនុគ្រោះពន្ធ ឬជំនួយក្នុងការចែកចាយសម្ភារៈសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត។ ការផ្តល់ហិរញ្ញប្បទានដោយប្រយោលមិនត្រឹមតែជួយកាត់បន្ថយការបត់បែនរបស់គណបក្សនយោបាយនៅក្នុង ការប្រើប្រាស់ជំនួយដែលបានផ្តល់ដោយរដ្ឋនោះទេ ប៉ុន្តែនេះក៏ អនុញ្ញាតឱ្យអ្នកឧបត្ថម្ភត្រួតពិនិត្យលើហិរញ្ញប្បទានបានកាន់តែងាយស្រួល ហើយក៏អាចជាការធានាបានថាពួកគេនឹងមិនប្រើសម្រាប់សម្រាប់គោលបំណងផ្សេងទៀតក្រៅពីអ្វីដែលមានចែង។

## ១. ប្រទេសកម្ពុជា

នៅប្រទេសកម្ពុជា ច្បាប់ស្តីពីការផ្តល់ហិរញ្ញប្បទានសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត គឺទើបតែចាប់ផ្តើមប៉ុណ្ណោះ។ គណបក្សណាដែលទទួលបានសម្លេងឆ្នោតលើសពី៣% (បីភាគរយ) នៅក្នុងការបោះឆ្នោតសភា គណបក្សនោះអាចនឹងទទួលបានហិរញ្ញប្បទានសាធារណៈ។ ទោះជាយ៉ាង ណា ពុំមានការចាត់តាំងភ្នាក់ងារណាមួយជាក់លាក់ឲ្យទៅត្រួតពិនិត្យលើការផ្តល់ហិរញ្ញប្បទាន យុទ្ធនាការឃោសនាបោះឆ្នោតនោះទេ។ ច្បាប់ស្តីពីគណបក្សនយោបាយនៅក្នុងប្រទេសកម្ពុជា ដែលបានប្រកាសឱ្យប្រើនៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ (ច្បាប់លេខ១១៩៧/០៧) ចែងពីគោលការណ៍នៃការផ្តល់ហិរញ្ញប្បទានសាធារណៈនៅក្នុងមាត្រា២៧ កថាខណ្ឌ៣ និងបញ្ជាក់បន្ថែមនៅមាត្រា២៨[8]។ គោលការណ៍នេះបានចែងថាមានការផ្តល់ថវិការសាធារណៈ ដោយស្មើភាពគ្នាទៅឱ្យគណបក្សនយោបាយទាំងអស់។ ទោះជាយ៉ាង

---

[7] តាមសេចក្តីយោងខាងលើ (Ibid) ទំព័រទី៦៥៩

[8] ច្បាប់ស្តីពី គណៈបក្សនយោបាយអនុម័ត នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧( ច្បាប់លេខ ១១៩៧/០៧)
មាត្រា២៧៖ ˝ ចាត់ទុកជាហិរញ្ញវត្ថុរបស់គណបក្សនយោបាយ ចំណូលដែលបានមកពីៈ
១.វិភាគទាន ឬភាគទានរបស់សមាជិក។
២.ចំណូលផ្សេងៗរបស់គណបក្សនយោបាយដែលបានមកពីការធ្វើអាជីវកម្មស្របច្បាប់។
៣.ប្រាក់ពីថវិការបស់រដ្ឋតាមកាលកំណត់ដូចមានចែងក្នុងមាត្រា២៨នៃច្បាប់នេះ។
៤.អំណោយរបស់ក្រុមហ៊ុនឯកជនខ្មែរ ឬសប្បុរសជនខ្មែរ។
៥.ទ្រព្យសម្បត្តិផ្ទាល់របស់គណបក្សនយោបាយ។
និងមាត្រា២៨៖ ˶រដ្ឋអាចផ្តល់ប្រាក់ពីថវិកាជាតិស្មើៗគ្នាដល់គ្រប់គណបក្សនយោបាយសម្រាប់តែប្រើប្រាស់ក្នុងយុទ្ធនាការឃោនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ(សមាជិកសភា)˝។
គណបក្សនយោបាយណាដែលមិនបានទទួលសន្លឹកឆ្នោតគាំទ្រចំនួន៣% នៃសន្លឹកឆ្នោតបានការសរុបទូទាំងប្រទេស ឬមិនបានទទួលអាសនៈមួយក្នុងសភា គណបក្សនយោបាយនោះត្រូវសងប្រាក់នោះគ្រប់ចំនួនមករដ្ឋវិញក្នុងរយៈពេល ៣ ខែ
យ៉ាងយូរចាប់ពីថ្ងៃប្រកាសលទ្ធផលជាស្ថាពរនៃការបោះឆ្នោត។

ណា មាត្រា២៨ ដាក់កម្រិតឲ្យគណបក្សនយោបាយត្រូវទទួលបានសម្លេងឆ្នោត៣%(បីភាគរយ)នៃសន្លឹកឆ្នោតទាំងអស់ បើមិនដូច្នេះទេ ត្រូវតែឲ្យប្រគល់ ហិរញ្ញប្បទានមកឲ្យរដ្ឋវិញ។ ជាការពិតណាស់គណបក្ស ៦ (ប្រាំមួយ) ក្នុងចំណោម ១១ (ដប់មួយ) ដែលបានការចូលរួមក្នុងការបោះឆ្នោតឆ្នាំ២០០៨ គួរតែត្រូវបានប្រគល់មកវិញនូវហិរញ្ញប្បទានទាំងអស់[9] ដោយសារតែមិនបានបំពេញនូវលក្ខខណ្ឌដែលមានចែងនៅក្នុងច្បាប់។[10]

ច្បាប់នេះមិនអនុញ្ញាតឲ្យគណៈបក្សនយោបាយប្រើប្រាស់ ហិរញ្ញប្បទានសាធារណៈ សម្រាប់គោលដៅផ្សេងក្រៅពីការឃោសនាបោះឆ្នោតឡើយ (មាត្រា២៨ កថាខណ្ឌ១) ហើយក៏សម្រាប់តែការបោះឆ្នោតតំណាងរាស្ត្រប៉ុណ្ណោះ មិនមែនសម្រាប់ការបោះឆ្នោតថ្នាក់ក្រោមជាតិទេ។ គួរកត់សម្គាល់ថាការផ្តល់ហិរញ្ញប្បទានទៅឲ្យគណបក្សនយោបាយនៅក្នុងអំឡុងពេលបោះឆ្នោតអាចត្រូវបានប្រើ ដើម្បីបង្កើនលទ្ធភាពរបស់គណបក្សនយោបាយសម្រាប់«ចូលរួមក្នុងជីវិតនយោបាយជាតិ» (មាត្រា២)[11] ។

មិនមានការចែងនៅក្នុងច្បាប់ស្តីពីទំនាក់ទំនងរវាងការផ្តល់ហិរញ្ញប្បទានសាធារណៈ និងការតម្រូវឲ្យគណបក្សនយោបាយ រក្សាទុកនិងបង្ហាញនូវរបាយការណ៍ហិរញ្ញវត្ថុរបស់ពួកគេ ហើយក៏ដូចជាមិនមាន(មិនទាន់មាន)នូវយន្តការ/ស្ថាប័នច្បាប់ ជាតិ សម្រាប់ត្រួតពិនិត្យទៅលើហិរញ្ញប្បទានសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោតដែរ[12]។ ការដាក់ទោសចំពោះការ បំពានកាតព្វកិច្ចក្នុងការបង្ហាញកំណត់ត្រាហិរញ្ញវត្ថុ ដូចដែលបានចែងនៅក្នុងមាត្រា៣១នៃច្បាប់នេះ ត្រូវបានចែងនៅក្នុងមាត្រា៣៨នៃច្បាប់ឆ្នាំ១៩៩៧[13]។ អនុលោមតាមមាត្រា៣២នៃច្បាប់នេះ គឺជាបន្ទុករបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងការកំណត់អំពីការរំលោភបំពានទាំងនេះ។ អនុលោមតាមមាត្រា៣០នៃច្បាប់ដដែលនេះ របាយការណ៍ទាំងអស់និងឯកសារគណនេយ្យនិងហិរញ្ញវត្ថុត្រូវបានរក្សាទុកយ៉ាងហោចណាស់ចំនួន៧(ប្រាំពីរ)ឆ្នាំ ហើយដែលអាចទទួលយកបានដើម្បីប្រើប្រាស់សម្រាប់ការត្រួតពិនិត្យ ឬការធ្វើអធិការកិច្ច។

លើសពីនេះទៀត យោងទៅតាមមាត្រា ២៧ កថាខណ្ឌ៤ នៃច្បាប់លេខ១១៩៧/០៧ គឺពុំមានការចែងអំពីការហាមទទួលអំណោយរបស់ក្រុមហ៊ុនឯកជនកម្ពុជា និងរបស់បុគ្គលកម្ពុជាណាម្នាក់ដើម្បីធ្វើការឃោស

---

[9] សូមមើលសេចក្តីយោងលេខ ២ ទំព័រទី ៦

[10] សូមមើលសេចក្តីយោងលេខ ៣ ទំព័រទី ៦

[11] សូមមើលសេចក្តីយោងលេខ ២

[12] ទោះជាយ៉ាងណា មាត្រា៣០ និង៣១ នៃច្បាប់ស្តីពីគណបក្សនយោបាយឆ្នាំ២០០៧ ទាមទារឲ្យគណបក្សនយោបាយធ្វើការទាក់ទងអំពីរបាយការណ៍ហិរញ្ញវត្ថុ និងគណនេយ្យ ទៅកាន់ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឲ្យបានមុនថ្ងៃទី៣១ ខែធ្នូ ជារៀងរាល់ឆ្នាំ។ តាមរយៈការពិនិត្យឡើងវិញមើលរបាយការណ៍គណនេយ្យ និងហិរញ្ញវត្ថុនៃគណនីទាំងនេះ ខាងក្រសួងអាចដឹងពីចំណាយ និងចំណូលរបស់គណបក្សក្នុងយុទ្ធនាការឃោសនាបោះឆ្នោត។ គណបក្សនយោបាយ ត្រូវមានកាតព្វកិច្ចដាក់របាយការណ៍ទៅក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយភ្ជាប់ទៅជាមួយរបាយការណ៍សកម្មភាពសំខាន់ៗរបស់គណបក្ស របាយការណ៍ចំនូល និងចំណាយប្រចាំឆ្នាំរបស់គណបក្ស ដែលបានរៀបចំដោយគណនេយ្យកររបស់គណបក្ស របាយការណ៍ធនាគាររបស់គណបក្ស និងបញ្ជីទ្រព្យសម្បត្តិរបស់គណបក្សដែលរួមមានចំនូល និងបំណុល។

[13] មាត្រា៣៨ នៃច្បាប់ដែលរៀបរាប់ខាងលើ បានចែងថា: «*បើគណបក្សណាមួយប្រព្រឹត្តល្មើសនឹងមាត្រា៣១ នៃច្បាប់នេះ នឹងត្រូវប្រឈមមុខនឹងការផាកពិន័យជាសាច់ប្រាក់ចំនួន ៣,០០០,០០០(បីលាន) រៀល។ នៅក្នុងករណីដែលប្រព្រឹត្តម្តងហើយ ម្តងទៀត នឹងត្រូវរងការពិន័យជាសាច់ប្រាក់ទ្វេដង នៃចំនួនប្រាក់ដែលបានពិន័យខាងលើនេះ និងលើសពីនេះទៅទៀត នឹងត្រូវហាមឃាត់សកម្មភាពរបស់គណបក្សជាបណ្តោះអាសន្ន*»។

នាបោះឆ្នោតទេ។ ក៏ប៉ុន្តែ គណៈបក្សនយោបាយត្រូវបានហាមមិនឲ្យទទួលរាល់ការបរិច្ចាគគ្រប់រូបភាពពី សមាគម អង្គការក្រៅរដ្ឋាភិបាល សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ វិទ្យាស្ថានសាធារណៈ ឬ ក្រុមហ៊ុនបរទេស។

## ២. ប្រទេសបារាំង

នៅប្រទេសបារាំង ភាពត្រឹមត្រូវនៃហិរញ្ញប្បទានមានកម្រិតខ្ពស់ ដែលត្រូវបានធានាតាមរយៈ ការកម្រិត ការចំណាយសម្រាប់ការបោះឆ្នោត ការហាមឃាត់ ការផ្តល់ហិរញ្ញប្បទានរបស់ក្រុមហ៊ុន សម្រាប់យុទ្ធនាការបោះឆ្នោត អាជ្ញាធរនៃស្ថាប័នត្រួតពិនិត្យ (ដែលមានដូចជាគណៈកម្មការជាតិត្រួតនិត្យ គណនេយ្យ ការបោះឆ្នោតនិងហិរញ្ញប្បទាននយោបាយ (National Commission for Control of Electoral Accounts and Political Financing-CNCCFP) និងចៅក្រមនៃការបោះឆ្នោត) ហើយនិងការដាក់ពិន័យ មិនឲ្យឈរឈ្មោះបោះឆ្នោតដែលនាំឲ្យមានការញញើតដល់អ្នកចូលរួមដទៃទៀត[14]។ ការធ្វើនេះ គឺដើម្បី ការពារដល់អ្នកដែលគ្មានសមត្ថភាព[15]គតិយុត្តក្នុងការឈរឈ្មោះបោះឆ្នោត[16]។

### ២.១. ច្បាប់ និងបទបញ្ញា

ប្រទេសបារាំងបានអនុវត្តច្បាប់ស្តីពីការផ្តល់ហិរញ្ញប្បទានសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត និងគណបក្សនយោបាយឆ្នាំ១៩៨៨ (ច្បាប់លេខ ៨៨-២២៧ ចុះថ្ងៃទី ១១ ខែមិនា ឆ្នាំ១៩៨៨) ជាមួយ នឹងការកែប្រែយ៉ាងច្រើនជាបន្តបន្ទាប់។ ក្របខណ្ឌ ច្បាប់បារាំងរួមមាន ច្បាប់ឆ្នាំ ១៩៩០ (ច្បាប់លេខ ៩០-៥៥ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩០) ច្បាប់ឆ្នាំ ១៩៩៣ (ច្បាប់លេខ ៩៣-១២២ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ១៩៩៣) ច្បាប់ឆ្នាំ ១៩៩៥ (ច្បាប់លេខ ៩៥-៦៣ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៩៥) ច្បាប់ឆ្នាំ ១៩៩៦ (ច្បាប់លេខ ៩៦-៣០០ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៩៦) និងច្បាប់ឆ្នាំ ២០០៣ (ច្បាប់លេខ ២០០៣-

---

[14] ភាពមិនអាចឈរឈ្មោះបាន មានន័យថា ជាស្ថានភាពមួយដែលបុគ្គលម្នាក់មិនបានបំពេញតាមតម្រូវការ ដើម្បីអាចឈរឈ្មោះសម្រាប់ការ បោះឆ្នោតនីមួយ។ ជាទូទៅ បេក្ខជនម្នាក់អាចឈរឈ្មោះបានដោយតម្រូវឲ្យបំពេញតាមលក្ខខណ្ឌដូចខាងក្រោម៖

- ត្រូវមានសញ្ជាតិបារាំង
- មិនត្រូវបានផ្តន្ទាទោសពីបទល្មើសព្រហ្មទណ្ឌធ្ងន់ធ្ងរណាមួយ
- (ត្រូវមានអាយុយ៉ាងតិច១៨ឆ្នាំ ក្នុងការឈរឈ្មោះជាបេក្ខជនសម្រាប់ការបោះឆ្នោតប្រធានាធិបតី និងរដ្ឋសភា និងយ៉ាងហោចណាស់ ត្រូវមានអាយុ២៤ឆ្នាំ សម្រាប់ការបោះឆ្នោតព្រឹទ្ធសភា)
- ត្រូវបំពេញកាតព្វកិច្ចយោធា
- បំពេញតាមការតម្រូវសិទ្ធិឈរឈ្មោះបោះឆ្នោតជាក់លាក់សម្រាប់ការបោះឆ្នោតមួយចំនួនៈ មិនអាចត្រូវបានជាប់ឆ្នោតក្នុងសភា តាមរយៈនាយកដ្ឋានដែលពួកគេមានតួនាទី ដូច្នេះពួកគេមិនអាចកេងចំណេញឥទ្ធិពលនៃមុខងាររបស់ពួកគេ ដែលនឹងអាចត្រូវបាន ជាប់ឆ្នោតនោះទេ

ក៏មានផងដែរការលក្ខខណ្ឌជាផ្លូវការ៖

- ចាំបាច់ត្រូវប្រកាសពីបេក្ខភាពរបស់បេក្ខជន
- បំពេញបែបបទមួយចំនួនដូចជា ការប្រកាសទ្រព្យសម្បត្តិ សម្រាប់ការបោះឆ្នោតជ្រើសរើសប្រធានាធិបតី និងសភា
- អនុវត្តតាមច្បាប់ស្តីពីការផ្តល់ហិរញ្ញប្បទានសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត៖ ជ្រើសរើសភ្នាក់ងារ និងរក្សាគណនីយុទ្ធនាការ ឃោសនាដែលនឹងត្រូវដាក់បន្ទាប់ពីការបោះឆ្នោត

[15] សមត្ថភាពផ្លូវច្បាប់គឺជាអំណាចដែលផ្តល់ដោយច្បាប់ទៅឲ្យរូបវន្តបុគ្គល ឬនីតិបុគ្គល ដើម្បីចុះកិច្ចសន្យា និងដើម្បីប្តឹង និងត្រូវបានប្តឹងក្នុង ឈ្មោះរបស់ខ្លួន

[16] តាមសេចក្តីយោងខាងលើ (Ibid)

១១៦៥ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៣)។ ច្បាប់ទាំងនេះរួមទាំងសេចក្តីសម្រេចមួយចំនួនរបស់ក្រុមប្រឹក្សាធម្មនុញ្ញ និងក្រុមប្រឹក្សារដ្ឋដែលជាអ្នកបកស្រាយនិងដាក់ឲ្យអនុវត្តនូវលិខិតបទដ្ឋានទាំងនោះ បង្កើតជាបណ្តុំនៃវិធានច្បាប់ស្តីពីការផ្តល់ហិរញ្ញប្បទានសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត។ ជារួមលិខិតបទដ្ឋានទាំងនោះ បង្កើតបានជា "សិទ្ធិពិតប្រាកដក្នុងការផ្តល់ហិរញ្ញប្បទាននយោបាយ" ដែលគ្រប់គ្រងមិនមែនត្រឹមតែយុទ្ធនាការឃោសនាបោះឆ្នោត និងសកម្មភាពរបស់គណបក្សនយោបាយ ប៉ុណ្ណោះទេ គឺរួមទាំងសវនកម្មនៃសកម្មភាពហិរញ្ញប្បទានរបស់មន្ត្រីជាប់ឆ្នោតថែមទៀតផងដើម្បីការពារប្រឆាំងនឹងការកេងប្រវ័ញ្ចនិងស៊ីសំណូក។ វិធានទាំងនេះមានចែងនៅក្នុងច្បាប់ និងបទបញ្ជាដែលមាននៅក្នុងក្រមស្តីពីការបោះឆ្នោត។ ទាំងនេះបានផ្តល់ឲ្យប្រទេសបារាំងនូវច្បាប់ដែលមានលក្ខណៈទូលំទូលាយនិងម៉ត់ចត់ តាមរបាយការណ៍ឆ្នាំ២០០៩ដែលផ្ញើទៅក្រុមប្រឹក្សាអឺរ៉ុបបានរៀបរាប់ថា៖ «ប្រទេសបារាំងមានច្បាប់ជាច្រើនដើម្បីធានាបាននូវកម្រិតខ្ពស់នៃតម្លាភាពក្នុងហិរញ្ញប្បទាននយោបាយដែលរួមមានយុទ្ធសាស្រ្តត្រួតពិនិត្យនិងការដាក់ទណ្ឌកម្ម។ *តាមការអង្កេតកន្លងមក ពុំមានគម្លាតឆ្ងាយគ្នាពេកទេរវាងអត្ថបទច្បាប់ដែលត្រូវអនុវត្ត និង ការអនុវត្តជាក់ស្តែងនៅក្នុងឆាកនយោបាយ*[17]»។

បេក្ខជនតម្រូវឲ្យចូលរួមជាមួយ "ភ្នាក់ងារហិរញ្ញវត្ថុ" ដែលជាបុគ្គលមានសមត្ថភាពគតិយុត្ត មិនមែនជាសាជីវកម្ម ឬក្រុមនៃមនុស្សផ្សេងទៀត។ ភ្នាក់ងារហិរញ្ញវត្ថុដែលត្រូវតែចុះបញ្ជីជាមួយនឹងប្រធាននាយកដ្ឋានដែលពាក់ព័ន្ធណាមួយ[18] ហើយដែលមានភារកិច្ចទទួលខុសត្រូវលើគ្រប់ប្រតិបត្តិការហិរញ្ញវត្ថុដែលទាក់ទិនទៅនឹងការឃោសនាបោះឆ្នោតដែលបេក្ខជនបានបង្កើត និងដើម្បី ធានាថាប្រតិបត្តិការទាំងអស់នេះត្រូវបានកត់ត្រាទុកយ៉ាងត្រឹមត្រូវ[19]។

## ២.២. ហិរញ្ញប្បទានសាធារណៈសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត

សិទ្ធិក្នុងការទទួលនូវហិរញ្ញប្បទានសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោតនេះ អាចអនុវត្តបាននៅតាមមណ្ឌលបោះឆ្នោតទាំងឡាយណាដែលមានប្រជាជនស្មើឬលើសពី៩,០០០(ប្រាំបួនពាន់)នាក់ ប៉ុន្តែមានអញ្ញត្រកម្មជាក់លាក់មួយចំនួន។ ច្បាប់ដែលទាក់ទងទៅនឹង៖ គណនីនៃយុទ្ធនាការឃោសនាបោះឆ្នោតរបស់បេក្ខជនឈរឈ្មោះបោះឆ្នោត[20] ទាក់ទងទៅនឹងស្ថាប័នជាក់លាក់ដែលទទួលខុសត្រូវក្នុងការគ្រប់គ្រងនិងត្រួតពិនិត្យនូវរាល់ចំណូលចំណាយនៃការបោះឆ្នោត ព្រមទាំងទាក់ទងនឹងការបង្កើត ឬការអនុវត្តន៍នូវការដាក់ទណ្ឌផ្សេងៗដែលអាចជាការផាកពិន័យ ការជាប់ពន្ធនាគារ ឬក៏មិនអាចឈរឈ្មោះសម្រាប់មុខងារសាធារណៈ។

---

[17] ក្រុមប្រឹក្សាអឺរ៉ុបឆ្នាំ២០០៧ ការវាយតម្លៃជុំទីបី៖ *របាយការណ៍វាយតម្លៃនៃប្រទេសបារាំង ស្តីពីការដាក់បន្ទុកផ្នែកព្រហ្មទណ្ឌ* Strasbourg: ក្រុមប្រឹក្សាអឺរ៉ុប បានទាញយកនៅ ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ពី http://www.coe.int/t/dghl/monitoring/greco/evaluations/round3/GrecoEval3(2008)5_France_One_EN.pdf

[18] អនុលោមតាមមាត្រា ៥ នៃច្បាប់ចុះថ្ងៃទី ០១ ខែកក្កដា ឆ្នាំ១៩០១ ស្តីពីសមាគម និង មាត្រា L ៥២-៥ នៃក្រមបោះឆ្នោត

[19] ក្រមបោះឆ្នោតមាត្រា L 52-10

[20] នេះគឺជា "ការចំនាយដោយផ្ទាល់រវាងបេក្ខជន និងកិច្ចព្រមព្រៀងរបស់គាត់ តាមរយៈអ្នកគាំទ្ររបស់គាត់ក៏ដូចជា គណបក្សនយោបាយ ក៏ដូចជាក្រុមដែលត្រូវបានបង្កើតឡើងដើម្បីផ្តល់ការគាំទ្រ ឬកំពុងផ្តល់ការគាំទ្រ។ បេក្ខជនវាយតម្លៃ និងរួមទាំងចំនូល និងចំនាយ ផលប្រយោជន៍ដោយផ្ទាល់ ឬដោយប្រយោល សេវាកម្ម និងការបរិច្ចាគគ្រប់ប្រភេទ ដែលគាត់ទទួលបាន" (មាត្រាL ៥២-១២ កថាខណ្ឌ១ នៃក្រមបោះឆ្នោត)

### ២.៣. ការកម្រិតលើការចំណាយក្នុងយុទ្ធនាការឃោសនាបោះឆ្នោត

ការបរិច្ចាគដែលធ្វើឡើងដោយបុគ្គលម្នាក់ត្រូវបានកម្រិតត្រឹម (€ ៤,៦០០ សម្រាប់ការបោះឆ្នោតមួយ[21]) ក៏ដូចជាកម្រិតទៅលើការធ្វើវិភាគទានពីគណបក្សនយោបាយដល់បុគ្គលដែលជាបេក្ខជនរបស់គណបក្សនេះផ្ទាល់ ហើយនិង ការបរិច្ចាគផ្ទាល់ខ្លួនរបស់បេក្ខជនទៅក្នុងយុទ្ធនាការឃោសនាបោះឆ្នោតរបស់ខ្លួន ដោយរួមទាំងការផ្តល់អំណោយគ្រប់រូបភាពដែលជាប្រយោជន៍ដល់គណបក្សនយោបាយ។ នីតិបុគ្គលនៃនីតិសាធារណៈក្តី ឬនីតិឯកជនក្តី «មិនអាចចូលរួមផ្តល់ហិរញ្ញប្បទានក្នុងយុទ្ធនាការបោះ-ឆ្នោតរបស់បេក្ខជនរូបណាមួយ មិនថាការបរិច្ចាគក្នុងរូបភាពណាក៏ដោយ ឬតាមរយៈការផ្តល់ជារបស់ ឬសេវាកម្ម ឬអត្ថប្រយោជន៍ផ្សេងទៀត ដោយផ្ទាល់ ឬដោយប្រយោល ក្នុងតម្លៃទាបជាងធម្មតា[22]»។

### ២.៤. ស្ថាប័នត្រួតពិនិត្យ

គណនីសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោតរបស់បេក្ខជនត្រូវបានត្រួតពិនិត្យជាប្រព័ន្ធដោយគណៈកម្មការជាតិគ្រប់គ្រងគណនេយ្យភាពនៃការបោះឆ្នោត និង ហិរញ្ញប្បទាននយោបាយ(CNCCFP) ដែលជាអាជ្ញាធររដ្ឋបាលឯករាជ្យ (ឬស្ថាប័នត្រួតពិនិត្យឯករាជ្យ)[23]។ គណៈកម្មការនេះមាន សមាសភាពចំនួន ៩(ប្រាំបួន)រូប ដែលត្រូវបានតែងតាំងដោយក្រឹត្យច្បាប់ សម្រាប់អាណត្តិប្រាំឆ្នាំ[24] និងត្រូវបោះឆ្នោតជ្រើសតាំង ប្រធាន និង អនុប្រធាន ដោយសមាជិកនៅក្នុងគណកម្មការនេះផ្ទាល់។ គណៈកម្មការនេះអាចប្រើប្រាស់មន្ត្រី និង អ្នកជំនាញដើម្បីជាជំនួយក្នុងការងាររបស់ខ្លួនផងដែរ លើសពីនេះទៅទៀតគណៈ-កម្មការនេះក៏អាចស្នើរសុំទៅមន្ត្រីប៉ូលីស ដើម្បីធ្វើការស៊ើបអង្កេត បើយល់ថាចាំបាច់សម្រាប់ការអនុវត្តន៍បេសកកម្មរបស់ខ្លួន[25]។

គណៈកម្មការនេះ(CNCCFP) មានភារកិច្ចក្នុងការត្រួតពិនិត្យហិរញ្ញប្បទានសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោតដូចខាងក្រោម៖

- **ប្រាក់តម្កល់គណនីយុទ្ធនាការឃោសនាបោះឆ្នោត៖** បេក្ខជននីមួយៗដែលបង្ហាញខ្លួននៅជុំទី១ ត្រូវដាក់ជូននូវគណនីយុទ្ធនាការឃោសនាបោះឆ្នោតរបស់ខ្លួននិងឧបសម្ព័ន្ធជាមួយឯកសារយោងទៅឲ្យសមាជិករបស់សមាគមនៃគណនេយ្យករស្របច្បាប់(Association of Chartered Accountants) ។
- **ការយល់ព្រម, ការបដិសេធ និង កំណែទម្រង់នៃគណនីយុទ្ធនាការឃោសនាបោះឆ្នោត៖** នីតិវិធីទាំងអស់នេះត្រូវធ្វើឡើងក្នុងរយៈពេល ៦(ប្រាំមួយ)ខែ បន្ទាប់ពីការដាក់ឯកសារគណនីយុទ្ធនាការ

[21] មាត្រា L ៥២-៨ កថាខណ្ឌ១ នៃក្រមដែលរៀបរាប់ខាងលើ

[22] មាត្រា L ៥២--៨ កថាខណ្ឌ២ នៃក្រមដែលរៀបរាប់ខាងលើ

[23] បទបញ្ញាលេខ ២០០៣-១១៦៥ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៣ (មាត្រា ៧. I).

[24] សមាជិកធម្មតា ឬសមាជិកកិត្តិយសចំនួន៣នាក់នៃក្រុមប្រឹក្សារដ្ឋ ដែលត្រូវបានតែងតាំងតាមសំណើររបស់អនុប្រធានក្រុមប្រឹក្សារដ្ឋ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយការិយាល័យ សមាជិកធម្មតា ឬសមាជិកកិត្តិយសចំនួន៣រូបនៃតុលាការកំពូល(*Cour de Cassation*) សមាជិកធម្មតា ឬសមាជិកកិត្តិយសចំនួនបីរូបនៃតុលាការសវនកម្ម(*Cour des comptes*) ដែលត្រូវបានតែងតាំងទៅតាមសំណើររបស់ប្រធានទីមួយ នៃតុលាការសវនកម្ម បន្ទាប់ពីពិគ្រោះយោបល់ជាមួយប្រធានអង្គជំនុំជម្រះ។ មាត្រាL ៥២-១៤ នៃក្រមបោះឆ្នោត

[25] មាត្រា L ៥២-១៤ កថាខណ្ឌចុងក្រោយ នៃក្រមដែលរៀបរាប់ខាងលើ

ឃោសនាបោះឆ្នោត។ ក្រោយរយៈពេលនេះ គណនីនេះនឹងត្រូវបានចាត់ទុកថាត្រូវទទួលបានការឯកភាព[26]។

- **ការបញ្ជូនទៅកាន់ចៅក្រមផ្នែកបោះឆ្នោត ក្នុងករណីដែលគណនីណាមួយត្រូវបានបដិសេធ៖** បន្ទាប់ពីការកែប្រែ ឬ ការបដិសេធនូវគណនីយុទ្ធនាការឃោសនាបោះឆ្នោត គណៈកម្មការជាតិ( CNC CFP)ធ្វើការទាក់ទងទៅចៅក្រមដែលមានយុត្តាធិការដើម្បីឱ្យចៅក្រមជាអ្នកសម្រេចថាតើត្រូវដកហូតបេក្ខភាពឬក៏លុបចោលការបោះឆ្នោតដែលបានបញ្ចប់រួចហើយ ឬប្រកាសថាបេក្ខជនសុំលាលែងពីតំណែងក្នុងករណីបេក្ខជន រូបនោះត្រូវបានគេបោះឆ្នោតជ្រើសរើសរួចហើយ។

- **ចំនួនទឹកប្រាក់ ដែលលើសពីការកម្រិតដោយច្បាប់ ទៅលើការចំណាយ៖** ក្នុងករណីដែលមានការចំណាយលើសពីចំនួនអតិបរមា គណៈកម្មការ CNCCFP ត្រូវកំណត់ចំនួននោះឲ្យច្បាស់ដើម្បីឲ្យ បេក្ខ-ជននោះធ្វើការសងទៅរតនាគារវិញ។

- **ការបោះផ្សាយនូវគណនីយុទ្ធនាការឃោសនាបោះឆ្នោត៖** គណៈកម្មការ CNCCFP ត្រូវធានានូវការបោះពុម្ពផ្សាយនូវគណនីយុទ្ធនាការឃោសនាបោះឆ្នោត ក្នុងទម្រង់មួយដែលងាយស្រួលយល់។

- **ការចងក្រងរបាយការណ៍ទៅសភា៖** ច្បាប់តម្រូវអោយក្នុងរយៈពេលមួយឆ្នាំបន្ទាប់ពីការបោះឆ្នោតសកល គណៈកម្មការ CNCCFP ត្រូវចងក្រងជារបាយការណ៍ទៅសភា ដែលបង្ហាញពីវង្វាយតម្លៃនៃប្រតិបត្តិការ ហិរញ្ញវត្ថុចំណាយរបស់គណបក្សនយោបាយជាមួយនឹងអនុសាសន៍ដែលសមគួរ ។

លើសពីនេះទៅទៀតក្រុមប្រឹក្សាធម្មនុញ្ញជា៖

- អាជ្ញាធរមានយុត្តាធិការក្នុងការវិនិច្ឆ័យពីភាពស្របច្បាប់នៃការបោះឆ្នោតប្រធានាធិបតី
- ចៅក្រមដែលធ្វើការសម្រេចពីភាពស្របច្បាប់នៃការបោះឆ្នោតសភា ហើយនិង សិទ្ធិគ្រប់គ្រាន់ក្នុងការទទួលបានបេក្ខភាព។
- អាជ្ញាធរដែលទទួលបណ្តឹងតវ៉ាសម្រាប់ បេក្ខជននៃការបោះឆ្នោតសភា និងប្រធានាធិបតីលើបញ្ហានៃការផ្តល់ហិរញ្ញប្បទានចំពោះការចំណាយក្នុងការបោះឆ្នោត[27]។
- ស្ថាប័នដែលទទួលបណ្តឹងតវ៉ា ពីបេក្ខជនក្នុងការបកស្រាយ ច្បាប់ និងបទប្បញ្ញត្តិផ្សេងៗនៃការបោះឆ្នោត និង សំណងដែលសមរម្យ (*recours de pleincontentieux*)។

## ២.៥. ទោសវិន័យ

ការខកខានក្នុងការរៀបចំដាក់បង្ហាញគណនីយុទ្ធនាការឃោសនាបោះឆ្នោត ក្នុងរយៈពេលជាក់លាក់មួយ អាចជាមូលហេតុក្នុងការបដិសេធនូវគណនី ហើយបេក្ខជនមិនត្រូវបានអនុញ្ញាតឲ្យឈរឈ្មោះសម្រាប់មុខងារសាធារណៈ រយៈពេលមួយឆ្នាំ[28]។ ការដាក់ទណ្ឌកម្មផ្សេងទៀតរួមមាន៖

[26] មាត្រា L ៥២-១៥ កថាខណ្ឌ១ នៃក្រមដែលរៀបរាប់ខាងលើ

[27] នៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១២ ក្រុមប្រឹក្សាបានចេញសេចក្តីសម្រេចលេខ ២៨៧១ ទាក់ទងនឹងការបោះឆ្នោត

[28] មិនមានបុរេវិនិច្ឆ័យ បើសិនបេក្ខជនត្រូវបានជាប់ឆ្នោត ដោយការបដិសេធនូវការបោះឆ្នោត ឬការដកចេញដោយហេតុថាបេក្ខជនរូបនោះត្រូវបានគេជំទាស់ ឬមិនមែន។ ច្បាប់ដែលពាក់ព័ន្ធនឹងចំនុចនេះមានភាពតឹងរឹងជាខ្លាំង ឧទាហរណ៍ចេញពីសេចក្តីសម្រេចមួយចំនួន សេចក្តីសម្រេចលេខ ៩៧-២៣៤៩ របស់ក្រុមប្រឹក្សាធម្មនុញ្ញចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៩៨ លើសំណុំរឿង AN Manche ការចុះឈ្មោះទី១៖ រាជកិច្ច ថ្ងៃទី

- បេក្ខជនត្រូវព្យួរសិទ្ធិជាបណ្ដោះអាសន្នសម្រាប់ការល្មើសនឹងវិន័យនៃការផ្ដល់ហិរញ្ញប្បទានការបោះឆ្នោត ។
- ការបដិសេធគណនី និងការបាត់បង់សិទ្ធិបណ្ដោះអាសន្នក្នុងការឈរឈ្មោះសម្រាប់មុខងារសាធារណៈក្នុងរយៈពេលមួយឆ្នាំក្នុងករណីដែលការបរិច្ចាគទៅឲ្យបេក្ខជនឈរឈ្មោះបោះឆ្នោតម្នាក់ លើសពីការកម្រិតរបស់ច្បាប់[29]។

ការគាំទ្រពីស្ថាប័នរដ្ឋាភិបាលត្រូវបានគេចាត់ទុកផងដែរថាជាផ្នែកមួយនៃការផ្ដល់ហិរញ្ញប្បទានយុទ្ធនាការរបស់បេក្ខជនក្នុងអំឡុងពេលបោះឆ្នោតក្នុងកង់តុង(canton) (ដែលជាភាសាខ្មែរប្រែថាឃុំ)។ បើទោះបីជា ការផ្ដល់ជំនួយនេះបានមកពីអាជ្ញាធរសាធារណៈតែមិននាំឲ្យមានការបដិសេធគណនីយុទ្ធនាការនេះទេ អាស្រ័យលើកាលៈទេសៈជាក់ស្ដែង[30]។ លើសពីនេះទៅទៀត ការបំពានវិធានហិរញ្ញប្បទានបោះឆ្នោតធ្ងន់ធ្ងរអាចនាំឲ្យមានការលើកពេលវេលាបោះឆ្នោត។

តាមមាត្រាL.១១៣-១ នៃក្រមស្ដីពីការបោះឆ្នោត បេក្ខជនត្រូវបង់ពិន័យជាទឹកប្រាក់៣៧៥០អឺរ៉ូ និង/ឬជាប់ពន្ធនាគារមួយឆ្នាំសម្រាប់អ្នកដែល៖

- បានប្រមូលមូលនិធិដោយល្មើសនឹងអ្វីដែលមាត្រាL.៥២-៤បានចែង
- បានទទួលមូលនិធិ ល្មើសនឹងអ្វីដែលមាត្រាL.៥២-៨ ឬ L. ៣០៨ បានចែង
- បានធ្វើឲ្យលើសដែនកំណត់នៃការចំណាយនៅក្នុងការបោះឆ្នោត
- មិនគោរពតាមបែបបទនៃការបង្កើតគណនីយុទ្ធនាការដែលមានចែងក្នុងមាត្រា L. ៥២-១២ និង L. ៥២-១៣
- ត្រូវបានរកឃើញថាក្លែងបន្លំគណនីនិងហិរញ្ញវត្ថុយុទ្ធនាការរបស់ខ្លួន ដើម្បីកាត់បន្ថយនូវចំនួនប្រាក់ដែលត្រូវរាយការណ៍ថាបានចំណាយ

នៅក្នុងករណីការរំលោភបំពានណាមួយទៅលើច្បាប់ដែលបានហាមឃាត់ គណៈកម្មការនេះត្រូវបញ្ជូនសំណុំរឿងទៅការិយាល័យព្រះរាជអាជ្ញាសាធារណៈ។

ពិន័យហិរញ្ញវត្ថុត្រូវធ្វើក្នុងទម្រង់ជា ការបង់ប្រាក់ទៅរតនាគារនូវចំនួនដែលស្មើនឹងទឹកប្រាក់ចំណាយលើសពីការកម្រិត (កំណត់ដោយគណៈកម្មការជាតិសម្រាប់គណនីយុទ្ធនាការឃោសនាបោះ-ឆ្នោត និង ហិរញ្ញប្បទាន នយោបាយ(National Commission for Compaign Accounts and Political

២៨ ខែកុម្ភៈ ឆ្នាំ១៩៩៨។ សេចក្ដីសម្រេចលេខ ៩៧-២៣០៩ របស់ក្រុមប្រឹក្សាធម្មនុញ្ញចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៩៨ លើសំណុំរឿង AN Moselle ការចុះឈ្មោះលើកទី៧៖ រាជកិច្ចថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ១៩៩៨ ការហាមឃាត់បណ្ដោះអាសន្ននៃបេក្ខជនមិនជាប់ឆ្នោត។

[29] សេចក្ដីសម្រេចលេខ ២០០២-២៩៥៥ របស់ក្រុមប្រឹក្សាធម្មនុញ្ញចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៣ លើសំណុំរឿង ANBouches-du-Rhône ប្រកាសទី១៖ រាជកិច្ច ចុះថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ២០០៣ អំណោយចំនួន € ៧៦២២ សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ ២០០២-៣២៥៧ ចុះថ្ងៃទី ០៦ ខែកុម្ភៈ ឆ្នាំ២០០៣ លើសំណុំរឿង AN Rhône ,ប្រកាសទី២៖ រាជកិច្ច ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០៣៖ អំណោយចំនួន € ៧២៣៩

[30] CE, Sect., Nov. 8, 1999, n°201966, Elect. cant. Bruz: JurisData n°1999-051114; Dr. adm. 1999, comm. 303; LPA 17 Jan 2000, p. 13, note E. Vital-Durand; RFD adm. 2000, p. 224, Section P. Terneyre.

Funding))[31] ហើយអាចក្លាយជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍។ ក៏អាចកើតមានផងដែរ ចំពោះការបាត់បង់សិទ្ធិពេញលេញរបស់បេក្ខជនក្នុងការទទួលបាននូវការទូទាត់សងទាំងមូល ឬ ជាផ្នែកនៃការចំណាយទាំងឡាយដែលបានកត់ត្រាទុកនៅក្នុងគណនី យុទ្ធនាការឃោសនាបោះឆ្នោត[32]។

ចន្លោះពីការបោះឆ្នោតស្រុក/ខណ្ឌ(canton) នៅខែមិនា ឆ្នាំ១៩៩២ និងការបោះឆ្នោតសភា នៅខែមិថុនា ឆ្នាំ២០០៧ គណៈកម្មការជាតិគ្រប់គ្រងគណនេយ្យភាពនៃការ បោះឆ្នោតនិងហិរញ្ញប្បទាននយោបាយ(CNCCFP) បានពិនិត្យមើលគណនីយុទ្ធនាការឃោសនាបោះឆ្នោតចំនួន ៧៥,៨៦៣ ហើយបានបដិសេធចំនួន ២១៥៧ គណនី (ស្មើនឹង២.៨៨%)។ ក្នុងការបោះឆ្នោតសភាចុងក្រោយនៅឆ្នាំ ២០០៧ គណៈកម្មការនេះ បានអនុម័តជាផ្លូវការនូវគណនីយុទ្ធនាការឃោសនាបោះឆ្នោតចំនួន៥៦១៨ នៃ ៧៦៣៩គណនី ហើយធ្វើការកែប្រែគណនីចំនួន១៥១០ និងជាលទ្ធផលបានបញ្ជូន ៥០៦ ទៅចៅក្រមកាត់ក្តីការបោះឆ្នោត។ ដូចនេះអាចសន្និដ្ឋានថា ទាំងបេក្ខជននិងទាំងគណបក្សបានយល់ដឹងពី ច្បាប់កាន់តែច្បាស់ ដែលបង្ហាញតាមរយៈការថយចុះនៃការបញ្ជូនពាក្យបណ្តឹងរបស់ គណៈកម្មការជាតិគ្រប់គ្រងគណនេយ្យភាពនៃការបោះឆ្នោត និង ហិរញ្ញប្បទាននយោបាយ(CNCCFP) ទៅក្រុមប្រឹក្សាធម្មនុញ្ញ បើប្រៀបធៀបទៅ ចំនួនបេក្ខជននៅក្នុងការបោះឆ្នោតសភា (៦,៦៣% ក្នុង ឆ្នាំ២០០៧ និង ១២,៥៥% ក្នុងឆ្នាំ១៩៩៣)។

ទោះបីជាប្រព័ន្ធបារាំងទទួលបានជោគជ័យ ក៏មិនអាចប្រកែកបានទេថា ច្បាប់ទាំងនេះកាន់តែមានភាពល្អិតល្អន់។ ភាពស្មុគស្មាញនៃច្បាប់នេះគឺមិនមានលក្ខណៈជាក់លាក់រហូតនោះទេប្រសិនបើ ពិចារណាលើឧទាហរណ៍ នៃការបរាជ័យក្នុងការអនុវត្តន៍គោលការណ៍ស្មោះត្រង់នៃទ្រឹស្តីច្បាប់សម្រាប់ការបោះឆ្នោតនីតិបញ្ញត្តិ ។ ឧទាហរណ៍មួយទៀត គឺបេក្ខជនត្រូវបានដកហូតនូវបេក្ខភាពក្នុងការឈរឈ្មោះបោះឆ្នោតដោយសារតែ ប្រព្រឹត្តិល្មើសនឹងច្បាប់ស្តីពីហិរញ្ញប្បទានសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត ខណៈពេលដែលបេក្ខជនត្រូវបានរកឃើញថា ឈ្នះការបោះឆ្នោតដោយសារតែការល្មើសច្បាប់ហិរញ្ញប្បទានការបោះឆ្នោតនោះនឹងត្រូវមោឃៈភាពដើម្បីជាការដាក់ទណ្ឌកម្មជាជាងដកហូតនូវ សិទ្ធិឈរឈ្មោះបោះឆ្នោតសម្រាប់មុខងារសាធារណៈ។

## ៣. ប្រទេសកូរ៉េខាងត្បូង

សាធារណរដ្ឋកូរ៉េបានដាក់ការវិវត្តន៍ជាទៀងទាត់នូវលិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលគ្រប់គ្រងហិរញ្ញប្បទានសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត។ វិធានដ៏តឹងរឹងសម្រាប់ការគ្រប់គ្រងនិងកម្រិតលើការចំណាយនិងការបរិច្ចាគក្នុងការផ្តល់ហិរញ្ញប្បទានយុទ្ធនាការឃោសនាបោះឆ្នោតត្រូវបានអនុម័ត ជាបន្តបន្ទាប់ជាមួយនឹង ប្រជាធិបតេយ្យភាវូបនីយកម្មនៃជីវិតនយោបាយអស់រយៈពេលជាងម្ភៃឆ្នាំកន្លងមកហើយ និងការបញ្ចប់នៃការគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់បេក្ខជន ដោយក្រុមពាណិជ្ជករនៃឧស្សាហកម្ម

[31] មាត្រា L ៥២-១៥ កថាខណ្ឌចុងក្រោយ នៃក្រមបោះឆ្នោត

[32] យោងតាមមាត្រា L ៥២-១៥ កថាខណ្ឌមុនចុងក្រោយ " *សំណងនៅពេលដែលតម្រូវដោយច្បាប់ គឺអាចធ្វើទៅបាន បន្ទាប់ពីទទួលបានការអនុម័តដោយគណៈកម្មការនេះតែប៉ុណ្ណោះ*" មាត្រា L ៥២-៤ នៃក្រមដែលរៀបរាប់ខាងលើ

ជាតិ។ ដើម្បីសម្រេចឲ្យបានដូចខាងលើ អាជ្ញាធរឯករាជ្យមួយគឺ គណៈកម្មការជាតិរៀបចំ ការបោះឆ្នោត (គ.ជ.ប) ត្រូវបានបង្កើតឡើង និងមានតួនាទីត្រួតពិនិត្យ លើការផ្តល់ហិរញ្ញប្បទាន សម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត។

### ៣.១. ច្បាប់និងបទបញ្ញា

បទបញ្ញត្តិទៅលើ ហិរញ្ញប្បទានសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោតគឺ មានចែងនៅក្នុង ច្បាប់ស្តីពីហិរញ្ញប្បទាននយោបាយ ឆ្នាំ១៩៦៥ (ត្រូវបានធ្វើវិសោធនកម្ម ដោយច្បាប់លេខ ១១៣៧៦ ថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១២)[33] និងច្បាប់ស្តីពីការបោះឆ្នោតជាមន្ត្រីសាធារណៈ នៃឆ្នាំ១៩៩៤ (១៩ មករា២០១២)[34]។

លោកប្រធានាធិបតី គីម យ៉ុងសាម (Kim Young Sam) ត្រូវបានជ្រើសតាំងជាប្រធានាធិបតីទីប្រាំពីររបស់ ប្រទេសកូរ៉េខាងត្បូង នៅក្នុងការបោះឆ្នោតប្រធានាធិបតី ឆ្នាំ១៩៩៣។[35] ក្រោមការដឹកនាំរបស់គាត់ អំពើពុករលួយនៅក្នុងសេវាសាធារណៈ ត្រូវបានបំបាត់ចោល និងមានការរឹតបន្តឹង ទៅលើការផ្តល់ហិរញ្ញប្បទានចំពោះការបោះឆ្នោត។ ការផ្តល់នូវឧបត្ថម្ភធនសាធារណៈ ទៅឲ្យគណបក្សនយោបាយត្រូវបានកើនឡើង ហើយការដាក់ទណ្ឌកម្មថ្មីសម្រាប់ការមិនអនុលោមតាមច្បាប់បានលេច រូបរាងឡើង។ អ្នកកាន់តំណែង មុនលោក គីម យ៉ុងសាម (Kim Young Sam) ពីរនាក់គឺ ជុន ឌូវ៉ាន (Chun Doo Hwan) និង រ៉ូ តេវូ (Roh Tae Woo) ត្រូវបានកាត់ទោស និងជាប់ពន្ធនាគារដោយការបង្កើតមូលនិធិឯកជន និងបង្ខំឱ្យក្រុមហ៊ុនធំៗបង់ថ្លៃសមាជិកភាព ទៅតាមសមាមាត្រនៃប្រាក់ចំណេញរបស់ពួកគេ[36]។ នៅឆ្នាំ១៩៩៤ ច្បាប់ស្តីពីការបោះឆ្នោតមន្ត្រីសាធារណៈត្រូវបានអនុម័ត(ឆ្នាំ១៩៩៤ បានកែសម្រួលនៅឆ្នាំ២០០០) ដើម្បីជៀសវាងនូវការអនុវត្តខុសច្បាប់ក្នុងការបោះឆ្នោត។ ច្បាប់ស្តីពីហិរញ្ញប្បទាននៃការបោះឆ្នោតឆ្នាំ១៩៦៥ ត្រូវបាន កែសម្រួលនៅឆ្នាំ២០០០ ដើម្បីទប់ស្កាត់ការផ្តល់ហិរញ្ញប្បទាន ខុសច្បាប់នៃសកម្មភាពនយោបាយ និងដើម្បីបង្កើតមូលដ្ឋានច្បាប់ និងតម្លាភាពសម្រាប់ការផ្តល់ហិរញ្ញប្បទាននយោបាយ[37]។ ក្នុងឆ្នាំ១៩៩៩ ប្រធានាធិបតីដែលមិនមានទំនាក់ទំនងនឹងវិស័យជំនួញសោះ ត្រូវបានជាប់ឆ្នោត ហើយកម្មវិធីប្រឆាំងនឹងអំពើពុករលួយត្រូវបានបើកឲ្យដំណើរការ។ ជាលទ្ធផល ច្បាប់ដែល មានលក្ខណៈតឹងរឹងត្រូវបានបញ្ញត្តិឡើងដើម្បីគ្រប់គ្រងការផ្តល់អំណោយ និងការបរិច្ចាគពីសាជីវកម្ម និងបុគ្គលម្នាក់ៗ[38]។

---

[33] ច្បាប់សម្រាប់សាធារណរដ្ឋកូរ៉េត្រូវបានដាក់ផ្សាយជាសាធារណៈក្នុង គេហទំព័ររបស់វិទ្យាស្ថានស្រាវជ្រាវច្បាប់កូរ៉េះ http://elaw.klri.re.kr/eng_service/main.do (អាចចូលមើលដោយសេរី)

[34] តាមសេចក្តីយោងខាងលើ (Ibid)

[35] គាត់បានចូលកាន់តំណែងនៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៣ និងបញ្ចប់នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៨។ រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៨៧ របស់ សាធារណរដ្ឋកូរ៉េ មាត្រា៧០ ចែងថា៖ "អាណត្តិរបស់ប្រធានាធិបតីមានរយៈពេល៥ឆ្នាំ ហើយប្រធានាធិបតីនឹងមិនត្រូវបានបោះឆ្នោតជ្រើសរើសម្តង ទៀតឡើយ"។ NNDB tracking the entire world *ប្រវត្តិរូបរបស់លោក គីមយ៉ុងសាម(Kim Young Sam)* ត្រូវបានទាយយកនៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៣ពី http://www.nndb.com/people/462/000111129/

[36] BlechingerVerena, *Corruption and Political Parties Management Systems International* ខែវិច្ឆិកា ឆ្នាំ២០០២

[37] សូមមើលសេចក្តីយោងលេខ ២៨

[38] វិទ្យាស្ថានអន្តរជាតិដើម្បីលទ្ធិប្រជាធិបតេយ្យ និងជំនួយការបោះឆ្នោត(IDEA) ហិរញ្ញប្បទានសម្រាប់គណបក្សនយោបាយ និងយុទ្ធនាការឃោសនា បោះឆ្នោត *Funding of Political Parties and Election Campaigns, Chapter 4 - Party Funding and Political Corruption in East Asia: The Cases of Japan, South Korea and Taiwan* ឆ្នាំ២០០៣

## ៣.២. ហិរញ្ញប្បទានសាធារណៈសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត

ប្រព័ន្ធហិរញ្ញប្បទានសាធារណៈ គឺត្រូវផ្តល់សម្រាប់សកម្មភាពនានា នៃការបោះឆ្នោត។ ជំនួយមានពីរប្រភេទដែលអាចប្រើបាន៖ ទីមួយគឺការឧបត្ថម្ភធនធម្មតា ដែលត្រូវបង់ប្រចាំត្រីមាស រៀងរាល់ឆ្នាំសម្រាប់ការផ្តល់ហិរញ្ញប្បទាននៃគណបក្សនយោបាយ និង ទីពីរគឺការឧបត្ថម្ភធនបោះឆ្នោតដែលត្រូវបង់ពីរថ្ងៃមុនពេលផុតកំណត់ សម្រាប់ការតែងតាំងដែលជាការបោះឆ្នោតប្រធានាធិបតី នីតិបញ្ញត្តិ និង ថ្នាក់មូលដ្ឋាន[39]។ ជំនួយសាធារណៈត្រូវបានបែងចែកដោយយោងទៅតាមចំនួនអាសនៈនៅក្នុងរដ្ឋសភាជាតិ ធ្វើដោយ គ.ជ.ប[40] ដែលត្រូវចេញផ្សាយរបាយការណ៍ប្រចាំត្រីមាសនៃឧបត្ថម្ភធនសាធារណៈ។ ថវិកាសម្រាប់ឧបត្ថម្ភធនសាធារណៈត្រូវផ្អែកលើចំនួននៃអ្នកបោះឆ្នោតនៅលើជុំនៃការបោះឆ្នោត (គុណនឹង១០០)[41]។

ជំនួយសាធារណៈត្រូវបានគេរំពឹងផងដែរ ក្នុងការលើកទឹកចិត្តដល់គណបក្សនយោបាយដើម្បីដាក់បញ្ចូលនូវបេក្ខជនជាស្ត្រី ឬ ជនពិការឲ្យមានអាទិភាព យោងតាមលក្ខណៈវិនិច្ឆ័យដែលបានកំណត់ដោយច្បាប់[42]។ លើសពីនេះទៀត ច្បាប់បានរឹតបន្តឹងលើការប្រើប្រាស់ឧបត្ថម្ភសាធារណៈដោយ ហាមឃាត់ការប្រើប្រាស់ហិរញ្ញប្បទាន ដែលប្រមូលទៅប្រើប្រាស់ក្នុងគោលបំណងផ្សេងពីការផ្តល់ហិរញ្ញប្បទានដល់សកម្មភាពនយោបាយ។ ការប្រើប្រាស់ដោយកេងបន្លំលើជំនួយនេះបណ្តាលឱ្យមានការកាត់បន្ថយ ឬការលុបចោលនូវឧបត្ថម្ភធនទាំងនេះដោយគ.ជ.ប ។

អ្នកដែលស្ថិតក្រោមការគ្រប់គ្រងដោយ ច្បាប់ស្តីពីហិរញ្ញប្បទាននយោបាយនេះ (ជំពូកទីVIIរបាយការណ៍ និង ការបង្ហាញព័ត៌មានរបស់ហិរញ្ញប្បទាននយោបាយ មាត្រា៣៤ និងបន្តបន្ទាប់) ត្រូវចាត់តាំងជាហិរញ្ញការ[43]។

របាយការណ៍គណនេយ្យត្រូវធ្វើឡើងដោយហិរញ្ញករ និងត្រូវមានព័ត៌មានផ្សេងៗដូចជា ព័ត៌មានលម្អិតអំពីចំណាយ និងចំណូល (មាត្រា៣៧ នៃច្បាប់ស្តីពីហិរញ្ញប្បទាននយោបាយ)។ របាយការណ៍គណនេយ្យត្រូវតែដាក់ជាមួយគណៈកម្មការចូលរួមចំណែក គឺ (គ.ជ.ប) សម្រាប់ការបោះ ឆ្នោត ប្រធានា-ធិបតី ឬនីតិបញ្ញត្តិ (មាត្រា៤០នៃច្បាប់ស្តីពី ហិរញ្ញប្បទាននយោបាយ)។

## ៣.៣. ការកំរិតលើការចំណាយក្នុងយុទ្ធនាការឃោសនាបោះឆ្នោត

ហិរញ្ញប្បទាននៃគណបក្សនយោបាយ និងយុទ្ធនាការឃោសនាបោះឆ្នោត ត្រូវបានដាក់កំហិតឲ្យសមស្របតាមច្បាប់ និងជាកម្មវត្ថុនៃប្រព័ន្ធរាយការណ៍សម្រាប់ការបោះឆ្នោតនីមួយៗ។ រូបវន្តបុគ្គល និងនីតិបុគ្គលដែលគ្រប់គ្រង ដោយច្បាប់ឯកជនអាចផ្តល់នូវ ការបរិច្ចាគទ្រព្យសម្បត្តិទៅគណបក្សនយោ

[39] ច្បាប់ស្តីពីហិរញ្ញប្បទាននយោបាយនៃសាធារណរដ្ឋកូរ៉េ ឆ្នាំ១៩៦៥ ត្រូវបានធ្វើវិសោធនកម្មដោយច្បាប់លេខ ១១៣៧៦ ថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១២ មាត្រា២៥ (៤)

[40] មាត្រា២៥ (១) & (៤) នៃច្បាប់ដែលរៀបរាប់ខាងលើ

[41] មាត្រា២៦ (១) នៃច្បាប់ដែលរៀបរាប់ខាងលើ

[42] មាត្រា២៦ (១) នៃច្បាប់ដែលរៀបរាប់ខាងលើ

[43] រួមទាំងតំណាងណាមួយនៃគណបក្សនយោបាយ តំណាងណាមួយនៃសមាគមអ្នកគាំទ្រ បេក្ខជនក្នុងការបោះឆ្នោតប្រធានាធិបតី ឬបេក្ខជនណាមួយដែលប្រកួតប្រជែងដើម្បីក្លាយជាអ្នកដឹកនាំនៃគណបក្សមួយ

បាយតាមកម្រិតដែលបាន អនុញ្ញាតដោយច្បាប់ស្តីពី ហិរញ្ញប្បទាននយោបាយ[44] និងច្បាប់ដែលកំណត់នូវចំនួនទឹកប្រាក់នៃការបរិច្ចាគសម្រាប់ការបោះឆ្នោតដែលមិនមានចំនួនលើសពី១០%(ដប់ភាគ រយ) នៃការចំណាយលើការបោះឆ្នោត (មាត្រា២ នៃច្បាប់ស្តីពី ហិរញ្ញប្បទាននយោបាយ)[45]។

សមាគមអ្នកគាំទ្រ (ឬក៏ koenkai គឺជាសមាគមដែលគាំទ្រដល់គណបក្សមួយ និង/ឬ បេក្ខជនឯករាជ្យ) ត្រូវបានអនុញ្ញាតឲ្យប្រមូលប្រាក់ចំនួន២,៥លានដុល្លារសហរដ្ឋអាមេរិកសម្រាប់ទីស្នាក់ការកណ្តាលនៃគណបក្ស និង/ឬ ២៥០.០០០ដុល្លារសហរដ្ឋអាមេរិក សម្រាប់គណបក្សមូលដ្ឋាន ឬជាបេក្ខជនឯករាជ្យ ហើយមូលនិធិដែលកំណត់ទាំងនេះត្រូវកើនឡើងទ្វេដងក្នុងអំឡុងពេលបោះឆ្នោត។ ច្បាប់ដដែលនេះក៏ផ្តល់នូវការឧបត្ថម្ភធនប្រចាំឆ្នាំសម្រាប់គណបក្សនយោបាយផងដែរ។ បេក្ខជនទទួលបានមូលនិធិពីច្បាប់ស្តីពីមូលនិធិនយោបាយ ចូលរួមប្រកួតប្រជែងការបោះឆ្នោតដើម្បីទទួលបានសំលេងឆ្នោត។ បេក្ខជនទាំងនោះរួមមាន៖ បេក្ខជនប្រធានាធិបតី បេក្ខជនសម្រាប់ចូលរួមការប្រកួតប្រជែងក្នុងបក្សរបស់ខ្លួនឯងនៅក្នុងការបោះឆ្នោតប្រធានាធិបតី បេក្ខជនដែលចូលរួមក្នុងការបោះឆ្នោតសម្រាប់ សភាជាតិ និង បេក្ខជនដែលចូលរួមក្នុងការបោះឆ្នោតសម្រាប់រដ្ឋាភិបាលថ្នាក់មូលដ្ឋាន។ បេក្ខជនទាំងនេះត្រូវតែ កំណត់សមាគមដែលគាំទ្រ[46]។ ច្បាប់ស្តីពីហិរញ្ញប្បទាននយោបាយបានឲ្យនិយមន័យសមាគមអ្នកគាំទ្រថាជាអង្គការដែលបានចុះបញ្ជីក្នុងគោលបំណងដើម្បីជួយផ្តល់ថវិកាសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោតរបស់បេក្ខជន ដែលពួកគេគាំទ្រដោយយោងទៅតាមវិធានដែល មានចែងនៅក្នុងច្បាប់។ ក្នុងអំឡុងពេលនៃការបោះឆ្នោត ម្ចាស់ជំនួយម្នាក់មិនអាចបរិច្ចាគលើសពី៩.៥០០ដុល្លារសហរដ្ឋអាមេរិក ដល់សមាគមមួយនោះទេ ហើយចំនួន៤៥០០ដុល្លារសហរដ្ឋអាមេរិកសម្រាប់ការបោះឆ្នោតប្រធានាធិបតី ឬបេក្ខជនមួយស្ថិតក្នុងគណបក្ស សម្រាប់ការបោះឆ្នោត ប្រធានាធិបតី ប្រសិនបើសមាគមនេះបានគាំទ្របេក្ខជននេះរួចមកហើយនៅក្នុងការបោះឆ្នោតសភា។ ច្បាប់នេះអនុញ្ញាតឱ្យមានអំណោយអនាមិកប្រចាំឆ្នាំតែមួយគត់ ហើយមានតម្លៃអតិបរមាស្មើ៩៥ដុល្លារសហរដ្ឋអាមេរិក ទោះជាយ៉ាងណា ច្បាប់នេះមិនបានបញ្ជាក់ថា តើម្ចាស់អំណោយ "អនាមិក" ត្រូវតែចុះឈ្មោះជាមួយអាជ្ញាធរ ដើម្បីធានាពីភាពអនាមិក[47] របស់គាត់ដែរឬទេ។

## ៣.៤. ស្ថាប័នត្រួតពិនិត្យ

គ.ជ.ប ត្រួតពិនិត្យបញ្ហានៃការផ្តល់ហិរញ្ញប្បទានសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត។ គណៈកម្មការនេះ ក៏ទទួលបន្ទុកផងដែរ ក្នុងការផ្តល់ឧបត្ថម្ភធនដល់គណបក្សនយោបាយ ត្រួតពិនិត្យការបង្កើត និង សកម្មភាពរបស់សមាគមអ្នកគាំទ្រ ប្រមូល និងចែកចាយនូវហិរញ្ញប្បទាននយោបាយ និង

---

[44] មនុស្សម្នាក់អាចផ្តល់ជាទឹកប្រាក់ ៨៣០០០ ដុល្លារសហរដ្ឋអាមេរិច ក្នុងមួយឆ្នាំទៅទីស្នាក់កណ្តាលនៃគណបក្សនយោបាយ និង ១៦៥០០ ដុល្លារសហរដ្ឋអាមេរិចទៅគណបក្សមូលដ្ឋាន ឬបេក្ខជនឯករាជ្យ និតិបុគ្គលត្រូវបានអនុញ្ញាតឲ្យផ្តល់ជាទឹកប្រាក់ ១៦៦០០០ ដុល្លារសហរដ្ឋអាមេរិកទៅទីស្នាក់ការកណ្តាលនៃគណបក្ស និង ៥១៥០០ ដុល្លារសហរដ្ឋអាមេរិក ទៅគណបក្សក្នុងមូលដ្ឋាន ឬបេក្ខជនឯករាជ្យ

[45] សូមមើលសេចក្តីយោងលេខ ២៨

[46] ច្បាប់ស្តីពីហិរញ្ញប្បទាននយោបាយនៃសាធារណរដ្ឋកូរ៉េ មាត្រា ៦

[47] អាជ្ញាធរមានកាតព្វកិច្ចថែរក្សាភាគអនាមិករបស់អ្នកផ្តល់ជំនួយតាមរយៈការប្រើប្រាស់ព័ត៌មានតែនៅក្នុងស្ថាប័ន ហើយនឹងមិនបញ្ជូនព័ត៌មានស្ថាប័នដ៏ទៃទៀត ឬផ្សាយជាសាធារណៈ

ត្រួតពិនិត្យលើការប្រើប្រាស់របស់ពួកគេ ស្ថិតនៅក្រោមលក្ខខណ្ឌដែលកំណត់ដោយច្បាប់ស្តីពីគោលនយោបាយហិរញ្ញប្បទាន។ គ.ជ.ប ក៏មានសិទ្ធិអំណាចត្រួតពិនិត្យ ក្នុងការអនុវត្តបទប្បញ្ញត្តិទៅលើការផ្តល់ហិរញ្ញប្បទាននៃយុទ្ធនាការឃោសនាបោះឆ្នោត រួមទាំងការអនុវត្តន៍នូវ វិធានដាក់លាក់ណាមួយនៃច្បាប់ស្តីពី ការផ្តល់ហិរញ្ញប្បទានការបោះឆ្នោត។

### ៣.៥. ទោសពិន័យ

ការដាក់ពិន័យអាចមានរហូតដល់ទៅ ១០.០០០ដុល្លារ និងដាក់ពន្ធនាគារប្រាំឆ្នាំ សម្រាប់ការប្រព្រឹត្តិបទល្មើសដែលផ្ទុយនឹងច្បាប់ស្តីពី ហិរញ្ញប្បទាននយោបាយ[48]។

## ៤. ប្រទេសហ្វីលីពីន

### ៤.១. ច្បាប់និងបទបញ្ញា

ច្បាប់និងបទប្បញ្ញត្តិ សម្រាប់ការត្រួតពិនិត្យនៃការផ្តល់ហិរញ្ញប្បទានសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោតគឺ មានចែងនៅក្នុងរដ្ឋធម្មនុញ្ញហ្វីលីពីន ក្នុងមាត្រាIX នៃគណៈកម្មការធម្មនុញ្ញ និងក្រមបោះឆ្នោតទូទៅ[49]។

### ៤.២. ហិរញ្ញប្បទានសាធារណៈសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត

ប្រទេសហ្វីលីពីននាពេលបច្ចុប្បន្នមិនទាន់មានហិរញ្ញប្បទានសាធារណៈសម្រាប់គាំទ្រគណបក្សនយោបាយ ឬយុទ្ធនាការឃោសនាបោះឆ្នោតនៅឡើយទេ[50]។

### ៤.៣. ការកំរិតលើការចំណាយក្នុងយុទ្ធនាការឃោសនាបោះឆ្នោត

សេចក្តីសម្រេចរបស់ គណៈកម្មការរៀបចំការបោះឆ្នោត(COMELEC) ហ្វីលីពីន បានបង្កើតនូវអង្គភាពហិរញ្ញប្បទានសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត ដែលត្រូវបានអនុម័តនៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១២[51] ដើម្បីកំណត់នូវវិន័យក្នុងការផ្តល់ហិរញ្ញប្បទានសម្រាប់យុទ្ធនាការនេះ និង ឯកសារដែលគណៈបក្សនយោបាយត្រូវផ្តល់ឲ្យអាចដាក់ឲ្យប្រើប្រាស់បានជាសាធារណៈ។ ជនណាក៏ដោយ អាចផ្តល់វិភាគទានទៅឲ្យបេក្ខជន ឬ គណបក្សនយោបាយបាន។ ជាតម្រូវការ ការរាយការណ៍ត្រូវធ្វើឡើងដោយអ្នកបរិច្ចាគ។ អ្នកបរិច្ចាគ ត្រូវតែដាក់របាយការណ៍នៃការផ្តល់វិភាគទាននេះ ទៅកាន់អង្គភាពហិរញ្ញប្បទានសម្រាប់ យុទ្ធនាការឃោសនាបោះឆ្នោតក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ បន្ទាប់ពីការបោះឆ្នោត។

---

[48] មាត្រា ៩៥ នៃច្បាប់ដែលរៀបរាប់ខាងលើ

[49] ក្រមនៃការបោះឆ្នោតទូទៅ (*ក្រមបោះឆ្នោត Omnibus*) ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៨៥ ផ្នែក៩៤-១១២

[50] Weissenbach, K.2010, *Political Parties and Party Types – Conceptual Approaches to the Institutionalization of Political Parties in Transitional States: The Case of the Philippines* Konrad-Adenauer-Stifung Konrad-Adenauer-Stiftung ទំព័រទី ៣៨

[51] គណៈកម្មការរៀបចំការបោះឆ្នោត(COMELEC) ឆ្នាំ២០១២ *សេចក្តីសម្រេចលេខ ៩៤៧៦* ក្រុងម៉ានីល ត្រូវបានទាញយកនៅថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៣ ពី http://www.comelec.gov.ph/uploads/Elections/2013natloc/res/com_res_9476.pdf

របាយការណ៍ នេះត្រូវតែមាន ឈ្មោះរបស់អ្នកទទួល ចំនួននៃការបរិច្ចាគ និងកាលបរិច្ឆេទនៃការផ្តល់វិភាគទាននេះ។ សេចក្តីប្រកាសអនុញ្ញាតឱ្យអ្នកបរិច្ចាគ ទទួលបាននូវការកាត់បន្ថយពន្ធ។ ការបរិច្ចាគពី៖

- ស្ថាប័នហិរញ្ញវត្ថុ សាធារណៈ ឬ ឯកជនផ្សេងទៀត
- នីតិបុគ្គល ឬរូបវន្តបុគ្គល[52]ដែលចុះកិច្ចសន្យាសាធារណៈ
- ស្ថាប័នអប់រំដែលទទួលបានមូលនិធិសាធារណៈ
- ភ្នាក់ងារ ឬ បុគ្គលិក នៃសេវាសាធារណៈ
- កងប្រដាប់អាវុធរបស់ប្រទេសហ្វីលីពីន និង
- ការបរិច្ចាគពីប្រភពបរទេសក៏ដូចជា ការផ្តល់វិភាគទានពីសាច់ញាត្តិថ្នាក់ទី១និងទី២ ត្រូវបានហាមឃាត់។

ទោះជាយ៉ាងណា ខណៈពេលដែលមិនមានការផ្តល់ហិរញ្ញប្បទានសាធារណៈ ជូនដល់យុទ្ធនាការឃោសនាបោះឆ្នោត ការចំណាយទៅលើយុទ្ធនាការឃោសនាបោះឆ្នោត ត្រូវបានកំណត់ដោយយោងទៅតាមសមាមាត្រដូចខាងក្រោម៖

- សម្រាប់ការបោះឆ្នោតជ្រើសរើសប្រធានាធិបតី និងអនុប្រធានាធិបតី៖ ១០ប៉េសូ (ប្រមាណ០,២៣ ដុល្លារសហរដ្ឋអាមេរិក) សម្រាប់អ្នកចុះឈ្មោះបោះឆ្នោតម្នាក់ៗ
- សម្រាប់បេក្ខជននៃការបោះឆ្នោតផ្សេងៗទៀត៖ ០៣ប៉េសូ (ប្រមាណ០.០៧ ដុល្លារសហរដ្ឋ-អាមេរិក) សម្រាប់អ្នកចុះឈ្មោះបោះឆ្នោតម្នាក់ៗ នៅក្នុងស្រុក ដែលជាកន្លែងដែលបេក្ខជនឈរឈ្មោះបោះឆ្នោត
- សម្រាប់បេក្ខជនឯករាជ្យដែលមិនមានការគាំទ្រពីគណបក្សនយោបាយណាមួយ៖ ០៥ប៉េសូ (ប្រមាណ០,១២ ដុល្លារសហរដ្ឋអាមេរិក) សម្រាប់អ្នកចុះឈ្មោះបោះឆ្នោតម្នាក់ៗ នៅក្នុងស្រុកដែលជាកន្លែងដែលបេក្ខជនឈរឈ្មោះបោះឆ្នោត និង
- សម្រាប់គណបក្សនយោបាយ និងបញ្ជីគណបក្ស៖ ០៥ប៉េសូ (ប្រមាណ០,១២ដុល្លារសហរដ្ឋ-អាមេរិក) សម្រាប់អ្នកចុះឈ្មោះបោះឆ្នោតម្នាក់ៗ នៅក្នុងស្រុកដែលជាកន្លែងដែលបេក្ខជនឈរឈ្មោះបោះឆ្នោត ។

[52] ដើម្បីទទួលបាននូវបុគ្គលភាពគតិយុត្តិដែលសំដៅលើការមានលទ្ធភាពក្នុងការទទួលបាននូវសិទ្ធិ និង កាតព្វកិច្ចគតិយុត្តិនៅក្នុងប្រព័ន្ធច្បាប់ជាក់លាក់មួយ ដូចជាការចុះកិច្ចសន្យា ការប្តឹង នឹងត្រូវបានប្តឹង។ បុគ្គលភាពគតិយុត្តិគឺជា បុរេលក្ខខណ្ឌនៃសមត្ថភាពគតិយុត្តិ ហើយសមត្ថភាពនៃបុគ្គលភាពគតិយុត្តិគឺសំដៅលើការបង្កើត កែប្រែ ផ្ទេរនូវសិទ្ធិ និងកាតព្វកិច្ច ។ល។
បុគ្គលភាពគតិយុត្តិ (lat. *persona iuris*) មានពីរប្រភេទគឺ៖ រូបវន្តបុគ្គល(មនុស្ស) និង នីតិបុគ្គល(ក៏ត្រូវបានហៅថា juristic or artificial or fictitious persons, lat. *persona ficta*) ដូចជា ក្រុមមនុស្ស ឬសាជីវកម្មដែលត្រូវបានការពារដោយច្បាប់។ នៅពេលដែល រូបវន្តបុគ្គលទទួលបាននូវបុគ្គលភាពគតិយុត្តិចាប់តាំងពីពេលចាប់កំណើត រីឯនីតិបុគ្គលគឺទទួលបាននៅពេលចុះបញ្ជីដោយអនុលោមតាមច្បាប់។

ទម្រង់បែបបទដើម្បីសុំសិទ្ធិចំណាយក្នុងនាមបេក្ខជនណាម្នាក់ សម្រាប់ការបោះឆ្នោតត្រូវដាក់ជូនទៅអង្គភាពហិរញ្ញប្បទានសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត។ ការខកខានមិនបានធ្វើ នាំឲ្យមានជាការចំណាយដែលគ្មានការអនុញ្ញាត ចំពោះគណនីរបស់បេក្ខជន។ លើសពីនេះទៀត របាយការណ៍នៃការចំណាយ ត្រូវតែដាក់ទៅហិរញ្ញប្បទានសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត មុននឹងការរៀបចំនៃការប្រកួតក្នុងឆាកនយោបាយ។ បេក្ខជនគ្រប់រូប ហេរញ្ញិកនៃគណបក្ស និងបុគ្គល ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់បេក្ខជន ឬ ហេរញ្ញិក[53]ដែលទទួលបន្ទុកទៅលើការចំណាយនៃការបោះឆ្នោត ត្រូវរក្សារបាយការណ៍នៃការចំណាយនីមួយៗ សម្រាប់រយៈពេល ៣ (បី) ឆ្នាំ។ របាយការណ៍គណនីទាំងនេះ អាចត្រូវបានផ្ទៀងផ្ទាត់ ដោយគណៈកម្មការរៀបចំការបោះឆ្នោត (COMELEC) ឬ តុលាការ ហើយពួកគេត្រូវតែបង្ហាញជាសាធារណៈ។ នៅពេលចាប់ផ្តើមយុទ្ធនាការឃោសនាបោះឆ្នោត អង្គភាពហិរញ្ញប្បទានសម្រាប់ យុទ្ធនាការឃោសនាបោះឆ្នោត ត្រូវជូនដំណឹងដល់បេក្ខជនពី កាតព្វកិច្ចរបស់ពួក គេ ដែលទាក់ទងទៅនឹងការប្រកាសនៃការចំណាយ និងចំណូល។ បន្ទាប់ពីនោះមក បេក្ខជនត្រូវតម្រូវឱ្យដាក់ក្នុងរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីការបញ្ចប់នៃការបោះឆ្នោតទៅ អង្គភាពហិរញ្ញប្បទាន សម្រាប់ យុទ្ធនាការឃោសនាបោះឆ្នោត ឬក្រុមប្រឹក្សាភិបាលមូលដ្ឋាន នូវរបាយការណ៍ទាំងអស់នៃការបរិច្ចាគ និងចំណាយដែលទាក់ទងនឹងយុទ្ធនាការឃោសនាបោះឆ្នោត។ នៅពេលជាមួយគ្នានេះ ហិរញ្ញិករបស់គណបក្សដែលបានចូលរួមក្នុងការបោះឆ្នោតត្រូវដាក់ជូនទៅអង្គភាពហិរញ្ញប្បទានសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត អំពីការបង្ហាញនៃការផ្តល់វិភាគទានដែលទទួលបាននិងការចំណាយនានាដោយគណបក្សដែលទាក់ទងជាមួយនឹងការបោះឆ្នោត។

### ៤.៤. ស្ថាប័នត្រួតពិនិត្យ

បទប្បញ្ញត្តិទាក់ទងទៅនឹង ការផ្តល់ហិរញ្ញប្បទានសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត នៅប្រទេសហ្វីលីពីន ស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ គណៈកម្មការរៀបចំការបោះឆ្នោត (COMELEC) ដែលជា អាជ្ញាធរជាតិឯករាជ្យ ដែលមានសមត្ថកិច្ចត្រួតពិនិត្យ និង វិនិច្ឆ័យ ដើម្បីជៀសវាងការចំណាយលើការបោះឆ្នោតលើស ដូច្នេះរាល់ការចំណាយលើយុទ្ធនាការឃោសនាបោះឆ្នោត ត្រូវបានកម្រិតដោយច្បាប់។ គណៈកម្មការរៀបចំការបោះឆ្នោត ត្រូវបានបង្កើតឡើងក្រោមរដ្ឋធម្មនុញ្ញឆ្នាំ១៩៤០ និងច្បាប់ខមមិនវែល (Commonwealth Act) លេខ៦០៧ នៅថ្ងៃទី១៨ខែកញ្ញា ឆ្នាំ១៩៤០[54]។

គណៈកម្មការរៀបចំការបោះឆ្នោត (COMELEC) គឺជាអ្នកទទួលខុសត្រូវ ក្នុងការត្រួតពិនិត្យនូវការផ្តល់ហិរញ្ញប្បទានសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត និងពង្រឹងការអនុវត្តន៍ច្បាប់ និង បទប្បញ្ញត្តិស្តីពីការបោះឆ្នោត និងការធ្វើប្រជាមតិ។ គណៈកម្មការនេះ មានអំណាចដើម្បីអនុម័តសេចក្តីសម្រេចនៃ

[53] សេចក្តីសម្រេចនៃគណៈកម្មការរៀបចំការបោះឆ្នោត(COMELEC) លេខ ៩៤៧៦ (Règles et règlements relatifs au financement des campagnes électorales pour les élections nationales et locales du 13 mai 2013 et les élections postérieures) វិធាន៧៖ ផ្នែកទី១ (C) ត្រូវបានទាញយកពី http://www.comelec.gov.ph/?r=Elections/2013natloc/res/res9476

[54] *ប្រវត្តិនៃគណៈកម្មការរៀបចំការបោះឆ្នោត* បានទាញយកនៅថ្ងៃ៥ ខែធ្នូ ឆ្នាំ២០១៣ ពី http://www.comelec.gov.ph/?r=AboutUs/HistoricalBackground

អំណាចត្រួតពិនិត្យលើបញ្ហាបោះឆ្នោត។ លើសពីនេះទៀត គណៈកម្មការបានបង្កើតឡើងនូវ អង្គភាពហិរញ្ញប្បទានសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោតជាចំណុះឲ្យខ្លួន[55]។ អង្គភាពហិរញ្ញប្បទានសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោតនេះមានសិទ្ធិអំណាច និង តួនាទីដែលពាក់ព័ន្ធទៅនឹងហិរញ្ញប្បទានសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត៖

- ធ្វើការត្រួតពិនិត្យ ការរៃអង្គាសប្រាក់ ការចំណាយរបស់បេក្ខជន និង គណបក្ស
- ទទួល និងរក្សាទុក របាយការណ៍ ហើយនិង របាយការណ៍ហិរញ្ញវត្ថុ ពីបេក្ខជនគណបក្ស អ្នកផ្តល់វិភាគទាន និង អ្នកចំណុះកិច្ចសន្យានៃការបោះឆ្នោត (ភាគីនៃកិច្ចសន្យាដែលទទួលរៀបចំការបោះឆ្នោត កិច្ចសន្យាផ្សាយពាណិជ្ជកម្ម ដែលចុះហត្ថលេខាជាមួយនឹងប្រព័ន្ធផ្សព្វផ្សាយ)
- ធ្វើការផ្តិតយកពត៌មាន និង ការផ្សព្វផ្សាយជាសាធារណៈ
- ធ្វើការកំណត់ដោយអនុលោមតាមបទប្បញ្ញត្តិច្បាប់ នៃការបោះឆ្នោត និងច្បាប់ផ្សេងៗទៀតដែលពាក់ព័ន្ធ
- ធ្វើការសំរបសំរួលជាមួយស្ថាប័នផ្សេងទៀតសម្រាប់ ការកាត់ទោសជនល្មើស ការដាក់ពិន័យ ហើយអាចឈានដល់ការដកហូតបេក្ខភាពជាអចិន្ត្រៃយ៍។

សេចក្តីសម្រេចរបស់គណៈកម្មការ (COMELEC) ចាត់ទុកជាសេចក្តីសម្រេចចុងក្រោយ និងបិទផ្លូវតវ៉ា។ ដើម្បីជួយដល់បេសកកម្មរបស់ខ្លួន អង្គភាពហិរញ្ញប្បទានសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត អាចស្នើសុំស្ថាប័នរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាលផ្សេងទៀត ដើម្បីផ្តល់ឲ្យខ្លួននូវជំនួយផ្សេងៗទៅតាមការចាំបាច់។

### ៤.៥. ទោសពិន័យ

ការខកខានក្នុងការបំពេញតាមការទាមទារ នៃហិរញ្ញប្បទានសម្រាប់យុទ្ធនាការឃោសនា បោះ-ឆ្នោតនេះ ដោយបេក្ខជន ឬគណបក្សរបស់បេក្ខជននឹងក្លាយជាកម្មវត្ថុនៃមោឃៈភាព ទៅលើការបោះឆ្នោតរបស់បេក្ខជន និងទទួលរងការពិន័យរដ្ឋបាលចាប់ពី ១,០០០.00 PhP (ប្រហែល២៣ដុល្លារសហរដ្ឋអាមេរិក ) រហូតដល់ ៣០,០០០.០០ PhP (ប្រមាណ៦៨៥ ដុល្លារសហរដ្ឋអាមេរិក) ។ ទឹកប្រាក់នៃការពិន័យនេះគឺស្ថិតក្រោមឆន្ទានុសិទ្ធរបស់ គណៈកម្មការរៀបចំការបោះឆ្នោត (COMELEC) តែមួយគត់។ នៅក្នុងករណីមិនរាងចាល ការដាកពិន័យត្រូវគុណទ្វេដង ហើយបេក្ខជននឹងត្រូវដកហូតបេក្ខភាពជាអចិន្ត្រៃយ៍។ ទោះជាយ៉ាងណា មាត្រដ្ឋានរបស់គណៈកម្មការរៀបចំការបោះឆ្នោត(COMELEC) បានចែងអំពីចំនួននៃការពិន័យ ដោយផ្អែកលើអាណត្តិ និង តំណែងនៃការបោះឆ្នោតរបស់បេក្ខជន ហើយថាតើបេក្ខជនមានការរាងចាលដែរទេ។

---

[55] សេចក្តីសម្រេចនៃគណៈកម្មការរៀបចំការបោះឆ្នោត (COMELEC) លេខ ៩៨៧៦ (ឆ្នាំ២០១៣)

## ៥. ប្រទេសឥណ្ឌូនេស៊ី

គណៈកម្មការជាតិរៀបចំការបោះឆ្នោត (Komisi Pemilihan Umum/ KPU) គឺជា ស្ថាប័នថ្នាក់ជាតិ ទទួលបន្ទុកលើការអនុវត្តន៍វិធានបោះឆ្នោត។ គណៈកម្មការនេះ ត្រូវបានបង្កើតឡើងក្រោមកំណែទំរង់រដ្ឋធម្មនុញ្ញ នៅក្នុងឆ្នាំ២០០១ ដែលអនុម័ត ដោយសភាប្រឹក្សាប្រជាជន(MPR)[56] ហើយអាណត្តិ រចនាសម្ព័ន្ធ និង អំណាចរបស់គណៈកម្មការនេះ ត្រូវបានចែងនៅក្នុងអនុក្រឹត្យរបស់ប្រធានាធិបតី លេខ៧០ ឆ្នាំ២០០១ ស្តីពីការបង្កើតនៃគណៈកម្មការជាតិរៀបចំការបោះឆ្នោត(KPU)។ ជាលទ្ធផលនៃការបង្កើតច្បាប់ លេខ២២/២០០៧ គណៈកម្មការជាតិរៀបចំការបោះឆ្នោត(KPU) ត្រូវបានបង្កើតឡើងជាគណៈកម្មការអចិន្ត្រៃយ៍ និងអព្យាក្រឹត្យថ្មីមួយ។

### ៥.១. ច្បាប់និងបទបញ្ជា

ប្រទេសឥណ្ឌូនេស៊ីបានមើលឃើញ ប្រជាធិបតេយ្យភាវូបនីយកម្មនៃជីវិតនយោបាយ បន្ទាប់ពីការដួលរលំនៃរដ្ឋាភិបាល*ស៊ូហារតូ* នៅក្នុងខែឧសភា ឆ្នាំ១៩៩៨ និង ការបោះឆ្នោត ខែមិថុនា ឆ្នាំ១៩៩៩ដែលអនុញ្ញាតឲ្យមានកំណែទម្រង់លើ គណបក្សនយោបាយ និងសកម្មភាពការបោះឆ្នោត[57]។ ច្បាប់ឥណ្ឌូនេស៊ីកំណត់ចេញនូវឧបករណ៍ស្របច្បាប់ក្នុងការគ្រប់គ្រងការចំណាយ និង វិភាគទានដែលបានចំណាយ ឬដែលទទួលបានសម្រាប់ការផ្តល់ហិរញ្ញប្បទាននៃយុទ្ធនាការឃោសនាបោះឆ្នោត។ ហិរញ្ញប្បទាននៃយុទ្ធនាការឃោសនាបោះឆ្នោតនិងវិភាគទានដែលអាចត្រូវបាន ទទួលដោយបេក្ខជនឈរឈ្មោះបោះឆ្នោត (គណបក្សនយោបាយ និង បុគ្គល) គឺត្រូវបានគ្រប់គ្រងដោយច្បាប់លេខ០៨ ឆ្នាំ២០១២ នៃសាធារណៈរដ្ឋឥណ្ឌូនេស៊ី ស្តីពីការបោះឆ្នោតទូទៅនៃសមាជិកសភាតំណាងរាស្ត្រ (House of Representatives) ក្រុមប្រឹក្សាតំណាងរាស្ត្រ(People's Representative Council) និង សភាតំណាងរាស្ត្រតំបន់(Regional House of Representatives) និង ច្បាប់លេខ៤២ ឆ្នាំ២០០៩ ស្តីពីការបោះឆ្នោតប្រធានាធិបតី[58]។

### ៥.២. ហិរញ្ញប្បទានសាធារណៈសម្រាប់យុទ្ធនាការឃោសនាការបោះឆ្នោត

ប្រព័ន្ធឧបត្ថមធនសាធារណៈសម្រាប់ហិរញ្ញប្បទាននៃយុទ្ធនាការឃោសនាបោះឆ្នោត ត្រូវបានចាប់ផ្តើមដាក់ឲ្យប្រើជាលើកដំបូង នាឆ្នាំ១៩៩៩ ប៉ុន្តែចំនួននៃឧបត្ថម្ភធននេះត្រូវបានកាត់បន្ថយយ៉ាងគំហុកក្នុងឆ្នាំ២០០៦[59]។ ច្បាប់ក៏បានតម្រូវឲ្យគណៈបក្សនយោបាយ ដាក់បញ្ជូនរបាយការណ៍ដំបូង ស្តីពីហិរញ្ញប្បទានសម្រាប់ការបោះឆ្នោត និងរបាយការណ៍នៃគណនីធនាគាររបស់*អាដហុក*(Ad hoc) ទៅ

---

[56] មាត្រា២២E (៥) នៃរដ្ឋធម្មនុញ្ញប្រទេសឥណ្ឌូនេស៊ី ឆ្នាំ១៩៤៥

[57] Ufen Andreas *Electoral Campaigning in Indonesia: The Professionalization and Commercialization after 1998* ក្នុងនិទានុប្បវត្តិ កិច្ចការបច្ចុប្បន្នអាស៊ីអាគ្នេយ៍ ២៩,៤,១១-៣៧ ឆ្នាំ២០១០

[58] ច្បាប់សាធារណរដ្ឋឥណ្ឌូនេស៊ីលេខ ០៨ ឆ្នាំ២០១២ ស្តីពីការបោះឆ្នោតទូទៅនៃសមាជិកនៃសភាតំណាង ក្រុមប្រឹក្សាតំណាងប្រជាជន និងសភាតំណាងតំបន់ មាត្រា ១៣០-១៣១ (*ការបកប្រែក្រៅផ្លូវការ និងគ្មានការអនុញ្ញាតនៃច្បាប់ខែសីហា ឆ្នាំ២០១២ ស្តីពីការបោះឆ្នោតទូទៅនៃសមាជិកនៃសភាតំណាង ក្រុមប្រឹក្សាតំណាងប្រជាជន និងសភាតំណាងតំបន់*)

[59] OHMAN សូមមើលសេចក្តីយោងលេខ ២ ទំព័រទី៧

គណៈកម្មការជាតិរៀបចំការបោះឆ្នោត(KPU) ចាប់ពីពេលដែលក្លាយជាបេក្ខភាពក្នុងការឈរឈ្មោះ បោះឆ្នោត[60] រហូតដល់ពីរថ្ងៃមុនពេលចាប់ផ្ដើមនៃយុទ្ធនាការឃោសនាបោះឆ្នោត[61]។ របាយការណ៍ មូលនិធិយុទ្ធនាការឃោសនាបោះឆ្នោតនៃអ្នកចូលរួមឈរឈ្មោះបោះឆ្នោត ត្រូវបញ្ជូនទៅគណនេយ្យករសាធារណៈសម្រាប់ធ្វើសវនកម្មតាមដានមិនឲ្យលើសពី៦០ថ្ងៃ បន្ទាប់ពីការបោះឆ្នោត[62]។ សវនកម្មត្រូវតែ បញ្ចប់នៅក្នុងអំឡុងពេល៣០(សាមសិប)ថ្ងៃ ហើយបន្ទាប់មកបេក្ខជនត្រូវដាក់ជូននូវលទ្ធផលនៃគណ-នេយ្យសាធារណៈទៅ គណៈកម្មការជាតិរៀបចំការបោះឆ្នោត(KPU) ក្នុងអំឡុងពេល ៧ (ប្រាំពីរ) ថ្ងៃ[63]។

៥.៣. ការកំរិតលើការចំណាយក្នុងយុទ្ធនាការឃោសនាបោះឆ្នោត

ការចំណាយនៃយុទ្ធនាការឃោសនាបោះឆ្នោតគឺជា កម្មវត្ថុក្នុងការកំណត់ នូវការបោះឆ្នោត គ្រប់ជាន់ថ្នាក់ (ថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់ក្រុង) និង ជាកម្មវត្ថុសម្រាប់ការត្រួតពិនិត្យទៅលើហិរញ្ញវត្ថុ និងគណនេយ្យសាធារណៈ។ ប្រភពនៃហិរិញ្ញប្បទានអាចបានមកពី គណបក្សនយោបាយ ការផ្ដល់វិភាគទានរបស់បេក្ខជន និងវិភាគទានផ្សេងៗទៀត។ ហិរញ្ញប្បទាននៃសកម្មភាពបោះឆ្នោតអាចមាន ទម្រង់ជាសាច់ប្រាក់ ទំនិញ ឬសេវាកម្ម។ វិភាគទានអាចបានមកពីរូបវន្តបុគ្គល ឬនីតិបុគ្គល ដែលគ្រប់គ្រងដោយនីតិឯកជន(ពាណិជ្ជកម្ម អង្គការមិនយកប្រាក់ចំនេញ ឬអង្គការមិនមែនរដ្ឋាភិបាល)។

ក្នុងករណីដែលវិភាគទានជាសាច់ប្រាក់ សាច់ប្រាក់នោះត្រូវតំកល់នៅក្នុងគណនីពិសេសមួយ ក្នុងគោលបំណង ដើម្បីផ្គត់ផ្គង់ហិរញ្ញប្បទានសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត ដល់បេក្ខជន (គណបក្សប្រកួតប្រជែងក្នុងការបោះឆ្នោត)[64]។ ក្នុងករណី ដែលវិភាគទានមានទម្រង់ជាទំនិញ ឬសេវាកម្ម ត្រូវតែធ្វើការវាយតម្លៃ ទៅតាមតម្លៃនៅលើទីផ្សារតាមកាលបរិច្ឆេទនៃការទទួលវិភាគទាននោះ។ គណ នេយ្យសម្រាប់សកម្មភាពយុទ្ធនាការឃោសនាបោះឆ្នោត ត្រូវតែផ្ដាច់ចេញពីគណនេយ្យទូទៅសម្រាប់សកម្មភាពនៃគណបក្សនយោបាយ។ នៅចុងបញ្ចប់នៃរយៈពេលកំណត់ដោយច្បាប់សម្រាប់យុទ្ធនា ការឃោសនាបោះឆ្នោត របាយការណ៍គណនេយ្យស្ដីពីការចំណាយ និងចំណូលត្រូវតែបញ្ជូនទៅគណនេយ្យករដែលបានចាត់តាំងដោយគណៈកម្មាការជាតិរៀបចំការបោះឆ្នោត(KPU)។

ច្បាប់លេខ០៨ កម្រិតនូវចំនួននៃវិភាគទានសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត៖ វិភាគទានពីរូបវន្តបុគ្គល មិនអាចលើសពី ៨៧,០០០ដុល្លារសហរដ្ឋអាមេរិកទេ[65] ហើយវិភាគទានពីនីតិបុគ្គលមិនអាចលើសពី ៦៥៦,០០០ ដុល្លារសហរដ្ឋអាមេរិក[66]។ អត្តសញ្ញាណនៃម្ចាស់ជំនួយត្រូវតែបង្ហាញ។ បេក្ខជនដែលទទួលបានចំនួនទឹកប្រាក់លើសពីការកំណត់ មិនអាចប្រើប្រាស់ថវិកាដែលលើសកម្រិតនេះបាន

[60] អ្នកចូលរួមការបោះឆ្នោត សំដៅទៅលើ "គណបក្សនយោបាយ និងបេក្ខជនDPD"

[61] ក្រឹត្យរបស់គណៈកម្មការជាតិរៀបចំការបោះឆ្នោត(KPU) លេខ៦៧៦ ឆ្នាំ២០០៣ មាត្រា៩(១ & ២)

[62] ច្បាប់លេខ ១២ នៃឆ្នាំ២០០៣ មាត្រា ៧៩(១)

[63] មាត្រា ៧៩(២) នៃច្បាប់ដែលបានរៀបរាប់ខាងលើ

[64] មាត្រា ១២៩(៤) នៃច្បាប់សាធារណរដ្ឋឥណ្ឌូនេស៊ីលេខ ០៨ ឆ្នាំ២០១២

[65] IDR ១ ០០០ ០០០ ០០០,០០ រូព្យាឥណ្ឌូនេស៊ី

[66] IDR ៧ ៥០០ ០០០ ០០០,០០ រូព្យាឥណ្ឌូនេស៊ី

ទេ។ បេក្ខជនទាំងនោះត្រូវរាយការណ៍អំពី ចំនួនហិរញ្ញប្បទានដែលលើសសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោតទៅគណៈកម្មការជាតិរៀបចំការបោះឆ្នោត(KPU) ហើយប្រគល់ចំនួនដែលលើសនោះទៅរតនាគារ ជាតិក្នុងអំឡុងពេល ១៤(ដប់បួន)ថ្ងៃ បន្ទាប់ពីបញ្ចប់រយៈពេលនៃយុទ្ធនាការឃោសនាបោះឆ្នោត (ច្បាប់លេខ០៨ មាត្រា១៣១ និងមាត្រាបន្តបន្ទាប់)។ ការអនុវត្តន៍ផ្ទុយពីបទប្បញ្ញត្តិទាំងនេះត្រូវបានផ្តន្ទាទោស ដោយពិន័យជាប្រាក់និងទោសព្រហ្មទណ្ឌ។

បេក្ខជនអាចមិនទទួលមូលនិធីពីគណបក្សបរទេស ពីអ្នកផ្តល់ជំនួយអនាមិក ពីរដ្ឋាភិបាលមូលដ្ឋាន ឬ រដ្ឋាភិបាលកណ្តាល ឬ ក្រុមហ៊ុនរដ្ឋសាធារណៈក្នុងតំបន់ឬមូលដ្ឋាន (ច្បាប់លេខ០៨ មាត្រា១៣៩ កថាខណ្ឌ១ ចំនុច C ៖« *រដ្ឋាភិបាល រដ្ឋាភិបាលថ្នាក់តំបន់ ក្រុមហ៊ុនគ្រប់គ្រងដោយរដ្ឋ ឬរដ្ឋាភិបាលថ្នាក់ភូមិ និងក្រុមហ៊ុនគ្រប់គ្រងថ្នាក់ភូមិ* ») ។

## ៥.៤. ស្ថាប័នត្រួតពិនិត្យ

អាជ្ញាធរមានសមត្ថកិច្ចសម្រាប់ ការត្រួតពិនិត្យហិរញ្ញប្បទាននៃយុទ្ធនាការឃោសនាបោះឆ្នោត គឺគណៈកម្មការជាតិរៀបចំការបោះឆ្នោត(KPU)[67]។ គណៈកម្មការនេះមាន កាតព្វកិច្ចត្រួតពិនិត្យហិរញ្ញប្បទានយុទ្ធនាការឃោសនាបោះឆ្នោត ដាក់ចេញនូវរបាយការណ៍ស្តីពីហិរញ្ញប្បទានយុទ្ធនាការឃោសនាបោះឆ្នោត ក៏ដូចជាដាក់ចេញផងដែរនូវរបាយការណ៍ ដែលទាក់ទងទៅនឹងថវិកាបន្ថែម ដែលបេក្ខជនទទួលបាន ឬប្រមូលបានដោយមិនស្របច្បាប់។

ទោះជាយ៉ាងណាសមត្ថកិច្ចរបស់ គណៈកម្មការជាតិរៀបចំការបោះឆ្នោត(KPU) ដើម្បីត្រួតពិនិត្យហិរញ្ញប្បទានយុទ្ធនាការឃោសនាបោះឆ្នោត ហាក់ដូចជាមានការកម្រិតទៅលើមុខងាររបស់គណៈកម្មការក្នុងការចាត់តាំង គណនេយ្យករទទួលបន្ទុកធ្វើសវនកម្មនៃយុទ្ធនាការឃោសនាបោះឆ្នោតរបស់បេក្ខជន និងការដាក់ជូននូវហិរញ្ញវត្ថុរបស់ពួកគេ ហើយនិងត្រូវប្រកាសជាសាធារណៈនូវលទ្ធផលនៃសវនកម្មនេះ [68]។

## ៥.៥. ទោសពិន័យ

ការខកខានក្នុងការអនុវត្តន៍កាតព្វកិច្ចនៃការរាយការណ៍ហិរញ្ញវត្ថុ នឹងត្រូវប្រឈមមុខចំពោះមោឃៈភាពនូវបេក្ខភាព និងការបោះឆ្នោតរបស់បេក្ខជននោះ[69] ។

[67] http://mediacenter.kpu.go.id/

[68] តាមសេចក្តីយោងខាងលើ (Ibid)

[69] មាត្រា ២៤៧ និងមាត្រា ១២៩(៤) នៃច្បាប់សាធារណរដ្ឋឥណ្ឌូនេស៊ីលេខ ០៨ ឆ្នាំ២០១២

## III. ការចុះឈ្មោះបោះឆ្នោត

ការអនុម័តស្តង់ដារអន្តរជាតិទៅលើការបង្កើតបញ្ជីបោះឆ្នោតគឺជាកត្តាដ៏សំខាន់ដើម្បីអនុវត្តសិទ្ធិបោះឆ្នោត។ គោលការណ៍ណែនាំរបស់សមាគមនៃការបោះឆ្នោតជាផ្លូវការរបស់អឺរ៉ុប (ACEEEO) ក្នុងការត្រួតពិនិត្យឡើងវិញ ទៅលើក្របខ័ណ្ឌច្បាប់សម្រាប់ជាអនុសាសន៍ដល់ការបោះឆ្នោត ដែលមានខ្លឹមសារដូចតទៅ: «យោងតាមក្របខ័ណ្ឌច្បាប់នឹងតម្រូវឲ្យ អ្នកបោះឆ្នោតចុះឈ្មោះ ដើម្បីរក្សាឲ្យបាននូវលក្ខណៈដែលប្រកបដោយ តម្លាភាព ភាពត្រឹមត្រូវ ការការពារសិទ្ធិរបស់ប្រជាពលរដ្ឋ ដែលគ្រប់អាយុចុះឈ្មោះបោះឆ្នោតតាមផ្លូវច្បាប់ និងការបង្ការចំពោះបុគ្គលដែលបានចុះឈ្មោះ ដោយ ខុសច្បាប់ ឬដោយ បន្លំបោកប្រាស់»[70]។

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ (ICCPR) ដែលប្រទេសកម្ពុជាក៏ជារដ្ឋសមាជិកផងនោះ ត្រូវធានាដល់ប្រជាពលរដ្ឋគ្រប់រូបនូវ «សិទ្ធិ និង ឱកាស(...) បោះឆ្នោត និង ត្រូវបានបោះឆ្នោតជ្រើសរើសនៅក្នុង ការបោះឆ្នោតដែលមានកាលកំណត់ពិតប្រាកដ ដែលគួរជាការបោះឆ្នោតប្រកបដោយភាពជាសកលនិងតម្លាភាព ហើយនឹងត្រូវបានធ្វើឡើងដោយការបោះឆ្នោតជាសម្ងាត់ ដើម្បីធានាឲ្យបាននូវការបញ្ចេញឆន្ទះដោយសេរីរបស់អ្នកបោះឆ្នោតទាំងអស់» (មាត្រា២៥ នៃកតិកាសញ្ញានេះ)[71]។ គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិបានផ្តល់នូវគោលការណ៍ណែនាំទៅលើការបកស្រាយមាត្រានេះ។ ដោយបានបញ្ជាក់ថានាឆ្នាំ១៩៩៦៖ «រដ្ឋជាសមាជិកត្រូវតែប្រើនូវរាល់វិធានការដ៏មានប្រសិទ្ធិភាពដើម្បីធានាឲ្យប្រាកដថា បុគ្គលគ្រប់រូបដែលទទួលបានសិទ្ធិបោះឆ្នោតអាចប្រើប្រាស់សិទ្ធិពួកគេបាន។ នៅពេលដែលអ្នកបោះឆ្នោតត្រូវបានតម្រូវឲ្យទៅធ្វើការចុះឈ្មោះពួកគាត់គួរតែទទួលបានការផ្តល់នូវភាពងាយស្រួលចំពោះការចុះឈ្មោះនេះ ដោយបញ្ចៀសនូវរាល់ ឧបសគ្គដែលអាចកើតមានផងដែរ[72]។» ត្រឹមចំណុចនេះនាំឲ្យអាចសន្និដ្ឋានបានថា ការសម្របសម្រួលទៅលើការចុះឈ្មោះអ្នកបោះឆ្នោត គឺជាកាតព្វកិច្ចដែលត្រូវបានដាក់ទៅលើរដ្ឋ។

ក្រមនៃការអនុវត្តន៍ល្អក្នុងការបោះឆ្នោត (Code of Good Practice in Electoral Matters) (១.២ បញ្ជីបោះឆ្នោត) ត្រូវបានទទួលយកដោយ គណៈកម្មការវេនេនីស[73] (Venice) ដែលបានដាក់ចេញ នូវលក្ខណៈ

---

[70] សមាគមនៃការបោះឆ្នោតជាផ្លូវការរបស់អឺរ៉ុប (ACEEEO) *ទ្រឹស្តី និងការអនុវត្តនៃការចុះឈ្មោះបោះឆ្នោត៖ និយមន័យ បទដ្ឋាន គោលការណ៍ និងឧទាហរណ៍* Budapest ឆ្នាំ២០០៩, បានទាញយកនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៣ ពី http://www.aceeeo.org/en/developing-accurate-voters/introductory-study-on-voters-registration

[71] ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិសម្រាប់ការការពារសិទ្ធិមនុស្ស *កតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ* ទីក្រុងញូវយ៉ក៖ ឆ្នាំ១៩៦៦ បានទាញយកនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៣ ពី http://www.ohchr.org/en/professionalinterest/pages/ccpr.aspx

[72] ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិសម្រាប់ការការពារសិទ្ធិមនុស្ស *សេចក្តីអធិប្បាយទូទៅ លេខ ២៥ សិទ្ធិក្នុងការចូលរួមក្នុងកិច្ចការសាធារណៈ សិទ្ធិបោះឆ្នោត និងសិទ្ធិស្មើភាពក្នុងការទទួលបាននូវសេវាសាធារណៈ* (មាត្រា ២៥) ទីក្រុងញូវយ៉កៈ៖ ឆ្នាំ១៩៦៦ បានទាញយកនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៣ ពី http://www.unhchr.ch/tbs/doc.nsf/0/d0b7f023e8d6d9898025651e004bc0eb

[73] នេះគួតែត្រូវបានកត់សម្គាល់ថា គណៈកម្មការវេននីស គឺជាស្ថាប័នបដិភាគរបស់ក្រុមប្រឹក្សាសហគមអឺរ៉ុប ។ គណៈកម្មការនេះមិនផ្សព្វផ្សាយអត្ថបទច្បាប់ដែលមានចំណងគតិយុត្តិនោះទេ ហើយលក្ខន្តិកៈដែលកំណត់ដោយក្រុមប្រឹក្សាអាចត្រូវបានមើលឃើញថាជាសូចនាករនៃការអនុវត្ត ឬបទដ្ឋានល្អ។ទោះបីជាយ៉ាងណាក៏ដោយ នេះគឺជាការកត់សម្គាល់មួយថាសូម្បីតែរដ្ឋជាសមាជិករបស់ក្រុមប្រឹក្សាអឺរ៉ុបក៏មិនតែងតែមានការបោះឆ្នោតដែលមានភាពយុត្តិធម៌ និងសេរីដែរ(ឧ.ប្រទេសរុស្ស៊ី ប្រទេសម៉ូដូវា និងប្រទេសអុយក្រែន)

វិនិច្ឆ័យសំខាន់ៗសម្រាប់ធ្វើឲ្យ បញ្ជីបោះឆ្នោតកាន់តែមានភាពជឿទុកចិត្តបាន[74]។ លក្ខណៈវិនិច្ឆ័យទាំងនេះ មានខ្លឹមសារដូចតទៅ:

- បញ្ជីបោះឆ្នោតត្រូវតែមានលក្ខណៈជាអចិន្ត្រៃយ៍និង ត្រូវផ្តល់នូវទិន្នន័យដែលថ្មីបំផុតជាទៀងទាត់ (យ៉ាងតិចមួយឆ្នាំម្តង)
- កាលបើអ្នកបោះឆ្នោតមិនទាន់ត្រូវបានចុះឈ្មោះដោយស្វ័យប្រវត្តិនោះ ការចុះឈ្មោះត្រូវធ្វើ ឡើងដោយមានរយៈពេលវែង ហើយចំពោះបញ្ជីបោះឆ្នោតទាំងនោះត្រូវធ្វើការបោះផ្សាយផង ដែរ
- នីតិវិធីរដ្ឋបាល ឬ នីតិវិធីតុលាការគួរតែបង្កើត ដោយអនុញ្ញាតឲ្យមានការចុះឈ្មោះបោះឆ្នោតដល់អ្នកដែលមិនទាន់បានចុះឈ្មោះ ក៏ដូចជាការផ្តល់នូវយន្តការធានាឲ្យបានថា ឈ្មោះដែលមិនត្រឹមត្រូវនៅលើបញ្ជីបោះឆ្នោត អាចធ្វើការកែប្រែបាន ហើយនិង
- ការចុះឈ្មោះបោះឆ្នោត មិនអាចធ្វើឡើងនៅមណ្ឌលបោះឆ្នោតនៅក្នុងថ្ងៃបោះឆ្នោតនោះឡើយ។

យោងទៅតាមសមាគមនៃការបោះឆ្នោតជាផ្លូវការរបស់អឺរ៉ុប (ACEEEO) តួនាទីដ៏សំខាន់របស់បញ្ជីបោះឆ្នោតគឺការពារទៅលើគោលការណ៍ចម្បងពីរនៃការបោះឆ្នោតប្រជាធិបតេយ្យ៖ គោលការណ៍នៃការបោះឆ្នោតជាសកល និងស្មើភាព ព្រមទាំងគោលការណ៍នៃការកំណត់អ្នកដែលមានសិទ្ធិបោះឆ្នោត។ (ACEEEO) បានបញ្ជាក់បន្ថែមទៀតថា «ទម្រង់បញ្ជីបោះឆ្នោតដែលស្របច្បាប់ត្រឹមត្រូវ និងមានលក្ខណៈពេញលេញគឺត្រូវកំណត់ច្បាស់លាស់ដោយច្បាប់។ នេះមិនទាន់គ្រប់គ្រាន់នៅឡើយក្នុងការអនុវត្តគោលការណ៍ និងបទដ្ឋានជាក់លាក់ណាមួយនោះទេ (ជាឧទាហរណ៍ដូចជា តម្រូវការទៅលើការចុះឈ្មោះបោះឆ្នោត) តែនេះក៏ផ្តោតជាសំខាន់ផងដែរក្នុងការតាក់តែងជាលម្អិតនូវនីតិវិធីទាំងមូលនៃការចុះឈ្មោះបោះឆ្នោត រួមបញ្ចូលទាំងករណី និងហេតុការណ៍ជាក់លាក់ដោយការគាំទ្រចំពោះក្រុមដែលងាយរងគ្រោះផងដែរ[75]។»

សេចក្តីអធិប្បាយទូទៅ (General Comment) លេខ២៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ (ICCPR) បានផ្តល់ជាអនុសាសន៍ថា នៅពេលដែលការទាមទារឲ្យមានការចុះឈ្មោះបោះឆ្នោត តម្រូវការលំនៅដ្ឋានគួរតែ «សមហេតុសមផល» និង «មិនគួរដាក់ឲ្យមានជាការដកហូតនូវសិទ្ធិបោះឆ្នោតចំពោះជនគ្មានលំនៅដ្ឋាននោះឡើយ[76]។» បន្ថែមពីលើនេះទៀត កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ បានកត់សំគាល់ថាយុទ្ធនាការចុះឈ្មោះ ចាំបាច់ក្នុងការធានាឲ្យ

---

[74] គណៈកម្មការអឺរ៉ុបសម្រាប់លទ្ធិប្រជាធិបតេយ្យតាមរយៈច្បាប់(គណៈកម្មការវេនីស Venice Commission) *ក្រមនៃការអនុវត្តល្អនៅក្នុងបញ្ហានៃការបោះឆ្នោត* ទីក្រុងវេនីស៖ ឆ្នាំ១៩៦៦ បានទាញយកនៅ ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៣ ពី http://www.venice.coe.int/webforms/documents/CDL-AD(2002)023rev.aspx

[75] សូមមើលសេចក្តីយោងលេខ ៦៤

[76] សូមមើលសេចក្តីយោងលេខ ៦៥

ប្រាកដថាបុគ្គលគ្រប់រូបទទួលបាននូវឱកាសដ៏យុត្តិធម៌ទៅលើការបញ្ចូលឈ្មោះទៅក្នុងបញ្ជីបោះឆ្នោត ហើយរដ្ឋក៏ត្រូវធានាលើបញ្ហានេះដែរ ។

បញ្ជីបោះឆ្នោត ឬសៀវភៅបោះឆ្នោតអាចកាន់តែយ៉ាប់យ៉ឺនទៅតាមពេលវេលា។ ទាំងនេះអាស្រ័យទៅលើភាពជាក់ស្ដែងនៃការស្លាប់របស់អ្នកបោះឆ្នោត ឬក៏ការប្រែក្លាយជាជនដែលគ្មានសិទ្ធិបោះឆ្នោត ឬការផ្លាស់ប្ដូរលំនៅដ្ឋានរបស់ពួកគាត់ ហើយអ្នកបោះឆ្នោតថ្មីប្រែក្លាយជាអ្នកដែលមានសិទ្ធិដើម្បីបូកបញ្ចូលទៅក្នុងបញ្ជី[77]។ ដើម្បីដោះស្រាយនូវភាពជាក់ស្ដែងទាំងនេះ សៀវភៅបោះឆ្នោតត្រូវតែផ្ដល់ឲ្យបាននូវទិន្នន័យដែលថ្មីបំផុត មុនត្រូវបានយកទៅប្រើប្រាស់នៅក្នុងដំណើរការបោះឆ្នោត។ ជាគោលការណ៍គំរូសំខាន់ពីរត្រូវបានប្រើប្រាស់ក្នុងការផ្ដល់នូវទិន្នន័យដែលថ្មីបំផុតនោះគឺៈ ការផ្ដល់ទិន្នន័យដែលថ្មីបំផុតតាមកាលកំណត់ និងការចុះឈ្មោះជាបន្ត។ ចំពោះករណីក្រោយមកទៀត បញ្ជីឈ្មោះត្រូវបានបើកឲ្យមានការផ្ដល់ទិន្នន័យដែលថ្មីបំផុតបានគ្រប់ពេលវេលា ហើយចំពោះការផ្ដល់ទិន្នន័យដែលថ្មីបំផុតតាមកាលកំណត់ គឺបញ្ជីឈ្មោះនឹងត្រូវធ្វើឲ្យមានការផ្ដល់ទិន្នន័យដែលថ្មីបំផុតជាធម្មតានៅមុនពេលបោះឆ្នោត[78]។

ការជ្រើសរើសយកប្រព័ន្ធមួយ ក្នុងចំណោមប្រព័ន្ធទាំងពីរគឺ ត្រូវតែបានប្រមើលមើលនៅក្នុងបរិបទនៃការអភិវឌ្ឍន៍របស់រចនាសម្ព័ន្ធរដ្ឋបាល នៅតាមបណ្ដាប្រទេសដែលបានពិភាក្សារៀងៗខ្លួន។ នៅក្នុងប្រទេសដែលមានប្រព័ន្ធដំណើរការល្អនៃ ការចុះបញ្ជីបណ្ដឹងរដ្ឋប្បវេណី ទិន្នន័យអាចត្រូវបានទាញយកពីប្រព័ន្ធនោះ ហើយដាក់បញ្ចូលជាមួយនឹងបញ្ជីបោះឆ្នោតដោយយោងទៅតាមគោលការណ៍ជាទៀងទាត់។ រាល់ការផ្លាស់ប្ដូរដែលជាប់ពាក់ព័ន្ធទាំងអស់ គឺត្រូវបានឆ្លុះបញ្ចាំងនៅក្នុងបញ្ជីឈ្មោះស៊ីវិលទាំងនេះគឺវាអាចសន្មតបានថា ជាធម្មតាបញ្ជីបោះឆ្នោតនឹងត្រូវមានគុណភាពល្អ[79]។ ទោះបីជាយ៉ាងណាក៏ដោយ សម្រាប់ប្រទេសដែលមិនមានបញ្ជីឈ្មោះស៊ីវិលត្រឹមត្រូវ ក៏នូវមានជម្រើសក្នុងការជ្រើសយកប្រព័ន្ធនៃការផ្ដល់ទិន្នន័យដែលថ្មីបំផុតតាមកាលកំណត់ ឬប្រព័ន្ធនៃការចុះឈ្មោះជាបន្ត។

បទពិសោធន៍ជាច្រើនពីបណ្ដាប្រទេសដែលត្រូវបានបង្ហាញពីប្រភេទ (ការកម្រិត) របស់ប្រព័ន្ធនៃការចុះឈ្មោះជាបន្ត ប្រហែលជាមិនសូវជាមានប្រសិទ្ធិភាពប៉ុន្មាននោះទេ។ ប្រព័ន្ធនេះត្រូវតែបានសន្មតថាប្រជាពលរដ្ឋមានការចាប់អារម្មណ៍ខ្លាំងឡើងទៅ ក្នុងការធានាថា ពួកគាត់មានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោតនៅពេលបោះឆ្នោត។ ពួកគេប្រហែលជាបរាជ័យក្នុងការជូនដំណឹងដល់ការចុះឈ្មោះ អំពីការផ្លាស់ប្ដូរដែលពាក់ព័ន្ធនៅក្នុងអំឡុងពេលនៃដំណាក់កាលចុះឈ្មោះ នៅក្នុងឆ្នាំណាមួយ ហើយគ្រាន់តែធ្វើនៅមុនថ្ងៃបោះឆ្នោតតែប៉ុណ្ណោះ[80]។ អនុសាសន៍មួយចំនួនត្រូវបានលើកឡើងថា ប្រទេសកម្ពុជាគួរតែអនុម័តយកប្រព័ន្ធនៃការចុះឈ្មោះជាបន្ត[81]។ នៅក្នុងកំឡុងពេលដែល គ.ជ.ប បានស្វែងយល់អំពី អត្ថប្រយោជន៍

---

[77] មូលនិធិអន្តរជាតិសម្រាប់ប្រព័ន្ធបោះឆ្នោត (IFES), *Civil and Voter Registries: Lessons Learned from Global Experiences*, edited by Michael Yard នៅខែមិថុនា ឆ្នាំ ២០១១ ហៅកាត់ថា (IFES) ២០១១

[78] តាមសេចក្ដីយោងខាងលើ (Ibid)

[79] តាមសេចក្ដីយោងខាងលើ (Ibid) ទំព័រទី១៧

[80] តាមសេចក្ដីយោងខាងលើ (Ibid) ទំព័រទី២២ និង២៣

[81] អ្នករាយការណ៍ពិសេស ទំព័រទី១៦ អនុសាសនិលេខ ៧៤

ដែលនាំមកតាមរយៈប្រព័ន្ធនេះ ហើយដោយបានប្រកាន់យកនូវគោលគំនិតថា ប្រព័ន្ធនេះ គឺមានការពឹងផ្អែកទៅលើ ការបង្កើតជាមុននូវដំណើរការចុះឈ្មោះស៊ីវិល[82] ដែលត្រូវការពេលវេលាសមស្របដើម្បីបង្កើតឡើង។

## ១.ប្រទេសកម្ពុជា

នេះអាចជាការសន្មតបានថាបញ្ជីបោះឆ្នោតនៅប្រទេសមួយចំនួន មានបញ្ចូលនូវពត៌មានដែលមិនពិតមួយចំនួន បូករួមទាំងករណីបាត់ឈ្មោះកើតមានផងដែរ[83]។ ចំពោះករណីប្រទេសកម្ពុជា គ.ជ.ប បានរកឃើញថា «ប្រាំបួន(៩)ភាគរយ នៃអ្នកដែលបានចុះឈ្មោះហើយ មិនអាចត្រូវបានរកឃើញ។ បន្ថែមពីលើនេះទៀត គ.ជ.ប បានបញ្ជាក់ថា ដប់បី(១៣) ភាគរយនៃឈ្មោះដែលត្រូវបានដាក់បញ្ចូលគឺខុស។»[84] ការវិវត្តន៍នៃបញ្ជីបោះឆ្នោតនឹងជួយបង្កើននូវភាពជឿទុកចិត្តទៅលើនីតិវិធីប្រជាធិបតេយ្យនៅក្នុងប្រទេសកម្ពុជា។ នៅក្នុងផ្នែកនេះ ទិដ្ឋភាពមួយចំនួននៃការចុះឈ្មោះបោះឆ្នោត ដែលមានភាពជាប់ទាក់ទងទៅនឹងប្រទេសកម្ពុជា នឹងត្រូវចាត់ទុកជាផ្នែកសំខាន់ ហើយនឹងត្រូវដាក់សម្រាប់ធ្វើការប្រៀបធៀបជាមួយនឹងស្តង់ដារ ដែលត្រូវបានកំណត់ដោយអង្គការអន្តរជាតិ និង ស្ថានភាពនយោបាយនៅក្នុងប្រទេសដទៃទៀត។

ក្នុងរយៈពេលនៃការចុះបោះឆ្នោត ប្រទេសកម្ពុជាបានអនុវត្តនូវ ប្រព័ន្ធទាំងពីរបញ្ចូលគ្នា ដែលបញ្ជីត្រូវបើកចំហក្នុងការផ្តល់នូវទិន្នន័យដែលថ្មីបំផុត ក្នុងពេលកំណត់ច្បាស់លាស់ជារៀងរាល់ឆ្នាំ (ចាប់ពីថ្ងៃទី០១ ខែតុលា រហូតដល់ថ្ងៃទី៣១ ខែធ្នូ)[85] ហើយបន្ថែមពីលើនេះគឺ ការផ្តល់ទិន្នន័យដែលថ្មីបំផុតតាមរយៈការប្រកួតប្រជែងនៅក្នុងការបោះឆ្នោត។

ជាការប្រៀបធៀប នៅប្រទេសហ្វីលីពីន បន្ទាប់ពីអត្តសញ្ញាណត្រូវបានធ្វើការផ្ទៀងផ្ទាត់ ទិន្នន័យផ្ទាល់ខ្លួនត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធ[86] ដូចគ្នាផងដែរនឹងជីវសញ្ញាណ(Biometric database) ដែលរួមមាន៖ ការស្កេនម្រាមដៃកំណត់ត្រាទុកនូវលក្ខណៈពិសេសនៃផ្ទៃមុខ ឬផ្នែកជំនួសដទៃទៀតតាមលក្ខណៈឌីជីថល ឬក៏ការថតទុកនូវហត្ថលេខាតាមបែបអេឡិចត្រូនិច[87]។ ទិន្នន័យត្រូវបានបញ្ជូនទៅមជ្ឈមណ្ឌលទិន្នន័យកណ្តាលតាមរយៈ ស៊ីឌី សម្រាប់ដាក់បញ្ចូលនៅក្នុងប្រព័ន្ធកណ្តាល[88]។ យោងទៅ

---

[82] សេចក្តីសង្ខេបរបស់ គ.ជ.ប ទំព័រទី១៨

[83] តាមសេចក្តីយោងខាងលើ (Ibid)

[84] http://www.cambodiadaily.com/elections/nec-opens-hotlines-for-names-missing-from-voter-lists-36152/

[85] សូមមើលសេចក្តីយោងលេខ ៧៥ «បញ្ជីបោះឆ្នោតអចិន្ត្រៃយ៍» អាចមើលក្នុងសេចក្តីសង្ខេបរបស់ (គ.ជ.ប) ទំព័រទី៦ នឹងប្រៀបធៀបជាមួយមាត្រា ៤៩ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ (ចបតរ)

[86] គណៈកម្មការរៀបចំការឆ្នោត(COMELEC) *ច្បាប់សាធារណៈរដ្ឋ លេខ៨១៨៩ ច្បាប់ស្តីពី ការចុះឈ្មោះបោះឆ្នោតបន្ត មាត្រា ១០* បានទាញយកនៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៣ ពី http://www.comelec.gov.ph/?r=References/RelatedLaws/ElectionLaws/Registration

[87] សូមមើលសេចក្តីយោងលេខ ៧០ ទំព័រទី១០៩

[88] មាត្រា ២២ នៃច្បាប់សាធារណៈរដ្ឋ លេខ៨១៨៩

តាមផ្នត់គំនិតនេះ ប្រព័ន្ធចាប់យកទិន្នន័យ គឺត្រូវបានចាត់ទុកជា «ប្រព័ន្ធបញ្ចូល» ហើយទិន្នន័យកណ្ដាលជា «ប្រព័ន្ធនៃ កំណត់ត្រា»[89]។ ទិន្នន័យនឹងត្រូវបានប្រើនាពេលក្រោយក្នុងការបង្កើតបញ្ជីបោះ ឆ្នោតនៅថ្ងៃបោះឆ្នោត និងការបង្កើតអត្តសញ្ញាណប័ណ្ណរបស់អ្នកបោះឆ្នោតដែលបម្រើជាឯកសារសម្រាប់ការកំណត់អត្តសញ្ញាណ[90] នៅឯមណ្ឌលបោះឆ្នោត[91]។

អត្តសញ្ញាណប័ណ្ណត្រូវជាច្បាប់ដើម ហើយបានក្លាយជាឯកសារមួយក្នុង ចំណោមឯកសារកំណត់អត្តសញ្ញាណដែលគួរឲ្យជឿជាក់បំផុតនៅក្នុងប្រទេស។ លេខអត្តសញ្ញាណដែលមានតែមួយ[92] គឺផ្ដល់នូវប្រព័ន្ធដែលមានលក្ខណៈសន្តិសុខផងដែរ[93]។

នៅប្រទេសកម្ពុជាប្រភពជារួមនៃបញ្ហាត្រូវបានកើនទ្វេដងនៅក្នុងបញ្ជីបោះឆ្នោត។ ចំពោះផ្នែកបច្ចេកទេស នេះគួរតែកំណត់ជាមួយបច្ចេកទេសប្រៀបផ្ទឹមទិន្នន័យ ជាឧទាហរណ៍ដូចជា ការប្រៀបធៀបឈ្មោះទាំងអស់ ថ្ងៃខែ ឆ្នាំកំណើត និងទីកន្លែងស្នាក់នៅ ក្នុងទិន្នន័យជាមូលដ្ឋានផ្សេងៗ។ ប្រព័ន្ធពត៌មានវិទ្យាទំនើប ក៏អាចរកឃើញនូវភាពស្រដៀងបំផុតជាច្រើននៅក្នុងករណីដែលឈ្មោះមិនស៊ីគ្នា ដោយពិតប្រាកដ (ឧទាហរណ៍ ដូចជាការប្រកបខ្វះតួអក្សរជាដើម)[94]។ បន្ថែមពីលើនេះ គណៈបក្សនយោបាយ សង្គមស៊ីវិល និងសាធារណៈជនទូទៅ គឺត្រូវបានប្រើប្រព័ន្ធនេះ ដើម្បីពិនិត្យពិច័យទៅលើទិន្នន័យក្នុងការធានានូវភាពត្រឹមត្រូវ។ ជាឧទាហរណ៍ មូលនិធិអន្តរជាតិសម្រាប់ប្រព័ន្ធបោះឆ្នោត (IFES) បញ្ជាក់ថា៖

> «ផ្នត់គំនិតគឺត្រូវមានយុទ្ធវិធីដែលអនុញ្ញាតឲ្យអ្នកដែលជាប់ពាក់ព័ន្ធអាច «ត្រួតពិនិត្យ» ទៅលើរាល់ការផ្លាស់ប្ដូរនៃការចុះឈ្មោះ។ នេះរួមបញ្ចូលទាំងការផលិតនូវរាល់របាយការណ៍ ដែលមានកាលកំណត់ដោយមានការបង្ហាញផងដែរចំពោះការបន្ថែម ការលុបចោលនិងការផ្លាស់ទាំងអស់ទៅលើបញ្ជីបោះឆ្នោត»[95]។ លើសពីនេះទៀត «សម្រាប់គោលបំណងនៃភាពច្បាស់ លាស់គឺមានសារៈសំខាន់ក្នុងការអនុញ្ញាតឲ្យមានការចូលទៅដល់ដោយទូលាយ ចំពោះ គណៈ បក្សនយោបាយ អង្គការសង្គមស៊ីវិល និងអ្នកបោះឆ្នោត ដើម្បីពិនិត្យពិច័យលើសៀវភៅបោះឆ្នោត»[96]។

---

[89] សូមមើលសេចក្ដីយោងលេខ ៧០ ទំព័រទី១១៣

[90] ពាក្យដែលប្រសើរជាងនេះគឺនឹងគួរតែប្រើ ពាក្យ *«ការបញ្ជាក់ហត្ថលេខា»*

[91] មាត្រា ២៥ នៃច្បាប់សាធារណៈរដ្ឋ លេខ៨១៨៩

[92] លេខ អត្តសញ្ញាណប្រៀបធៀបនឹង ការកត់សំគាល់ពត៌មានអ្នកបោះឆ្នោត(VIN) RA 8189(សូមមើលសេចក្ដីយោងលេខ ៧៨) មាត្រា ២៦

[93] សូមមើលសេចក្ដីយោងលេខ ៧០ ទំព័រទី១១១

[94] ប្រៀបធៀបជាមួយមូលនិធិអន្តរជាតិសម្រាប់ប្រព័ន្ធបោះឆ្នោត (IFES) ២០១១ ទំព័រទី២៥ ការផ្គូរផ្គងប្រហែល «រួមនូវការបូកបញ្ចូលរួមមាន៖ ឈ្មោះចុងក្រោយដូចគ្នា អក្សរដំបូងនិង ថ្ងៃខែឆ្នាំកំណើត ឈ្មោះនិងឆ្នាំកំណើតដូចគ្នា ឬក៏ត្រកូលបញ្ច្រាសជាមួយឈ្មោះ ហើយថ្ងៃ ខែ ឆ្នាំកំណើតដូចគ្នា ទាំងអស់នេះអាចត្រូវបានរកឃើញនូវច្បាប់ចម្លងដែលមានមន្ទិលសង្ស័យមួយចំនួនដូចជា អ្នកបោះឆ្នោតជាញឹកញាប់បង្កើតឲ្យមានការផ្លាស់ប្ដូរបន្តិចបន្តួចទៅលើពត៌មាន ដែលពួកគេផ្ដល់ឲ្យនៅពេលចុះឈ្មោះ ច្រើនដង»

[95] សូមមើលសេចក្ដីយោងលេខ ៧០ ទំព័រទី១៩

[96] តាមសេចក្ដីយោងខាងលើ (Ibid) ទំព័រទី១៥

យន្តការដើម្បីបញ្ជាក់ថាប្រជាពលរដ្ឋមិនត្រូវបានដកហូតសេរីភាពក្នុងកំឡុងពេលនៃដំណើរការបោះឆ្នោត គឺតាមរយៈការបោះផ្សាយនូវបញ្ជីបោះឆ្នោតសម្រាប់សាធារណៈជនធ្វើការពិនិត្យឡើងវិញ ហើយក៏ដើម្បីអនុញ្ញាតឲ្យអ្នកបោះឆ្នោត ធ្វើការត្រួតពិនិត្យលើទិន្នន័យរបស់ពួកគេ ដូចនឹងសៀវភៅបោះឆ្នោតរបស់ប្រទេសកម្ពុជា ក៏ត្រូវបានចាត់ទុកថាមានលក្ខណៈជាអចិន្ត្រៃយ៍[97]។ ហើយការពិនិត្យឡើងវិញ ព្រមទាំងធ្វើការចុះឈ្មោះបោះឆ្នោត និងការផ្តល់សុពលភាពទៅលើសៀវភៅបោះឆ្នោត គឺត្រូវធ្វើឡើងចាប់ពីថ្ងៃទី១ ខែតុលា ដល់ ថ្ងៃទី៣១ ខែធ្នូ ជារៀងរាល់ឆ្នាំ។ ទោះបីជាយ៉ាងណាក៏ដោយ ដូចនឹងបទពិសោធន៍នៅក្នុងបណ្តាប្រទេសដទៃ បានផ្តល់ជាយោបល់ថា ជនដែលជាប់ពាក់ព័ន្ធមួយចំនួនគិតចង់ធ្វើឲ្យមានការផ្តល់ទិន្នន័យដ៏ថ្មីបំផុតចំពោះពត៌មាននៃការបោះឆ្នោតរបស់ពួកគេ នៅក្រៅកំឡុងពេលបោះឆ្នោត ហើយនេះប្រហែលជាមិនមែនជាមធ្យោបាយដ៏មានប្រសិទ្ធភាព ក្នុងការពង្រឹងនូវភាពត្រឹមត្រូវនៃបញ្ជីបោះឆ្នោតនោះទេ។

នៅក្នុងការប្រកួតប្រជែងនៃការបោះឆ្នោតរបស់ប្រទេសកម្ពុជា យន្តការបន្ថែមត្រូវអនុវត្ត។ គ.ជ.ប បានផ្តល់នូវការជូនដំណឹងអំពីពត៌មានរបស់អ្នកបោះឆ្នោត (VIN) ទៅប្រជាពលរដ្ឋទាំងអស់ដែលមានក្នុងបញ្ជីបោះឆ្នោតជាផ្លូវការឆ្នាំ២០១២។ សម្រាប់ការបោះឆ្នោតនាឆ្នាំ២០១៣នេះ ត្រូវបានធ្វើពីថ្ងៃទី ០១ ដល់ថ្ងៃទី២៥ ខែមិថុនា តាមរយៈគណៈកម្មការរៀបចំការបោះឆ្នោត ឃុំ/សង្កាត់ (គឃ/សប) នៅក្នុងកិច្ចសហប្រតិបត្តិការជាមួយនឹងអាជ្ញាធរតាមតំបន់[98]។ លើសពីនេះទៀត (ជាបឋម) បញ្ជីបោះឆ្នោតត្រូវបានបោះផ្សាយ ក្នុងរយៈពេល ៣០ថ្ងៃមុនថ្ងៃបោះឆ្នោតនៅឯគណៈកម្មការរៀបចំការបោះឆ្នោត ឃុំ/សង្កាត់ (គឃ/សប) និង ១ថ្ងៃមុនថ្ងៃបោះឆ្នោតនៅឯមណ្ឌលបោះឆ្នោតនីមួយៗ។ គ.ជ.ប ក៏បានផ្តល់នូវ ខ្សែទូរស័ព្ទជាបន្ទាន់ចំនួនប្រាំខ្សែ ដែលអាចឲ្យអ្នកបោះឆ្នោតអាច ប្រើក្នុងការពិនិត្យទិន្នន័យរបស់ពួកគេ។

នៅក្នុងប្រទេសកម្ពុជា ប្រជាពលរដ្ឋត្រូវមានឯកសារមួយចំនួនដែលអាចយកទៅបង្ហាញ ដើម្បីធ្វើឲ្យឈ្មោះរបស់ពួកគេបានបញ្ចូលទៅក្នុងបញ្ជីបោះឆ្នោត ហើយឯកសារដែល ត្រូវបានប្រើជាញឹកញាប់នោះគឺ អត្តសញ្ញាណប័ណ្ណ និងលិខិតឆ្លងដែន[99]។ ទោះបីជា មានគម្រោង មួយចំនួនត្រូវបានបង្កើតនៅក្នុងប្រទេសកម្ពុជាសម្រាប់ការផ្តល់នូវអត្តសញ្ញាណប័ណ្ណចំពោះជនដែលគ្រប់អាយុតាមផ្លូវច្បាប់ទាំងអស់ ដោយហេតុថាមានប្រជាពលរដ្ឋខ្មែរមួយចំនួនធំ ដែលនៅមិនទាន់បានកាន់កាប់នូវអត្តសញ្ញាណប័ណ្ណដែលខ្លួនគួរតែមាននៅឡើយនោះទេ។

ចំពោះស្ថានភាពទាំងនេះ មូលនិធិអន្តរជាតិសម្រាប់ប្រព័ន្ធបោះឆ្នោត (IFES) បានបញ្ជាក់ថា នេះគឺជា «ការបង្កើតនូវទម្រង់ជារូម ចំពោះការកំណត់អត្តសញ្ញាណដោយសំបុត្របញ្ជាក់ ដែលធ្វើឡើងដោយអាជ្ញាធរតាមតំបន់ ឬអ្នកជិតខាងម្នាក់ ឬច្រើននាក់ អាចចុះហត្ថលេខាលើសំបុត្រភស្តុតាង ការបញ្ជាក់ពីទោសវិន័យចំពោះការផ្តល់សក្ខីភាពទុច្ចរិត ក្នុងការកំណត់អត្តសញ្ញាណរបស់បុគ្គលដែលត្រូវ

[97] តាមសេចក្តីយោងខាងលើ (Ibid)

[98] សូមមើលសេចក្តីយោងលេខ ៧៥ ទំព័រទី៥

[99] ប្រៀបធៀបជាមួយ មាត្រា៥៤ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ (ចបតរ)

បានចោទជាសំណួរ[100]។ ទោះបីជាយ៉ាងនេះក៏ដោយ នេះគឺត្រូវបានតាមមកជាមួយនូវការព្រមានគឺៈ «ហានិភ័យនៃការការពារគឺ ប្រហែលជាអាចទៅរួចសម្រាប់បុគ្គលមួយក្រុមតូច ដែលបានបញ្ចូលនូវការកើនឡើងនៃការបោះឆ្នោតជាមួយនឹងការសន្មតនូវចំនួនអ្នកបោះឆ្នោត[101]។

ប្រទេសកម្ពុជាបានដើរតាមគំរូនៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ (ច.ប.ត.រ) មាត្រា៥៤ B ដោយបញ្ជាក់ «ប្រជាពលរដ្ឋ ដែលមកបង្ហាញខ្លួន អាចកំណត់អត្តសញ្ញាណរបស់ខ្លួនបានដោយការធានាអះអាងរបស់អ្នកមានសិទ្ធិបោះឆ្នោតពីររូបក្នុងឃុំ/សង្កាត់ នោះធ្វើឡើងនៅចំពោះមុខមេឃុំ/ចៅសង្កាត់ ឬចំពោះមុខជំទប់ ចៅសង្កាត់រង (ក្នុងករណីដែល មេឃុំ/ចៅសង្កាត់អវត្តមាន) ដោយបញ្ជាក់ថាអ្នកសុំចុះឈ្មោះនោះ ពិតជាមនុស្សដូចដែលសាមីខ្លួនបានបញ្ជាក់អះអាងពិតប្រាកដមែន។»[102] នៅក្នុងពេលអតីតកាល វិញ្ញាប័ណ្ណប័ត្រ គឺសំដៅទៅលើខ្លឹមសារខាងលើ ដែលត្រូវបានទទួលស្គាល់ក្នុងទម្រង់លិខិត ១០១៨។

នៅក្នុងការបោះឆ្នោតពីមុន ប្រជាពលរដ្ឋមួយចំនួនធំដែលមិនបានកាន់កាប់អត្តសញ្ញាណប័ណ្ណត្រូវតែពឹងផ្អែកលើ ទម្រង់លិខិត១០១៨។ ទោះបីជាយ៉ាងណាក៏ដោយ ការអនុវត្តន៍ជាក់ស្តែងបានផ្តល់អញ្ញត្រកម្មដល់ មេឃុំ /ចៅសង្កាត់ ជាមួយសេរីភាពថាគួរផ្តល់ ឬមិនផ្តល់ទម្រង់លិខិតនេះ។ នេះបានធ្វើឲ្យទម្រង់លិខិតក្លាយទៅជាមុខសញ្ញាសម្រាប់ការរិះគន់ទៅវិញ[103]។ គ.ជ.ប និងក្រសួងមហាផ្ទៃមានការឆ្លើយតប ទៅនឹងការរិៈគន់តាមរយៈសេចក្តីណែនាំដែលធ្វើឡើងនាថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១១ ដែលទម្រង់លិខិត ១០១៨ ត្រូវបានជំនួសដោយ «វិញ្ញាប័ណ្ណប័ត្រនៃការកំណត់អត្តសញ្ញាណ» (CoI)[104]។ ការការពារប្រឆាំង និងការបន្លំបោកប្រាស «វិញ្ញាប័ណ្ណប័ត្រនៃការកំណត់អត្តសញ្ញាណ» (CoI) គឺត្រូវចេញដោយ មានភ្ជាប់ជាមួយនូវលេខសំគាល់ ហើយនឹងភ្ជាប់ជាមួយរូបថតរបស់អ្នកដាក់ពាក្យ ស្នើសុំ[105]។ ទោះបីជាយ៉ាងនេះ ក៏នៅមានចំណុចមួយចំនួនដែលទាមទារឲ្យមាននូវយន្តការដោះស្រាយបន្ថែមដើម្បីធ្វើឲ្យប្រព័ន្ធបោះឆ្នោតនេះកាន់តែមានប្រសិទ្ធភាព តាមរយៈការជំរុញបន្ថែមឲ្យមានការចូលរួមពីមេឃុំ/ចៅសង្កាត់ដែលមានសមត្ថកិច្ចដើម្បីបំពេញនូវចន្លោះខ្វះខាតលើការត្រួតពិនិត្យចំពោះការរំលោភបំពាន និងពង្រឹងបន្ថែមទៅលើប្រព័ន្ធនៃការចុះឈ្មោះបោះឆ្នោតរបស់ប្រទេសកម្ពុជា[106]។ ជាមធ្យោបាយមួយផងដែរ ការណែនាំនូវប្រព័ន្ធជីវសញ្ញាណ(biometric) ក៏អាចចាត់ទុកជាយន្តការមួយក្នុងការធានានូវភាព

---

[100] មាត្រា៦៤ នៃច្បាប់ដែលបានរៀបរាប់ខាងលើ

[101] សូមមើលសេចក្តីយោងលេខ ៧០ ទំព័រទី១៨

[102] មាត្រា ៦៤ និងមាត្រាបន្តបន្ទាប់ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ

[103] បណ្តាញអាស៊ីសម្រាប់ការបោះឆ្នោតដោយសេរី នៃកម្ពុជា(ANFREL Cambodia) ទំព័រទី៤០ រហូតដល់ ៥៦ និងរបាយការណ៍របស់មជ្ឈមណ្ឌល សិទ្ធិមនុស្សកម្ពុជា(CCHR) ទំព័រទី១៥ និងទំព័របន្តបន្ទាប់

[104] សូមមើលសេចក្តីយោងលេខ ៧៥ ទំព័រទី១៩

[105] គណៈកម្មការរៀបចំការបោះឆ្នោត(COMFREL) ទំព័រទី១៩ ហើយនឹងសេចក្តីសង្ខេបរបស់ គ.ជ.ប ទំព័រទី១៩

[106] ជាឧទាហរណ៍សំណួរដែលត្រូវបានលើកឡើង នៅពេលដែលពត៌មានត្រូវបានផ្តល់ដោយគ.ជ.ប ២៧០ ០០០ *«វិញ្ញាប័ណប័ត្រនៃការកំណត់អត្តសញ្ញាណ» (CoI) ត្រូវបានដាក់ចេញចន្លោះពេលនៃការបញ្ចប់នៃការចុះឈ្មោះ បោះឆ្នោត និងថ្ងៃនៃការបោះឆ្នោត* (http://www.cambodiadaily.com/elections/questions-raised-over-forms-used-for-voters-with-no-id-41437/ Cambodia daily of 30 August 2013)

ត្រឹមត្រូវនៃអត្តសញ្ញាណប័ណ្ណរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូបដែលអាចជួយដោះ ស្រាយនូវស្ថានភាពបែបនេះ[107]។

នៅក្នុងប្រទេសកម្ពុជា មានភាពមិនសមស្របមួយចំនួននៅក្នុងបញ្ជីបោះឆ្នោត ដែលអាចសំដៅទៅលើការប្រកបឈ្មោះខុស។ នៅពេលដែលទិន្នន័យ ត្រូវបានផ្លាស់ប្តូរ រវាងរដ្ឋាភិបាលគ្រប់ជាន់ថ្នាក់ និងភ្នាក់ងារផ្សេងៗ ជាឧទាហរណ៍ ពីកម្រិតឃុំ/សង្កាត់ ទៅ **គ.ជ.ប** បញ្ហានេះអាចកាន់តែដុនដាប ប្រសិនបើនីតិវិធីសម្រាប់ការផ្លាស់ប្តូរទិន្នន័យ រួមបញ្ចូលទាំងកំហុស ដែលអាចកើតមាននិងធ្វើឲ្យបិតបេរយូរអង្វែងនៅពេលដែលទិន្នន័យត្រូវបានបញ្ជូនរវាង ទីភ្នាក់ងាររដ្ឋាភិបាលទាំងនោះ។ នៅក្នុងប្រទេសកម្ពុជា ឈ្មោះនៃអ្នកបោះឆ្នោតត្រូវបានកត់សម្គាល់នៅកម្រិតតំបន់ ដោយការសរសេរដោយដៃ បញ្ជូនបន្តទៅស្ថាប័នកុំព្យូទ័ររបស់ **គ.ជ.ប** ហើយក៏ជាកន្លែងដែលទិន្នន័យត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធពត៌មានវិទ្យា។ កំឡុងពេលនៃដំណើរការនេះ កំហុសដែលមិនអាចគេចវេសបាន នឹងអាចកើតមានឡើង ដោយយោងទៅលើភាពមិនអាចបកស្រាយបានទៅលើការសរសេរដោយដៃរបស់ មេឃុំ/ចៅសង្កាត់ ឬក៏កំហុសឆ្គងរបស់ពួកគេនៅពេលបញ្ចូលទិន្នន័យ[108]។ ក្នុងករណីការប្រកបឈ្មោះមិនត្រឹមត្រូវនៅក្នុងបញ្ជីបោះឆ្នោតចុងក្រោយ ហើយបានបន្សល់ទុកនូវឆន្ទានុសិទ្ធិដល់គណៈកម្មការនៃ មណ្ឌលបោះឆ្នោត ដើម្បីត្រួតពិនិត្យថាបុគ្គលនេះអាចបោះឆ្នោតបានឬអត់។ ភាពពិតជាក់ស្តែង នេះបានបន្សល់ទុកនូវចន្លោះ ប្រហោងសម្រាប់ឆន្ទានុសិទ្ធិ ដែលប្រហែលជាប្រើទៅលើការបំពារបំពាន[109]។

## ២. ប្រទេសបារាំង

### ២.១. ការចុះឈ្មោះបោះឆ្នោត

ដើម្បីអាចបោះឆ្នោតបាន អ្នកបោះឆ្នោតត្រូវតែធ្វើការចុះឈ្មោះនៅក្នុងបញ្ជីបោះឆ្នោត។ តាមរយៈការប្រើប្រាស់នូវបញ្ជីឈ្មោះស៊ីវិល ដែលមានរួមបញ្ចូលជាមួយ ថ្ងៃខែឆ្នាំកំណើត និងអាសយដ្ឋាននៃលំនៅដ្ឋានរបស់ប្រជាពលរដ្ឋបារាំងម្នាក់ៗ ដែលការចុះឈ្មោះបោះឆ្នោត ត្រូវបានអនុវត្តដោយស្វ័យប្រវត្តិ ចំពោះបុគ្គលដែលមានអាយុពីដប់ប្រាំបី(១៨)ឆ្នាំ ហើយមានឈ្មោះនៅក្នុងបញ្ជីឈ្មោះស៊ីវិល[110]។ ប្រសិនបើបុគ្គលណាម្នាក់ស័គ្រចិត្តដាក់បញ្ចូលឈ្មោះរបស់គាត់ចូលទៅក្នុងបញ្ជីបោះឆ្នោត គឺចាំបាច់ត្រូវតែមានអាយុចាប់ពីដប់ប្រាំបី(១៨)ឆ្នាំមុនពេលកាន់កាប់សន្លឹកឆ្នោតដំបូងរបស់ខ្លួន ហើយនឹងចាំបាច់ជា ប្រជា-ពលរដ្ឋបារាំង (ក្នុងករណីប្រជាពលរដ្ឋរបស់សហគមន៍អឺរ៉ុបដែលមានលំនៅដ្ឋាននៅក្នុងប្រទេសបារាំង

---

[107] ប្រទេសកម្ពុជាធ្លាប់មានបទពិសោធន៍រួចមកហើយជាមួយនឹងបច្ចេកវិទ្យាដែលចាំបាច់ក្នុងការអនុវត្តនេះ។ សូមមើលទំព័រទី ៩៣ខាងក្រោមនៃឯកសារស្រាវជ្រាវនេះ។

[108] សូមមើលសេចក្តីយោងលេខ ៩៨ ទំព័រទី២០

[109] ក្នុងករណីធ្ងន់ធ្ងរជាងនេះ អាចនាំទៅរកបទល្មើសបន្លំ

[110] គេហទំព័រជាផ្លូវការរបស់ក្រសួងមហាផ្ទៃនៃប្រទេសបារាំង ត្រូវបានទាញយកនៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៣ ពី http://www.interieur.gouv.fr/Elections/Comment-voter/L-inscription-sur-les-listes-electorales

អាចចុះឈ្មោះបាននៅក្នុង «បញ្ជីបន្ថែម» ហើយគ្រាន់តែអាចចូលរួមក្នុងការបោះឆ្នោតជ្រើសរើស ក្រុម-ប្រឹក្សាក្រុង និង/ឬ ការបោះឆ្នោតរបស់សហគមន៍អឺរ៉ុបទាំងមូល)[111]។ ទីតាំងនៃការចុះបញ្ជីអាចជា៖

- សាលាក្រុងនៃក្រុងរបស់អ្នកស្នើសុំ ដែលជាកម្មវត្ថុនៃពន្ធក្នុងស្រុក សម្រាប់រយៈពេលយ៉ាងតិចប្រាំ(៥)ឆ្នាំ
- សាលាក្រុងនៃលំនៅដ្ឋានដោយមានបញ្ជាក់ថាអ្នកស្នើសុំរូបនេះ បានស្នាក់នូវអស់រយៈពេល យ៉ាងតិចប្រាំមួយ(៦)ខែបន្តជាប់ៗគ្នា ឬ
- សាលាក្រុងនៃក្រុងរបស់អ្នកស្នើសុំ ដែលជាកម្មវត្ថុនៃលំនៅដ្ឋានដោយការចាំបាច់ ក្នុងនាមជាមន្ត្រីសាធារណៈ[112]។

ដើម្បីអាចបំពេញ គ្រប់លក្ខខណ្ឌនៃការចុះឈ្មោះបោះឆ្នោត អ្នកស្នើសុំចាំបាច់ត្រូវផ្តល់ដល់មន្ត្រីសាធារណៈនៃសាលាក្រុង នូវរាល់ឯកសារដែលទាមទារ តាមរយៈប្រៃសណីយ៍ ដោយតាមបុគ្គល ឬក៏តាមប្រព័ន្ធអេឡិចត្រូនិច (ការប្រើប្រាស់នូវ ទំព័រដើមដែលដាក់ជូនសាធារណៈជន ដែលអាចប្រើប្រាស់បាននាពេលថ្មីៗនេះ នៅតាមបណ្តារដ្ឋចំនួន ពីរពាន់(២០០០))[113]។ ជាគោលការណ៍ អ្នកបោះឆ្នោតត្រូវតែចុះឈ្មោះមុនបំណាច់ឆ្នាំនៃការចាប់ដំណើរការបោះឆ្នោត (មុនថ្ងៃទី៣១ ខែធ្នូ)[114]។ ឯកសារដែលត្រូវយកទៅបង្ហាញរួមមាន អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន ព្រមទាំងត្រូវបង្ហាញនូវលិខិត ដែលបញ្ជាក់អំពីអាសយដ្ឋាន ឬក៏ទីកន្លែងស្នាក់នៅ[115]។ ទម្រង់បែបបទស្នើសុំសម្រាប់ការចុះឈ្មោះបោះឆ្នោត អាចទាញយកបាននៅលើបណ្តាញ[116]។

២.២. ដំណើរការនៃការបង្កើតបញ្ជីបោះឆ្នោត

វិទ្យាស្ថានជាតិសម្រាប់ការសិក្សាអំពីស្ថិតិនិងសេដ្ឋកិច្ច (INSEE) គឺទទួលខុសត្រូវលើការគ្រប់គ្រងចំពោះបញ្ជីបោះឆ្នោតជាទូទៅនៅក្នុងកម្រិតថ្នាក់ជាតិ តាមរយៈស្ថាប័នតាមតំបន់របស់ខ្លួន។ នេះគឺជាចំណុចសំអាងសម្រាប់ ការត្រួតពិនិត្យទៅលើបញ្ជីបោះឆ្នោត ដែលបានចូលរួមគ្រប់គ្រងដោយ ក្រុង និង វិទ្យាស្ថានជាតិសម្រាប់ការសិក្សាអំពីស្ថិតិនិងសេដ្ឋកិច្ច (INSEE)។ ក្រុងបញ្ជូនពត៌មាន ទៅឲ្យវិទ្យាស្ថានជាតិសម្រាប់ការសិក្សាអំពីស្ថិតិនិងសេដ្ឋកិច្ច (INSEE) សម្រាប់អ្នកបានស្នើសុំចុះឈ្មោះ ឬក៏ត្រូវបានដកចេញពី បញ្ជីរបស់ពួកគេរួចទៅហើយនោះ។ ចំណែកឯវិទ្យាស្ថានជាតិសម្រាប់ការសិក្សាអំពីស្ថិតិ និង សេដ្ឋកិច្ច (INSEE) ក៏ទទួលខុសត្រូវក្នុងការបញ្ជូនទៅរាជធានីនូវពត៌មានដូចខាងក្រោម៖

---

[111] តាមសេចក្តីយោងខាងលើ (Ibid)

[112] តាមសេចក្តីយោងខាងលើ (Ibid)

[113] តាមសេចក្តីយោងខាងលើ (Ibid)

[114] តាមសេចក្តីយោងខាងលើ (Ibid)

[115] តាមសេចក្តីយោងខាងលើ (Ibid)

[116] តាមសេចក្តីយោងខាងលើ (Ibid)

ទម្រង់បែបបទស្នើសុំសម្រាប់ការដកចេញពីបញ្ជីឈ្មោះរបស់អ្នកដែលគ្រប់អាយុដប់ប្រាំបី(១៨)ឆ្នាំ បញ្ជីនៃអ្នកបោះឆ្នោតបារាំងដែលមានបំណងបោះឆ្នោតនៅបរទេស ពត៌មានដែលជាប់ពាក់ព័ន្ធនឹងការបាត់បង់សិទ្ធិពលរដ្ឋ។ ក្រុងនឹងបន្តបញ្ជូនពត៌មានដែលជាប់ពាក់ព័ន្ធនឹងសិទ្ធិប្រជាពលរដ្ឋ ទៅកាន់វិទ្យាស្ថានជាតិសម្រាប់ការសិក្សាអំពីស្ថិតិនិងសេដ្ឋកិច្ច (INSEE)។ ទិន្នន័យទាំងនេះគឺទាមទារឲ្យបង្កើតនូវបញ្ជីឈ្មោះនៃការកំណត់អត្តសញ្ញាណជាតិរបស់រូបវន្តបុគ្គល (*“Répertoire national d'identification des personnes physiques”*) ហើយបង្កើតឲ្យមានជាស្ថិតិលម្អិតដូចជា សិទ្ធិទទួលបានការបោះឆ្នោត និងទីកន្លែងណា ដែលពួកគេអាចបោះឆ្នោតបាន។ សហប្រតិបត្តិការរវាង ក្រុង និង វិទ្យាស្ថានជាតិសម្រាប់ការសិក្សាអំពីស្ថិតិនិងសេដ្ឋកិច្ច (INSEE) គឺដើម្បីធានាឲ្យបាននូវការចុះឈ្មោះជារួមតែមួយ ទៅក្នុងបញ្ជីបោះឆ្នោត ហើយក៏ដើម្បីបញ្ចៀសនូវការចេញជា កាតបោះឆ្នោតច្រើន។ ការបង្កើតឲ្យមាន បញ្ជីបោះឆ្នោតគឺជាទំនួលខុសត្រូវរបស់ថ្នាក់ក្រុង។

វិទ្យាស្ថានជាតិសម្រាប់ការសិក្សាអំពីស្ថិតិនិងសេដ្ឋកិច្ច (INSEE) សម្រេចលើទម្រង់បែបបទស្នើសុំចុះឈ្មោះដែលដាក់នៅសាលាក្រុង។ នេះអាចកំណត់បានថា ទម្រង់បែបបទស្នើសុំណាអាចទទួលបានការចុះឈ្មោះដោយស្វ័យប្រវត្តិ (ជាឧទាហរណ៍ បញ្ជីឈ្មោះរបស់ជនដែលមានអាយុគ្រប់ដប់ប្រាំបីឡើង (១៨) ឆ្នាំ ដែលត្រូវបានផ្តល់ដោយ វិទ្យាស្ថានជាតិសម្រាប់ការសិក្សាអំពីស្ថិតិនិងសេដ្ឋកិច្ច (INSEE) អ្នកបោះឆ្នោតដែលបានដកចេញពីបញ្ជីដែលផ្តល់ដោយវិទ្យាស្ថានជាតិសម្រាប់ការសិក្សាអំពីស្ថិតិនិង សេដ្ឋកិច្ច(INSEE)[117] ព្រមទាំងការកំណត់ដែលបានបញ្ជាក់ថាអ្នកបោះឆ្នោតបានចុះឈ្មោះជាន់ស្ទួន។ វិទ្យាស្ថានជាតិសម្រាប់ការសិក្សាអំពីស្ថិតិនិងសេដ្ឋកិច្ច (INSEE) មានសមត្ថកិច្ចក្នុងការសម្រេចថាតើគួរឬមិនគួរ បង្កើតឲ្យមានការផ្លាស់ប្តូរនៅក្នុងបញ្ជី ហើយនៅក្នុងករណីដែលទំនាស់រវាងអ្នកស្នើសុំកើតមានប្រហែលជាត្រូវ ប្តឹងឧទ្ធរណ៍ទៅតុលាការ (*“juged’instance”)*[118]។

## ២.៣. យន្តការដើម្បីធានានូវភាពត្រឹមត្រូវនៃបញ្ជីបោះឆ្នោត

គណៈកម្មការរដ្ឋបាលមានសិទ្ធិអំណាចក្នុងការរៀបចំ និងកែប្រែទៅលើបញ្ជីបោះឆ្នោតសម្រាប់មណ្ឌលបោះឆ្នោតនីមួយៗនៅតាមក្រុង[119]។ បញ្ជីនេះគឺជា កម្មវត្ថុសម្រាប់ការត្រួតពិនិត្យឡើងវិញជាប្រចាំដោយគណៈកម្មការរដ្ឋបាល។ បញ្ជីឈ្មោះអ្នកបោះឆ្នោតរួមមានពីរប្រភេទគឺ បញ្ជីបោះឆ្នោតសម្រាប់ប្រជាពលរដ្ឋ បារាំង (*“liste électorale”*) និងបញ្ជីបោះឆ្នោតដទៃទៀតសម្រាប់ការបោះឆ្នោតតាមតំបន់ និងរបស់សហគមន៍អឺរ៉ុប ដោយប្រជាពលរដ្ឋដែលមិនមែនជា ប្រជាពលរដ្ឋបារាំង តែជាប្រជាពលរដ្ឋនៃរដ្ឋ

---

[117] វិទ្យាស្ថានជាតិសម្រាប់ការសិក្សាអំពីស្ថិតិនិងសេដ្ឋកិច្ច (INSEE) http://www.insee.fr/en/

[118] តាមសេចក្តីយោងខាងលើ (Ibid)

[119] មាត្រា L.១៧ នៃក្រមបោះឆ្នោត «កថាខណ្ឌទី១៖ មណ្ឌលបោះឆ្នោតនីមួយៗ គឺត្រូវបានចាត់តាំងទៅតាមតំបន់នៃទីតាំងភូមិសាស្ត្រ។ កថាខណ្ឌទី២៖ បញ្ជីនៃបោះឆ្នោតរបស់មណ្ឌលបោះឆ្នោតនីមួយៗ ត្រូវបានបង្កើតឡើងដោយគណៈកម្មការរដ្ឋបាលនៃមណ្ឌលបោះឆ្នោត ទាំងនេះរៀងខ្លួនៗ ហើយសមាសភាពរួមមាន ចៅហ្វាយក្រុង ឬក៏អ្នកតំណាងរបស់គាត់ អ្នកតំណាងរដ្ឋបាលដែលតែងតាំងដោយចៅហ្វាយខេត្ត ឬក៏ចៅហ្វាយខេត្តរង និងសមាជិកមួយរូបទៀតត្រូវបានតែងតាំងដោយ ប្រធាននៃសាលាដំបូង»។

ជាសមាជិកណាមួយរបស់សហគមន៍អឺរ៉ុប ប៉ុន្តែមានទីលំនៅនៅក្នុងប្រទេសបារាំង[120]។ អ្នកបោះឆ្នោតមិនអាចចុះឈ្មោះ ក្នុងបញ្ជីទាំងពីរនាពេលដំណាលគ្នាបាននោះទេ។ សេវារបស់សាលាក្រុងគឺទទួលខុសត្រូវលើការទទួលយកនូវទម្រង់បែបបទ ដោយមិនមានសិទ្ធិអំណាចក្នុងការបដិសេធ ចំពោះទម្រង់បែបបទសម្រាប់ការចុះឈ្មោះបោះឆ្នោតនោះឡើយ។ អំណាចនេះគឺជា សិទ្ធិអំណាចផ្ដាច់មុខរបស់គណៈកម្មការរដ្ឋបាល។ ការិយាល័យនៃក្រុងត្រូវផ្ញើទម្រង់លិខិតចុះឈ្មោះបោះឆ្នោតទៅគណៈកម្មាធិការរដ្ឋបាលដូចនេះ អាចធានាបានថាអ្នកស្នើសុំចុះឈ្មោះបោះឆ្នោតអាចបំពេញនូវរាល់លក្ខខណ្ឌនៃការចុះឈ្មោះបោះឆ្នោតបាន។ ចំពោះករណីនៃការចុះឈ្មោះបោះឆ្នោតដោយស្វ័យប្រវត្តិ គណៈកម្មាធិការត្រួតពិនិត្យឡើងវិញទៅលើការចុះឈ្មោះបោះឆ្នោតនេះដោយពឹងផ្អែកលើបញ្ជីដែលរៀបរៀងដោយវិទ្យាស្ថានជាតិសម្រាប់ការសិក្សាអំពីស្ថិតិនិងសេដ្ឋកិច្ច (INSEE)។ គណៈកម្មការអាចដកចេញនូវអ្នក បោះឆ្នោតពីបញ្ជីប្រសិនបើពួកគេមិនបានបំពេញនូវគ្រប់លក្ខខ័ណ្ឌដែលបានកំណត់[121]។

ក) តារាងបន្ថែម និងលុបចោល (ដែលអាចហៅម្យ៉ាងទៀតបានថាជា តារាងកែតម្រូវនាថ្ងៃទី១០ ខែមករា *“10 January Modification Table” or “Tableau rectificatif du 10 janvier”*)

គណៈកម្មការរដ្ឋបាលគួរតែបង្កើតនូវ សេចក្តីថ្លែងការណ៍នៃការផ្លាស់ប្តូរដែលកើតមានឡើងចំពោះបញ្ជីបោះឆ្នោត (គិតចាប់ពីថ្ងៃទី០១ ដល់០៩ ខែមករា)។ តារាងនេះផ្ទុកទៅដោយអ្នកបោះឆ្នោតថ្មីៗនិងអ្នកដែលបានត្រូវបានដកឈ្មោះចេញហើយនោះ។ បន្ទាប់មកតារាងគឺត្រូវបានបំពេញដោយ រដ្ឋលេខាដ្ឋានរបស់សាលាក្រុងនាថ្ងៃទី១០ ខែមករា និងបិទប្រកាសក្នុងរយៈពេលដប់(១០)ថ្ងៃ[122]។

ខ) តារាងកែតម្រូវចុងក្រោយ (*“Tableau définitif des rectifications”*)

តារាងកែតម្រូវចុងក្រោយត្រូវបានបង្កើតឡើងនៅថ្ងៃចុងក្រោយនៃខែកុម្ភៈជារៀងរាល់ឆ្នាំ។ តារាងនេះត្រូវ មានរួមបញ្ចូលនូវការកែតម្រូវទាំងអស់ដែលបានធ្វើចាប់តាំងពីថ្ងៃទី១០ ខែមករានាឆ្នាំជាមួយគ្នា។ ហើយតារាងនេះក៏ នឹងត្រូវបញ្ចូលទិន្នន័យជាមួយបញ្ជីបោះឆ្នោតជាទូទៅ ដោយសាលាក្រុង ហើយផ្ញើទៅអភិបាលខេត្ត[123]។

គ) បញ្ជីបោះឆ្នោតចុងក្រោយ

ថ្ងៃចុងក្រោយនៃខែកុម្ភៈនាឆ្នាំដដែល បញ្ជីបោះឆ្នោតចុងក្រោយរបស់មណ្ឌលបោះឆ្នោតនីមួយៗគឺត្រូវបានបង្កើតឡើងដោយគណៈកម្មការរដ្ឋបាល[124]។ នៅក្នុងក្រុង ដែលមានមណ្ឌលបោះ- ឆ្នោតច្រើន

[120] Ministerial Circular NOR/INTA 1317573C of 25 July 2013 on the revision and maintenance of voter lists and additional voter list (*Circulaire ministérielle NOR/INTA 1317573C du 25 juillet 2013 relative à la révision et à la tenue des listes électorales et des listes électorales complémentaires*).

[121] មាត្រា L.២៣ នៃក្រមបោះឆ្នោត

[122] Ministerial Circular NOR/INTA 1317573C of 25 July 2013 on the revision and maintenance of voter lists and additional voter list, Annex 1.

[123] សូមមើលសារាចរដែលរៀបរាប់ខាងលើ

[124] សូមមើលសារាចរដែលរៀបរាប់ខាងលើ

បញ្ជីឈ្មោះជាទូទៅរបស់ឃុំត្រូវបានបង្កើតឡើងដោយគណៈកម្មការរដ្ឋបាលកណ្តាល[125]។ បញ្ជីបោះឆ្នោតថ្មីត្រូវបានតាក់តែងឡើងដោយបញ្ជីបោះឆ្នោតពីមុន ដែលប្លុករួមទាំងការធ្វើវិសោធនកម្មលើតារាងបន្ថែមនិងលុបចោល ជាមួយនឹងតារាងកែតម្រូវចុងក្រោយផងដែរ។ ការថតចំលងនៃបញ្ជីបោះឆ្នោតចុងក្រោយត្រូវបានបញ្ជូនទៅអភិបាលខេត្តដោយអភិបាលក្រុង។ ការច្របាច់បញ្ចូលគ្នានៃបញ្ជីបោះឆ្នោតទាំងនេះ ត្រូវបានធ្វើជារៀងរាល់៣(បី) ឬ ៥(ប្រាំ)ឆ្នាំម្តងដែលបញ្ជីនៃតំបន់នីមួយៗត្រូវបានប្លុក បញ្ចូលគ្នាហើយអ្នកបោះឆ្នោតដែលបានធ្វើនូវលេខសំគាល់អត្តសញ្ញាណនៃការបោះឆ្នោតថ្មី ដោយសំអាងថាពួកគេមានឈ្មោះនៅក្នុងបញ្ជីថ្មី។ នេះត្រូវបានធ្វើជាធម្មតាដើម្បីធានាថា រាល់បញ្ជីបោះឆ្នោតទាំងអស់មានភាពស្រុះស្រួលគ្នានៅទូទាំងប្រទេស។ បន្ទាប់ពីការបង្កើតនូវបញ្ជីបោះឆ្នោតចុងក្រោយបំផុតរួចមក កាតបោះឆ្នោតនឹងត្រូវផ្ញើទៅអ្នកបោះឆ្នោតទាំងអស់។ ក្នុងកំឡុងពេលនៃការបោះឆ្នោតបញ្ជី នៃសេចក្តីពន្យល់ដែលរួមមានច្បាប់ចំលងនៃបញ្ជីបោះឆ្នោតត្រូវបានប្រើសម្រាប់ការចុះហត្ថលេខាដោយ អ្នកបោះឆ្នោតនៅមណ្ឌលបោះឆ្នោត។

## ២.៤. ការដែលសាធារណៈទទួលបានពត៌មានអំពីបញ្ជីបោះឆ្នោត

យោងទៅតាមមាត្រា L.២៨ នៃក្រមបោះឆ្នោតបារាំងបានបញ្ជាក់ថា៖ «រាល់អ្នកបោះឆ្នោត បេក្ខជននិងគណបក្សនយោបាយណាមួយ ឬក៏ក្រុម មានសិទ្ធិចូលទៅកាន់ ឬក៏ថតចំលងនូវបញ្ជីបោះឆ្នោត[126]។ សិទ្ធិនេះមិនត្រូវបានដាក់កម្រិត ទៅលើការចុះឈ្មោះអ្នកបោះឆ្នោតនៅក្នុងក្រុងនោះឡើយ។ ចំពោះការស្បថចូលកាន់តំណែងគឺទាមទារឲ្យមានការចុះហត្ថលេខាពាក្យសម្បថដែលអ្នកប្រើប្រាស់ប្តេជ្ញាមិនប្រើប្រាស់បញ្ជីទាំងនេះសម្រាប់ផលប្រយោជន៍ស្វនតួនោះទេ។ ការចូលទៅកាន់បញ្ជីបោះឆ្នោតគឺប្រហែលជាតាមរយៈ «នៅនឹងកន្លែង“on the spot” » ដែលជាការចូលទៅកាន់ដោយសេរី ដោយការផ្តល់ជាសន្លឹកឯកសារថតចំលង ឬក៏ការថតចំលងដោយសេរីតាមរយៈអ៊ីម៉ែល។ តំលៃសេវានៃការផ្តល់ឲ្យនេះត្រូវគិតដោយផ្អែកទៅលើអ្វីដែលបានកំណត់ដោយបទបញ្ជារបស់ នាយករដ្ឋមន្ត្រី។

## ២.៥. ការបោះឆ្នោតនៅមណ្ឌលផ្សេងទៀតដែលខុសពីទីកន្លែងចុះឈ្មោះបោះឆ្នោត

ដោយសំអាងទៅលើសៀវភៅបោះឆ្នោតរបស់ប្រទេសបារាំង ដែលត្រូវបានចែករំលែក និងចូលទៅកាន់មណ្ឌលបោះឆ្នោតនីមួយៗនោះ អ្នកបោះឆ្នោតរបស់ប្រទេសបារាំង អាចប្រើប្រាស់មណ្ឌលបោះឆ្នោតនៅក្នុងតំបន់នីមួយៗដោយមិនចាំបាច់មានការរៀបចំជាមុននោះទេ។

---

[125] គណៈកម្មការ ធ្វើការសម្រេចទៅលើទម្រង់បែបបទនៃការស្នើសុំសម្រាប់ការចុះឈ្មោះបោះឆ្នោតដែលត្រូវបានដាក់ ជូននៅឯសាលាក្រុង។ គណកម្មការ ធ្វើការសម្រេចលើទម្រង់បែបបទនៃការស្នើសុំសម្រាប់ការចុះឈ្មោះបោះឆ្នោតដោយស្វ័យប្រវត្តិ(បញ្ជីនៃយុវជនដែលគ្រប់ អាយុដប់ប្រាំបី (១៨) ឆ្នាំដែលបានផ្តល់ដោយ វិទ្យាស្ថានជាតិសម្រាប់ ការសិក្សាអំពីស្ថិតិនិងសេដ្ឋកិច្ច (INSEE)) ហើយនឹងសម្រេចទៅលើ ទម្រង់របស់អ្នកដែលនឹងត្រូវធ្វើការលុបចេញពីបញ្ជី

[126] មាត្រា L.២៨ នៃក្រមបោះឆ្នោត រដ្ឋាភិបាលរបស់ប្រទេសបារាំង

២.៦. ភស្តុតាងក្នុងបញ្ជាក់ពីអត្តសញ្ញាណដែលត្រូវការក្នុងការបោះឆ្នោត

អ្នកបោះឆ្នោតម្នាក់ៗត្រូវបានផ្ញើឲ្យនូវ កាតបោះឆ្នោតមុនពេលបោះឆ្នោត ដែលពួកគេអាចប្រើ-ប្រាស់ ជាការកំណត់អត្តសញ្ញាណដើម្បីអាចបោះឆ្នោតបាន។ អ្នកបោះឆ្នោតប្រហែលជានឹងប្រើផងដែរនូវរូបថតដែល អាចកំណត់អំពីអត្តសញ្ញាណ និងទទួលស្គាល់ដោយច្បាប់[127]។

## ៣. ប្រទេសកូរ៉េខាងត្បូង

### ៣.១. ការចុះឈ្មោះបោះឆ្នោត

នាចុងឆ្នាំ ២០១២ គណៈកម្មការជាតិរៀបចំការបោះឆ្នោតរបស់ប្រទេសកូរ៉េខាងត្បូង (គ.ជ.ប) បានធ្វើការណែនាំស្តីពី «បញ្ជីបោះឆ្នោតដែលបានដាក់បញ្ចូលគ្នា integrated electoral register »។ ប្រព័ន្ធនៃការចុះឈ្មោះបោះឆ្នោតដោយស្វ័យប្រវត្តិ និងបង្កើតបញ្ជីបោះឆ្នោតដោយផ្អែកទៅលើកំណត់ ត្រាតាមប្រព័ន្ធឌីជីថលពីរដ្ឋាភិបាលថ្នាក់តំបន់ ទិន្នន័យនៃការបោះឆ្នោតពីមុនមក និងភ្នាក់ងារនានាដែលទទួលបន្ទុកក្នុងកត់ត្រានូវការកើត ការស្លាប់ និងការរៀបការជាដើម។ នេះអាចអនុញ្ញាតឲ្យ(គ.ជ.ប) រក្សាលំនឹងចំពោះការធ្វើឲ្យមាននូវការផ្តល់ពត៌មានដែលថ្មីបំផុតចំពោះបញ្ជីបោះឆ្នោតដែលបានឆ្លងកាត់នូវឯកសារ យោងដោយមានភ្ជាប់ជាមួយពត៌មានផ្សេងៗ ជាមួយនឹងប្រភពដទៃទៀតសម្រាប់អភិវឌ្ឍភាពត្រឹមត្រូវដោយជៀសវាងនូវ ការជាន់គ្នានៃទិន្នន័យ ឫ ភាពមិនត្រឹមត្រូវដោយការដាក់បញ្ចូលឈ្មោះអ្នកដែលបានចែកឋានរូចទៅហើយនោះ។ លើសពីនេះទៅទៀតពត៌មាននេះក៏បង្កើតឲ្យមានបញ្ជីបោះឆ្នោតមួយដែលត្រូវបានចែករំលែកដល់គ្រប់មណ្ឌលបោះឆ្នោតទូទាំងប្រទេសកូរ៉េខាងត្បូងហើយដែលអាចអនុញ្ញាត ឲ្យបុគ្គលទៅបោះឆ្នោតទៅតាមតំបន់ដោយមិនចាំបាច់ធ្វើឲ្យមានការរៀបចំជាមុន ហើយក៏បានរួមបញ្ចូលផងដែរនូវ លេខនៃលក្ខណៈពិសេសប្រើសម្រាប់កាត់បន្ថយចំពោះការអនុវត្តការបោះឆ្នោតខុសច្បាប់។ ជាចុងក្រោយ ជាបញ្ជីបោះឆ្នោតត្រូវបានអនុវត្តដោយស្វ័យប្រវត្តិ គឺមានន័យថា បុគ្គលដែលមានសិទ្ធិបោះឆ្នោតគឺត្រូវបានចុះឈ្មោះបោះឆ្នោតដោយស្វ័យប្រវត្តិតែម្តង ហើយមិនចាំបាច់តម្រូវឲ្យពួកគេធ្វើសកម្មភាពណាមួយឡើយ[128]។

---

[127] *ប័ណ្ណបោះឆ្នោត*(Carte Électorale) រដ្ឋាភិបាលបារាំង ឆ្នាំ២០១២ បានទាញយកនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៣ ពី http://vosdroits.service-public.fr/particuliers/F1962.xhtml#OuSAd

[128] គណៈកម្មការជាតិរៀបចំការបោះឆ្នោតនៃសាធារណរដ្ឋកូរ៉េ (គ.ជ.ប) ២០០៩ *ការបង្ហាញអំពីនយោបាយ និងប្រព័ន្ធ បោះឆ្នោតរបស់ប្រទេសកូរ៉េខាងត្បូង* ទំព័រទី៦៨ គណៈកម្មការជាតិរៀបចំការបោះឆ្នោតនៃសារធារណរដ្ឋកូរ៉េ (គ.ជ.ប)២០១៣ *សំណួរនិងចំលើយពាក់ព័ន្ធនឹងអ្នកអវត្តមាននៅពេលបោះឆ្នោត និងការរួមបញ្ចូលគ្នានៃបញ្ជីបោះឆ្នោត* បានទាញយកនៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៣ ពី http://www.nec.go.kr/engvote_2013/04_news/01_02.jsp?num=49&pg=1&col=&sw=

### ៣.២. ដំណើរការនៃការបង្កើតបញ្ជីបោះឆ្នោត

បញ្ជីបោះឆ្នោតត្រូវបានបង្កើតឡើងដោយមានកាលកំណត់ គឺមុនពេលបោះឆ្នោតនីមួយៗ ដោយប្រព័ន្ធស្វ័យប្រវត្តិរបស់កុំព្យូទ័រ[129]។ ទោះបីជាយ៉ាងណាក៏ដោយ ទិន្នន័យនៃការបោះឆ្នោត ដែលជាបង្អែករបស់បញ្ជីបោះឆ្នោតគឺត្រូវតែបន្តធ្វើឲ្យមានការផ្តល់ពត៌មានថ្មីបំផុត ដោយឆ្លងការយោងជាមួយទិន្នន័យដែលរដ្ឋាភិបាលសំអាងមួយចំនួនទៀតផង[130]។

### ៣.៣. យន្តការដើម្បីធានានូវភាពត្រឹមត្រូវនៃបញ្ជីបោះឆ្នោត

ដូចដែលអ្វីដែលបានបញ្ជាក់ពីខាងលើ បញ្ជីបោះឆ្នោតត្រូវបានពិនិត្យឆ្លងជាមួយនឹងទិន្នន័យរបស់រដ្ឋាភិបាល។ ពួកគេបានបង្កើតឲ្យមាន ការអង្កេតជាសាធារណៈ ដែលសេចក្តីលម្អិតមានដូចមានក្នុងចំណុចខាងក្រោម។

### ៣.៤. ការដែលសាធារណៈទទួលបានពត៌មានអំពីបញ្ជីបោះឆ្នោត

នៅពេលដែលបញ្ជីបោះឆ្នោតត្រូវបានបង្កើត ដោយតាមជាមួយនឹងការប្រកាសអំពីការបោះឆ្នោត អ្នកបោះឆ្នោតអាចត្រួតពិនិត្យឡើងវិញតាមប្រព័ន្ធបណ្តាញ ឬក៏បណ្តាការិយាល័យដែលបានចាត់តាំង។ អ្នកបោះឆ្នោតមានលទ្ធភាពធ្វើការរាយការណ៍អំពីភាពមិនត្រឹមត្រូវនៃបញ្ហាណាមួយ ទៅប្រធានគណៈ-កម្មការរៀបចំការបោះឆ្នោតតាមមូលដ្ឋាន។ ប្រសិនបើអ្នកបោះឆ្នោតមិនពេញចិត្តចំពោះ ការឆ្លើយតបរបស់គណៈកម្មការរៀបចំការបោះឆ្នោតតាមមូលដ្ឋានរបស់ពួកគេ ពួកគាត់អាចប្តឹងឧទ្ធរណ៍ទៅកាន់សមាជិកគណៈកម្មការរៀបចំការបោះឆ្នោតតាមតំបន់បន្តទៀតបាន[131]។

### ៣.៥. ការបោះឆ្នោតនៅមណ្ឌលផ្សេងទៀតដែលខុសពីទីកន្លែងចុះឈ្មោះបោះឆ្នោត

អ្នកបោះឆ្នោតអាចបោះឆ្នោតនៅមណ្ឌលបោះឆ្នោត ដែលបានចាត់តាំងជាមុន ពីចម្ងាយដោយមិនចាំបាច់មានការចុះឈ្មោះជាមុននោះទេ។ មណ្ឌលបោះឆ្នោតទាំងនេះ ស្រង់សន្លឹកឆ្នោតចេញពីបញ្ជីបោះ-ឆ្នោតគ្រប់ទីកន្លែងទូទាំងប្រទេស[132] ហើយបើកចំហក្នុងរយៈពេល មួយអាទិត្យមុនដើម្បីអាចឲ្យអ្នកដែលចូលរួមបានរាប់សំលេងរបស់ពួកគាត់[133]។

---

[129] គណៈកម្មការជាតិរៀបចំការបោះឆ្នោតនៃសាធារណរដ្ឋកូរ៉េ (គ.ជ.ប) ២០013 *FAQ: តើអ្វីគឺជា «សមាហរណកម្មបញ្ជីបោះឆ្នោត»?* បានទាញយកនៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៣ ពី http://www.nec.go.kr/engvote_2013/06_feedback/02_01.jsp. និងការបង្ហាញអំពីនយោបាយ និងប្រព័ន្ធបោះឆ្នោតរបស់ប្រទេសកូរ៉េខាងត្បូង ទំព័រទី៦៨

[130] *សំណួរ និងចំលើយពាក់ព័ន្ធនឹងការអវត្តមានក្នុងពេលបោះឆ្នោត និងការរួមបញ្ចូលគ្នានៃបញ្ជីបោះឆ្នោត*

[131] តាមសេចក្តីយោងខាងលើ (Ibid) ទំព័រទី៧០

[132] តាមសេចក្តីយោងខាងលើ (Ibid)

[133] *ការបង្ហាញអំពីនយោបាយ និងប្រព័ន្ធ បោះឆ្នោតរបស់ប្រទេសកូរ៉េខាងត្បូង* ទំព័រទី៩៩

៣.៦. ភស្តុតាងក្នុងបញ្ជាក់ពីអត្តសញ្ញាណដែលត្រូវការក្នុងការបោះឆ្នោត

អ្នកបោះឆ្នោតប្រហែលជាត្រូវប្រើអត្តសញ្ញាណប័ណ្ណ ឬក៏ចុះហត្ថលេខាបន្ទះអេឡិចត្រូនិច ជាមួយស្នាមមេដៃ ឬក៏ហត្ថលេខា[134]។

## ៤. ប្រទេសហ្វីលីពីន

៤.១. ការចុះឈ្មោះបោះឆ្នោត

អាស្រ័យដោយការបង្កើតនូវការចុះឈ្មោះថ្មីនាឆ្នាំ១៩៩៨ ការចុះឈ្មោះបោះឆ្នោតនៅក្នុងប្រទេសហ្វីលីពីនគឺត្រូវបានធ្វើតាមដំណើរការជាបន្តបន្ទាប់[135]។ ដែលជាការត្រួតពិនិត្យ ដោយគណៈកម្មការរៀបចំការបោះឆ្នោត(COMELEC) ក្រុមប្រឹក្សាភិបាលទទួលបន្ទុករៀបចំការបោះឆ្នោត (Election Management Board) ដែលត្រូវបានអនុវត្ត ដោយមន្ត្រីរៀបចំការបោះឆ្នោត ដោយចាត់ទុកជា «មន្ត្រីជាន់ខ្ពស់ ឬក៏អ្នកតំណាងស្របច្បាប់របស់គណៈកម្មការនៅតាមទីក្រុង ឬរាជធានី»[136]។ នេះគឺជា ការធ្វើសហប្រតិបត្តិការជាមួយ ក្រុមប្រឹក្សាភិបាលដែលទទួលបន្ទុក លើការចុះឈ្មោះបោះឆ្នោត ដែលមន្ត្រីបោះឆ្នោតគឺជាប្រធាន ហើយសមាជិកដទៃទៀតគឺសំដៅទៅលើ «មន្ត្រីសាធារណៈដែលភាគច្រើនជាអ្នកដែលមានតំណែងខ្ពស់ និង មន្ត្រីអគ្រានុកូលដ្ឋាន ឬក៏ក្នុងករណីអវត្តមានរបស់ពួកគេ ហេរញ្ញឹករបស់ទីក្រុងឬរាជធានី នឹងទទួលបន្ទុកជំនួស»[137]។

នៅក្នុងការអនុវត្តន៍ការចុះឈ្មោះបោះឆ្នោតត្រូវធ្វើឡើងនៅការិយាល័យដាក់បញ្ចូលទិន្នន័យ ដែលជាញឹកញយធ្វើជាមួយបុគ្គលពីររូបគឺ មន្ត្រីរៀបចំការបោះឆ្នោត និងជំនួយការ[138]។ មុនពេលដែលទិន្នន័យរបស់អ្នកស្នើសុំបានដាក់បញ្ចូលទៅក្នុងប្រព័ន្ធ គាត់ចាំបាច់ត្រូវតែបានកំណត់អត្តសញ្ញាណ។ ចំណុចខ្វះ-ខាតនៅត្រង់នេះគឺ «ការកំណត់អត្តសញ្ញាណមានការពឹងផ្អែកតែទៅលើ ការប្រគល់ជូននូវ អត្តសញ្ញាណស្របច្បាប់តែមួយមុខគត់»[139]។ នេះមិនអាចជាការជឿទុកចិត្តបានទាំងស្រុងនោះទេ ដោយសារថា អត្តសញ្ញាណប័ណ្ណក្លែងក្លាយមានចំនួនច្រើន ហើយដែលជាការងាយស្រួលនៅក្នុងប្រទេសហ្វីលីពីននោះ[140]។ នេះនឹងនាំមកនូវតម្រូវការ ចំពោះសំបុត្រកំណើតផងដែរ។

ទម្រង់បែបបទសម្រាប់ការចុះឈ្មោះបោះឆ្នោតណាមួយ នៅក្នុងសៀវភៅបោះឆ្នោត (ដូចជាការស្នើសុំនូវការកែតម្រូវទិន្នន័យ ឬក៏បញ្ជូនទិន្នន័យមួយទៅទីកន្លែងដទៃ) គឺចាំបាច់ត្រូវតែដាក់ជូនទៅមន្ត្រី

---

[134] សូមមើលសេចក្តីយោងលេខ ១២២

[135] សូមមើលសេចក្តីយោងលេខ៧០ ទំព័រទី១០២

[136] មាត្រា ៣ ចំណុច ក នៃច្បាប់សាធារណៈរដ្ឋ លេខ៨១៨៩

[137] មាត្រា ១៥ កថាខណ្ឌ ១ នៃច្បាប់ដែលបានរៀបរាប់ខាងលើ

[138] សូមមើលសេចក្តីយោងលេខ ៧០ ទំព័រទី១០៩

[139] តាមសេចក្តីយោងខាងលើ (Ibid) ទំព័រទី១០៧

[140] តាមសេចក្តីយោងខាងលើ (Ibid)

ទទួលបន្ទុកការបោះឆ្នោត ដែលជាអ្នកបញ្ជូនករណីនេះទៅ ក្រុមប្រឹក្សាភិបាលដែលទទួលបន្ទុករៀបចំការបោះឆ្នោត ហើយបន្ទាប់មកធ្វើការសម្រេច ដោយការបោះឆ្នោតយកមតិភាគច្រើន[141]។ ប្រសិនបើក្រុមប្រឹក្សាភិបាលសម្រេចអនុញ្ញាតលើ ការបន្ថែមអ្នកបោះឆ្នោតទៅក្នុងបញ្ជីបោះឆ្នោត មន្ត្រីដែលរៀបចំការបោះឆ្នោត ត្រូវបង្កើតលេខសំគាល់អត្តសញ្ញាណរបស់អ្នកបោះឆ្នោត ហើយចេញនូវកាតសំគាល់អត្តសញ្ញាណដល់ អ្នកបោះឆ្នោតដែលបានចុះឈ្មោះហើយ។ ទោះបីជាគោលការណ៍ នេះគឺជាដំណើរការបន្តបន្ទាប់ក៏ដោយ ក៏ការចុះឈ្មោះបោះឆ្នោតត្រូវបានបញ្ឈប់ «រយៈពេល១២០ (មួយរយម្ភៃ)ថ្ងៃ មុនពេលការបោះឆ្នោតជាទៀងទាត់ ហើយរយៈពេល៩០ (កៅសិប)ថ្ងៃ មុនការបោះឆ្នោតជាពិសេស»[142]។

៩.២. ដំណើរការនៃការបង្កើតបញ្ជីបោះឆ្នោត

ដោយស្ថិតនៅក្រោម ច្បាប់ស្តីពីការចុះឈ្មោះបោះឆ្នោតនាឆ្នាំ១៩៩៦ រដ្ឋាភិបាលបានចាប់ផ្តើមប្រមូលទិន្នន័យរបស់អ្នកបោះឆ្នោតនៅក្នុងឆ្នាំ១៩៩៨ ដើម្បីបង្កើតនូវបញ្ជីបោះឆ្នោតថ្មីមួយ[143]។

ទោះបីជាដែលទីភ្នាក់ងាររដ្ឋាភិបាលប្រទេសហ្វីលីពីន បានរក្សានូវចំនួន ទិន្នន័យសំខាន់ៗរបស់អ្នកចុះឈ្មោះបោះឆ្នោត ហើយដែលបូកបញ្ចូលផងដែរនូវ ទិន្នន័យរបស់ប្រជាពលរដ្ឋ សំខាន់មួយផ្នែកទិន្នន័យរបស់អ្នកបោះឆ្នោត មិនត្រូវបានទាញយកពីពត៌មាន ដែលមានស្រាប់ ប៉ុន្តែគឺជាជាងពីការបង្កើតថ្មីតែម្តង[144]។ ការប្រមូលទិន្នន័យត្រូវធ្វើឡើង នៅក្នុងអំឡុងពេលនៃដំណើរការចុះឈ្មោះបោះឆ្នោត។ បន្ថែមលើនេះ ទិន្នន័យនេះមិនអាចត្រូវបានប្រើទៅរួចនោះទេ ចំពោះទិន្នន័យ ដែលបានមកពីបញ្ជីឈ្មោះស៊ីវិលពីព្រោះទិន្នន័យនេះត្រូវបានចាត់ទុកជាឯកសាររូបភាពនៅក្នុងកុំព្យូទ័រ (ត្រូវស្កេននូវ សន្លឹកឯកសារនៃសំបុត្រកំណើត និងវិញ្ញាប័ណ្ណប័ត្រដទៃទៀត) ដែលមិនអាចទាញយកបានដើម្បីបម្រើសាធារណជន[145]។

៩.៣. យន្តការដើម្បីធានានូវភាពត្រឹមត្រូវនៃបញ្ជីបោះឆ្នោត

ទោះបីជាថាបញ្ជីបោះឆ្នោត ដែលធ្វើឡើងតាមប្រព័ន្ធកុំព្យូទ័រ អាចរក្សាទុកបានរយៈពេលយូរឆ្នាំ ប៉ុន្តែបញ្ហានៃអ្នកបោះឆ្នោតជំនួស និងការខ្វះទំនុកចិត្តនៅតែកើតមានដដែល[146]។ ដើម្បីអាចជំនះបាននូវបញ្ហាទាំងនេះ គណៈកម្មការរៀបចំការបោះឆ្នោត(COMELEC) បានចាប់ផ្តើមអនុវត្ត នូវប្រព័ន្ធសម្រាប់កំណាត់ពីសុពលភាពរបស់អ្នកបោះឆ្នោត (VVS)។ ប្រព័ន្ធនេះមានរួមបញ្ចូលនូវការផ្តិតមេដៃរបស់អ្នកបោះឆ្នោតដែលបោះឆ្នោតជាលើកដំបូង ការប្រមូលជីវសញ្ញាណ(Biometric database) របស់អ្នកដែលបានចុះឈ្មោះរួច ដោយបង្កើតឲ្យមានទិន្នន័យចំបងសម្រាប់ពឹងផ្អែកក្នុងការបង្កើតបញ្ជីបោះឆ្នោត[147]។ គម្រោងត្រូវបានបង្កើតឡើងសម្រាប់ការបន្ថែម ប្រព័ន្ធកំណាត់អត្តសញ្ញាណដោយការស្កេនម្រាមដៃជាស្វ័យប្រវត្តិ

---

[141] មាត្រា ២០ នៃច្បាប់សាធារណៈរដ្ឋ លេខ៨១៨៩

[142] មាត្រា ៨ នៃច្បាប់ដែលរៀបរាប់ខាងលើ

[143] មាត្រា ៧ នៃច្បាប់ដែលរៀបរាប់ខាងលើ

[144] សូមមើលសេចក្តីយោងលេខ ៧០ ទំព័រទី១០៦

[145] តាមសេចក្តីយោងខាងលើ Ibid) ទំព័រទី១២៣

[146] តាមសេចក្តីយោងខាងលើ (Ibid) ទំព័រទី១០៥

[147] តាមសេចក្តីយោងខាងលើ (Ibid)

(Automated Fingerprint Identification System) ដែលនឹងអនុញ្ញាតការលុបចោលនូវឈ្មោះ ស្ទួនគ្នាដែលបានបញ្ចូលទៅក្នុងបញ្ជីរួចទៅហើយនោះ។ ជាការពិត ដែលការសាកល្បងគម្រោង (Automated Fingerprint Identification System) បានធ្វើនៅឆ្នាំ២០១៣នេះក្នុងតំបន់មួយនៃប្រទេសហ្វីលីពីន ហើយបានរកឃើញថា ៧.៥(ប្រាំពីរចុចប្រាំ) ភាគរយ នៃអ្នកដែលបានចុះឈ្មោះហើយមានការស្ទួនគ្នា។ នៅថ្នាក់ជាតិ គឺភាគរយនេះអាចជាចំណុចសំខាន់ចំពោះលទ្ធផលបោះឆ្នោតដ៏តឹងរឹងបាន[148]។ ប្រព័ន្ធកំណត់អត្តសញ្ញាណម្រាមដៃដោយស្វ័យប្រវត្តិ (Automated Fingerprint Identification System) គឺជាវិធីដ៏មានប្រសិទ្ធិភាពមួយ ដែលអាចរកឃើញចំពោះឈ្មោះដែលស្ទួនគ្នា ឬជាការចុះឈ្មោះចំនួនច្រើនដង។

## ៤.៤. ការដែលសាធារណៈទទួលបានពត៌មានអំពីបញ្ជីបោះឆ្នោត

បញ្ជីបោះឆ្នោតរបស់ប្រទេសហ្វីលីពីនមិនត្រូវបានដាក់ជាសាធារណៈនោះទេ ប៉ុន្តែអាចអនុញ្ញាតឲ្យស្ថាប័នមិនមែនពាណិជ្ជកម្មធ្វើការស្នើសុំពី គណៈកម្មការរៀបចំការបោះឆ្នោត(COMELEC) សម្រាប់តម្លៃជាធម្មតា[149]។

## ៤.៥. ការបោះឆ្នោតនៅមណ្ឌលផ្សេងទៀតដែលខុសពីទីកន្លែងចុះឈ្មោះបោះឆ្នោត

ច្បាប់របស់ប្រទេសហ្វីលីពីនមិនផ្តល់ឲ្យមាន ការបោះឆ្នោតនៅមណ្ឌលបោះឆ្នោតខុសគ្នា ពីទីកន្លែងដែលពួកគាត់បានចុះឈ្មោះនោះទេ។ ផ្ទុយទៅវិញច្បាប់[150]បានបញ្ជាក់ច្បាស់ថា «បុគ្គលណាម្នាក់ដែលមានលំនៅដ្ឋានជាបណ្តោះអាសន្នក្នុងទីក្រុង រាជធានី ឬប្រទេសដទៃទៀត អាស្រ័យដោយហេតុផលតែមួយគត់ គឺជាប់ពាក់ព័ន្ធនឹងការងាររបស់គាត់(...) មិនគួរបាត់បង់លំនៅដ្ឋានដើមរបស់គាត់ឡើយ»។ ទោះបីជាយ៉ាងណាក៏ដោយអ្នកបោះឆ្នោត «ដែលបានផ្ទេរលំនៅទៅកាន់ទីក្រុង ផ្សេងត្រូវអនុវត្តតាមមន្ត្រីរៀបចំការបោះឆ្នោតនៅលំនៅដ្ឋានថ្មីរបស់គាត់ សម្រាប់ការផ្ទេរបាយការណ៍នៃការចុះឈ្មោះរបស់គាត់»[151]។

## ៤.៦. ភស្តុតាងក្នុងបញ្ជាក់ពីអត្តសញ្ញាណដែលត្រូវការក្នុងការបោះឆ្នោត

ទម្រង់នៃរូបថតសម្រាប់កំណត់អត្តសញ្ញាណដែលមានសុពលភាពត្រូវបានប្រើសម្រាប់ការបោះឆ្នោតនៅក្នុងប្រទេសហ្វីលីពីន។ ពុំមានខចែងដោយឡែកចំពោះបុគ្គលដែលកាន់កាប់អត្តសញ្ញាណប័ណ្ណគ្មានសុពលភាព អាចបោះឆ្នោតបានឡើយ[152]។

---

[148] តាមសេចក្តីយោងខាងលើ (Ibid) ទំព័រទី១២៣

[149] គណៈកម្មការរៀបចំការ បោះឆ្នោត(COMELEC) *សំណួរ និងចំលើយអំពីបញ្ជីបោះឆ្នោត* បានទាញយកនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៣ពី http://www.comelec.gov.ph/?r=faq/qnavl

[150] មាត្រា ៩ កថាខណ្ឌ ២ នៃច្បាប់សាធារណៈរដ្ឋ លេខ៨១៨៩

[151] មាត្រា ១២ នៃច្បាប់ដែលរៀបរាប់ខាងលើ

[152] សូមមើលសេចក្តីយោងលេខ ៧០ ទំព័រទី១០៧

## ៥. ប្រទេសឥណ្ឌូនេស៊ី

### ៥.១. ការចុះឈ្មោះបោះឆ្នោត

យោងទៅតាមច្បាប់បោះឆ្នោតថ្មី ការចុះឈ្មោះបោះឆ្នោតតាមកាលកំណត់ គឺពឹងផ្អែកទៅលើការផ្ទេរនូវ"ទិន្នន័យប្រជាជន"ពីកម្រិតរដ្ឋបាលផ្សេងៗគ្នា ទៅកាន់ស្ថាប័នគ្រប់គ្រងការបោះឆ្នោត[153]។ ទិន្នន័យនេះ រួមជាមួយនឹងទិន្នន័យនៃអ្នកបោះឆ្នោតពីក្រៅប្រទេសដែលត្រូវបានផ្តល់ឲ្យដោយក្រសួងការ បរទេស គឺរួមបញ្ចូលគ្នា ហើយក្លាយទៅជា «ទិន្នន័យប្រជាពលរដ្ឋអំពីអ្នកដែលអាចជាអ្នកបោះឆ្នោត»។ ដោយទិន្ន ន័យនេះនឹងត្រូវផ្ទៀងផ្ទាត់ដោយគណៈកម្មការរៀបចំការបោះឆ្នោត ជាមួយនឹងទិន្នន័យអ្នកបោះឆ្នោតដែលបន្សល់ទុកមកពីការបោះឆ្នោតអាណត្តិមុន ហើយនឹងត្រូវផ្តល់ទិន្នន័យដែលថ្មីបំផុតដោយមន្ត្រីសាធារណៈណាមួយដែលត្រូវបានចាត់តាំងឲ្យទទួលបន្ទុកទៅលើបញ្ហានេះ ដែលហៅថា ផេនតាលី(*Pantarlih*)[154] ។ ដំណើរការនេះត្រូវធ្វើឡើងក្នុងរយៈពេល១០ (ដប់) ខែមុនពេលបោះឆ្នោតផេនតាលី(*Pantarlih*) ហើយត្រូវតែត្រួតពិនិត្យទិន្នន័យជាមួយនឹង អ្នកដែលអាចក្លាយជាអ្នកបោះឆ្នោតទៅតាមដែនដី/រាជធានីនីមួយៗដោយឡែកពីគ្នា។ នៅពេលធ្វើការផ្តល់នូវទិន្នន័យថ្មីៗ ផេនតាលី(*Pantarlih*) និងប្រគល់ប័ណ្ណ(token)ទៅឲ្យអ្នកបោះឆ្នោតសម្រាប់ជាភស្តុតាងថាពួកគេបានចុះឈ្មោះបោះឆ្នោតរួចហើយ[155]។

### ៥.២. ដំណើរការនៃការបង្កើតបញ្ជីបោះឆ្នោត

ចំពោះបញ្ជីឈ្មោះបោះឆ្នោតប្រទេសឥណ្ឌូនេស៊ីគឺយកទៅតាមវិធីត្រួតពិនិត្យតាមសម័យកាល។ កាលពីមុនបញ្ជីឈ្មោះពីដើមគឺយោងតាមទិន្នន័យជំរឿនដែលថ្មីបំផុត។ ក៏ប៉ុន្តែ ដោយសារតែមានកំហុសឆ្គងច្រើនពេក និងការពិតដែលនេះជាកាតព្វកិច្ចរបស់អ្នកបោះឆ្នោត ក្នុងការបញ្ជាក់ថាឈ្មោះរបស់ពួកគេគឺស្ថិតនៅក្នុងបញ្ជីឈ្មោះបោះឆ្នោត នៅពេលប្រកួតប្រជែងការបោះឆ្នោតដែលជាហេតុនាំអោយរដ្ឋាភិបាលសម្រេចចិត្តធ្វើកាផ្លាស់ប្តូរនីតិវិធីនេះ[156]។ មូលហេតុចុងក្រោយគឺ នៅក្នុងការបោះឆ្នោតនីតិបញ្ញត្តិនាឆ្នាំ២០០៩ មានការរិះគន់យ៉ាងខ្លាំងទៅលើបញ្ជីបោះឆ្នោតដែលមានគុណភាពអន់ហើយថែមទាំងទទួលរងការគំរាមថាអាចនឹងខិតជិតទៅរកការបរាជ័យ[157]។ ដើម្បីដោះស្រាយនូវបញ្ហាទាំងអស់នេះ ច្បាប់នៃការ បោះឆ្នោតត្រូវបានធ្វើវិសោធនកម្ម ហើយរដ្ឋាភិបាលទើបនឹងបង្កើតនូវប្រពន្ធ័ធ្វើអត្តសញ្ញាណប័ណ្ណ

---

[153] មាត្រា ១ កថាខណ្ឌ ៦ នៃច្បាប់សាធារណៈរដ្ឋឥណ្ឌូនេស៊ី លេខ០៨ ឆ្នាំ២០១២ *«គណកម្មការជាតិរៀបចំការ បោះឆ្នោត ដោយក្នុងហៅថា KPU គឺជា ស្ថាប័នជាតិ អចិន្ត្រៃយ៍ នឹង ឯករាជ្យ ដែលទទួលបន្ទុក ក្នុងការអនុវត្តន៍ការបោះឆ្នោត»*

[154] មាត្រា ១ កថាខណ្ឌ ១៤ នៃច្បាប់ដែលរៀបរាប់ខាងលើ៖ *«មន្ត្រីផ្តល់នូវទិន្នន័យដែលថ្មីបំផុត នៃអ្នកបោះឆ្នោត នៅទីនេះត្រូវបានហៅថា ផេនតាលី(Pantarlih) គឺជាមន្ត្រី ដែលចាត់តាំងដោយ KPU ឬ PPLN ថ្នាក់ដែនដី និង ក្រុង ក្នុងការរៀបចំ នូវការប្រមូលទិន្នន័យថ្មីបំផុត នៃអ្នកបោះឆ្នោត»*

[155] មាត្រា ៣៤ នៃច្បាប់ដែលរៀបរាប់ខាងលើ

[156] សូមមើលសេចក្តីយោងលេខ ៣៣ ទំព័រទី ៤៧

[157] បណ្តាញអាស៊ីសម្រាប់ការបោះឆ្នោតដោយសេរី (ANFREAL ឥណ្ឌូនេស៊ី) ទំព័រទី ២៦

ជីវសញ្ញាណ (Biometric ID card) ដែលធំជាងគេលើពិភពលោក ដែលបានដាក់ឲ្យប្រើប្រាស់នៅឆ្នាំ២០១៤ ដើម្បីត្រួតពិនិត្យព័ត៌មានអ្នកបោះឆ្នោតឲ្យបានត្រឹមត្រូវ[158]។

## ៥.៣. យន្តការដើម្បីធានានូវភាពត្រឹមត្រូវនៃបញ្ជីឈ្មោះបោះឆ្នោត

ច្បាប់ចម្លងនៃបញ្ជីឈ្មោះបោះឆ្នោតបឋម ត្រូវបានផ្តល់ទៅឲ្យគណបក្សនយោបាយដែលឈរឈ្មោះបោះឆ្នោត។ ស្ថាប័នគ្រប់គ្រងការបោះឆ្នោតនៅថ្នាក់តំបន់ត្រូវធ្វើការវាយតំលៃនូវការដាក់បញ្ចូលពត៌មាន និងយោបល់ដែលទទួលបានក្នុងរយៈពេល១៤(ដប់បួន)ថ្ងៃ បន្ទាប់ពីការបញ្ចប់នៃការរយៈពេលបិទផ្សាយ ហើយបន្ទាប់មកត្រូវផ្សព្វផ្សាយនូវបញ្ជីឈ្មោះបោះឆ្នោតបឋមដែលបានកែតម្រូវរួចក្នុងរយៈពេលប្រាំពីរ(៧)ថ្ងៃផ្សេងទៀត ដោយក្នុងនោះអនុញ្ញាតឲ្យមានការផ្តល់យោបល់បន្ថែមដែលនឹងត្រូវបានកែតម្រូវតាមក្នុងរយៈពេល១៤ (ដប់បួន)ថ្ងៃបន្ទាប់ពីការបញ្ចប់នៃការបិទផ្សាយជាលើកទីពីរ។ បញ្ជីឈ្មោះបោះឆ្នោតដំបូងដែលកែតម្រូវរួចជាលើកទីពីរនេះនឹងត្រូវបានបញ្ជូនទៅកាន់អង្គការត្រួតពិនិត្យការបោះឆ្នោតថ្នាក់តំបន់ ជាអ្នកសម្រេចចុងក្រោយ ហើយបញ្ជីបោះឆ្នោតនោះនឹងក្លាយជាបញ្ជីឈ្មោះបោះឆ្នោតអចិន្ត្រៃយ៍តែម្តង។ អាជ្ញាធរតំបន់ ត្រូវតែបិទផ្សាយជាសាធារណៈនូវបញ្ជីឈ្មោះបោះឆ្នោតអចិន្ត្រៃយ៍ចាប់ពីពេលនេះ(ប្រហែល៦.៥ខែមុនការបោះឆ្នោត)រហូតដល់ថ្ងៃបោះឆ្នោត[159]។ ចំនុចនេះគឺបានផ្តល់រយៈពេលវែងសម្រាប់អ្នកបោះឆ្នោតក្នុងការត្រួតពិនិត្យការចុះឈ្មោះបោះឆ្នោត និងដើម្បីធានាថាទិន្នន័យដែលត្រឹមត្រូវរបស់អ្នកបោះឆ្នោតត្រូវបានបញ្ចូលរួចរាល់។

## ៥.៤. ការដែលសាធារណៈទទួលបានពត៌មានអំពីបញ្ជីបោះឆ្នោត

ដូចដែលបានរៀបរាប់ខាងលើ អាជ្ញាធរបោះឆ្នោតតាមតំបន់គឺតម្រូវឲ្យមានធ្វើការបិទផ្សាយជាសាធារណៈនូវការចុះឈ្មោះបោះឆ្នោតក្នុងរយៈពេល៦.៥ ខែមុនការបោះឆ្នោត។

## ៥.៥. ការបោះឆ្នោតនៅមណ្ឌលផ្សេងទៀតដែលខុសពីទីកន្លែងចុះឈ្មោះបោះឆ្នោត

នៅក្នុងប្រទេសឥណ្ឌូនេស៊ី លក្ខណៈពិសេសមួយដែលសម្របសម្រួលដល់ការចូលរួមនៃប្រជាពលរដ្ឋឥណ្ឌូនេស៊ីនៅពេលបោះឆ្នោតគឺ បញ្ជីឈ្មោះបោះឆ្នោតបន្ថែម។ នេះគឺជាបញ្ជីឈ្មោះពិសេសសម្រាប់អ្នកបោះឆ្នោត «ដែលបានចុះឈ្មោះបោះឆ្នោតនៅក្នុងបញ្ជីបោះឆ្នោតអចិន្ត្រៃយ៍នៅក្នុងមណ្ឌលបោះឆ្នោតណាមួយជាក់លាក់ (...) ប៉ុន្តែដោយសារហេតុផលណាមួយច្បាស់លាស់ អ្នកបោះឆ្នោតនោះមិនអាចធ្វើការបោះឆ្នោតនៅក្នុងមណ្ឌលបោះឆ្នោត(...) ដែលពួកគេបានចុះឈ្មោះ[160]»។ «ដើម្បីបាន បញ្ចូលទៅក្នុងការចុះឈ្មោះបោះឆ្នោតបន្ថែម ប្រជាពលរដ្ឋនោះត្រូវផ្តល់នូវភស្តុងតាងនៃអត្តសញ្ញាណផ្ទាល់ និងប័ណ្ណចុះឈ្មោះដែលបានផ្តល់អោយនៅពេលចុះឈ្មោះថាជាអ្នកបោះឆ្នោតនៅក្នុងការចុះ

---

[158] The Indonesia advances world's most ambitious biometric-based national identity card project, last retrieved on 2/06/2014 from: http://www.networkworld.com/news/2012/092012-indonesia-biometrics-262628.htm

[159] មាត្រា ៣៩ នៃច្បាប់សាធារណៈរដ្ឋឥណ្ឌូនេស៊ី លេខ០៨ ឆ្នាំ២០១២

[160] មាត្រា ៤០ កថាខណ្ឌទី ២ នៃច្បាប់ដែលរៀបរាប់ខាងលើ

ឈ្មោះបោះឆ្នោតអចិន្ត្រៃយ៍នៃមណ្ឌលបោះឆ្នោតដែលបានចាត់តាំងនោះ[161]។ អ្នកបោះឆ្នោតអាចត្រូវបានបញ្ចូលទៅក្នុងការចុះឈ្មោះបោះឆ្នោតបន្ថែម៣(បី)ថ្ងៃមុនថ្ងៃបោះឆ្នោត។ លក្ខណៈពិសេសនេះបានជួយសម្រួលយ៉ាងច្រើនដល់ការចូលរួមនៃអ្នកបោះឆ្នោតដែលបានចុះឈ្មោះនៅកន្លែងមួយ (ឧទាះ ទីកន្លែងដែលគ្រួសាររបស់ពួកគេរស់នៅ) ប៉ុន្តែធ្វើការ និងរស់នៅជាធម្មតានៅកន្លែងដទៃទៀត[162]។

៥.៦. ភស្តុតាងក្នុងបញ្ជាក់ពីអត្តសញ្ញាណដែលត្រូវការក្នុងការបោះឆ្នោត

ច្បាប់បោះឆ្នោតប្រទេសឥណ្ឌូនេស៊ីក៏បានផ្តល់នូវលទ្ធភាពដល់អ្នកចុះឈ្មោះបោះឆ្នោតណាដែលខ្វះនូវឯកសារអត្តសញ្ញាណជាផ្លូវការផងដែរ។ ប្រសិនបើឈ្មោះរបស់ពួកគេបានបាត់ចេញពីបញ្ជីនោះ ពួកគេអាចទាក់ទងទៅនឹងគណៈកម្មការរៀបចំការបោះឆ្នោតថ្នាក់ខេត្ត ដើម្បីធ្វើការចុះឈ្មោះ និងបញ្ចូលពួកគេទៅក្នុងបញ្ជីបោះឆ្នោតពិសេស។ ច្បាប់ពុំមានចែងអំពី ខណាមួយថាអ្វីដែលអាចចាត់ទុកថាជាភស្តុតាងដែលមានសុពលភាពសម្រាប់អ្នកបោះឆ្នោតអាចនឹងមានសិទ្ធិគ្រប់គ្រាន់ក្នុងការបញ្ចូលនៅក្នុងបញ្ជីឈ្មោះបោះឆ្នោតពិសេសនោះទេ[163]។ សេចក្តីលំអិតបែបនេះនឹងមានចែងនៅក្នុង បទបញ្ញត្តិដែលនឹងត្រូវចេញដោយគណៈកម្មាធិការរៀបចំការបោះឆ្នោតជំនួសវិញ ប៉ុន្តែបញ្ញត្តិនេះមិនទាន់មាននៅក្នុងពេលស្រាវជ្រាវនេះនៅឡើយទេ ដោយហេតុថាច្បាប់នៃប្រទេសឥណ្ឌូនេស៊ីមានកាលបរិច្ឆេទត្រឹមឆ្នាំ២០១២។

## IV. ការត្រួតពិនិត្យដោយស្ថាប័នគ្រប់គ្រងការបោះឆ្នោត

នៅក្នុងការសិក្សាប្រៀបធៀបដ៏វែងរបស់ស្ថាប័នគ្រប់គ្រងការបោះឆ្នោតបរទេស- វិទ្យាស្ថានអន្តរជាតិដើម្បីប្រជាធិបតេយ្យ និងជំនួយការបោះឆ្នោត (The International Institute for Democratic and Electoral Assistance IDEA) បានរកឃើញថា៖ ការអនុវត្តន៍ដែលមានប្រសិទ្ធភាពបំផុតនៃស្ថាប័នគ្រប់គ្រងការបោះឆ្នោតគឺមិនងាយក្នុងការកំណត់នោះទេ ហើយត្រូវបានកំណត់ជំនួសវិញនូវ៧ចំណុចដែលសំខាន់សម្រាប់អត្ថប្រយោជន៍ និងប្រសិទ្ធភាព[164]ដល់ស្ថាប័នគ្រប់គ្រងការបោះឆ្នោត។ ដោយរួមមាន៖ ឯករាជ្យ ភាពមិនលំអៀង សមាហរណកម្ម តម្លាភាព ប្រសិទ្ធភាព វិជ្ជាជីវនិយម និងស្មារតីនៃការផ្តល់សេវា[165]។

ការសិក្សានេះក៏បានកំណត់ចំណាំអំពីមូលហេតុចំបងទាំងប្រាំនៃការបរាជ័យរបស់ស្ថាប័នគ្រប់គ្រងការបោះឆ្នោតក្នុងការបំពេញភារកិច្ចរបស់ពួកគេផងដែរគឺ៖

---

[161] មាត្រា ៤០ កថាខណ្ឌទី ៣ នៃច្បាប់ដែលរៀបរាប់ខាងលើ

[162] មាត្រា ៤០ កថាខណ្ឌទី ២ នៃច្បាប់ដែលរៀបរាប់ខាងលើ

[163] មាត្រា ៤០ កថាខណ្ឌទី ៥ នៃច្បាប់ដែលរៀបរាប់ខាងលើ៖ នៅក្នុងករណីដែលមានប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត ប៉ុន្តែមិនមានកាន់នូវប័ណ្ណស្នាក់នៅ ហើយ/ឬ ក៏មិនបានចុះឈ្មោះនៅ ក្នុងបញ្ជីបោះឆ្នោតដំបូង បញ្ជីបោះឆ្នោតដំបូងដែលបានកែតម្រូវ ហើយបញ្ជីបោះឆ្នោតអចិន្ត្រៃយ៍ ឬក៏បញ្ជីបោះឆ្នោតបន្ថែម នោះគ.ជ.ប.ថ្នាក់ខេត្តគួរតែចុះឈ្មោះ នឹង បញ្ចូលពួកគេទៅក្នុងបញ្ជីបោះឆ្នោតពិសេស

[164] វិទ្យាស្ថានអន្តរជាតិ ដើម្បីប្រជាធិបតេយ្យ នឹង ជំនួយការបោះឆ្នោត (IDEA) ២០០៦ *Electoral Management Design: The International IDEA Handbook* Stockholm ទំព័រទី ៦៩

[165] តាមសេចក្តីយោងខាងលើ (Ibid) ទំព័រទី ១២/២២

- កង្វះខាតនូវទំនុកចិត្តទៅលើស្ថាប័នគ្រប់គ្រងការបោះឆ្នោត ឥទ្ធិពលរបស់រដ្ឋាភិបាល និង/ឬ ឥទ្ធិពលនយោបាយទៅលើការសម្រេចចិត្តរបស់ស្ថាប័នគ្រប់គ្រងការបោះឆ្នោត

- ការដែលស្ថាប័នគ្រប់គ្រងការបោះឆ្នោតលំអៀងគាំទ្រតែគណបក្សនយោបាយដែលជាសមាជិករបស់ខ្លួន

- កង្វះខាតនូវវិជ្ជាជីវនិយមនៃស្ថាប័នគ្រប់គ្រងការបោះឆ្នោត និង

- ការអសមត្ថភាពនៃស្ថាប័នគ្រប់គ្រងការបោះឆ្នោត ឬក៏ការប្រើប្រាស់ហិរញ្ញវត្ថុមិនសមរម្យ[166]។

ដើម្បីសម្រេចឲ្យបាននូវផលប្រយោជន៍ និងប្រសិទ្ធភាពព្រមទាំងដោះស្រាយនូវមូលហេតុថាតើហេតុអ្វីស្ថាប័នគ្រប់គ្រងការបោះឆ្នោតមានភាពអន់ថយ រដ្ឋត្រូវតែផ្ដល់នូវប្រព័ន្ធតុលាការដែលរឹងមាំ អភិវឌ្ឍនូវប្រពៃណីក្នុងការរៀបចំការបោះឆ្នោតដែលប្រកបដោយភាពយុត្តិធម៌ និងប្រើប្រាស់មន្ត្រីបោះឆ្នោតជំនាញនៅក្នុងដំណើរការបោះឆ្នោត។

ស្ថាប័នគ្រប់គ្រងការបោះឆ្នោតគឺត្រូវបានចាត់ទុកជាប្រព័ន្ធមួយក្នុងចំណោមប្រព័ន្ធគំរូទាំងបី៖ ឯករាជ្យ រដ្ឋាភិបាល ឬ ចំរុះ។ ប្រព័ន្ធគំរូនីមួយៗ មានគុណសម្បត្តិនិង គុណវិបត្តិ ហើយត្រូវបានប្រើប្រាស់ដោយមានប្រសិទ្ធភាព ឬគ្មានទៅតាមប្រទេសខុសៗគ្នា។ ប្រព័ន្ធគំរូទាំងនេះត្រូវបានរៀបរាប់ដូចខាងក្រោម៖

*ស្ថាប័នគ្រប់គ្រងការបោះឆ្នោតឯករាជ្យ*

ស្ថាប័នគ្រប់គ្រងការបោះឆ្នោតដែលធ្វើការដោយឯករាជ្យពីរដ្ឋាភិបាលត្រូវបានគេសំគាល់ថាពុំមានភាពលំអៀង និងមិនស្ថិតក្រោមឥទ្ធិពលនយោបាយដែលអាចនឹងបង្កើននូវភាពយុត្តិធម៌សម្រាប់ការបោះឆ្នោត។ ស្ថាប័នប្រភេទនេះក៏ផ្ដល់នូវគុណសម្បត្តិផងដែរដោយអាច៖

- ផ្ដោតសំខាន់ទាំងស្រុងតែទៅលើការគ្រប់គ្រងការបោះឆ្នោត

- ធ្វើការអភិវឌ្ឍឲ្យមានអ្នកជំនាញសមរម្យដែលចាំបាច់សម្រាប់ធ្វើការរៀបចំការបោះឆ្នោតប្រកបដោយ យុត្តិធម៌ និង ចាត់ចែងបានល្អ

- គ្រប់គ្រងថវិការ និងសកម្មភាពដោយខ្លួនពួកគេ និង

- សម្របសម្រួលការបោះឆ្នោតរដ្ឋបាលពីការិយាល័យតែមួយ។

គុណវិបត្តិរបស់ប្រព័ន្ធគំរូនេះគឺ៖

[166] តាមសេចក្ដីយោងខាងលើ (Ibid) ទំព័រទី ២៩៧

- អាចនឹងមានការផ្តាច់ខ្លួនចេញពីរដ្ឋាភិបាល និងអ្នកសម្រេចចិត្តពាក់ព័ន្ធទៅនឹងដំណើរការនៃការបោះឆ្នោត

- ភាគរយខ្ពស់ក្នុងការផ្លាស់ប្តូរបុគ្គលិកដែលជាហេតុធ្វើឲ្យបាត់បង់នូវស្មារតីជាក្រុមដែលពួកគេធ្លាប់ធ្វើការរួមគ្នានិងអ្នកជំនាញនៅចន្លោះពេលបោះឆ្នោត[167]

- មានការចំណាយច្រើន ដោយសារតែមានការលំបាកច្រើនក្នុងការប្រើប្រាស់ធនធានរបស់រដ្ឋាភិបាលដែលមានស្រាប់សម្រាប់គោលបំណងរបស់ស្ថាប័នគ្រប់គ្រងការបោះឆ្នោត[168]។

*ស្ថាប័នគ្រប់គ្រងការបោះឆ្នោតរបស់រដ្ឋាភិបាល*

ស្ថាប័នគ្រប់គ្រងការបោះឆ្នោតរបស់រដ្ឋាភិបាលប្រព្រឹត្តទៅនៅក្នុងនាយកដ្ឋានរដ្ឋ នឹងត្រូវទទួលខុសត្រូវចំពោះមុខនីតិប្រតិបត្តិ នឹងត្រូវបានដឹកនាំដោយមន្ត្រី និងមន្ត្រីរាជការស៊ីវិល។ គុណសម្បត្តិដែលល្អបំផុតរបស់ប្រព័ន្ធគំរូនេះគឺ ស្ថិតនៅក្នុងការទំនាក់ទំនងដ៏ជិតស្និតជាមួយរដ្ឋាភិបាលដែលនោះនឹង៖

- អនុញ្ញាត្តិឲ្យពួកគេរក្សាទុកនូវបុគ្គលិក និងអភិវឌ្ឍនូវស្មារតីជាក្រុមដែលពួកគេធ្លាប់ធ្វើការរួមគ្នា
- អាចឲ្យពួកគេទាក់ទងទៅកាន់បុគ្គលិករដ្ឋាភិបាលដែលមានបទពិសោធន៍ ហើយនឹង
- អាចឲ្យពួកគេប្រើប្រាស់នូវធនធានដែលមានស្រាប់របស់រដ្ឋាភិបាលដើម្បីជួយកាត់បន្ថយនូវការចំណាយ[169]។

គុណវិបត្តិរបស់ប្រព័ន្ធគំរូនេះគឺ៖

- សំគាល់ឃើញអំពីការខ្វះខាតនូវភាពឯករាជ្យ និងភាពយុត្តិធម៌
- ពឹងផ្អែកទៅលើការសម្រេចចិត្តផ្ទៃក្នុងនៃនាយកដ្ឋានរដ្ឋាភិបាលចំពោះថវិកា និងសាជីវកម្ម និង
- ស្ថាប័នគ្រប់គ្រងការបោះឆ្នោតរបស់រដ្ឋាភិបាលនេះអាចខំប្រឹងប្រែងដើម្បីកែទម្រង់ប្រព័ន្ធការិយាល័យធិបតេយ្យដើម្បីគ្រប់គ្រងការបោះឆ្នោតកាន់តែប្រសើរ[170]។

*ស្ថាប័នគ្រប់គ្រងការបោះឆ្នោតចំរុះ*

---

[167] សូមមើលទំព័រទី ៤៣ ដល់ ៤៥ ខាងក្រោមនៃឯកសារស្រាវជ្រាវនេះ ត្រង់ចំណុច ស្តីពី ស្ថាប័នគ្រប់គ្រងការបោះឆ្នោតអចិន្ត្រៃយ៍ នឹងបណ្តោះអាសន្ន

[168] សូមមើលសេចក្តីយោងលេខ ១៥៦ ទំព័រទី ២១

[169] រដ្ឋាភិបាលដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយស្ថាប័នគ្រប់គ្រងការបោះឆ្នោត EMB ក៏អាចផ្តោតទៅលើការងារទាំងមូលលើការគ្រប់គ្រងការបោះឆ្នោត និងការបង្កើតជំនាញការដែលចាំបាច់នឹងសាកសមដើម្បីរៀបចំការបោះឆ្នោតដែលមានលក្ខខណៈយុត្តិធម៌ និងការរៀបចំល្អដូចជាស្ថាប័នរៀបចំការបោះឆ្នោតដែលមានឯករាជ្យមួយ។

[170] តាមសេចក្តីយោងខាងលើ (Ibid) ទំព័រទី១៣ និង ២១

ស្ថាប័នគ្រប់គ្រងការបោះឆ្នោតចំរុះត្រូវបានបង្កើតឡើងដោយធាតុពីរ៖ មួយគឺឯករាជ្យ និងមួយទៀតគឺរដ្ឋាភិបាល។ ប្រព័ន្ធគំរូនេះតែងតែយកទៅតាមទម្រង់ភ្នាក់ងារត្រួតពិនិត្យឯករាជ្យជាមួយនឹងការទទួលខុសត្រូវដែលមានកំណត់ និងអំណាចនៃរដ្ឋាភិបាលដែលការទទួលខុសត្រូវរបស់ពួកគេគឺខុសៗគ្នាទៅតាមកម្រិតនៃការបោះឆ្នោតរដ្ឋបាល។ គុណសម្បត្តិ និងគុណវិបត្តិនូវស្មារតីជាក្រុមដែលពួកគេធ្លាប់ធ្វើការរួមគ្នានៃប្រព័ន្ធគំរូនេះ ដែលអាចប្រមើលឃើញគឺ ពឹងផ្អែកទៅលើ វិធីជាក់លាក់មួយដែលនឹងធ្វើការបែងចែកការទទួលខុសត្រូវរវាងឯករាជ្យភាព និងអំណាចរដ្ឋាភិបាលដោយក្នុងនោះក៏គិតអំពីបទបញ្ញត្តិ និងស្ថានភាពនយោបាយដែលប្រព័ន្ធគំរូទាំងនេះប្រព្រឹត្តិទៅ។ ក៏ប៉ុន្តែជាទូទៅគុណ- សម្បត្តិ និងគុណវិបត្តិរបស់ប្រព័ន្ធនេះគឺជាការបញ្ចូលគ្នានៃប្រព័ន្ធគំរូទាំងពីរខាងលើ[171]។

*ស្ថាប័នគ្រប់គ្រងការបោះឆ្នោតអចិន្ត្រៃយ៍ និងបណ្តោះអាសន្ន*

ចំណាត់ថ្នាក់ចុងក្រោយដែលស្ថាប័នគ្រប់គ្រងការបោះឆ្នោតអាចនឹងត្រូវរាប់បញ្ចូលជាការឆ្លុះបញ្ចាំងថាតើនេះគឺជាភ្នាក់ងារអចិន្ត្រៃយ៍ ឬបណ្តោះអាសន្ន។ ជាធម្មតា កត្តាក្នុងការកំណត់គឺថាតើចំនួននៃការបោះឆ្នោតដែលធ្វើឡើងនៅក្នុងប្រទេសគឺធានានូវភាពអចិន្ត្រៃយ៍នៃស្ថាប័នគ្រប់គ្រងការបោះឆ្នោតដែរទេ។ ក៏ប៉ុន្តែវាត្រូវបានគេកត់សម្គាល់ថា ការចំណាយក្នុងការបង្កើតស្ថាប័នគ្រប់គ្រងការបោះឆ្នោតសារជាថ្មីសម្រាប់ការបោះឆ្នោតអាណត្តិនីមួយៗអាចនឹងជាចំណុចសំខាន់។ គុណវិបត្តិចំបងនៃប្រព័ន្ធបណ្តោះអាសន្នគឺ នឹងនាំឲ្យបាត់បង់អ្នកជំនាញបន្ទាប់ពីស្ថាប័នត្រូវបានរំសាយនៅពេលដែលការបោះឆ្នោតត្រូវបានបញ្ចប់[172]។

ប្រភេទនៃស្ថាប័នគ្រប់គ្រងការបោះឆ្នោតសម្រាប់ប្រទេសដែលធ្វើការវិភាគនៅក្នុងឯកសារស្រាវជ្រាវនេះមានដូចតទៅ៖

**ប្រទេសកម្ពុជា** ត្រូវបានគេចាត់ទុកថានៅក្នុងប្រព័ន្ធស្ថាប័នគ្រប់គ្រងការបោះឆ្នោតឯករាជ្យ និង បណ្តោះ-អាសន្ន។[173] ស្ថាប័ននេះគឺបណ្តោះអាសន្នដោយសារការធ្វើការរក្សាទុកបុគ្គលិកអចិន្ត្រៃយ៍យ៉ាងតិចតួចបំផុតនៅចន្លោះពេលបោះឆ្នោត ហើយស្ថាប័ននេះគឺឯករាជ្យដោយសារគណៈកម្មាធិការរៀបចំការបោះឆ្នោត(គ.ជ.ប)គឺត្រូវបានបង្កើតឡើងដោយច្បាប់ដើម្បីប្រព្រឹត្តទៅដោយឯករាជ្យពីស្ថាប័នរដ្ឋ ហើយសមាជិករបស់គ.ជ.ប ត្រូវបានតែងតាំងដោយរដ្ឋសភា។

**ប្រទេសកូរ៉េខាងត្បូង** មាននូវស្ថាប័នគ្រប់គ្រងការបោះឆ្នោតដែលអចិន្ត្រៃយ៍ និងឯករាជ្យ[174] គឺ គណៈ-កម្មការរៀបចំការបោះឆ្នោត(គ.ជ.ប)។

**ប្រទេសភីលីពីន** មាននូវស្ថាប័នគ្រប់គ្រងការបោះឆ្នោតដែលអចិន្ត្រៃយ៍ និងឯករាជ្យ[175] គឺ គណៈកម្មការរៀបចំការបោះឆ្នោត(COMELEC)។

[171] តាមសេចក្តីយោងខាងលើ (Ibid) ទំព័រទី១៤-១៥ និង ២១
[172] តាមសេចក្តីយោងខាងលើ (Ibid) ទំព័រទី១៧
[173] តាមសេចក្តីយោងខាងលើ (Ibid) ទំព័រទី៣០៦
[174] តាមសេចក្តីយោងខាងលើ (Ibid) ទំព័រទី៣១៤

**ប្រទេសឥណ្ឌូនេស៊ី** មាននូវស្ថាប័នគ្រប់គ្រងការបោះឆ្នោតដែលអចិន្ត្រៃយ៍ និងឯករាជ្យ[176] គឺ គណៈកម្មការជាតិរៀបចំការបោះឆ្នោត(KPU)។

**ប្រទេសបារាំង** ប្រកាន់យកស្ថាប័នគ្រប់គ្រងការបោះឆ្នោតដែលអចិន្ត្រៃយ៍ និងចំរុះ[177] ជាមួយនឹងការគ្រប់គ្រងការបោះឆ្នោតដោយបែងចែករវាងក្រុមប្រឹក្សាធម្មនុញ្ញដែលឯករាជ្យ និងការិយាល័យបោះឆ្នោតរដ្ឋាភិបាលទទួលបន្ទុកការបោះឆ្នោតដែលស្ថិតនៅក្នុងក្រសួងមហាផ្ទៃ។

ពុំមានប្រព័ន្ធស្ថាប័នគ្រប់គ្រងការបោះឆ្នោតណាមួយល្អជាងគេឡើយទេ។ ឧទាហរណ៍៖ នៅពេលដែលស្ថាប័នគ្រប់គ្រងការបោះឆ្នោតឯករាជ្យអាចនឹងមើលទៅឃើញថាល្អជាង ស្ថាប័នគ្រប់គ្រងការបោះឆ្នោតរបស់រដ្ឋាភិបាល ការសន្មតបែបនេះពុំអាចកំណត់អំពីគុណភាពនៃស្ថាប័នគ្រប់គ្រងការបោះឆ្នោតបាននោះទេ។ ឧទាហរណ៍៖ ប្រទេសស៊ីមបាវ៉េមាននូវ ស្ថាប័នគ្រប់គ្រងការបោះឆ្នោតដែលឯករាជ្យ និងមានចរិការគ្រប់គ្រាន់[178] ចំណែកឯប្រទេសអាមេរិក ប្រកាន់យកស្ថាប័នគ្រប់គ្រងការបោះឆ្នោតដោយរដ្ឋាភិបាល[179]។ ក៏ប៉ុន្តែ បើធ្វើការប្រៀបធៀបនូវគុណភាពនៃការគ្រប់គ្រងការបោះឆ្នោត ដូចគ្នានឹងកំណត់សំគាល់នូវភាពយុត្តិធម៌រវាងឧទាហរណ៍ទាំងពីរនេះ វានឹងបង្ហាញយ៉ាងច្បាស់ថា ការបំពេញមុខងារដ៏មានប្រសិទ្ធិភាពនៃស្ថាប័នគ្រប់គ្រងការបោះឆ្នោតបូករួមនូវចំណុចដទៃជាច្រើនជាជាងការប្រព្រឹត្តទៅដោយលើឯករាជ្យភាពតែមួយមុខ។ ជំនួសមកវិញការផ្តោតសំខាន់ទៅលើលទ្ធផលនៃគោលដៅនៅក្នុងចំណុចសំខាន់នោះគឺ ឯករាជ្យ ភាពមិនលំអៀង សមាហរណកម្ម តម្លាភាព ប្រសិទ្ធភាព វិជ្ជាជីវនិយម និងស្មារតីនៃការផ្តល់សេវា គឺជាការអនុវត្តដែលមានប្រសិទ្ធភាពបំផុតក្នុងការធ្វើឲ្យកាន់តែប្រសើរឡើង[180]នូវសមត្ថភាពនៃស្ថាប័នគ្រប់គ្រងការបោះឆ្នោតដោយមិនគិតអំពីប្រព័ន្ធគំរូនៃស្ថាប័នគ្រប់គ្រងការបោះឆ្នោតដែលមានស្រាប់ហើយនោះទេ។

## ១. ប្រទេសកម្ពុជា

### ១.១. រចនាសម្ព័ន្ធ សមាសភាព និង ទិដ្ឋភាពទូទៅនៃស្ថាប័នគ្រប់គ្រងការបោះឆ្នោត

ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្ររបស់ប្រទេសកម្ពុជាដំបូងត្រូវបានរៀបចំឡើងដោយអាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិប្រចាំកម្ពុជា (United Nations Transitional Authority in Cambodia - UNTAC) ក្នុងឆ្នាំ១៩៩៣។ ចាប់តាំងពីពេលនោះមក គណៈកម្មាធិការរៀបចំការបោះឆ្នោត (NEC) ត្រូវបានបង្កើតឡើងដោយអនុលោមទៅតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

---

[175] តាមសេចក្តីយោងខាងលើ (Ibid) ទំព័រទី៣១៨

[176] តាមសេចក្តីយោងខាងលើ (Ibid) ទំព័រទី៧ និង ១៧

[177] តាមសេចក្តីយោងខាងលើ (Ibid) ទំព័រទី១៤ និង ៣១០

[178] តាមសេចក្តីយោងខាងលើ (Ibid) ទំព័រទី៣៣

[179] តាមសេចក្តីយោងខាងលើ (Ibid) ទំព័រទី៧

[180] តាមសេចក្តីយោងខាងលើ (Ibid) ទំព័រទី៦៩

('ចបត៖' or "ច្បាប់") ដែលបានអនុម័តនៅក្នុងឆ្នាំ១៩៩៧[181] នឹងត្រូវបានធ្វើវិសោធកម្មបីដង (២០០២ ២០០៦ និង ២០១១)។ គណៈកម្មាធិការរៀបចំការបោះឆ្នោតត្រូវបានបង្កើតឡើងដើម្បីរៀបចំគ្រប់គ្រង និង ត្រួតត្រាទៅលើការបោះឆ្នោតសមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា និង ក្រុមប្រឹក្សារាជធានី/ខេត្ត និង ក្រុង/ស្រុក/ខ័ណ្ឌ ហើយនិង ក្រុមប្រឹក្សា ឃុំ/សង្កាត់[182]។

គ.ជ.ប. គឺជាស្ថាប័នគ្រប់គ្រងការបោះឆ្នោតអចិន្ត្រៃយ៍ដែលត្រូវតែមានឯករាជ្យ និង អព្យាក្រឹត្យ ក្នុងការបំពេញមុខងាររបស់ខ្លួន[183]។ ជាងនេះទៅទៀត គណៈកម្មាធិការរៀបចំការបោះឆ្នោតក៏បាន អភិវឌ្ឍ នូវភារកិច្ចរបស់ខ្លួនឲ្យក្លាយជាស្ថាប័នជាតិដែលផ្តល់នូវយុត្តិធម៌ ការជឿទុកចិត្ត និងតម្លាភាពនៅ ក្នុងដំណើរការបោះឆ្នោត[184]។ គោលបំណងនៃការបង្កើតគណៈកម្មាធិការរៀបចំការបោះឆ្នោតគឺដើម្បី អភិវឌ្ឍសមត្ថភាពរបស់ស្ថាប័នជាតិ ដើម្បីដំណើរការទៅនៃការបោះឆ្នោតដែលសេរី និងយុត្តិធម៌នៅ ក្នុងប្រទេសកម្ពុជា។ ដើម្បីសម្រេចបាននូវគោលដៅនេះ សមាជិករបស់គណៈកម្មាធិការ និង គណកម្មការ បោះឆ្នោតដទៃទៀតនៅគ្រប់លំដាប់ថ្នាក់ត្រូវរក្សានូវភាពមិនលំអៀងផង និងអព្យាក្រឹត្យភាពផងដែរក្នុង ការបំពេញតួនាទីរបស់ពួកគេដែលពាក់ព័ន្ធទៅនឹងកិច្ចការបោះឆ្នោត[185]។

គ.ជ.ប គឺមានរចនាសម្ព័ន្ធរួមគ្នា និងអនុគណៈកម្មការសម្របសម្រួលដូចជា គ.ជ.ប ខេត្ត/ក្រុង (គជ/ឃ) និង គ.ជ.ប ភូមិ/សង្កាត់(គឃ/សប) និង គណៈកម្មការមណ្ឌលបោះឆ្នោត(គកប)[186] ព្រមទាំង អនុគណៈកម្មការចំពោះកិច្ច ខុទ្ទកាល័យគ.ជ.ប និងអ្នកនាំពាក្យគ.ជ.ប ព្រមទាំងអគ្គលេខាធិការដ្ឋាន នៃគ.ជ.ប[187] ។

## ១.២. របៀបដែលសមាជិកត្រូវបានតែងតាំងទៅស្ថាប័នគ្រប់គ្រងការបោះឆ្នោត

សមាជិកគណៈកម្មការគ.ជ.ប ត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ ក្រោមការណែនាំ (តាមការ បោះឆ្នោត) របស់រដ្ឋសភា។ សមាជិក គ.ជ.ប ត្រូវបានចាត់តាំងដោយយោងទៅតាម បីដំណាក់កាល។ ទីមួយ ក្រសួងមហាផ្ទៃគឺទទួលបន្ទុកក្នុងការរៀបចំសេចក្តីព្រាងស្នើរសមាសភាពរបស់គ.ជ.ប យ៉ាងតិច ៩(ប្រាំបួន)ខែ មុនថ្ងៃបោះឆ្នោត នឹងត្រូវបញ្ជូនសេចក្តីព្រាងទៅឲ្យទីស្តីការគណៈរដ្ឋមន្ត្រី។ ទីពីរ សំណើរ សមាសភាពនឹងត្រូវបញ្ជូនទៅកាន់រដ្ឋសភាដើម្បីផ្តល់សច្ចានុមតិ។ ជាចុងក្រោយ ក្រោមការយល់ព្រម របស់រដ្ឋសភាសមាជិកនៃគ.ជ.បនឹងត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យយ៉ាងតិច៧(ប្រាំពីរ)ខែ មុនថ្ងៃ

---

181 មាត្រា ១ និង ៤ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកតំណាងរាស្ត្រ

182 ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកតំណាងរាស្ត្រ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ច្បាប់ស្តីពីការបោះឆ្នោត ជ្រើសតាំងក្រុមប្រឹក្សារាជធានី/ខេត្ត នឹង ក្រុង/ស្រុក/ខ័ណ្ឌ នឹង ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សាឃុំ/សង្កាត់

183 មាត្រា ១២(១) នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកតំណាងរាស្ត្រ

184 គណកម្មាធិការរៀបចំការបោះឆ្នោតនៃព្រះរាជាណាចក្រកម្ពុជា «*គ.ជ.ប.៖ ប្រវត្តិ គ.ជ.ប.*» ទាញយកកាលពីថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ ២០១៣ ពី http://www.necelect.org.kh/nec_english/index.php?option=com_content&view=article&id=78&Itemid=152

185 មាត្រា ១២(២) នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកតំណាងរាស្ត្រ

186 មាត្រា ១១ នៃច្បាប់ដែលរៀបរាប់ខាងលើ

187 គ.ជ.ប. ការបោះឆ្នោតជ្រើសតាំងសមាជិកតំណាងរាស្ត្រ ឆ្នាំ២០១៣ "*An Overview: Briefing for the International Observers*" (ថ្ងៃសៅរ៍ ទី ២៧ ខែ កក្កដា ឆ្នាំ ២០១៣) ទំព័រទី៤

បោះឆ្នោត[188]។ សមាជិកគណៈកម្មការ គ.ជ.ប មានអាណត្តិប្រាំឆ្នាំ ហើយសមាជិកគណៈកម្មការគ.ជ.ប ទាំងអស់ត្រូវចូលកាន់តំណែងយ៉ាងតិចប្រាំពីរខែ មុននឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីមួយៗ[189]។

១.៣. ភារកិច្ច និង អំណាចនៃស្ថាប័នគ្រប់គ្រងការបោះឆ្នោត

គ.ជ.ប គឺទទួលបន្ទុករៀបចំផែនការ គ្រប់គ្រង និងត្រួតពិនិត្យការបោះឆ្នោតថ្នាក់ជាតិនៅក្នុងប្រទេសកម្ពុជា។ ដើម្បីអនុវត្តនូវកាតព្វកិច្ចទាំងនេះ គ.ជ.ប មានភារកិច្ចដូចតទៅ[190] ៖

- ដាក់នូវវិធាន បកស្រាយ និងដាក់ឲ្យអនុវត្តទៅតាមប្រព្រឹត្តទៅនៃការចុះឈ្មោះបោះឆ្នោត បទបញ្ជាផ្ទៃក្នុង និងឯកសារដែលពាក់ព័ន្ធឲ្យស្របទៅនឹងរដ្ឋធម្មនុញ្ញប្រទេសកម្ពុជា និងច្បាប់បោះឆ្នោត និងច្បាប់ពាក់ព័ន្ធដទៃទៀត
- សង្កេត គ្រប់គ្រង និងត្រួតពិនិត្យការចុះឈ្មោះ និងភាពយុត្តិធម៌នៃបេក្ខជននយោបាយ
- ត្រួតពិនិត្យបញ្ជីគណនេយ្យធនាគារនៃថវិកានយោបាយរបស់គណបក្សនយោបាយនីមួយៗ
- អប់រំប្រជាពលរដ្ឋដើម្បីធានាថារាល់ដែលពាក់ព័ន្ធការបោះឆ្នោតត្រូវបានផ្សព្វផ្សាយយ៉ាងពេញលេញទៅដល់ប្រជាពលរដ្ឋទាំងអស់
- ជ្រើសរើស ចាត់តាំង អប់រំ និងត្រួតពិនិត្យការងារនៃគណៈកម្មការរៀបចំការបោះឆ្នោត និងមន្ត្រីនៅគ្រប់ជាន់ថ្នាក់
- ចែកចាយគ្រឿងបរិក្ខារ ឯកសារ និងសម្ភារៈ ដើម្បីជាជំនួយដល់ការចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោត
- ផ្តល់នូវរាល់វិធានចាំបាច់ដើម្បីធានានូវសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈនៅអំឡុងពេលចុះឈ្មោះបោះឆ្នោត និងពេលបោះឆ្នោត
- រៀបចំ អភិវឌ្ឍ និងធ្វើឲ្យមានសុពលភាពនូវបញ្ជីបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោត
- ចាត់ចែង នូវការចុះឈ្មោះរបស់គណបក្សនយោបាយដែលមានបំណងចូលរួមក្នុងយុទ្ធនាការបោះឆ្នោត
- ដាក់កំហិត និងត្រួតពិនិត្យមណ្ឌលបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការបូកសរុប និងប្រកាសលទ្ធផលបោះឆ្នោត បែងចែងអសនៈដល់អ្នកឈ្នះ និងប្រកាសនូវបេក្ខជនដែលជាប់ឆ្នោត និង

---

[188] មាត្រា ១៣(ថ្មី) នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកតំណាងរាស្ត្រ

[189] មាត្រា ៣(ថ្មី) នឹង ១៣(ថ្មី) នៃច្បាប់ដែលរៀបរាប់ខាងលើ

[190] សូមមើលសេចក្តីយោងលេខ ១៧៨ ទំព័រទី៥ ដល់ ៦

- ដោះស្រាយបណ្ដឹង និងការប្ដឹងតវ៉ាដែលទាក់ទងទៅនឹងការចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោត

១.៤. ភ្នាក់ងារពាក់ព័ន្ធដែលបានជួយសម្របសម្រួលដល់ការបោះឆ្នោត

ក្រុមប្រឹក្សាធម្មនុញ្ញគឺជាអំណាចកំពូលសម្រាប់ការប្ដឹងតវ៉ារាល់វិវាទបោះឆ្នោត។

## ២. ប្រទេសបារាំង

### ២.១. រចនាសម្ព័ន្ធ សមាសភាព និងទិដ្ឋភាពទូទៅនៃស្ថាប័នគ្រប់គ្រងការបោះឆ្នោត

ក្រុមប្រឹក្សាធម្មនុញ្ញជាអ្នកអនុវត្តនូវមុខងាររបស់ស្ថាប័នគ្រប់គ្រងការបោះឆ្នោតរបស់ប្រទេសបារាំង និងត្រូវបានបង្កើតឡើងដោយរដ្ឋធម្មនុញ្ញនៃសាធារណៈរដ្ឋទីប្រាំ អនុម័តនៅថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៥៨[191]។ ក្រុមប្រឹក្សានេះត្រូវបានបង្កើតឡើងក្នុងគោលបំណងធ្វើជាអ្នកគាំពារក្នុងការបែងចែក អំណាចរវាងសភា និងអង្គនីតិប្រតិបត្តិ[192] ហើយក៏ជាអាជ្ញាធរដែលខ្ពស់ជាងគេក្នុងការសម្រេចរាល់វិវាទ បោះឆ្នោត និងធម្មនុញ្ញភាព។

ខុសពីស្ថាប័នគ្រប់គ្រងការបោះឆ្នោតនៅប្រទេសដទៃទៀត ក្រុមប្រឹក្សាធម្មនុញ្ញប្រទេសបារាំងមិនធ្វើការត្រួតពិនិត្យទៅលើការបោះឆ្នោតជ្រើសតាំងប្រធានាធិបតី និងសភាតំណាងរាស្ត្រនោះទេ ប៉ុន្តែវាក៏មានអំណាចក្នុងការកាត់ក្ដីទៅលើធម្មនុញ្ញភាពនៃច្បាប់។ ជាងនេះទៅទៀត ក្រសួងមហាផ្ទៃក៏ធ្វើការរួមជាមួយនឹងក្រុមប្រឹក្សាធម្មនុញ្ញក្នុងការរៀបចំនៃការប្រព្រឹត្តទៅនៃការបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់តំបន់ប្រកបដោយយុត្តិធម៌ និងតម្លាភាពនៅពេលដែលគណៈកម្មការជាតិគ្រប់គ្រង គណនេយ្យភាពនៃការបោះឆ្នោត និងហិរញ្ញប្បទាននយោបាយ (National Commission for Control of Electoral Accounts and Political Finance CNCCFP)

ដើរតួនាទីជាភ្នាក់ងារជំនាញដើម្បីធានាថា បទបញ្ញត្តិនូវចរិការដ្ឋចំពោះហិរញ្ញប្បទានក្នុង យុទ្ធនាការឃោសនាបោះឆ្នោតត្រូវបានគោរពតាមដោយបេក្ខជន។

### ២.២. តើសមាជិកនៃស្ថាប័នគ្រប់គ្រងការបោះឆ្នោតត្រូវបានចាត់តាំងដោយរបៀបណា

ប្រធានាធិបតី និងប្រធាននៃសភានីមួយៗដោយម្នាក់ៗត្រូវចាត់តាំងសមាជិកចំនួនបីរូបក្នុងចំណោមសមាជិកទាំង៩(ប្រាំបួន)របស់ក្រុមប្រឹក្សាធម្មនុញ្ញ ដោយមានអាណត្តិ៩(ប្រាំបួន)ឆ្នាំ។ អាណត្តិរបស់សមាជិកត្រូវផ្លាស់ថ្មីរៀងរាល់៣(បី)ឆ្នាំម្ដង ប្រធានាធិបតី និងសភានីមួយៗ ចាត់តាំងសមាជិក

---

[191] *បទបង្ហាញទូទៅ* អង្គការ បានទាញយកកាលពីថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ ២០១៣ ពី http://www.conseil-constitutionnel.fr/conseil-constitutionnel/english/presentation/general-presentation/general-presentation.25739.html.

[192] Pasquale Pasquino "*The New Constitutional Adjudication in France*" សាកលវិទ្យាល័យញូវយ៉ក ទំព័រទី៣

១(មួយ)រូបទៅក្នុងក្រុមប្រឹក្សាធម្មនុញ្ញដោយបេក្ខជននោះអាចនឹងត្រូវចាត់តាំងជាច្រើនអាណត្តិ។ ពុំមានលក្ខខណ្ឌអាយុ ឬក៏មុខងារនោះទេក្នុងការក្លាយជាសមាជិកនៃក្រុមប្រឹក្សាធម្មនុញ្ញ។ ក៏ប៉ុន្តែសមាជិកត្រូវប្រកាន់ខ្ជាប់ស្របតាមលក្ខខ័ណ្ឌច្បាប់ពាក់ពន្ធ័នឹងទំនាស់ផលប្រយោជន៍ដូចគ្នាទៅនឹងសមាជិកសភា ហើយមិនត្រូវឈរឈ្មោះជាបេក្ខជនបោះឆ្នោតនោះទេ។ ជាងនេះទៅទៀត អតីតប្រធានាធិបតីមានសិទ្ធិក្នុងការកាន់មុខតំណែងណាមួយនៅក្នុងក្រុមប្រឹក្សាធម្មនុញ្ញ[193]។

## ២.៣. ភារកិច្ច និងអំណាចនៃស្ថាប័នគ្រប់គ្រងការបោះឆ្នោត

រដ្ឋាភិបាលពិភាក្សាជាមួយនឹងក្រុមប្រឹក្សាធម្មនុញ្ញទៅលើច្បាប់ទាក់ទងការចាត់ចែងនៃការរាប់ចំនួនឆ្នោតសម្រាប់ការបោះឆ្នោតប្រធានាធិបតី និងការធ្វើប្រជាមតិ[194]។ ក្រុមប្រឹក្សាក៏ផ្តល់នូវការអង្កេតទៅលើការបោះឆ្នោតសភា និងការបោះឆ្នោតប្រធានាធិបតីអាណត្តិមុន ក៏ដូចជាការបោះឆ្នោតដែលនឹងធ្វើឡើងនៅពេលខាងមុខ ក្នុងគោលបំណងណែនាំដល់វិធានការនៃអាជ្ញាធរសាធារណៈដែលអាចជួយឲ្យប្រសើរឡើងនូវការរៀបចំនិងប្រព្រឹត្តទៅនៃការបោះឆ្នោត[195]។ ក្រុមប្រឹក្សាក៏ទទួលបន្ទុកក្នុងការប្រកាសជាផ្លូវការនូវលទ្ធផលនៃការបោះឆ្នោត និងគឺជាភ្នាក់ងារច្បាប់កំពូលក្នុងការដោះស្រាយនូវវាលវិវាទទាក់ទងនឹងការបោះឆ្នោត។ លើសពីនេះទៅទៀត ក្រុមប្រឹក្សាធម្មនុញ្ញមានកាតព្វកិច្ចក្នុងការកំណត់អំពីភាពត្រឹមត្រូវនៃការអនុវត្តរដ្ឋធម្មនុញ្ញ ដោយធ្វើការសម្រេចថា ច្បាប់បោះឆ្នោត និងបទបញ្ញត្តិដែលចូលជាធរមានហើយ ឬក៏កំពុងព្រាង គឺស្របទៅនឹងរដ្ឋធម្មនុញ្ញដែរទេ[196]។

## ២.៤. ភ្នាក់ងារពាក់ព័ន្ធដែលបានជួយសម្របសម្រួលដល់ការបោះឆ្នោត

- *ក្រសួងមហាផ្ទៃ(Ministry of Interior- MOI)*

ក្រសួងមហាផ្ទៃក៏មានកាតព្វកិច្ចដែរពាក់ព័ន្ធទៅនឹងរដ្ឋបាលនៃការបោះឆ្នោត[197]។ ព្រមទាំង ទទួលបន្ទុកក្នុងការរៀបចំបច្ចេកទេស និងភស្តុភារទាំងអស់សម្រាប់ការបោះឆ្នោតថ្នាក់ជាតិ[198]។ ក្រសួងមហាផ្ទៃ[199]ក៏ចេញនូវសេចក្តីណែនាំស្តីពីបញ្ហាច្បាប់ និងអង្គការទៅឲ្យសាលាខេត្តណាដែលទទួកបន្ទុកក្នុងការចុះឈ្មោះបោះឆ្នោត រៀបចំលទ្ធផលបោះឆ្នោតជាតារាង និងបញ្ជូនឯកសារទាំងនេះទៅឲ្យក្រសួងមហា

---

[193] សូមមើលសេចក្តីយោងលេខ ១៨២

[194] តាមសេចក្តីយោងខាងលើ (Ibid)

[195] តាមសេចក្តីយោងខាងលើ (Ibid)

[196] សូមមើលសេចក្តីយោងលេខ ១៨៣ ទំព័រទី៧ និង សេចក្តីយោងលេខ ១៨២

[197] ការិយាល័យសម្រាប់វិទ្យាស្ថានប្រជាធិបតេយ្យ នឹង សិទ្ធិមនុស្ស (ODIHR) ឆ្នាំ ២០១៣ *"Parliamentary Elections":* ថ្ងៃទី ១០ ដល់១៧ ខែមិថុនា ឆ្នាំ២០១២ ទំព័រទី៥ ទីក្រុងវីយ៉ែន ODIHR

[198] តាមសេចក្តីយោងខាងលើ (Ibid)

[199] «ប្រធាននៃនាយកដ្ឋាន ទីប្រជុំជនដែលគឺជារដ្ឋាភិបាលថ្នាក់តំបន់នៅក្នុងប្រទេសមួយចំនួន» Longman Dictionary of Contemporary English, Fifth Edition.

ផ្ទៃ។ សាលាខេត្តនីមួយៗក៏ត្រូវជ្រើសតាំងគណៈកម្មការ៣(បី)ក្នុងការត្រួតពិនិត្យដំណើរការបោះឆ្នោតនៅតាមកម្រិតនាយកដ្ឋាន[200]។

- *ក្រសួងការបរទេស និង អឺរ៉ុប (The Ministry of Foreign and European Affairs- MFEA)*

ក្រសួងការបរទេសនិងកិច្ចការអឺរ៉ុប គឺទទួលបន្ទុកក្នុងការចាត់ចែងការបោះឆ្នោតសម្រាប់ប្រជាពលរដ្ឋបារាំងដែលរស់នៅឯបរទេស។ កុងស៊ុលត្រូវធ្វើការជូនដំណឹងដល់ប្រជាពលរដ្ឋបារាំងដែលចុះឈ្មោះបោះឆ្នោតនៅបរទេសអំពីនីតិវិធីនៃការបោះឆ្នោតបេក្ខជនឈរឈ្មោះបោះឆ្នោត និងទីកន្លែងនៃមណ្ឌលបោះឆ្នោត[201]។

- *គណៈកម្មការជាតិគ្រប់គ្រងគណនេយ្យភាពនៃការបោះឆ្នោត និងហិរញ្ញប្បទាននយោបាយ (National Commission for Control of Electoral Accounts and Political Finance- CNCCFP)*

គណៈកម្មការជាតិគ្របគ្រងគណនេយ្យភាពនៃការបោះឆ្នោត និងហិរញ្ញប្បទាននយោបាយ ត្រូវបានបង្កើតឡើងក្រោមច្បាប់ឆ្នាំ១៩៩០ និងមានសមាជិក៩(ប្រាំបួន)រូបដែលបានធ្វើការជ្រើសរើសមកពីតុលាការកំពូល[202]។ ៣(បីរូប) ត្រូវបានជ្រើសរើសដោយ/និង ពីតុលាការនីមួយៗដូចតទៅ៖ ក្រុមប្រឹក្សារដ្ឋ (Conseil d'Etat) សាលាកំពូល (Cour de cassation) និងតុលាការគណនេយ្យ[203] (Cour des comptes)។ គណៈកម្មការមានគោលដៅចម្បងចំនួនពីរ៖ មួយគឺធ្វើការត្រួតពិនិត្យទៅលើគណនេយ្យភាពនៃយុទ្ធនាការបោះឆ្នោតរបស់បេក្ខជន នឹងកំណត់ចំនួនទឹកប្រាក់ជាក់លាក់ដែលរដ្ឋត្រូវធ្វើការសងទៅឲ្យបេក្ខជននីមួយៗក្នុងការចំណាយទៅលើយុទ្ធនាការឃោសនាបោះឆ្នោត មួយទៀតគឺ ផ្ទៀងផ្ទាត់ការប្រព្រឹត្តទៅរបស់គណបក្សនយោបាយទៅនឹងបទបញ្ញត្តិដែលចែងអំពីការគ្រប់គ្រងថវិការបស់ពួកគេ[204]។

ក្នុងការកាត់ក្តីវិវាទបោះឆ្នោត ពេលដែលការបោះឆ្នោតត្រូវបានបញ្ចប់ គឺមានតុលាការដែលមានយុត្តាធិការខុសៗគ្នាក្នុងការដោះស្រាយនូវបញ្ហាចោទណាមួយជាក់លាក់។ ពួកគេគឺ៖

- *តុលាការដំបូង (Court of First Instance)*

តុលាការដំបូងគឺជាភ្នាក់ងារតុលាការដែលត្រួតពិនិត្យបណ្តឹងដែលដាក់ដោយអ្នកបោះឆ្នោត ឬក៏សាលាខេត្តដែលមានសមត្ថកិច្ចប្រឆាំងទៅនឹងគណៈកម្មការរដ្ឋបាលក្រុងពាក់ព័ន្ធទៅនឹងការចុះឈ្មោះ

---

[200] សូមមើលសេចក្តីយោងលេខ ១៨៨

[201] តាមសេចក្តីយោងខាងលើ (Ibid) ទំព័រទី៦

[202] គណៈកម្មការជាតិគ្របគ្រងគណនេយ្យនៃការបោះឆ្នោត នឹង ហិរញ្ញវត្ថុនយោបាយ (CNCCFP) បទបង្ហាញ *«បីរូបពីក្រុមប្រឹក្សារដ្ឋ បីរូបពីតុលាការនៃសាលាកំពូល នឹង បីរូបពីតុលាការគណនេយ្យ»*

[203] តាមសេចក្តីយោងខាងលើ (Ibid)

[204] តាមសេចក្តីយោងខាងលើ (Ibid)

បោះឆ្នោត[205]។ ការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចរបស់តុលាការដំបូង អាចប្តឹងទៅតុលាការឧទ្ធរណ៍។

- *តុលាការរដ្ឋបាល (Administrative Court)*

តុលាការរដ្ឋបាលត្រួតពិនិត្យបណ្តឹងទាក់ទងទៅនឹងការចុះឈ្មោះបេក្ខជនឈរឈ្មោះបោះឆ្នោត។ ក្នុងករណីដែលមានការរាយការណ៍ទ្រព្យសម្បត្តិដែលមិនពេញលេញ និងមិនប្រក្រតីដោយបេក្ខជនណាមួយ ឬដាក់បណ្តឹងដោយរដ្ឋអំណាចថ្នាក់ស្រុកទៅតុលាការនេះ ហើយត្រូវតែសម្រេចរឿងក្តីនេះក្នុងរយៈពេល៣(បី)ថ្ងៃ[206]។ ក្នុងករណីដែលសាលក្រមនៃតុលាការរដ្ឋបាលត្រូវបានប្តឹងឧទ្ធរណ៍នោះវិវាទនេះនឹងត្រូវបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញតាមរយៈសេចក្តីស្នើសុំដើម្បីសំរេចមោឃៈភាពទៅលើការបោះឆ្នោត[207]។

- *ក្រុមប្រឹក្សាធម្មនុញ្ញ (The Constitutional Council)*

ក្រុមប្រឹក្សាធម្មនុញ្ញ មានសមត្ថកិច្ចក្នុងការសម្រេចទៅលើរាល់វិវាទណាដែលពាក់ព័ន្ធទៅនឹងសុពលភាពនៃការបោះឆ្នោតប្រធានាធិបតី និងសភា[208]។ អ្នកចុះឈ្មោះបោះឆ្នោត និង បេក្ខជនឈរឈ្មោះបោះឆ្នោតណាមួយមានបញ្ហាពាក់ព័ន្ធទៅនឹងតំបន់បោះឆ្នោត ធម្មនុញ្ញភាពអាចនឹងដាក់បណ្តឹងប្រឆាំងតវ៉ានឹងលទ្ធផលបោះឆ្នោតក្នុងរយៈពេល១០(ដប់)ថ្ងៃបន្ទាប់ពីការប្រកាសនូវលទ្ធផល[209]។

## ៣. ប្រទេសកូរ៉េខាងត្បូង

### ៣.១. រចនាសម្ព័ន្ធ សមាសភាព និង ទិដ្ឋភាពទូទៅនៃស្ថាប័នគ្រប់គ្រងការបោះឆ្នោត

ស្ថាប័នគ្រប់គ្រងការបោះឆ្នោតរបស់ប្រទេសប្រទេសកូរ៉េខាងត្បូង គឺជាគណៈកម្មការរៀបចំការបោះឆ្នោត (National Election Commission- NEC)[210]។ គ.ជ.ប គឺជាភ្នាក់ងារឯករាជ្យដែលមានឋានៈស្របច្បាប់ស្មើនឹង សភា និងតុលាការកំពូល។ គ.ជ.ប. ត្រូវបានបង្កើតឡើងនៅថ្ងៃទី១៥ ខែមិនា ឆ្នាំ ១៩៦០។ យោងតាមមាត្រា១១៤ នៃរដ្ឋធម្មនុញ្ញសាធារណៈរដ្ឋប្រទេសកូរ៉េខាងត្បូង គ.ជ.ប. ត្រូវបានបង្កើតឡើងដើម្បីត្រួតពិនិត្យភាពយុត្តិធម៌ «គ្រប់គ្រងការបោះឆ្នោតនឹងប្រជាមតិក៏ដូចជាបញ្ហាដែលពាក់ព័ន្ធទៅនឹងគណបក្សនយោបាយ»។ តួនាទីនិងការរៀបចំចាត់ចែងរបស់គ.ជ.ប.ត្រូវបានគ្រប់គ្រងដោយរដ្ឋ

---

205 សូមមើលសេចក្តីយោងលេខ ១៨៨ ទំព័រទី២០

206 តាមសេចក្តីយោងខាងលើ (Ibid)

207 មាត្រា L.159 ដល់ L.160 នៃក្រមបោះឆ្នោត

208 សូមមើលសេចក្តីយោងលេខ ១៨២

209 សូមមើលសេចក្តីយោងលេខ ១៨៨

210 គណៈកម្មការរៀបចំការបោះឆ្នោត ២០១៣ គ.ជ.ប ទីក្រុងស៊ូល បានទាញយកកាលពីថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ ២០១៣ ពី http://www.nec.go.kr/engvote_2013/01_aboutnec/03_01.jsp

ធម្មនុញ្ញសាធារណៈរដ្ឋប្រទេសកូរ៉េខាងត្បូង(មាត្រា១១៤ ដល់១១៦) និងច្បាប់នៃគណៈ កម្មការរៀបចំការបោះឆ្នោត ឆ្នាំ១៩៦៣ ដែលត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ក្រោយៗមកទៀត[211]។

### ៣.២. របៀបដែលសមាជិកត្រូវបានតែងតាំងទៅស្ថាប័នគ្រប់គ្រងការបោះឆ្នោត

គ.ជ.ប មានសមាជិក៩(ប្រាំបួន)រូប (សមាជិកគណៈកម្មការ) ដោយសមាជិក៣(បី) រូបតែងតាំងដោយប្រធានាធិបតីនៃសាធារណៈរដ្ឋ ៣(បី) រូបត្រូវបានជ្រើសតាំងដោយរដ្ឋសភានិង៣(បី) រូបទៀតត្រូវបានចាត់តាំងដោយប្រធានអង្គចៅក្រមនៃតុលាការកំពូល។ ប្រធាននិងសមាជិកអចិន្ត្រៃយ៍ (សមាជិកគណៈកម្មការអចិន្ត្រៃយ៍)ត្រូវបានជ្រើសតាំងដោយសមាជិកដទៃទៀត។ ប្រធានទទួលភារកិច្ចតំណាងឲ្យគណៈកម្មការ និងទទួលបន្ទុកក្នុងការត្រួតពិនិត្យរាល់សកម្មភាពរបស់គណៈកម្មការ។ សមាជិក អចិន្ត្រៃយ៍មានគោលដៅជួយដល់ប្រធាននៃគណៈកម្មការក្នុងការបំពេញតួនាទីរបស់គាត់ និងត្រួតពិនិត្យការងាររបស់លេខាធិការដ្ឋាននៃគណៈកម្មការ ហើយនេះគឺជាមុខងារពេញម៉ោង។ សមាជិកត្រូវបានជ្រើសតាំងដោយមានអាណត្តិ៦(ប្រាំមួយ)ឆ្នាំ។ សមាជិករបស់គណៈកម្មការមិនត្រូវបានដកចេញពី តំណែងទេ លើកលែងតែសមាជិករូបនេះចូលរួមជាមួយគណបក្សនយោបាយ ឬក៏ចូលរួមទៅក្នុង សកម្មភាពនយោបាយ ឬក៏ទាល់តែមានការប្តឹងប្រឆាំងនឹងគាត់ ឬក៏គាត់ត្រូវបានកាត់ទោសឲ្យជាប់គុក។ សមាជិកនៃ គ.ជ.ប មិនអាចជាសមាជិកនៃគណបក្សនយោបាយ ឬក៏ចូលរួមក្នុងសកម្មភាពនយោបាយ។ លក្ខខណ្ឌក្នុងការជ្រើសរើសពួកគាត់គឺពួកគាត់ត្រូវភ្ជាប់ទៅនឹងកំរិតសិក្សា បទដ្ឋានសីលធម៌ជាប់ខ្លួន ចំណេះដឹងផ្នែកច្បាប់ ឬធ្វើការខាងវិស័យអប់រំ។

### ៣.៣. ភារកិច្ច និងអំណាចនៃស្ថាប័នគ្រប់គ្រងការបោះឆ្នោត

គណៈកម្មការរៀបចំការបោះឆ្នោតត្រូវបានបែងចែកចេញជាបួនកម្រិត គ.ជ.ប នៅថ្នាក់ជាតិ និងគណៈកម្មាធិការផ្សេងៗទៀតនៅថ្នាក់តំបន់ ឬថ្នាក់មូលដ្ឋាន (ខេត្ត/ក្រុង ស្រុក/សង្កាត់ ភូមិ)។

គ.ជ.ប ជាអាជ្ញាធរមានសមត្ថកិច្ចទៅលើការគ្រប់គ្រងការបោះឆ្នោតប្រជាមតិ និងកិច្ចការរដ្ឋបាលដែលទាក់ទងទៅនឹងគណបក្សនយោបាយ និងថវិកាបស់ពួកគេ។ សមត្ថកិច្ចរបស់គ.ជ.ប បូករួមទាំងការបោះឆ្នោតប្រធានាធិបតី សភា និងការបោះឆ្នោតតំបន់។ គ.ជ.ប ក៏ចូលរួមទៅក្នុងការគ្រប់គ្រង និងត្រួតពិនិត្យទៅលើការបោះឆ្នោតប្រធាននៃសហករណ៍កសិកម្ម ក៏ដូចជាសាកលវិទ្យាធិការនៃសាកលវិទ្យាល័យ។ គ.ជ.ប ក៏ទទួលបន្ទុកក្នុងការផ្តល់ឧបត្ថម្ភធនដល់គណបក្សនយោបាយ ត្រួតពិនិត្យនូវការបង្កើត និងសកម្មភាពនៃសមាគមអ្នកគាំទ្រ ប្រមូលនិងចែកចាយថវិកានយោបាយ និងតាមដាននូវការប្រើប្រាស់ថវិកាទាំងនោះឲ្យស្របទៅនឹងលក្ខខណ្ឌដែលបានចែងនៅក្នុងច្បាប់ស្តីពីគោលនយោបាយហិរញ្ញប្បទាន។

គ.ជ.ប ក៏មាននូវអំណាចនិយតកម្មក្នុងការអនុវត្តន៍នូវច្បាប់ស្តីពី ហិរញ្ញប្បទាននៃយុទ្ធនាការឃោសនាបោះឆ្នោតដែលរួមមាននូវផ្នែកនៃមាត្រាមួយចំនួននៃច្បាប់ស្តីពីហិរញ្ញទាននៃការបោះឆ្នោត។

---

[211] បណ្ណាល័យច្បាប់នៃសមាជប្រទេសកូរ៉េខាងត្បូង មើល http://www.glin.gov/view.do?documentID=91682&summaryLang=en&fromSearch=true.

បន្ថែមពីលើនេះ ការស្នើនូវវិសោធនកម្មនៃច្បាប់បោះឆ្នោតត្រូវដាក់ជូនទៅឲ្យគ.ជ.បត្រួតពិនិត្យ។ ជាចុងក្រោយ ក្នុងករណីចាំបាច់គណៈកម្មការអាចនឹងចេញនូវមតិយោបល់ទៅឲ្យរដ្ឋសភា ដោយស្នើសុំឲ្យមានកំណែទម្រង់ទៅលើច្បាប់បោះឆ្នោត។

៣.៤. ភ្នាក់ងារពាក់ព័ន្ធដែលបានជួយសម្របសម្រួលដល់ការបោះឆ្នោត

ពុំមានភ្នាក់ងារណាជួយដល់រដ្ឋបាលនៃការបោះឆ្នោតនៅប្រទេសប្រទេសកូរ៉េខាងត្បូងឡើយ ដោយសារថា គ.ជ.ប មានគុណសម្បត្តិ និង ធនធានគ្រប់គ្រាន់ក្នុងការគ្របដណ្តប់នូវរាល់បញ្ហាដែលទាក់ទងនឹងការបោះឆ្នោត[212]។

## ៤. ប្រទេសហ្វីលីពីន

៤.១. រចនាសម្ព័ន្ធ សមាសភាព និងទិដ្ឋភាពទូទៅនៃស្ថាប័នគ្រប់គ្រងការបោះឆ្នោត

គណៈកម្មការរៀបចំការបោះឆ្នោត (COMELEC) ត្រូវបានបង្កើតឡើងដោយរដ្ឋធម្មនុញ្ញឆ្នាំ១៩៤០ ដែលបានធ្វើវិសោធនកម្មទៅលើរដ្ឋធម្មនុញ្ញឆ្នាំ១៩៣៥[213]។ មុនការបង្កើតគណៈកម្មការរៀបចំការបោះឆ្នោត (COMELEC) ការបោះឆ្នោតស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងមហាផ្ទៃ។ យោងតាមរដ្ឋធម្មនុញ្ញឆ្នាំ១៩៧៣ សមាជិកភាពនិងអំណាចរបស់គណៈកម្មការបានពង្រីកវិសាលភាពកាន់តែធំឡើង ប៉ុន្តែតាមរយៈរដ្ឋធម្មនុញ្ញឆ្នាំ១៩៨៧ សមាជិកភាពរបស់គណៈកម្មការនេះបានកាត់បន្ថយមកវិញពី ៩(ប្រាំបួន)រូបមកត្រឹម៧(ប្រាំពីរ)រូប សម្រាប់អណត្តិ រយៈពេល៧(ប្រាំពីរ)ឆ្នាំ ដោយពុំមានការតែងតាំងឡើងវិញ[214]។

រាល់ដំណើរការនៃការបោះឆ្នោតនៅក្នុងប្រទេសហ្វីលីពីន គឺស្ថិតក្រោមការគ្រប់គ្រងរបស់គណៈកម្មការរៀបចំការបោះឆ្នោត (COMELEC)។ គណៈកម្មការនេះគឺជាអង្គភាពអចិន្ត្រៃយ៍និងឯករាជ្យ[215] ដែលយោងតាមរដ្ឋធម្មនុញ្ញដោយតម្រូវឲ្យប្រតិបត្តិដោយឯករាជ្យពីអំណាចនីតិប្រតិបត្តិ អំណាចនីតិបញ្ញត្តិ និងអំណាចតុលាការរបស់រដ្ឋាភិបាល។ ដើម្បីសម្របសម្រួលប្រការនេះ គណៈកម្មការទទួលបានស្វ័យភាពថវិកា[216]។

---

[212] សូមមើលសេចក្តីយោងលេខ ២០១

[213] «*ប្រវត្តិ*» ចូលមើលនៅថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ទាញយកពី http://www.comelec.gov.ph/?r=AboutUs/HistoricalBackground.

[214] តាមសេចក្តីយោងខាងលើ (Ibid)

[215] «*គណៈកម្មការរៀបចំការបោះឆ្នោតប្រទេសហ្វីលីពីន*» ចូលមើលនៅថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ទាញយកពី http://www.aaea-sec.org/home/popContryView.do?seq_no=17.

[216] «*ទិដ្ឋភាពទូទៅនៃគណៈកម្មការរៀបចំការបោះឆ្នោត*» ចូលមើលនៅថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ទាញយកពី http://www.comelec.gov.ph/?r=AboutUs/OrganizationalInfo.

### ៤.២. របៀបដែលសមាជិកត្រូវបានតែងតាំងទៅស្ថាប័នគ្រប់គ្រងការបោះឆ្នោត

គណៈកម្មការរៀបចំការបោះឆ្នោត (COMELEC) មានសមាជិកចំនួន៦រូប និងប្រធាន១រូប។ គណៈ-កម្មការនេះត្រូវបានតែងតាំងដោយប្រធានាធិបតីហ្វីលីពីនសម្រាប់អាណត្តិរយៈពេល៧ឆ្នាំ[217]។ ដើម្បីមានលក្ខណៈសម្បត្តិគុណវុឌ្ឍិសម្រាប់ការតែងតាំង បេក្ខជនត្រូវតែមានដើមកំណើតហ្វីលីពីនមាន អាយុយ៉ាងហោចណាស់៣៥(សាមសិបប្រាំ)ឆ្នាំ និងជាសមាជិកនៃគណៈមេធាវីហ្វីលីពីន ដែលមានបទពិសោធន៍ផ្នែកច្បាប់យ៉ាងហោចណាស់១០(ដប់)ឆ្នាំ។ លើសពីនេះ បេក្ខជនទាំងនោះមិនអាចជាបេក្ខជនឈរឈ្មោះសម្រាប់មុខនាទីណាមួយនៅក្នុងការបោះឆ្នោតឡើយ[218]។

### ៤.៣. ភារកិច្ច និងអំណាចនៃស្ថាប័នគ្រប់គ្រងការបោះឆ្នោត

គណៈកម្មការរៀបចំការបោះឆ្នោត (COMELEC) មានមុខងាររដ្ឋបាលចំបងក្នុងការពង្រឹងការអនុវត្តន៍ និងគ្រប់គ្រងរាល់ច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធនឹងការប្រតិបត្តិនៃការបោះឆ្នោត ការធ្វើប្រជាមតិ និងការបោះឆ្នោតបញ្ចប់អណត្តិ[219]។ ដើម្បីបំពេញអាណត្តិការងារនេះប្រកបដោយប្រសិទ្ធភាព រដ្ឋធម្មនុញ្ញផ្តល់ឲ្យគណៈកម្មការរៀបចំការបោះឆ្នោត (COMELEC) នូវសមត្ថកិច្ចក្នុងការសម្រេចចិត្តលើរាល់បញ្ហានានាពាក់ព័ន្ធនឹងការបោះឆ្នោតរួមមាន ការកំណត់ចំនួននិងទីតាំងនៃមណ្ឌលបោះឆ្នោត ការតែងតាំងមន្ត្រីបោះឆ្នោតនិងមន្ត្រីអធិការកិច្ច និងការចុះឈ្មោះបោះឆ្នោត[220]។ លើសពីនេះ គណៈកម្មការក៏ត្រូវបានផ្តល់សិទ្ធិអំណាចជូនក្នុងការចុះបញ្ជីសម្ព័ន្ធអង្គការ និងតែងតាំងស្ថាប័នគ្រប់គ្រងការបោះឆ្នោតថ្នាក់ស្រុក[221] និងតាមរយៈការឯកភាពពីប្រធានាធិបតីតំណាងឲ្យភ្នាក់ងារពង្រឹងការអនុវត្តច្បាប់ និងកងកម្លាំងប្រដាប់អាវុធរបស់ប្រទេសហ្វីលីពីន ក្នុងគោលបំណងធានាឲ្យការបោះឆ្នោតប្រព្រឹត្តទៅប្រកបដោយភាពសេរី មានសណ្តាប់ធ្នាប់ ស្មោះត្រង់ សន្តិភាព និងអាចជឿជាក់បាន[222]។ តាមរយៈការផ្តួចផ្តើមរបស់ខ្លួន ឬការឆ្លើយតបទៅបណ្តឹងគណៈកម្មការរៀបចំការបោះឆ្នោត (COMELEC) អាចធ្វើញត្តិនៅក្នុងតុលាការសម្រាប់ការដាក់បញ្ចូលឬដកចេញនូវឈ្មោះអ្នកបោះឆ្នោត និងក្នុងការស្វែងរកការបំពានច្បាប់បោះឆ្នោតដែល អាចកើតមាន[223]។

មុខងាររបស់គណៈកម្មការរៀបចំការបោះឆ្នោត (COMELEC) ក្នុងការផ្តល់អនុសាសន៍ អនុញ្ញាតឲ្យខ្លួនអាចស្នើទៅសមាជនូវវិធានការណ៍នានា ដើម្បីកាត់បន្ថយការចំណាយនៃការបោះឆ្នោតឲ្យនៅទាបបំផុត ដើម្បីទប់ស្កាត់និងដាក់ទណ្ឌកម្មទៅលើរាល់ទំរង់នៃបទល្មើសនៃការបោះឆ្នោតមានដូចជា ការក្លែង

---

[217] តាមសេចក្តីយោងខាងលើ (Ibid)

[218] រដ្ឋធម្មនុញ្ញហ្វីលីពីន ឆ្នាំ១៩៨៧ «*គណៈកម្មការរៀបចំការបោះឆ្នោត*» ផ្នែកទី ១(១)

[219] ផ្នែកទី ២(១) នៃរដ្ឋធម្មនុញ្ញហ្វីលីពីន ឆ្នាំ១៩៨៧

[220] ផ្នែកទី ២(៣) នៃរដ្ឋធម្មនុញ្ញហ្វីលីពីន ឆ្នាំ១៩៨៧

[221] ផ្នែកទី ២(៥) នៃរដ្ឋធម្មនុញ្ញហ្វីលីពីន ឆ្នាំ១៩៨៧

[222] ផ្នែកទី ២(៤) នៃរដ្ឋធម្មនុញ្ញហ្វីលីពីន ឆ្នាំ១៩៨៧

[223] ផ្នែកទី ២(៦) នៃរដ្ឋធម្មនុញ្ញហ្វីលីពីន ឆ្នាំ១៩៨៧ *«រួមមាន ទាំងអំពើ ឬ កំហុសដែលចាត់ទុកថាជា ការបន្លំបោកប្រាស់ បទល្មើស នឹង ការអនុវត្តន៍ដែលមិនត្រឹមត្រូវតាមច្បាប់»*

បន្លំ ការអនុវត្តមិនត្រឹមត្រូវ និងបេក្ខភាពរំខាន[224]។ ស្រដៀងគ្នានេះ គណៈកម្មការនេះក៏អាចផ្តល់នូវអនុសាសន៍ជូនប្រធានាធិបតីអំពី ការដកចេញពីតំណែងនៃមន្ត្រីឬបុគ្គលិកណាមួយដែលខ្លួនបានតែងតាំងជាតំណាង ឬអំពីការដាក់ចេញនូវសកម្មភាពវិន័យផ្សេងទៀតណាមួយសម្រាប់ការអនុវត្តន៍ខុសពីការណែនាំរបស់ខ្លួន[225]។ លើសពីនេះ គណៈកម្មការរៀបចំការបោះឆ្នោត (COMELEC) ក៏មានមុខងារ រាយការណ៍ផងដែរ តាមរយៈការផ្តល់ជូនប្រធានាធិបតីនិងសមាជនូវរបាយកាណ៍ពិស្តារស្តីពីការប្រតិបត្តិ នៃការបោះឆ្នោតនិងការធ្វើប្រជាមតិ[226]។

គណៈកម្មការរៀបចំការបោះឆ្នោត (COMELEC) ក៏មានយុត្តាធិការចំបងទៅលើរាល់កិច្ចការ ពាក់ព័ន្ធនឹងការបោះឆ្នោត លទ្ធផលនៃការបោះឆ្នោត និងលក្ខណៈសម្បត្តិគុណវុឌ្ឍិនៃរាល់មន្ត្រីក្រុង ខេត្ត និងតំបន់ ហើយសេចក្តីសម្រេចរបស់គណៈកម្មការនេះជាសេចក្តីសម្រេចចុងក្រោយប្រសិនបើពាក់ពន្ធ័នឹងមន្ត្រីក្រុង[227]។ ផ្ទុយទៅវិញ មានតុលាការជាច្រើនផ្សេងទៀតដែលជាមជ្ឈត្តករសម្រាប់ការដោះស្រាយក្នុងទំនាស់ចំពោះបញ្ហាលទ្ធផលនៃការបោះឆ្នោតសម្រាប់ការិយាល័យរដ្ឋផ្សេងៗ។ បញ្ហាទាំងនេះមានបង្ហាញពិស្តារនៅផ្នែក៤.៤ ខាងក្រោម។

ករណីដោយឡែកនៅទីនេះគឺ គណៈកម្មការរៀបចំការបោះឆ្នោត (COMELEC) ពុំមានសមត្ថកិច្ចក្នុងការសម្រេចទៅលើបញ្ហាពាក់ព័ន្ធ និងសិទ្ធិបុគ្គលក្នុងការបោះឆ្នោតដែលជាបញ្ហារដ្ឋធម្មនុញ្ញនោះទេ ហើយទំនាស់ពាក់ព័ន្ធបញ្ហានេះគឺត្រូវដោះស្រាយតាមរយៈតុលាការ[228]។

## ៤.៤. ភ្នាក់ងារពាក់ព័ន្ធដែលបានជួយសម្របសម្រួលដល់ការបោះឆ្នោត

- *តុលាការនៃការបោះឆ្នោតរបស់ប្រធានាធិបតី(PET)*

តុលាការនៃការបោះឆ្នោតរបស់ប្រធានាធិបតី(PET) គឺជាតុលាការឯករាជ្យ ដែលបង្កើតឡើង ដើម្បីព្យាយាមដោះស្រាយ ទទួលព័ត៌មាន និងសម្រេចចិត្តទៅលើការតវ៉ាពាក់ព័ន្ធនឹងការបោះឆ្នោតសម្រាប់ការិយាល័យប្រធានាធិបតី និងអនុប្រធានាធិបតីនៃប្រទេសហ្វីលីពីន[229]។ ប្រធានតុលាការនៃការបោះឆ្នោតរបស់ប្រធានាធិបតី (PET) មានសមាជិកចំនួន៩(ប្រាំបួន)រូប។ ដែលសមាជិក៧រូបត្រូវតែជាចៅក្រមនៃតុលាការកំពូល និងត្រូវបានតែងតាំងដោយប្រធាននៃអង្គចៅក្រមដែលជាប្រធានតុលាការ នៃការបោះ

[224] ផ្នែកទី ២(៧) នៃរដ្ឋធម្មនុញ្ញហ្វីលីពីន ឆ្នាំ១៩៨៧
[225] ផ្នែកទី ២(៨) នៃរដ្ឋធម្មនុញ្ញហ្វីលីពីន ឆ្នាំ១៩៨៧
[226] ផ្នែកទី ២(៩) នៃរដ្ឋធម្មនុញ្ញហ្វីលីពីន ឆ្នាំ១៩៨៧
[227] ផ្នែកទី ២(២) នៃរដ្ឋធម្មនុញ្ញហ្វីលីពីន ឆ្នាំ១៩៨៧
[228] ផ្នែកទី ២(៣) នៃរដ្ឋធម្មនុញ្ញហ្វីលីពីន ឆ្នាំ១៩៨៧
[229] *ច្បាប់ Batas PambansaBlg. ៨៨៤* កាលពីថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ ២០១៣ ពី http://www.lawcenter.ph/law-library/laws/batas-pambansa/an-act-constituting-an-independent-presidential-electoral-tribunal-to-try-hear-and-decide-election-contests-in-the-office-of-president-and-vice-president-of-the-philippines-appropriating-funds-there/

ឆ្នោតរបស់ប្រធានាធិបតី (PET) ផងដែរ[230]។ ៦(ប្រាំមួយ)រូបទៀតត្រូវបានជ្រើសរើស ចេញពីសមាជិកព្រឹទ្ធសភា ឬរដ្ឋសភា ដែលអ្នកទាំងនេះត្រូវបានជ្រើសរើសដោយផ្អែកលើតំណាងតាម សមាមាត្រនៃគណបក្សនយោបាយ[231]។ តុលាការនៃការបោះឆ្នោតរបស់ប្រធានាធិបតី(PET) មានអំណាច ដូចគ្នាទៅនឹងតុលាការទូទៅដូចជា សមត្ថកិច្ចក្នុងការចេញដីកាតុលាការ និងតម្រូវឲ្យមានការអនុវត្តអនុលោមទៅតាមបទបញ្ជារបស់ខ្លួន[232]។ ជាក់ស្តែង តុលាការនៃការបោះឆ្នោតរបស់ប្រធានាធិបតី(PET) មានអំណាចក្នុងការផ្តល់អនុសាសន៍ចំពោះការចោទប្រកាន់ជាបន្ទាន់ទៅលើបុគ្គលដែលខ្លួនរកឃើញថា បានចូលរួមនៅក្នុងភាពមិនប្រក្រតីនៃការបោះឆ្នោតណាមួយ[233]។

លើសពីនេះ តុលាការនៃការបោះឆ្នោតរបស់ប្រធានាធិបតី (PET) ត្រូវបានផ្តល់សិទ្ធិអំណាចជូនក្នុងការដាក់ឬរក្សាហិបឆ្នោត លទ្ធផលបោះឆ្នោត និងរាល់វត្ថុប្រើប្រាស់សម្រាប់ការបោះឆ្នោតនៅទីតាំងដែលមានសន្តិសុខនិងសុវត្ថិភាព ក្រោមការការពាររបស់អ្នកតំណាងដែលខ្លួនបានតែងតាំង។ តុលាការនៃការបោះឆ្នោតរបស់ប្រធានាធិបតី (PET) ក៏ទទួលខុសត្រូវដោះស្រាយទំនាស់ពាក់ព័ន្ធនឹងលទ្ធផលបោះឆ្នោតផងដែរ។

- *តុលាការនៃការបោះឆ្នោតរបស់ព្រឹទ្ធសភា(SET)*

យោងតាមរដ្ឋធម្មនុញ្ញ តុលាការនៃការបោះឆ្នោតរបស់ព្រឹទ្ធសភា(SET) គឺជាសមត្ថកិច្ចតែមួយដែលទទួលខុសត្រូវលើរាល់ការបោះឆ្នោតព្រឹទ្ធសភា[234]។ តុលាការនៃការបោះឆ្នោតរបស់ព្រឹទ្ធសភា(SET)គឺជាតុលាការឯករាជ្យនិងអព្យាក្រឹត្យដែលមានសមាជិកចំនួន៩រូប។ ៣(បី)រូបគឺជាចៅក្រមនៃតុលាការកំពូល និង ត្រូវបានតែងតាំងដោយប្រធាននៃអង្គចៅក្រម ហើយ៦(ប្រាំមួយ)រូបទៀតគឺជាសមាជិកព្រឹទ្ធសភាដែលត្រូវបានជ្រើសរើសដោយផ្អែកលើតំណាងតាមសមាមាត្រនៃគណបក្សនយោបាយ[235]។

- *តុលាការនៃការបោះឆ្នោតរបស់រដ្ឋសភា(HRET)*

ស្រដៀងគ្នាទៅនឹងព្រឹទ្ធសភា ការបោះឆ្នោតរដ្ឋសភាក៏ត្រូវបានគ្រប់គ្រង ដោយតុលាការនៃការបោះឆ្នោតរដ្ឋសភាដែលដើរតួនាទីជាចៅក្រមតែមួយគត់នៃការតវ៉ានានាពាក់ព័ន្ធនឹងការបោះឆ្នោតរដ្ឋសភា[236]។ តុលាការនៃការបោះឆ្នោតរបស់រដ្ឋសភា(HRET) មានសមាជិកចំនួន៩រូប ៣រូបគឺជាចៅក្រម

---

[230] ផ្នែកទី១ នៃ *ច្បាប់ Batas PambansaBlg. ៨៨៤*

[231] ផ្នែកទី១ នៃ *ច្បាប់ Batas PambansaBlg. ៨៨៤*

[232] ផ្នែកទី៨ផ្នែកទី១ នៃ *ច្បាប់ Batas PambansaBlg. ៨៨៤* ៖ "*ការធ្វើសក្ខីកម្ម ការចាប់ឃុំសាក្សី ក្នុងគោលបំណងបង្ខំឲ្យពួកគេបង្ហាញខ្លួន ការបង្កើតនូវឯកសារ នឹង ភស្តុតាងដទៃទៀត*»

[233] ផ្នែកទី៩ផ្នែកទី១ នៃ *ច្បាប់ Batas PambansaBlg. ៨៨៤* ៖ ការរំខាននូវលទ្ធផលបោះឆ្នោត ក្នុងរូបភាព ខកខានក្នុងការចុះហត្ថលេខា នឹងផ្តិតស្នាមមេដៃដែល ចាំបាច់ដោយសមាជិកណាមួយ ឬក៏សមាជិកនៃគណៈកម្មការអង្កេតការបោះឆ្នោត ឬក៏គណៈកម្មការត្រួតពិនិត្យ ឬក៏ការពន្យារពេលដែលមិនចាំ បាច់ ក្នុងការផ្ញើរ ឬបញ្ជូន នៃលទ្ធផលបោះឆ្នោត ឬក៏ដឹកជញ្ជូន នឹងទុកនូវនៃប្រអប់ឆ្នោត

[234] ផ្នែកទី១៧ នៃរដ្ឋធម្មនុញ្ញប្រទេសហ្វីលីពីន ឆ្នាំ១៩៨៧

[235] ផ្នែកទី១៧ នៃរដ្ឋធម្មនុញ្ញប្រទេសហ្វីលីពីន ឆ្នាំ១៩៨៧

[236] «*សមាជនៃហ្វីលីពីន*» បានទាញយកកាល ថ្ងៃទី០៨ វិច្ឆិកា ឆ្នាំ ២០១៣ ពី http://www.dbm.gov.ph/wp-content/OPCCB/OPIF2012/Congress/Congress.pdf.

មកពីតុលាការកំពូលដែលតែងតាំងដោយប្រធានចៅក្រម រីឯ៦រូបទៀតជាសមាជិករដ្ឋសភា ដែលត្រូវបាន ជ្រើសរើសយោងតាមតំណាងតាមសមាមាត្ររបស់គណបក្សនយោបាយនៅក្នុងសភា។ តុលាការនេះ មានចៅក្រមជាន់ខ្ពស់ជាប្រធាន[237]។

- *តុលាការស៊ើបសួរថ្នាក់តំបន់ (RTC)*

តុលាការស៊ើបសួរថ្នាក់តំបន់ (RTC) ជាតុលាការកម្រិតទីពីរ មានយុត្តាធិការក្នុងការដោះស្រាយវិវាទរដ្ឋប្បវេណី វិវាទព្រហ្មទណ្ឌ យុត្តាធិការដំបូង និងយុត្តាធិការសាលាឧទ្ធរណ៍[238]។ តំបន់នីមួយៗនៃតំបន់ទាំង១៣ គឺសុទ្ធសឹងតែមានតុលាការស៊ើបសួរថ្នាក់តំបន់ (RTC)[239] ដែលទទួលខុសត្រូវក្នុងការដោះស្រាយទំនាស់នៃលទ្ធផលបោះឆ្នោតថ្នាក់ក្រុង[240]។

## ៥. ប្រទេសឥណ្ឌូនេស៊ី

### ៥.១. រចនាសម្ព័ន្ធ សមាសភាព និងទិដ្ឋភាពទូទៅនៃ ស្ថាប័នគ្រប់គ្រងការបោះឆ្នោត

គណៈកម្មការជាតិរៀបចំការបោះឆ្នោត(KPU) ត្រូវបានបង្កើតឡើងតាមរយៈកំណែទម្រង់រដ្ឋធម្មនុញ្ញឆ្នាំ២០០១ ដែលបានអនុម័តដោយសភាក្រុមប្រឹក្សាប្រជាជន(MPR)[241]។ អាណត្តិ រចនាសម្ព័ន្ធ និងអំណាចរបស់គណៈកម្មការជាតិរៀបចំការបោះឆ្នោត(KPU) ត្រូវបានចុះនៅក្នុងក្រឹត្យរបស់ប្រធានាធិបតីលេខ៧០ ឆ្នាំ២០០១ ស្តីពី"ការបង្កើតគណៈកម្មការជាតិរៀបចំការបោះឆ្នោត"។ នៅក្នុង២០០៧ ការអនុម័តច្បាប់២២/២០០៧ បានបង្កើតនូវគណៈកម្មការជាតិរៀបចំការបោះឆ្នោត(KPU) ថ្មី អចិន្ត្រៃយ៍ និងមិនចូលបក្សសម្ព័ន្ធដែលមានសមាជិកចំនួន១១(ដប់មួយ)រូប[242]។ នៅក្នុងឆ្នាំ២០១១ ច្បាប់នេះត្រូវបានជំនួសដោយច្បាប់១៥/២០១១ ដែលបានកាត់បន្ថយសមាជិកភាពរបស់គណៈកម្មការជាតិរៀបចំការបោះឆ្នោត (KPU) មកត្រឹម៧(ប្រាំពីរ)រូប សម្រាប់អាណត្តិរយៈពេល៥(ប្រាំ)ឆ្នាំ ដែលមានប្រធានត្រូវបានជ្រើសរើសចេញពីសមាជិករបស់ខ្លួនផ្ទាល់។ ចាប់តាំងពីការបង្កើតគណៈកម្មការជាតិរៀបចំការបោះឆ្នោត (KPU)

---

237 ផ្នែកទី១៧ នៃរដ្ឋធម្មនុញ្ញប្រទេសហ្វីលីពីន ឆ្នាំ១៩៨៧

238 «*ច្បាប់រៀបចំឡើងវិញនៃប្រព័ន្ធតុលាការ១៩៨០(The Judiciary Reorganization Act)*» ផ្នែកទី ១៩ ២០ ២១ ២២ បានទាញយកនៅថ្ងៃទី ១២ វិច្ឆិកា ឆ្នាំ ២០១៣ ពី http://www.chanrobles.com/bataspambansabilang129.html.

239 សូមមើលតាមច្បាប់ដែលរៀបរាប់ខាងលើ

240 «*ក្រមបោះឆ្នោត(Ominibus Election Code)*» មាត្រាXXI ផ្នែកទី២៥១ និង ២៥២ បានទាញយកពី http://www.comelec.gov.ph/?r=References/RelatedLaws/OmnibusElectionCode/OECArt21&bn=Back+to+Search+Results&b=search%26searchbox%3DOmnibus%2Bcode%23ps2034

241 រដ្ឋធម្មនុញ្ញប្រទេសឥណ្ឌូនេស៊ី មាត្រា ២២E (៥)

242 កម្មវិធីអភិវឌ្ឍនៃអង្គការសហប្រជាជាតិ(United Nations Development Programme(UNDP)), Multi-Donor Programme - Support to Indonesia's Democratic Elections (Elections MDP) ទំព័រទី៧

អង្គភាពនេះទទួលបានជោគជ័យក្នុងការដំណើរការការបោះឆ្នោតសភា និងការបោះឆ្នោតប្រធានាធិបតីនៅក្នុងឆ្នាំ២០០៤ និង ២០០៩[243]។

គណៈកម្មការជាតិរៀបចំការបោះឆ្នោត(KPU) គឺជាគណៈកម្មការអចិន្ត្រៃយ៍និងឯករាជ្យ មិនទទួលរងឥទ្ធិពលពីភ្នាក់ងារនយោបាយណាមួយឡើយ[244]។ ជារចនាសម្ព័ន្ធរបស់គណៈកម្មការជាតិរៀបចំការបោះឆ្នោត (KPU) បែងចែងដំណើរការរបស់ខ្លួនចេញជាស្ថាប័ន/ការិយាល័យអចិន្ត្រៃយ៍ទទួលខុសត្រូវលើអ្នកបោះឆ្នោតសរុបតាមតំបន់និងខេត្ត។

គណៈកម្មការជាតិរៀបចំការបោះឆ្នោត(KPU) ទទួលខុសត្រូវលើរាល់ការងាររដ្ឋបាល និង ភស្តុភារពាក់ព័ន្ធនឹងការបោះឆ្នោត មុខងាររបស់ខ្លួនត្រូវបានត្រួតពិនិត្យដោយស្ថាប័នត្រួតពិនិត្យការបោះឆ្នោតដែលដើរតួនាទីជាភ្នាក់ងារត្រួតពិនិត្យការអនុវត្តតាមបទបញ្ញត្តិ។ អង្គភាពទាំងពីរនេះមានពណ៌នាពិស្តារនៅផ្នែក៥.៤ ខាងក្រោម។

## ៥.២. របៀបដែលសមាជិកត្រូវបានតែងតាំងទៅស្ថាប័នគ្រប់គ្រងការបោះឆ្នោត

សមាជិករបស់គណៈកម្មការជាតិរៀបចំការបោះឆ្នោត(KPU) ត្រូវមានអាយុយ៉ាងហោចណាស់៣៥(សាមសិបប្រាំ)ឆ្នាំ ជាប្រជាពលរដ្ឋឥណ្ឌូនេស៊ីដែលមានសញ្ញាប័ត្រយ៉ាងហោចណាស់ត្រឹមកម្រិតបរិញ្ញាប័ត្របូករួមទាំងចំណេះដឹងពាក់ព័ន្ធនឹងដំណើរការនៃការបោះឆ្នោត។ សមាជិកទាំងនេះមិនត្រូវជាសមាជិកនៃគណបក្សនយោបាយណាមួយមិនមានកាន់មុខនាទីនយោបាយនៅក្នុងជួររដ្ឋាភិបាល ឬក្រុមហ៊ុនរបស់រដ្ឋ ពុំមានកំណត់ត្រាបទល្មើសណាមួយ និងមិនមែនជាប្រពន្ធប្តីរបស់បេក្ខជនឈរឈ្មោះបោះឆ្នោតណាមួយឡើយ[245]។ សមាជិកទាំង៧(ប្រាំពីរ)រូបរបស់គណៈកម្មការជាតិរៀបចំការបោះឆ្នោត(KPU) ត្រូវតែងតាំងដោយការបោះឆ្នោតនៅក្នុងរដ្ឋសភាចេញពីបញ្ជីឈ្មោះបេក្ខជនទាំង១៤ (ដប់បួន)រូបដែលផ្តល់ដោយប្រធានរដ្ឋសភា[246]។

## ៥.៣. ភារកិច្ច និងអំណាចនៃស្ថាប័នគ្រប់គ្រងការបោះឆ្នោត

គណៈកម្មការជាតិរៀបចំការបោះឆ្នោត(KPU) ទទួលខុសត្រូវអនុវត្ត និងគ្រប់គ្រងការបោះឆ្នោតជាតិជ្រើសប្រធានាធិបតីនិង អនុប្រធានាធិបតី ការបោះឆ្នោតសភាថ្នាក់ជាតិនិងថ្នាក់តំបន់ ការបោះឆ្នោតជ្រើសរើសអភិបាលខេត្តនិងអភិបាលក្រុង[247]។ យោងតាមមាត្រា៨ នៃច្បាប់ស្តីពីភ្នាក់ងារគ្រប់គ្រងការបោះឆ្នោតដែលបានអនុម័តនៅក្នុងឆ្នាំ២០១១ គណៈកម្មការជាតិរៀបចំការបោះឆ្នោត (KPU) មានភារកិច្ចនិងសមត្ថកិច្ចដូចខាងក្រោម៖

---

[243] តាមសេចក្តីយោងខាងលើ (Ibid) ទំព័រទី៧ និង ៨

[244] ច្បាប់លេខ ១៥/២០១១ ស្តីពីភ្នាក់ងារគ្រប់គ្រងការបោះឆ្នោត, ជំពូកទី ៣៖ មាត្រា ៣(៣) (បកប្រែក្រៅផ្លូវការ ដោយមូលនិធិអន្តរជាតិសំរាប់ប្រព័ន្ធបោះឆ្នោត(IFES))

[245] មាត្រា ១១(a,b,e,f,l,m) នៃច្បាប់លេខ ១៥/២០១១

[246] មាត្រា ១២ (២)(៤) នៃច្បាប់លេខ ១៥/២០១១

[247] មាត្រា ៨ នៃច្បាប់លេខ ១៥/២០១១

- ធ្វើផែនការ និងរៀបចំផែនការថវិការនិងកម្មវិធីពាក់ព័ន្ធនឹងដំណើរការនៃការបោះឆ្នោត
- បង្កើតយន្តការនិងនីតិវិធីដំណើរការជាស្តង់ដាសម្រាប់ដំណើរការនៃការបោះឆ្នោតនៅកម្រិតជាតិ ខេត្ត និងមូលដ្ឋាន
- ដាក់ចេញនូវការណែនាំទូទៅ និងជាលក្ខណៈបច្ចេកទេសសម្រាប់ដំណាក់កាលនីមួយៗនៃដំណើរការនៃការបោះឆ្នោត[248]
- រៀបចំ សម្របសម្រួល វាយតម្លៃ និងត្រួតពិនិត្យរាល់ដំណើរការនៃការបោះឆ្នោត
- រៀបចំកសាង និងធ្វើឲ្យមានសុពលភាពនូវបញ្ជីឈ្មោះបោះឆ្នោត និងទិន្នន័យការចុះឈ្មោះផ្អែកលើទិន្នន័យចំនួនប្រជាជនដែលបានរៀបចំនិងផ្តល់ជូនដោយភ្នាក់ងាររដ្ឋាភិបាលផ្សេងទៀត
- ជ្រើសរើសការិយាល័យគណនេយ្យសាធារណៈដើម្បីធ្វើសវនកម្មលើមូលនិធិនៃយុទ្ធនាការបោះឆ្នោត និងរាយការណ៍អំពីលទ្ធផលដែលខ្លួនរកឃើញ
- ពិចារណាលើបណ្តឹងនៃបទល្មើសនៃច្បាប់បោះឆ្នោតនិងក្រមសីលធម៌ តាមរយៈការតាមដាននូវលទ្ធផលដែលរកឃើញ និងរបាយការណ៍ដែលគាំទ្រដោយអង្គភាពត្រួតពិនិត្យការបោះឆ្នោត
- បញ្ឈប់ជាបណ្តោះអាសន្ន ឬដាក់ទណ្ឌកម្មផ្នែករដ្ឋបាលទៅលើសមាជិកនៃក្រុមប្រឹក្សាត្រួតពិនិត្យការបោះឆ្នោតថ្នាក់ជាតិ ខេត្ត តំបន់/ក្រុង ដែលធ្វើឲ្យអន្តរាយដល់ការអនុវត្តន៍ ការបោះឆ្នោត និងការអនុវត្តន៍សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាកិត្តិយសនៃភ្នាក់ងារគ្រប់គ្រងការបោះឆ្នោត(DKPP)[249] និង
- បំពេញភារកិច្ចនិងកាតព្វកិច្ចផ្សេងទៀតដែលផ្តល់ដោយច្បាប់និងបទបញ្ញត្តិដែលសំដៅគ្រប់គ្រងដំណើរការបោះឆ្នោត។

## ៥.៤. ភ្នាក់ងារពាក់ព័ន្ធដែលបានជួយសម្របសម្រួលដល់ការបោះឆ្នោត

*ស្ថាប័នត្រួតពិនិត្យការបោះឆ្នោត*

[248] ការអនុវត្តនៃគោលការណ៍ណែនាំគឺផ្អែកលើ ច្បាប់លេខ ១០/២០០៨ ស្តីពីយន្តការបោះឆ្នោតទូទៅ នឹងច្បាប់លេខ ២/២០០៨ ស្តីពីគណបក្សនយោបាយ

[249] ពាក្យ DKPP តំណាងឲ្យ ក្រុមប្រឹក្សាជាកិត្តិយសនៃស្ថាប័នគ្រងគ្រងការបោះឆ្នោត (*DewanKehormatanPenyelenggaraPemilu*)

ក្នុងនាមជាសមត្ថកិច្ចត្រួតពិនិត្យរបស់គណៈកម្មការជាតិរៀបចំការបោះឆ្នោត(KPU) ស្ថាប័នត្រួតពិនិត្យការបោះឆ្នោតមានអំណាចដូចខាងក្រោម[250]៖

- ត្រួតពិនិត្យការរៀបចំការបោះឆ្នោតក្នុងលក្ខខ័ណ្ឌៈ ការធ្វើផែនការនិងភស្តុភារ ការកំណត់មណ្ឌលបោះឆ្នោត ការផ្សព្វផ្សាយព័ត៌មានស្តីពីការបោះឆ្នោត និងការត្រួតពិនិត្យមុខងារបោះឆ្នោតដូចបានកំណត់នៅក្នុងច្បាប់បោះឆ្នោត
- ត្រួតពិនិត្យដំណើរការនៃការបោះឆ្នោតរួមមានៈ ការផ្តល់ទិន្នន័យដ៏ថ្មីបំផុតរបស់អ្នកបោះឆ្នោត ការបញ្ជាក់អំពីបេក្ខជនឈរឈ្មោះបោះឆ្នោត ត្រួតពិនិត្យដំណើរការនៃការតែងតាំង ការរាប់សន្លឹកឆ្នោត និងការបញ្ជាក់អំពីលទ្ធផលបោះឆ្នោត
- ត្រួតពិនិត្យការដោះស្រាយបណ្តឹងពាក់ព័ន្ធនឹង បទល្មើសនៃការបោះឆ្នោតដោយស្ថាប័នមានសមត្ថកិច្ច និងត្រួតពិនិត្យការដាក់ទណ្ឌកម្មទៅលើអ្នកទាំងឡាយដែលត្រូវបានរកឃើញថាមានទោសដោយអាជ្ញាធរដែលពាក់ព័ន្ធ
- វាយតម្លៃ និងធ្វើរបាយការណ៍ស្តីពីការត្រួតពិនិត្យដំណើរការនៃការបោះឆ្នោត និង
- បង្កើតស្ថាប័នត្រួតពិនិត្យការបោះឆ្នោតថ្នាក់ខេត្ត និង តែងតាំងនិងបញ្ឈប់សមាជិកនៃស្ថាប័នត្រួតពិនិត្យការបោះឆ្នោតថ្នាក់ខេត្ត។

*អង្គភាពមានសមត្ថកិច្ច* - ស្ថាប័នត្រួតពិនិត្យការបោះឆ្នោតទទួលខុសត្រូវត្រួតពិនិត្យការអនុវត្តន៍ការបោះឆ្នោតនៅក្នុងប្រទេសឥណ្ឌូនេស៊ី(ច្បាប់លេខ០៨ មាត្រា១(១៧))។ នីតិវិធីក្នុងការដោះស្រាយវិវាទនៃការបោះឆ្នោតគឺតម្រូវដោយច្បាប់ (ច្បាប់លេខ០៨ មាត្រា២៥៧ និងមាត្រាបន្ទាប់) ដែលបានកំណត់ថាស្ថាប័នត្រួតពិនិត្យការបោះឆ្នោតជាស្ថាប័នមានសមត្ថកិច្ច។ នីតិវិធីដោះស្រាយវិវាទទាំងនេះមានកំណត់យ៉ាងពិស្តារនៅក្នុងច្បាប់លេខ០៨។ ប្រការនេះកំណត់នូវនីតិវិធីទូទៅមួយ និងទុកឲ្យស្ថាប័នត្រួតពិនិត្យការបោះឆ្នោតកំណត់ពីនីតិវិធីជាក់លាក់តាមរយៈបទបញ្ញត្តិដ៏ពិស្តារ។ ដំបូងច្បាប់កំណត់ថារបាយការណ៍ និងលទ្ធផលដែលរកឃើញពាក់ព័ន្ធនឹងទំនាស់ ត្រូវបញ្ជូនទៅអង្គភាពត្រួតពិនិត្យការបោះឆ្នោត។ ផ្អែកលើឯកសារដែលទទួលបាន ស្ថាប័នត្រួតពិនិត្យការបោះឆ្នោត ត្រូវរៀបចំកិច្ចប្រជុំដំបូងរវាងភាគីនៃវិវាទដោយព្យាយាមតាមរយៈការពិភាក្សានិងការមូលមតិសម្រេចឲ្យនូវការឯកភាពរួមគ្នា។ ស្ថាប័នត្រួតពិនិត្យការបោះឆ្នោត ត្រូវធ្វើសេចក្តីសម្រេចចិត្ត តាមរយៈការមូលមតិរវាងសមាជិករបស់ខ្លួន។ សេចក្តីសម្រេចចិត្តរបស់ស្ថាប័នត្រួតពិនិត្យការបោះឆ្នោតលើវិវាទណាមួយដែលស្ថិតក្រោមយុត្តាធិការរបស់ខ្លួនគឺបិទផ្លូវតវ៉ា ហើយមានលក្ខណៈចាប់បង្ខំ ដែលភាគីវិវាទត្រូវតែអនុវត្តតាមជាដាច់ខាត លើកលែងតែ វិវាទពាក់ព័ន្ធនឹងការបញ្ជាក់នូវលក្ខណៈសម្បត្តិគុណវឌ្ឍិនៃគណបក្សនយោបាយដែលចូលរួមប្រកួតប្រជែង និងបញ្ជីឈ្មោះចុងក្រោយនៃបេក្ខជនសម្រាប់ការឈរឈ្មោះជាសមាជិកនៃអាជ្ញាធរ តាម

[250] មាត្រា ៨ នៃច្បាប់លេខ ១៥/២០១១

ថ្នាក់មូលដ្ឋាននានា។ ចំពោះករណីលើកលែងទាំងនេះ ភាគីចុងចោទមានសិទ្ធិប្តឹងទៅតុលាការរដ្ឋបាលរបស់រដ្ឋ។

*ក្រុមប្រឹក្សាកិត្តិយសនៃភ្នាក់ងារគ្រប់គ្រងការបោះឆ្នោត(DKPP)*

ក្រុមប្រឹក្សាកិត្តិយសនៃភ្នាក់ងារគ្រប់គ្រងការបោះឆ្នោត(DKPP) ត្រូវបានបង្កើតឡើងជាក្រុមប្រឹក្សាសីលធម៌ថ្នាក់ជាតិអចិន្ត្រៃយ៍។ សមាជិករបស់ក្រុមប្រឹក្សានេះត្រូវចាប់ផ្តើមកិច្ចប្រជុំដំបូងរបស់ខ្លួនមិនឲ្យលើសពីពីរខែបន្ទាប់ពីសមាជិករបស់ គណៈកម្មការជាតិរៀបចំការបោះឆ្នោត (KPU) និងសមាជិករបស់ស្ថាប័នត្រួតពិនិត្យការបោះឆ្នោតបានស្បថចូលកាន់តំណែង[251]។ សមាសភាពរបស់ក្រុមប្រឹក្សាកិត្តិយសនៃភ្នាក់ងារគ្រប់គ្រងការបោះឆ្នោត (DKPP) រួមមាន តំណាង១រូបពីគណៈកម្មការជាតិរៀបចំការបោះឆ្នោត (KPU) តំណាង១រូបពីស្ថាប័នត្រួតពិនិត្យការបោះឆ្នោត តំណាង១រូបពីគណបក្សនយោបាយនីមួយៗ ដែលមានអាសនៈនៅក្នុងរដ្ឋសភា តំណាង១រូបពីរដ្ឋាភិបាល និងថ្នាក់ដឹកនាំសហគមន៍៤[252] ឬ ៥រូប[253]។ រាល់សមាជិកទាំងអស់របស់ក្រុមប្រឹក្សាកិត្តិយសនៃភ្នាក់ងារគ្រប់គ្រងការបោះឆ្នោត (DKPP) គឺមានអាណត្តិរយៈពេល៥ឆ្នាំ[254]។

ក្រុមប្រឹក្សា កិត្តិយសនៃភ្នាក់ងារគ្រប់គ្រងការបោះឆ្នោត(DKPP) ទទួលខុសត្រូវអនុវត្ត និងឯកភាពលើក្រមសីលធម៌ដើម្បីរក្សាឯករាជ្យភាព សុចរិតភាព និងភាពជឿជាក់ទៅលើសមាជិករបស់គណៈ-កម្មការជាតិរៀបចំការបោះឆ្នោត (KPU) និងសមាជិករបស់ស្ថាប័នត្រួតពិនិត្យការបោះឆ្នោត[255]។ លើសពីនេះ ក្រុមប្រឹក្សាកិត្តិយសនៃភ្នាក់ងារគ្រប់គ្រងការបោះឆ្នោត (DKPP) ក៏ទទួលខុសត្រូវក្នុងការត្រួតពិនិត្យឡើងវិញ និងសម្រេចចិត្តទៅលើបណ្តឹងនិង/ឬរបាយការណ៍នៃបទល្មើសដែលបានចោទប្រកាន់ពាក់ព័ន្ធនឹងក្រមសីលធម៌[256]។ ជាមួយគ្នានេះ ក្រុមប្រឹក្សាកិត្តិយសនៃភ្នាក់ងារគ្រប់គ្រងការបោះឆ្នោត (DKPP) ត្រូវបានផ្តល់សិទ្ធិអំណាចជូនក្នុងការផ្តល់អនុសាសន៍ចំពោះការបញ្ឈប់សមាជិករបស់គណៈកម្មការជាតិរៀបចំការបោះឆ្នោត(KPU)[257] និងសមាជិករបស់ស្ថាប័នត្រួតពិនិត្យការបោះឆ្នោតផងដែរ[258]។ សេចក្តី

[251] មាត្រា ១០៩(១) (៣) នៃច្បាប់លេខ ១៥/២០១១

[252] ប្រសិនបើ ចំនួននៃអ្នកតំណាងគណបក្សនយោបាយនៅក្នុងរដ្ឋសភា គឺមានចំនួនសេស

[253] ប្រសិនបើ ចំនួននៃអ្នកតំណាងគណបក្សនយោបាយនៅក្នុងរដ្ឋសភា គឺមានចំនួនគូ

[254] មាត្រា ១០៩(៤) (១០) នៃច្បាប់លេខ ១៥/២០១១

[255] មាត្រា ១១០ (១) នៃច្បាប់លេខ ១៥/២០១១

[256] មាត្រា ១០៩ (២) នៃច្បាប់លេខ ១៥/២០១១

[257] មាត្រា ២៨ នៃច្បាប់លេខ ១៥/២០១១

[258] មាត្រា ១០០ នៃច្បាប់លេខ ១៥/២០១១

សម្រេចរបស់ក្រុមប្រឹក្សាកិត្តិយសនៃភ្នាក់ងារគ្រប់គ្រងការបោះឆ្នោត (DKPP) គឺមានលក្ខណៈចាប់បង្ខំ និង បិទផ្លូវតវ៉ា[259]។

## V. ការវិភាគ

### ហិរញ្ញប្បទានសម្រាប់យុទ្ធនាការឃោសនាការបោះឆ្នោត

ក្នុងករណីហិរញ្ញប្បទានសម្រាប់យុទ្ធនាការឃោសនាការបោះឆ្នោត មានបញ្ហាចំបងចំនួនពីរដែលនឹងត្រូវដោះស្រាយ។ ទីមួយគឺការផ្តល់ហិរញ្ញប្បទានសាធារណៈ ដើម្បីដំណើរការការិយាល័យនយោបាយ និងទីពីរគឺដែនកំណត់នៃការចំណាយលើយុទ្ធនាការ។ ចំណុចទីមួយត្រូវបានទទួលស្គាល់ថាជាបញ្ហាដ៏សំខាន់ក្នុងការកាត់បន្ថយអំពីពុករលួយ និងសម្របសម្រួលឲ្យមានការចូលរួមប្រសើជាងមុនពីតំណាងគណបក្សនយោបាយ តាមរយៈការអនុញ្ញាតឲ្យបេក្ខជន ដែលពុំមានលទ្ធភាពទទួលបានមូលនិធិសម្រាប់ការធ្វើហិរញ្ញប្បទានសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត អាចដំណើរការការិយាល័យរបស់ខ្លួន ដូចនេះ ការផ្តល់ហិរញ្ញប្បទានសាធារណៈនេះ អាចជួយដល់ការចូលរួមឈរបោះឆ្នោតរបស់ប្រជាជន "សាមញ្ញ"។ ការកម្រិតនៃការចំណាយលើយុទ្ធនាការក៏ដើរតួនាទីស្រដៀងគ្នាផងដែរ។ ប្រការនេះជួយទប់ស្កាត់បុគ្គលដែលមានលទ្ធភាពទទួលបានមូលនិធិច្រើន មិនឲ្យប្រើប្រាស់ថវិកាច្រើនលើសលុបជាងគូរប្រកួតប្រជែងនៅក្នុងសកម្មភាពយុទ្ធនាការឃោសនាបោះឆ្នោតមានដូចជា ការផ្សាយពាណិជ្ជកម្ម ការរៀបចំកម្មវិធីនានា និងការធ្វើដំណើរទូទាំងប្រទេសដើម្បីធានាអំពីជោគជ័យរបស់ខ្លួនលើគូរប្រជែងដែលពុំសូវមានលទ្ធភាពខាងថវិកា។ សម្រាប់មូលហេតុទាំងនេះ ក្នុងរយៈពេលជាង២៥ឆ្នាំចុងក្រោយ ប្រទេសបារាំងនិងកូរ៉េខាង-ត្បូងបានកសាងនូវរបបដ៏ឆ្លាតវៃក្នុងការផ្តល់ហិរញ្ញប្បទានជាសាធារណៈចំពោះយុទ្ធនាការឃោសនាបោះឆ្នោតដើម្បីដាក់កម្រិតនិងធ្វើសវនកម្មលើការចំណាយ និងកាត់ទោសចំពោះអ្នកប្រព្រឹត្តល្មើស។ តែបើទោះបីជាខ្លួនមិនមានការផ្តល់ហិរញ្ញប្បទានជាសាធារណៈសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោតក៏នៅក្នុងឆ្នាំ២០១២ ប្រទេសហ្វីលីពីនបានបើកស្ថាប័នជំនាញខាងផ្តល់ហិរញ្ញប្បទានសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោតនៅក្នុងគណៈកម្មការរៀបចំការបោះឆ្នោតរបស់ខ្លួន ដើម្បីស៊ើបអង្កេតនិងពង្រឹងការអនុវត្តន៍ការដាក់កម្រិតលើការចំណាយសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោតនេះ។ ប៉ុន្តែដោយសារភាពស្មុគស្មាញនៅក្នុងការធ្វើសវនកម្មប្រកបដោយប្រសិទ្ធភាពលើសកម្មភាពនានារបស់គណបក្សនយោបាយ ប្រទេសហ្វីលីពីនក៏កំពុងព្យាយាមសម្រេចឲ្យបានចំពោះការប្រកាន់ខ្ជាប់ចំពោះដំណើរការនេះ។ ដូចគ្នានេះដែរ ដើម្បីអត្ថប្រយោជន៍ក្នុងការកាត់បន្ថយអំពើពុករលួយ និងការលើកកម្ពស់ការចូលរួមប្រកបដោយប្រជាធិបតេយ្យ ប្រទេសឥណ្ឌូនេស៊ីបានចាប់ផ្តើមនៅក្នុងឆ្នាំ១៩៩៩ ដោយធ្វើការណែនាំយន្តការនានាក្នុងការផ្តល់ហិរញ្ញប្បទានសាធារណៈសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត និងក្នុងការដាក់កម្រិតលើការចំណាយសម្រាប់យុទ្ធនាការនេះ។ ប៉ុន្តែមធ្យោបាយស្រដៀងគ្នាទៅនឹងប្រទេសហ្វីលីពីន

[259] មាត្រា ១១២ (១២) នៃច្បាប់លេខ ១៥/២០១១

ភាពសំបូរបែបនៅក្នុងការសម្រេចឲ្យបាននូវរបបហិរញ្ញប្បទាននយោបាយប្រកបដោយប្រសិទ្ធភាព នៅតែជាការងារដែលកំពុងដំណើរការទៅមុខជានិច្ច។

ការចាប់ផ្តើមនូវការផ្តល់ហិរញ្ញប្បទានសាធារណៈសម្រាប់យុទ្ធនាការនយោបាយ និងការកំណត់នូវចំណាយលើយុទ្ធនាការនយោបាយ អាចផ្តល់អត្ថប្រយោជន៍ជាច្រើនដល់ដំណើរការប្រកបដោយលក្ខណៈប្រជាធិបតេយ្យ។ ប៉ុន្តែដូចដែលប្រទេសហ្វីលីពីននិងឥណ្ឌូនេស៊ីបង្ហាញកិច្ចខិតខំប្រឹងប្រែងនេះគឺពិតជាមានលក្ខណៈសំបូរបែបពេក ហើយប្រសិនបើកិច្ចខិតខំប្រឹងប្រែងនេះចង់ទទួលបានជោគជ័យ គឺតម្រូវឲ្យមានយន្តការរាយការណ៍ដែលរៀបចំឡើងយ៉ាងល្អ រួមជាមួយនឹងការិយាល័យដែលមានធនធានគ្រប់គ្រាន់ជាមួយនឹងអ្នកជំនាញផ្នែកគណនេយ្យរបស់តុលាការ និងស្ថាប័នត្រួតពិនិត្យដែលមានជំនាញ និងមិនពាក់ព័ន្ធក្នុងរឿងនយោបាយ។ ប្រសិនបើពុំមានវិធីសាស្រ្តលំអិតដូចនៅក្នុងប្រទេសបារាំង និងកូរ៉េខាងត្បូងទេ ការចាប់ផ្តើមវិធានការណ៍នេះ អាចប្រែក្លាយទៅជាឧបសគ្គចំពោះការចូលរួមប្រកបដោយលក្ខណៈប្រជាធិបតេយ្យទៅវិញ។

### ការចុះឈ្មោះបោះឆ្នោត

ដោយសារកម្រិតការអភិវឌ្ឍសេដ្ឋកិច្ចខ្ពស់ជាងប្រទេសផ្សេងទៀត ដែលបានសិក្សានៅក្នុងឯកសារនេះ ប្រទេសបារាំងនិងកូរ៉េខាងត្បូងមានធនធានគ្រប់គ្រាន់ក្នុងការចាប់ផ្តើមប្រព័ន្ធនៃការចុះឈ្មោះបោះឆ្នោតដោយស្វ័យប្រវត្តិ តាមរយៈការប្រមូលព័ត៌មានរបស់អ្នកបោះឆ្នោតមកពីដេតាបេស ឌីជីថលរបស់រដ្ឋាភិបាល(digitalised government database)ជាច្រើន។ ប្រព័ន្ធទាំងនេះត្រូវចំណាយច្រើន មានលក្ខណៈបច្ចេកទេសសំបូរបែប និងយឺតយ៉ាវក្នុងការអនុវត្តន៍ ប៉ុន្តែបន្ទាប់ពីបានចាប់ផ្តើម អាចជួយកាត់បន្ថយចំណាយ និងកំហុសជាច្រើនដែលពាក់ព័ន្ធនឹងការដំណើរការការបោះឆ្នោត។ ប៉ុន្តែវិធីសាស្រ្តនេះមិនមែនជាជម្រើសដែលអាចអនុវត្តបាននៅគ្រប់ប្រទេសនោះទេ។ ឧទាហរណ៍ ប្រទេសឥណ្ឌូនេស៊ី មានបំណង ក្នុងការលើកកម្ពស់ភាពត្រឹមត្រូវនៃបញ្ជីឈ្មោះបោះឆ្នោត និងភាពប្រក្រតីនៃការបោះឆ្នោតរបស់ខ្លួនតាមរយៈការបង្កើតឲ្យមានឋានានុក្រមឯករាជ្យជាច្រើនក្នុងការត្រួតពិនិត្យការប្រតិបត្តិរបស់ការិយាល័យបោះឆ្នោត។

ដូចកម្ពុជាដែរ ឥណ្ឌូនេស៊ីមានសហគមន៍ដាច់ស្រយាលដែលពិបាកធ្វើដំណើរទៅមក ហើយការបង្កើតមណ្ឌលបោះឆ្នោតមានលក្ខណៈសំបូរបែប។ ស្រដៀងគ្នាដែរ មនុស្សជាច្រើនបានធ្វើចំណាកស្រុកដើម្បីស្វែងរកការងារនៅតំបន់ផ្សេងៗ។ ដើម្បីអនុញ្ញាតឲ្យប្រជាជនទាំងនេះអាចបោះឆ្នោតបាន ឥណ្ឌូនេស៊ីកំពុងតែបង្កើតនូវបញ្ជីឈ្មោះបោះឆ្នោត"បន្ថែម" ដែលក្នុងនោះអនុញ្ញាតឲ្យប្រជាជនអាចចុះឈ្មោះបោះឆ្នោតប្រសិនបើពួកគេមិនអាចត្រឡប់ទៅស្រុកកំណើតដើម្បីបោះឆ្នោតបាន។ ប្រទេសហ្វីលីពីនជួបប្រទះបញ្ហាស្រដៀងគ្នាផងដែរ ប៉ុន្តែប្រទេសនេះកំពុងដោះស្រាយបញ្ហាទាំងនេះតាមរយៈវិធីសាស្រ្តបច្ចេកទេសចំរុះរវាងប្រទេសបារាំងនិងកូរ៉េខាងត្បូង រីឯវិធីសាស្រ្តរបស់ឥណ្ឌូនេស៊ីគឺផ្តោតខ្លាំងលើបទបញ្ញត្តិ។ គណៈកម្មការបោះឆ្នោតរបស់ហ្វីលីពីនមានអំណាច និងភារកិច្ចធំទូលាយ ដែលរួមមានទាំងការបញ្ជូនមន្ត្រីបោះឆ្នោតទៅតាមផ្ទះប្រជាជន ដើម្បីធានាថា មនុស្សច្រើនតាមដែលអាចធ្វើទៅបាន

បានចុះឈ្មោះក្នុងបញ្ជីបោះឆ្នោត[260]។ ប៉ុន្តែសវនករបានបង្ហាញថា ៧,៥%នៃបញ្ជីបោះឆ្នោត ការចុះឈ្មោះមិនបានត្រឹមត្រូវនោះទេ។ ដើម្បីលើកកម្ពស់បញ្ហានេះ ហ្វីលីពីនបានចាប់ផ្ដើមកសាងបញ្ជីបោះឆ្នោតថ្មី ដែលតម្រូវឲ្យអ្នកបោះឆ្នោតនីមួយៗត្រូវ "កត់ឈ្មោះចូល" តាមរយៈទិន្នន័យជីវសញ្ញាណ (Biometric data) មានដូចជា ស្នាមម្រាមដៃជាមួយម៉ាស៊ីនស្កេនឌីជីថល។ បន្ទាប់មកទិន្នន័យជីវសញ្ញាណ (Biometric data) នេះ នឹងបញ្ចូលព័ត៌មានអ្នកបោះឆ្នោតនីមួយៗទៅក្នុងបញ្ជីបោះឆ្នោត និងដើម្បីធានាថាពុំមាននរណាម្នាក់អាចបោះឆ្នោតពីរដងនោះទេ។

ខណៈដែលប្រព័ន្ធប្រទេសបារាំង និងជាពិសេសប្រព័ន្ធប្រទេសកូរ៉េខាងត្បូងគឺជាវិធីសាស្រ្តដ៏ប៉ិនប្រសព្វ និងមានប្រសិទ្ធភាពជាងគេ ប្រព័ន្ធទាំងនេះក៏ជាប្រព័ន្ធដែលមានតម្រូវការផ្នែកបច្ចេកទេសខ្ពស់ និងតម្រូវឲ្យមានឌីជីថលនិយម(Digitalization)ខ្ពស់ ភាពប៉ិនប្រសព្វផ្នែកបច្ចេកវិទ្យាព័ត៌មាន និង សមាហរណកម្មអន្តរនាយកដ្ឋានផងដែរ។ ខណៈដែលតំបន់អាស៊ីគឺកំពុងស្ថិតនៅក្នុងដំណើរការនៃការ បង្កើតបទបញ្ញត្តិ ឬបទបញ្ជាថ្មីសម្រាប់ការចុះឈ្មោះបោះឆ្នោត និងការកំណត់អត្តសញ្ញាណអ្នកបោះឆ្នោតពុំមានបទពិសោធន៍ជាក់ស្តែងណាមួយអាចយកមកប្រើប្រាស់សម្រាប់ជាឧទាហរណ៍ទេ។ វិធីសាស្រ្តរបស់ហ្វីលីពីនអំពីការប្រើប្រាស់ទិន្នន័យជីវសញ្ញាណ (Biometric data) ដើម្បីចុះឈ្មោះនិងកំណត់អត្តសញ្ញាណអ្នកបោះឆ្នោតនីមួយៗអាចជាឧទាហរណ៍ដ៏ល្អសម្រាប់យកមកពិចារណាក្នុងការចុះឈ្មោះ និងបង្កើតបញ្ជីឈ្មោះបោះឆ្នោត។ យោងតាមភាពជាក់ស្តែង មានប្រទេសជាច្រើនប្រើប្រាស់ប្រព័ន្ធជីវសញ្ញាណ (Biometric data) នៅតាមប៉ុស្តិ៍អន្តោប្រវេសន៍នៃអាកាសយានដ្ឋានរបស់ខ្លួន ហើយបច្ចេកវិទ្យានេះប្រហែល ជាអាចផ្ទេរ សម្រាប់ប្រើប្រាស់ក្នុងការបង្កើតបញ្ជីឈ្មោះបោះឆ្នោតបាន។ កម្ពុជាមានបទពិសោធន៍ពី តម្រូវការ ចាំបាច់នៃបច្ចេកវិទ្យាក្នុងការអនុវត្តការងារនេះ។ បច្ចុប្បន្ន ប៉ុស្តិ៍ត្រួតពិនិត្យអន្តោប្រវេសន៍នៅអាកាសយានដ្ឋានភ្នំពេញ តម្រូវឲ្យមនុស្សដែលចេញនិងចូល ចុះព័ត៌មានតាមប្រព័ន្ធជីវសញ្ញាណ (Biometric data) ជាមួយនឹងម៉ាស៊ីនស្កេនមេដៃឌីជីថល ដែលបន្ទាប់មកឧបករណ៍នេះនឹងបញ្ជូនព័ត៌មាននានាទៅកាន់ឧបករណ៍ផ្ទុកព័ត៌មានឌីជីថល(digital storage facility)។ ដំណើរការស្រដៀងគ្នាក្នុងការប្រមូល និងរក្សាទុកទិន្នន័យជីវសញ្ញាណ (Biometric data) របស់បុគ្គលដែលនឹងត្រូវបន្ថែមទៅលើដំណើរការនៃការបោះឆ្នោត នឹងបង្ហាញពីមធ្យោបាយបច្ចេកទេសដែលអាចអនុវត្តបានក្នុងការលើកកម្ពស់ភាពត្រឹមត្រូវនៃបញ្ជីបោះឆ្នោត ធ្វើឲ្យមានលក្ខណៈឌីជីថលនិងបង្កើតនូវការចុះឈ្មោះបោះឆ្នោតរួមមួយ និង បង្កើនលទ្ធភាពរបស់ប្រជាជនក្នុងការបោះឆ្នោតនៅក្នុងតំបន់ដែលពួកគេមិនអាចចុះឈ្មោះបាន។ អត្ថប្រយោជន៍ចម្បងពីរនៃវិធីសាស្រ្តនេះ អាចមានដូចជា ភាពយុត្តិធម៌នៃការបោះឆ្នោតត្រូវបានលើកកម្ពស់នៅពេលដែលនេះបង្ហាញពីភាពត្រឹមត្រូវនៃបញ្ជីបោះឆ្នោត រីឯការចំណាយអាចត្រូវបានកាត់បន្ថយបន្ទាប់ពីចាប់ផ្តើមដំណើរការប្រព័ន្ធនេះនៅពេលដែលតម្រូវការមន្ត្រីរដ្ឋបាលកាន់តែតិចដើម្បីរៀបចំបញ្ជីឈ្មោះបោះឆ្នោតនៅតាមខេត្តនីមួយៗ។ ជាចុងក្រោយនេះ ប្រព័ន្ធទាំងនេះក៏អាចត្រូវបានប្រើប្រាស់ដើម្បីសម្របសម្រួលគម្រោងការងារណាមួយរបស់រដ្ឋាភិបាលនៅពេលអនាគតដូចជា៖

[260] Commission on Election, Republic Act No. 8189, Section 36, last retrieved on 02/06/2014 from: http://www.comelec.gov.ph/?r=References/RelatedLaws/ElectionLaws/Registration/RA8189

អត្តសញ្ញាណប័ណ្ណជាតិ លិខិតឆ្លងដែនដែលទំនើបជាងមុន ប័ណ្ណសេវាសុខភាព និងការចុះបញ្ជីបទល្មើសបែបទំនើប។

### ស្ថាប័នត្រួតពិនិត្យ

អ្វីដែលឯកសារសិក្សានេះលើកយកមកបង្ហាញគឺ ទម្រង់នៃស្ថាប័នត្រួតពិនិត្យមិនមែនជាកត្តាដ៏សំខាន់ជំរុញនូវប្រសិទ្ធិភាពក្នុងប្រតិបត្តិការរបស់ស្ថាប័ននេះឲ្យមានភាពល្អិតល្អន់ និង ដាក់បន្ទុកទៅលើប្រតិបត្តិការរបស់គណបក្សនយោបាយ ប៉ុន្តែគឺដោយសារធនធាននៃស្ថាប័ននេះពោរពេញទៅដោយជំនាញនិងវិជ្ជាជីៈវិញទេ។ ក្នុងន័យនេះ ប្រទេសកម្ពុជាមានរួចទៅហើយនូវទម្រង់គ្រប់គ្រងដែលអាចយកមកធ្វើការប្រៀបធៀបទៅនឹងករណីសិក្សានៃបណ្តាប្រទេសផ្សេងៗ ដូចក្នុងករណីស្ថាប័នជំនាញក្នុងការរៀបចំការបោះឆ្នោតដែលមានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងតុលាការជំនាញដើម្បីដោះស្រាយវិវាទបោះឆ្នោត ដែលមានក្រុមប្រឹក្សាធម្មនុញ្ញ។

ប្រទេសណាដែលមានបំនងចង់អភិវឌ្ឍសមត្ថភាពរបស់ស្ថាប័នត្រួតពិនិត្យរបស់ខ្លួនបន្ថែមទៀត អាចយកគំរូតាមប្រទេសមួយចំនួនដែលមានប្រព័ន្ធបោះឆ្នោតកម្រិតខ្ពស់ និងមានប្រសិទ្ធិភាព និងស្ថាប័នដែលមានបទពិសោធន៍លើផ្នែកនេះដោយស្នើសុំឲ្យផ្តល់ជូនសេវាកម្មផ្សព្វផ្សាយតាមរយៈការហ្វឹកហ្វឺន និងជំនួយបច្ចេកទេសជាដើម។

## VI. សេចក្តីសន្និដ្ឋាន

វិធីសាស្រ្តផ្សេងៗពីគ្នានៅក្នុងករណីសិក្សាដែលបានលើកយកមកនេះបង្ហាញថា មិនមាន «ការអនុវត្តន៍ដ៏ល្អបំផុតជាងគេ» នៅក្នុងដំណើរការបោះឆ្នោតនោះទេ។ បទបញ្ញត្តិស្តីពីហិរញ្ញប្បទាន ការចុះឈ្មោះបោះឆ្នោត និងស្ថាប័នគ្រប់គ្រងលើការបោះឆ្នោត អាចមានទម្រង់ផ្សេងៗ និងលទ្ធផលនៃគុណភាពប្រព័ន្ធបោះឆ្នោតមិនត្រូវបានបង្ហាញទេ។ ក្នុងន័យនេះគឺទាមទារនូវការធានាឲ្យបានការអនុវត្តន៍បទប្បញ្ញត្តិឲ្យកាន់តែម៉ឺងម៉ាត់ សមត្ថភាពវិជ្ជាជីវៈរបស់បុគ្គលិក និងការបញ្ចូល និងពង្រីកគុណភាពទិន្នន័យទៅក្នុងបញ្ជីឈ្មោះបោះឆ្នោត។ ដូចដែរបានពិភាក្សាក្នុងការវិភាគខាងលើ ករណីសិក្សាទាំងនេះបង្ហាញពីវិធីសាស្រ្តមួយចំនួនដែលប្រទេសកម្ពុជាអាចពិចារណាយកមកប្រើប្រាស់ស្របទៅតាមស្ថានភាពជាក់ស្តែងក្នុងប្រទេស ទៅតាមការចាំបាច់។

# គន្ថនិទេស

## ១. លិខិតបទដ្ឋានអន្តរជាតិ

- កតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ (ICCPR) ចូលជាធរមាននៅថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៧៦ http://www.ohchr.org/en/professionalinterest/pages/ccpr.aspx
- មហាសន្និបាតនៃអង្គការសហប្រជាជាតិ ឯកសារ A/HRC/២១/៦៣ របាយការណ៍របស់អ្នករាយការណ៍ពិសេសទៅលើ ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា Surya P. Subedi ធ្វើនៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១២ ហៅកាត់ថា អ្នករាយការណ៍ពិសេស
- *សេចក្តីអធិប្បាយទូទៅ (General Comment) លេខ២៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ (ICCPR)* http://www.refworld.org/publisher,HRC,GENERAL,,453883fc22,0.html
- គណៈកម្មការអឺរ៉ុបសម្រាប់លទ្ធិប្រជាធិបតេយ្យតាមរយៈច្បាប់ (គណៈកម្មការ វេននីស) *ក្រមនៃការអនុវត្តល្អក្នុងការបោះឆ្នោត* ទីក្រុងវេននីស ឆ្នាំ២០០២ ត្រូវបានទាញយកនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៣ ពី http://www.venice.coe.int/webforms/documents/CDL-AD(2002)023rev.aspx

## ២. ច្បាប់ជាតិ

- ប្រទេសកម្ពុជា

- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ (ចបតរ) និងច្បាប់វិសោធនកម្មស្តីពី ការបោះ-ឆ្នោតជ្រើសតាំងតំណាងរាស្ត្រ (ចបតរ) ព្រមទាំងការធ្វើវិសោធនកម្មចុងក្រោយនៅខែមករា ឆ្នាំ២០១៣ (ការបកប្រែក្រៅផ្លូវការ) ហៅកាត់ថា (ចបតរ)

- ប្រទេសបារាំង

- *ក្រមបោះឆ្នោត* (មាត្រា L៩ ដល់ L១៥(១) មាត្រា L៣០ ដល់ L៣៥ មាត្រា R១ ដល់ R៤ R៥ à R១៧(១)) http://www.legifrance.gouv.fr/affichCode.do;jsessionid=DD81BD6FC08D0B9A6788703E84B770CA.tpdjo11v_3?cidTexte=LEGITEXT000006070239&dateTexte=20131122
- រដ្ឋាភិបាលនៃប្រទេសបារាំង ក្រមបោះឆ្នោត មាត្រា L២៨ ទីក្រុងប៉ារីស ឆ្នាំ១៩៨៨

- Juris Classeur Administratif, Fasc. 80 : DROIT DES FINANCEMENTS POLITIQUES
- ច្បាប់លេខ ២០០៣-១១៦៥ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៣
- ច្បាប់រៀបចំអង្គការចុះថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ១៩៦២ ត្រូវបានធ្វើវិសោធនកម្មដោយច្បាប់រៀបចំអង្គការចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១១ និងច្បាប់រៀបចំអង្គការចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០០៦ ហើយ និង ច្បាប់រៀបចំអង្គការដែលទាក់នឹងហិរញ្ញប្បទាន របស់គណបក្សនយោបាយ ឆ្នាំ១៩៨៨ ១៩៩០ និង១៩៩៥
- *សារាចរ(Circular) ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ ២០១៣ ស្តីពីការត្រួតពិនិត្យឡើងវិញ និង ការគ្រប់គ្រងនៃបញ្ជីបោះឆ្នោត ភ្ជាប់ជាមួយនឹង ឧបសម្ព័ន្ធទី ១ ស្តីពីការអនុវត្តនូវកម្មវិធីត្រួតពិនិត្យឡើងវិញនៃបញ្ជីបោះឆ្នោត* http://circulaire.legifrance.gouv.fr/pdf/2013/07/cir_37324.pdf

- ប្រទេសឥណ្ឌូនេស៊ី

- រដ្ឋធម្មនុញ្ញប្រទេសឥណ្ឌូនេស៊ី ឆ្នាំ១៩៤៥
- ច្បាប់លេខ ១២ នៃឆ្នាំ ២០០៣ (ប្រទេសឥណ្ឌូនេស៊ី)
- ច្បាប់ ១៥/២០១១ (បកប្រែក្រៅផ្លូវការ ដោយមូលនិធិអន្តរជាតិសម្រាប់ប្រព័ន្ធបោះឆ្នោត (IFES)
- ច្បាប់នៃសាធារណរដ្ឋឥណ្ឌូនេស៊ីលេខ ០៨ ឆ្នាំ២០១២ ស្តីពីការបោះឆ្នោតទូទៅនៃសមាជិកនៃសភាតំណាង ក្រុមប្រឹក្សាតំណាងប្រជាជន និងសភាតំណាងតំបន់ (*ការបកប្រែក្រៅផ្លូវការ និងគ្មានការអនុញ្ញាតនៃច្បាប់ខែសីហា ឆ្នាំ២០១២ ស្តីពីការបោះឆ្នោតទូទៅនៃសមាជិកនៃសភាតំណាង ក្រុមប្រឹក្សាតំណាងប្រជាជន និងសភាតំណាងតំបន់*) ហៅកាត់ថា ច្បាប់បោះឆ្នោតឥណ្ឌូនេស៊ីឆ្នាំ២០១២
- ក្រឹត្យរបស់គណៈកម្មការជាតិរៀបចំការបោះឆ្នោត(KPU) លេខ៦៧៦ ឆ្នាំ២០០៣

- ប្រទេសកូរ៉េខាងត្បូង

- រដ្ឋធម្មនុញ្ញសាធារណៈរដ្ឋកូរ៉េ ឆ្នាំ១៩៨៧
- ច្បាប់នៃគណៈកម្មការរៀបចំការបោះឆ្នោត (ត្រូវបានវិសោធនកម្មដោយ ច្បាប់លេខ ១០៣០៣ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ ២០១០

- *ច្បាប់ស្តីពីមូលនិធិនយោបាយ (ត្រូវបានធ្វើវិសោធនកម្មដោយ ច្បាប់លេខ ១១៣៧៦ ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១២)*[261] *រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋកូរ៉េ (ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៤៨)* http://english.ccourt.go.kr/home/att_file/download/Constitution_of_the_Republic_of_Korea.pdf

- ប្រទេសហ្វីលីពីន

- រដ្ឋធម្មនុញ្ញនៃប្រទេសហ្វីលីពីនឆ្នាំ ១៩៨៧
- ក្រមនៃការបោះឆ្នោតទូទៅ (*ក្រមបោះឆ្នោត Omnibus*) ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៨៥ ផ្នែក៩៤-១១២
- *«ច្បាប់រៀបចំឡើងវិញនៃប្រព័ន្ធតុលាការ១៩៨០(The Judiciary Reorganization Act)»* ផ្នែកទី ១៩ ២០ ២១ ២២ បានទាញយកនៅថ្ងៃទី ១២ វិច្ឆិកា ឆ្នាំ ២០១៣ ពី http://www.chanrobles.com/bataspambansabilang129.html.
- *ច្បាប់Batas PambansaBlg. 884*, បានទាញយកនៅថ្ងៃ ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ពី: http://www.lawcenter.ph/law-library/laws/batas-pambansa/an-act-constituting-an-independent-presidential-electoral-tribunal-to-try-hear-and-decide-election-contests-in-the-office-of-president-and-vice-president-of-the-philippines-appropriating-funds-there/
- ច្បាប់នៃសាធារណៈរដ្ឋរបស់ប្រទេសហ្វីលីពីន លេខ៨១៨៩ *«បញ្ញត្តិអំពីនីតិវិធី និងការអនុញ្ញាតទៅលើមូលនិធិដែល សមរម្យ»* ចុះថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ១៩៩៦ ហៅកាត់ ថា RA ៨១៨៩ បានទាញយកពី http://www.comelec.gov.ph/?r=References/RelatedLaws/ElectionLaws/Registration

## ៣. ប្រភពឯកសារបន្ទាប់បន្សំ

– សមាគមនៃការបោះឆ្នោតជាផ្លូវការរបស់អឺរ៉ុប (ACEEEO) ។ *Theory and Practice of Voter Registration* បានទាញពី: http://www.aceeeo.org/images/BodnarE_KaszasA_THEORY%20AND%20PRACTICE%20OF%20VOTER%20REGISTRATION.pdf

[261] សូមមើលសេចក្តីយោងលេខ ២៨

– AJDA 2013, *Quels sont les motifs du rejet du compte de campagne de Nicolas Sarkozy ?*, Bernard Maligner, p. 1810

– បណ្ដាញអាស៊ីសម្រាប់ការបោះឆ្នោតដោយសេរី នៃកម្ពុជា(ANFREL Cambodia) *ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រកម្ពុជា នាថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០០៨* របាយការណ៍ស្ដីពីបេសកកម្មនៃការអង្កេតលើការបោះឆ្នោតជាអន្តរជាតិ http://anfrel.org/2008-mission-report-cambodias-national-assembly/, ហៅកាត់ថា ANFREL Cambodia.

– បណ្ដាញអាស៊ីសម្រាប់ការបោះឆ្នោតដោយសេរី (ANFREL) *លទ្ធិប្រជាធិបតេយ្យជាងមួយទសវត្សនៅក្នុងប្រទេស ឥណ្ឌូនេស៊ី ការបោះឆ្នោតនីតិបញ្ញត្តិ* របាយការណ៍ស្ដីពីបេសកកម្មនៃការអង្កេតលើការបោះឆ្នោតជាអន្តរជាតិ អាចទាញបានពី http://anfrel.org/2009-mission-report-indonesia-legislative-election/ ហៅកាត់ថា ANFREL Indonesia.

– សមាគមនៃការបោះឆ្នោតជាផ្លូវការរបស់អឺរ៉ុប (ACEEEO) *ទ្រឹស្ដី និងការអនុវត្តនៃបញ្ជីបោះឆ្នោត - និយមន័យ បទដ្ឋាន គោលការណ៍ ឧទាហរណ៍* Budapest:២០០៩ បានទាញយកនៅថ្ងៃ ទី២០ ខែវិច្ឆិកា ឆ្នាំ២០១៣ ពី: http://www.aceeeo.org/en/developing-accurate-voters/introductory-study-on-voters-registration

– Blechinger Verena *Corruption and Political Parties Management Systems International* ខែវិច្ឆិកា ឆ្នាំ ២០០២

– របាយការណ៍របស់ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា(CCHR) ឆ្នាំ ២០១១ ការពង្រឹងដំណើរការបោះឆ្នោត និង ការអនុវត្តនូវលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា៖ របាយការណ៍ទៅលើវេទិការស្ដីពីការបោះឆ្នោត និង គំលាតនៃលទ្ធិប្រជាធិបតេយ្យ។ ហៅកាត់ថា របាយការណ៍CCHR

– គណៈកម្មធិការជាតិរៀបចំការបោះឆ្នោតនៃកម្ពុជា (គ.ជ.ប) ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ២០១៣៖ *"An Overview: Briefing for the International Observers"* នាថ្ងៃ សៅរ៍ ទី ២៧ ខែកក្កដា ឆ្នាំ ២០១៣។ ហៅកាត់ថា ការសង្ខេបនៃគ.ជ.ប

– *ប័ណ្ណបោះឆ្នោត(Carte Électorale)* រដ្ឋាភិបាលបារាំង ឆ្នាំ២០១២ បានទាញយកនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៣ ពី http://vosdroits.service-public.fr/particuliers/F1962.xhtml#OuSAd

– គណៈកម្មការរៀបចំការបោះឆ្នោត(COMELEC) គេហទំព័រ: http://www.comelec.gov.ph/

– សេចក្តីសម្រេចគណៈកម្មការរៀបចំការបោះឆ្នោត(COMELEC) លេខ ៩៤៧៦

– គណៈកម្មការរៀបចំការបោះឆ្នោត(COMELEC) ឆ្នាំ ២០១២ *សេចក្តីសម្រេចលេខ ៩៤៧៦* ទីក្រុងម៉ានីល ត្រូវបានទាញ យកនៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៣ ពី http://www.comelec.gov.ph/uploads/Elections/2013natloc/res/com_res_9476.pdf

– គណៈកម្មការរៀបចំការបោះឆ្នោត(COMELEC) ឆ្នាំ ២០១៣ *សំណួរ និងចម្លើយអំពីបញ្ជីបោះឆ្នោត* ទីក្រុងម៉ានីល ត្រូវបាន ទាញយកនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៣ ពី http://www.comelec.gov.ph/?r=faq/qnavl

– គណៈកម្មការរៀបចំការបោះឆ្នោត(COMFREL) នៅកម្ពុជា ឆ្នាំ២០១៣ របាយការណ៍ចុងក្រោយស្តីពី ការវិភាគនៃបញ្ជីបោះ ឆ្នោត ការចុះឈ្មោះបោះឆ្នោត និងសវនកម្មនៃបញ្ជីបោះឆ្នោត បូករួមទាំងការពិនិត្យបញ្ជាក់នៃទម្រង់បែបបទក្នុងការលុបចោល សម្រាប់ការបោះឆ្នោតជាតិ ឆ្នាំ២០១៣ (SVRA-Plus) ខែមិនា ឆ្នាំ២០១៣

– *«សមាជនៃប្រទេសហ្វីលីពីន»* ត្រូវបានទាញយកនៅថ្ងៃ ០៨ ខែវិច្ឆិកា ឆ្នាំ ២០១៣ ពី: http://www.dbm.gov.ph/wp-content/OPCCB/OPIF2012/Congress/Congress.pdf.

– គេហទំព័រក្រុមប្រឹក្សាធម្មនុញ្ញបារាំង(Conseil Constitutionnel): http://www.conseil-constitutionnel.fr/conseil-constitutionnel/english/homepage.14.html

– ក្រុមប្រឹក្សាអឺរ៉ុបឆ្នាំ២០០៧ ការវាយតំលៃនៃជុំទី បី៖ របាយការណ៍វាយតំលៃនៃប្រទេសបារាំង ស្តីពីការពាក់ព័ន្ធក្នុងបទឧក្រិដ្ឋ Strasbourg: ក្រុមប្រឹក្សាអឺរ៉ុប បានទាញយកនៅ ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ពី http://www.coe.int/t/dghl/monitoring/greco/evaluations/round3/GrecoEval3(2008)5_France_One_EN.pdf

– គណៈកម្មការអឺរ៉ុប *សេចក្តីសង្ខេបនៃបទដ្ឋានអន្តរជាតិសម្រាប់ការបោះឆ្នោត* ការកែសម្រួលលើកទីពីរ http://eeas.europa.eu/eueom/pdf/compendium-of-int-standards-for-elections_en.pdf

– *បេសកកម្មក្នុងការអង្កេតការបោះឆ្នោតដោយសហគមន៍អឺរ៉ុប ទៅលើប្រទេសកម្ពុជា នាឆ្នាំ២០០៨* ដែលបានចេញផ្សាយនៅ ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៨ បានទាញយកពី http://eeas.europa.eu/eueom/missions/2008/cambodia/index_en.htm, cited as EU EOM 2008

– *គោលការណ៍ណែនាំសម្រាប់ការពិនិត្យឡើងវិញនៃក្របខណ្ឌច្បាប់នៃការបោះឆ្នោត* http://www.osce.org/odihr/elections/13960

- Hopkins Jonathan (ឆ្នាំ២០០៤) *The problem with party finance : theoretical perspectives on the funding of party politics.* Party politics ១០(៦) ទំព័រ ៦២៧-៦៥១ ទំព័រ ៦២៨

- http://www.conseil-constitutionnel.fr/conseil-constitutionnel/francais/documentation/dossiers-thematiques/election-presidentielle-2012/faq/financement-et-prise-en-charge-de-la-campagne-electorale/financement-prise-en-charge-de-la-campagne-electorale-et-controle-des-comptes-des-candidats.104047.html

- http://www.cnccfp.fr/index.php?art=684 : Financement des campagnes électorales : le contrôle des comptes de campagne.

- http://www.assemblee-nationale.fr/connaissance/fiches_synthese/septembre2012/fiche_15.asp

- http://www.monde-diplomatique.fr/mav/125/BREVILLE/48410 : Sous une pluie de dollars

- http://www.civicedu.go.kr/eng/index.html

- http://www.aceeeo.org/en/about-us/overview

- http://www.undp.org/content/undp/en/home/ourwork/democraticgovernance/overview.htmlhttp://mediacenter.kpu.go.id/

- វិទ្យាស្ថានអន្តរជាតិដើម្បីលទ្ធិប្រជាធិបតេយ្យ និងជំនួយការបោះឆ្នោត(IDEA) 2006 *Electoral Management Design: The International IDEA Handbook*. Stockholm ទំព័រ ៦៩

- IFES, A brief introduction to public funding of political parties and election campaigns ឆ្នាំ២០១១

- Institut National de la Statistique et des Études Économiques(INSEE), http://www.insee.fr/en/

- បទដ្ឋានអន្តរជាតិ និងការព្រមព្រៀងស្តីពី សិទ្ធិក្នុងការបោះឆ្នោតជាប្រជាធិបតេយ្យ៖ ការអនុវត្ត ដែលនាំទៅរក ការបោះឆ្នោតប្រជាធិបតេយ្យដែលមានប្រសិទ្ធិភាពបំផុត(OSCE)

- វិទ្យាស្ថានអន្តរជាតិដើម្បីលទ្ធិប្រជាធិបតេយ្យ និងជំនួយការបោះឆ្នោត(IDEA) *អ្នកចូលរួមបោះឆ្នោតចាប់តាំងពីឆ្នាំ១៩៤៥* របាយការណ៍ជាសកលឆ្នាំ២០០២ បានទាញយកពី http://www.idea.int/publications/vt/ ហៅកាត់ថា IDEA

- វិទ្យាស្ថានអន្តរជាតិដើម្បីលទ្ធិប្រជាធិបតេយ្យ និងជំនួយការបោះឆ្នោត(IDEA) ហិរញ្ញប្បទានសម្រាប់គណបក្សនយោបាយ និងយុទ្ធនាការឃោសនា បោះឆ្នោត Funding of Political Parties and Election Campaigns, Chapter 4 - Party Funding and Political Corruption in East Asia: The Cases of Japan, South Korea and Taiwan ឆ្នាំ២០០៣

– មូលនិធិអន្តរជាតិសម្រាប់ប្រព័ន្ធបោះឆ្នោត (IFES), *Civil and Voter Registries: Lessons Learned from Global Experiences*, edited by Michael Yard នៅខែមិថុនា ឆ្នាំ ២០១១ ហៅកាត់ថា (IFES) ២០១១

– ក្រឹត្យរបស់គណៈកម្មការជាតិរៀបចំការបោះឆ្នោត(KPU) លេខ៦៧៦ ឆ្នាំ២០០៣

– ក្រសួងមហាផ្ទៃ http://www.interieur.gouv.fr/Elections/Comment-voter/L-inscription-sur-les-listes-electorales

– គណៈកម្មការជាតិរៀបចំការបោះឆ្នោត ឆ្នាំ២០១៣ *(គ.ជ.ប)* ទីក្រុងសេអូល ត្រូវបានទាញយកពី http://www.nec.go.kr/engvote_2013/01_aboutnec/03_01.jsp

– វិទ្យាស្ថានជាតិនៃលទ្ធិប្រជាធិបតេយ្យ របាយការណ៍ស្តីពី សវនកម្មលើបញ្ជីបោះឆ្នោត *(VRA)* នៅក្នុងប្រទេសកម្ពុជា ឆ្នាំ២០១៣ ហៅកាត់ថា NDI VRA

– គ.ជ.ប *ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនាឆ្នាំ២០១៣* រាជធានីភ្នំពេញ ឆ្នាំ២០១៣ បានទាញយកពី http://www.necelect.org.kh/nec_english/images/stories/Observation/The%202013%20National%20Assembly%20Election%20an%20Overview.pdf

– ការិយាល័យសម្រាប់វិទ្យាស្ថានប្រជាធិបតេយ្យ និង សិទ្ធិមនុស្ស (ODIHR) *Parliamentary Elections: 10 and 17 June 2012, Vienna* ទីក្រុងវីយ៉ែន ODIHR

– Pasquale Pasquino “The New Constitutional Adjudication in France” សាកលវិទ្យាល័យញូវយ៉ក

– “សេចក្តីស្នើកំណែទម្រង់ច្បាប់ស្តីពីហិរញ្ញប្បទានសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោតសម្រាប់ការបោះឆ្នោតថ្នាក់ជាតិ” ដោយលោក Pierre Mazeaud, *របាយការណ៍ផ្ញើទៅកាន់ប្រធានរដ្ឋសភាជាតិ* ការចងក្រងរបាយការណ៍ផ្លូវការ ឯកសារជាភាសាបារាំង ទីក្រុងប៉ារីស ឆ្នាំ២០០៩ រដ្ឋធម្មនុញ្ញនៃប្រទេសហ្វីលីពីន មាត្រា IX

– គេហទំព័រគណៈកម្មការជាតិរៀបចំការបោះឆ្នោតនៃសាធារណរដ្ឋកូរ៉េ ពី http://www.nec.go.kr/engvote_2013/main/main.jsp

– NNDB tracking the entire world *ប្រវត្តិរូបរបស់លោក គីមយ៉ុងសាម(Kim Young Sam)* ត្រូវបានទាយយកពី http://www.nndb.com/people/462/000111129/

- កម្មវិធីអភិវឌ្ឍនៃអង្គការសហប្រជាជាតិ(United Nations Development Programme(UNDP)), Multi-Donor Programme - Support to Indonesia’s Democratic Elections (Elections MDP)
- Ufen Andreas *Electoral Campaigning in Indonesia: The Professionalization and Commercialization after 1998* ក្នុងនិទានុប្បវត្តិកិច្ចការបច្ចុប្បន្នអាស៊ីអាគ្នេយ៍ ឆ្នាំ២០១០
- អង្គការសហប្រជាជាតិ ក្រុមប្រឹក្សាសិទ្ធិមនុស្ស *របាយការណ៍នៃអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពនៃសិទ្ធិមនុស្សក្នុង ប្រទេសកម្ពុជា* Surya P. Subedi: http://www.ohchr.org/Documents/HRBodies/HRCouncil/RegularSession/Session21/A-HRC-21-63_en.pdf
- Weissenbach, K.2010. *Political Parties and Party Types – Conceptual Approaches to the Institutionalization of Political Parties in Transitional States: The Case of the Philippines* Konrad-Adenauer-Stiftung